# ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០

## កិច្ចប្រជុំស្តីពីការផ្សព្វផ្សាយពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន

https://grandnewsasia.com/ 30-06-2020

កំពង់ឆ្នាំង៖ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ លេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តកំពង់ឆ្នាំង បានរៀបចំវេទិកាដើម្បីផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់ប្រជាពលរដ្ឋ រស់នៅឃុំកោះថ្កូវ ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាព លោកស្រី ប៊ិន សុភី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តកំពង់ឆ្នាំង។ ដោយមានការចូលរួមពីលោកស្រី ពេជ្រ សុភា ប្រធានមន្ទីរកិច្ចការនារីខេត្ត លោកអនុប្រធានមន្ទីរសង្គមកិច្ច លោកអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត លោកស្រីអភិបាលរងស្រុកជលគិរី លោក លោកស្រីជាថ្នាក់ដឹកនាំមន្ទីរ អង្គភាព ជាក្រុមលេខានៃគណៈកម្មាធិការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត, កម្លាំងមានសមត្ថកិច្ច, មេ ឃុំ មេភូមិ, អាជ្ញាធរ, និងប្រជាពលរដ្ឋជាច្រើនទៀតចូលរួមផងដែរ។

គោលបំណងនៃការរៀបចំវេទិកា គឺដើម្បីឱ្យប្រជាពលរដ្ឋយល់កាន់តែច្បាស់អំពីការធ្វើចំណាកស្រុក ជៀសវាងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន តាមការឃោសនារបស់មេខ្យល់អូសទាញ និងដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមគ្រប់រូបភាពផងដែរ។

នៅក្នុងឱកាសនោះលោកស្រី បានលើកឡើងថា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងការគិតគូរយកចិត្តទុកដាក់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងក្រោមអនុសាសន៍ ណែនាំរបស់លោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) និងក្រោមការចង្អុលទិសដោយផ្ទាល់ពីប្រធាន (គ.ខ.ប.ជ) ខេត្ត បានជម្រុញពង្រឹងការអនុវត្តការងារដល់គណៈកម្មាធិការ គ.ខ.ប.ជ រាជធានី ខេត្ត ក្រុមលេខាធិការដ្ឋាន និងក្រុមការងារជំនាញអន្តរ មន្ទីរ អង្គភាព ឱ្យយកចិត្តទុកដាក់ខ្ពស់អនុវត្តការងាររួមគ្នាបង្ការទប់ស្កាត់ និងចាត់វិធានការតាមច្បាប់ឱ្យបានទាន់ពេលវេលា ចំពោះជនល្មើស និងមេខ្យល់ដែលបានប្រើប្រជាកិច្ចុតតាមគ្រប់រូបភាព។

នៅក្នុងឱកាសនោះលោកស្រី បានធ្វើផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីវិធានការការពារខ្លួនពីជំងឺផ្សេងៗ ជាពិសេសជំងឺកូវីដ១៩ ដែលកំពុងរីករាលដាលទូទាំងសកលលោក ត្រូវតែប្រុងប្រយ័ត្ន និងអនុវត្តតាមវិធានការ របស់រាជរដ្ឋាភិបាលកម្ពុជា និងតាមគោលការណ៍ ណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានជាប្រចាំ ដើម្បីចូលរួមទាំងអស់គ្នាកុំឱ្យកើតមានជំងឺកូវីដ១៩ នៅក្នុងដំណាក់កាលដែលមានរលកទី២នេះ នៅក្នុងសហគមន៍យើងជាដាច់ខាត។ លោកស្រី បានធ្វើការអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់គ្នាត្រូវបង្កើនការផលិតផ្នែកកសិកម្ម តាមរយៈ ការដាំដុះ ការចិញ្ចឹមសត្វជាដើម ដើម្បីដោះស្រាយបញ្ហាជីវភាព។ ក្នុងនោះលោកស្រី រួមជាមួយក្រុមការងារបានចែកក្រម៉ា ជូនដល់ប្រជាពលរដ្ឋចូលរួមក្នុងកម្មវិធី។ នឹងបន្តយកសម្ភារ រួមជាមួយថវិកាមួយចំនួន ជូនដល់លោកយាយ ចាស់ជរាអាយុ៩១ ឆ្នាំ មានជំងឺ ប្រចាំកាយចំនួន១គ្រួសារ និងផ្តល់សម្ភារដល់ឃុំ រួមមាន៖ អង្ករ ចំនួន ០៤ បេគូច ឃីត៤ និងជូនដល់ស្ត្រីមេម៉ាយចំនួន ០២គ្រួសារ តាមរយៈនារីស្រុកផងដែរ៕

# កិច្ចប្រជុំបូកសរុបលទ្ធផលសកម្មភាពការងារប្រចាំឆមាស ទី១ ឆ្នាំ២០២០

https://gdlf-kh.com/ 2020/06/30/ Kao sophy ខេត្តព្រះសីហនុ

ខេត្តព្រះសីហនុ៖ ព្រឹកថ្ងៃអង្គារ ១០កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រ្តី និងកុមារខេត្តព្រះសីហនុ បើកកិច្ចប្រជុំបូកសរុបលទ្ធផលសកម្មភាពការងារប្រចាំឆមាស ទី១ ឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ ប្រាក់ ច័ន្ទសុខា ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រ្តី និងកុមារខេត្តព្រះសីហនុ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវជាសមាជិកក្រុមប្រឹក្សាខេត្ត អភិបាលរងខេត្ត អភិបាលក្រុង ស្រុក មន្ទីរអង្គភាពពាក់ព័ន្ធជុំវិញខេត្ត នៅសាលាខេត្តព្រះសីហនុ ។

លោកជំទាវ ប្រាក់ ច័ន្ទសុខា ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រ្តី និងកុមារខេត្តព្រះសីហនុ មានប្រសាសន៍ថា ស្របតាមគោលនយោបាយអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយសុខុមាលភាពពិសេសការលើកកម្ពស់ការចូលរួមរបស់ស្រ្តីក្នុងការកសាងចក្ខុវិស័យដែលជាយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍន៍ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ដើម្បីសម្រេចបានសមភាព យេនឌ័រ ឆ្លើយតបនឹងតម្រូវការរបស់ស្រ្តី និងកុមារ ជនងាយរងគ្រោះ។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រ្តី និងកុមារអនុ វត្តតាមផែនការសកម្មភាពឆ្នាំ ២០២០ ប្រកបដោយឆន្ទះមោះមុតក្រោមការគាំទ្របច្ចេកទេស និងថវិកាពីក្រុមប្រឹក្សា គណៈអភិបាលខេត្ត មន្ទីរ អង្គភាពពាក់ព័ន្ធនឹងមានកិច្ចសហការល្អជាមួយអង្គការម្លប់តាប៉ាង អង្គការអេលឃីដស៍ អង្គការយូនីសេស អង្គការសង្គ្រោះកុមារ និងអង្គការហ្វ្រេនអ៊ិនធីណាស់សិនណល ។

លោកជំទាវ បន្តថាគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រ្តី និងកុមារ បានចុះសួរសុខទុក្ខប្រជាពលរដ្ឋក្រីក្រ ស្រ្តី កុមារ ជនពិការ និងជនចាស់ជរាជួបបញ្ហាប្រឈម និងកម្មករ កម្មការិនីចំនួន ១៣លើក ។ ទន្ទឹមនោះក៏មានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយមានដូចជាការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីគោលនយោបាយឧបត្ថម្ភសាច់ប្រាក់ដល់ស្រ្តីក្រីក្រមាន ផ្ទៃពោះនិងកុមារអាយុក្រោម ២ឆ្នាំ នៅមានកម្រិត៖

-ករណីអំពើហិង្សាក្នុងគ្រួសារមិនទាន់ទប់ស្កាត់បានទាំងស្រុង

-ការរំលោភបំពានផ្លូវភេទលើស្រ្តី និងកុមារនៅមានការកើតឡើង

-ការសិក្សាពីចម្ងាយរបស់កុមារនៅតាមជនបទដាច់ស្រយាលមួយចំនួនក្នុងស្ថានភាពការទប់ស្កាត់ជំងឺកូវីដ ១៩ មានកម្រិតអប្បបរមា។

-កិច្ចសហការរវាងអាជ្ញាធរមូលដ្ឋាននិង គ.ក.ន.ក ឃុំ-សង្កាត់ ក្នុងការចុះតាមដានស្ថានភាពជីវភាពរបស់ប្រជាពលរដ្ឋនៅមានកម្រិត។ លោកជំទាវ ប្រាក់ ច័ន្ទសុខា បានបន្តថា ទិសដៅការងារអនុវត្តបន្តគឺ

-ប្រជុំពិភាក្សាគ្រោងថវិកាសកម្មភាពការងារប្រចាំឆមាសទី២ ឆ្នាំ ២០២០

-រៀបចំផែនការសកម្មភាព និងផែនការថវិកាសម្រាប់ឆ្នាំ ២០២១

-ចុះគាំទ្រកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក ក្រុង-ស្រុក

-ចុះពិនិត្យតាមមត្តេយ្យសិក្សាសហគមន៍

-ជំរុញការការពារសុខមាលភាពស្រ្តី និងកុមារការពារជំងឺឆ្លងនានា និងតាមដានការចុះទិន្នន័យស្រ្តីក្រីក្រមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ តាមមូលដ្ឋាន

-ជម្រុញការតាមដានផ្តល់សេវាដល់អ្នកផ្ទុកមេរោគអេដស៍ និងស្រ្តីមានជំងឺរ៉ាំរ៉ៃផ្សេងៗនៅតាមមូលដ្ឋាន

-សហការចូលរួមអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាល

-សហការផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការទប់ស្កាត់ជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទដល់យុវវ័យ និងស្ត្រីនៅតាមមូលដ្ឋានឱ្យមានប្រសិទ្ធភាព។

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៥២នាក់

https://www.facebook.com/GDIOfficial 30-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៥២នាក់ ស្រី ២៣នាក់ និងកុមារ ០៧នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៣នាក់

https://www.facebook.com/GDIOfficial 30-06-2020

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃបានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៣នាក់ ស្រី ២១នាក់ និងពលរដ្ឋថៃចាកចេញមានចំនួន ០១នាក់ មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ពលរដ្ឋខ្មែរ០៣នាក់ ត្រូវអាជ្ញាធរថៃ យកមកប្រគល់ឲ្យភាគីកម្ពុជាវិញ តាមច្រកអន្តរជាតិជាំ

---

http://kampucheathmey.com/ 1/7/2020 10:38 Am អត្ថបទ ៖ ចាន់ ធី

ឧត្តរមានជ័យ ៖ អាជ្ញាធរថៃ បានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន០៣នាក់រួចផុតទោស យកមកប្រគល់ឲ្យភាគីកម្ពុជាយើង តាមច្រកអន្តរជាតិជាំ ភូមិលើភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីវេលាម៉ោង ១៦និង១៧នាទី ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។ សមត្ថកិច្ចបានឲ្យដឹងថា ពលរដ្ឋដែលរួចផុតទោសរួមមាន ៖ ១- ឈ្មោះ ថា ទូច ភេទប្រុស អាយុ៤០ឆ្នាំ រស់នៅភូមិលំទង ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ២- ឈ្មោះ តង សឿ ភេទប្រុស អាយុ៤៥ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ៣- ឈ្មោះ ឈុន ដារ៉ា ភេទប្រុស អាយុ៣០ឆ្នាំ រស់នៅភូមិត្រពាំងបី ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

ក្នុងនោះ ពលរដ្ឋខ្មែរទាំង០៣នាក់នេះ ត្រូវបានទាហានថៃចាប់ខ្លួន កាលពីថ្ងៃទី១២,០២,២០១៨ ពីបទឆ្លងដែនចូលកាប់ឈើគ្រញូងក្នុងទឹកដីថៃដោយខុសច្បាប់ ជាប់គុកនៅស្រុកខាន់ថាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ។ ចូលតាមច្រកអូរស្មាច់ ស្ថិតក្នុងភូមិសាស្ត្រភូមិអូរស្មាច់ ឃុំអូរស្មាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ បច្ចុប្បន្ន ពលរដ្ឋខ្មែរចំនួន០៣នាក់ ក្រោយពីសមត្ថកិច្ចធ្វើការអប់រំរួច ត្រូវបានឲ្យទៅស្រុកកំណើតវិញរៀងៗខ្លួន៕

## សេចក្តីថ្លែងការណ៍៖ ពលករខ្មែរកំពុងជាប់នៅប្រទេសហ៊្សកដានីត្រូវការជំនួយដើម្បីបានត្រឡប់មកប្រទេសកំណើតវិញ

https://www.central-cambodia.org/km/ **ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២០**

មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស (**សង់ត្រាល់**) សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាជួយអន្តរាគមន៍ភ្លាមៗ ដើម្បីសម្របសម្រួលឱ្យប្រជាពលរដ្ឋខ្មែរ ដែលកំពុងជាប់នៅប្រទេសហ៊្សកដានី(Jordan) បានត្រឡប់មកប្រទេសកម្ពុជាវិញ។ ក្រុមហ៊ុន Vega Textile Co., Ltd និង Camel Textile International Corporation គឺជារោងចក្រកាត់ដេរ ស្ថិតនៅទីក្រុងអាល់ការ៉ាក់ (Al-Karak) នៅប្រទេសហ៊្សកដានី បានបញ្ចប់កិច្ចសន្យាការងារពលករខ្មែរយ៉ាងហោចណាស់សរុប ២១ នាក់កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ។ យោងតាមកិច្ចសន្យាសម្រាប់ពលករចំណាកស្រុកក្នុងប្រទេសហ៊្សកដានី និង កិច្ចព្រមព្រៀងដោយផ្ទាល់មាត់របស់ពលករជាមួយក្រុមហ៊ុនមុនពេលដែលពួកគាត់បានចេញដំណើរពីប្រទេសកម្ពុជា ក្រុមហ៊ុន Vega Textile និង Camel Textile ទទួលខុសត្រូវក្នុងការទិញសំបុត្រយន្តហោះឱ្យពួកគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ នៅពេលដែលកិច្ចសន្យាការងាររបស់ពលករខ្មែរទាំងនេះត្រូវបានបញ្ចប់ ។

ប៉ុន្តែក្រុមហ៊ុន Vega Textile និង Camel Textile ខកខានមិនបានទិញសំបុត្រយន្តហោះ ព្រមទាំងមិនបានជូនដំណឹងដល់ពលករខ្មែរអំពីពេលវេលាដែលក្រុមហ៊ុនគ្រោងទិញសំបុត្រយន្តហោះនោះទេ ។ លើសពីនេះទៀត ក្រុមហ៊ុន Vega Textile និង Camel Textile មិនបានផ្តល់អត្ថប្រយោជន៍ផ្នែកគាំពារសង្គមដែលកន្លងមកក្រុមហ៊ុនបានកាត់ពីប្រាក់ឈ្នួលរបស់ពលករជារៀងរាល់ខែដែលអត្ថប្រយោជន៍ទាំងនោះយ៉ាងហោចណាស់ប្រមាណ ១០០០ ដុល្លារអាមេរិកសម្រាប់ពលករម្នាក់ៗ ។ ពលករខ្មែរទាំងនេះបានជាប់នៅប្រទេសហ៊្សកដានីដោយគ្មានការងារធ្វើ នឹងបាត់បង់ប្រាក់ចំណូលអស់រយៈពេល ០៣ ខែមកហើយ ។

ក្រុមហ៊ុន Vega Textile និង Camel Textile មានក្រុមហ៊ុនមេដែលមានការិយាល័យកណ្តាលនៅប្រទេសតៃវ៉ាន់។ យោងតាមបញ្ជីព័ត៌មាន ក្រុមហ៊ុនមេនេះក្រៅពីធ្វើការបញ្ជាទិញពីរោងចក្រទាំងពីរខាងលើក៏មានរោងចក្រយ៉ាងហោចណាស់ ០២ ដេរនៅប្រទេសកម្ពុជារួមមាន ៖

១. រោងចក្រអុបធីមឹម ហ្វេសិន មេនូហ្វេកធឺរីង ឯ.ក (Optimum Fashion Manufacturing Co., Ltd.) មានអាសយដ្ឋាននៅភូមិព្រៃផ្តៅ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

២. រោងចក្រយូ អាយ ស៊ី អឺភែរឹល មេនូហ្វេកធឺរីង (U.I.C Apparel Manufacturing Co., Ltd.) មានអាស័យដ្ឋាននៅភូមិត្រពាំងទូល សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ រដ្ឋមន្ត្រីក្រសួងការងាររបស់ប្រទេសហ៊្សកដានី ឯកឧត្តម Nidal Bataineh បានចុះទៅពិនិត្យមើលដោយផ្ទាល់នូវស្ថានភាពរបស់កម្មករនិយោជិតនៅរោងចក្រ Vega Textile និង Camel Textile បន្ទាប់ពីកម្មករនិយោជិតបានប្តឹងទៅក្រសួងការងាររបស់ប្រទេសហ៊្សកដានី ។ យោងតាម សេចក្តីថ្លែងការណ៍ របស់ក្រសួងការងាររបស់ប្រទេសហ៊្សកដានី រដ្ឋមន្ត្រីបានបង្គាប់ឱ្យរោងចក្រ Vega Textile និង Camel Textile ចាត់វិធានការកែតម្រូវលក្ខខណ្ឌការងារ ហើយក៏បានបញ្ជាឱ្យអធិការការងារចុះទៅពិនិត្យមើលរោងចក្រនេះក្នុងរយៈពេល ២សប្តាហ៍ ដើម្បីធានាថាក្រុមហ៊ុននេះអនុវត្តតាមច្បាប់ ។ បន្ទាប់ពីក្រុមហ៊ុនបានព្យាយាមរារាំងមិនឱ្យ

ពលករខ្មែរជួបជាមួយមន្ត្រីរបស់ក្រសួងការងាររបស់ប្រទេសហ្សកដានីជាច្រើនលើកច្រើនសា ជាចុងក្រោយ ពលករខ្មែរបានជួប និងពិភាក្សាដោយផ្ទាល់ជាមួយមន្ត្រីរបស់ក្រសួងការងាររបស់ហ្ស៊កដានីកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០២០ ដោយបានលើកឡើងពីការទាមទាររបស់ពួកគាត់ក្នុងការត្រឡប់មកស្រុកកំណើតវិញ ហើយទាមទារអត្ថប្រយោជន៍ផ្នែកកិច្ចគាំពារសង្គមពីក្រុមហ៊ុន Vega Textile និង Camel Textile ។

យើងខ្ញុំទទួលស្គាល់ថាមានការរឹតត្បិតនៃការធ្វើដំណើរតាមផ្លូវអាកាស ដែលអាចជាមូលហេតុដែលធ្វើឲ្យពួកគាត់កំពុងជាប់គាំងនៅប្រទេសហ្ស៊កដានី ហើយយើងក៏សង្កេតឃើញដែរថា បច្ចុប្បន្នមានការបើកជើងហោះហើរមួយចំនួនពីប្រទេសហ្ស៊កដានីទៅកាន់ទីក្រុងឌូបៃ និង ប្រទេសហ្កាតា ។ អ្នកធ្វើដំណើរពីទីក្រុងឌូបៃ និង ប្រទេសហ្កាតាអាចធ្វើដំណើរទៅកាន់ប្រទេសកូរ៉េខាងត្បូង និងទីក្រុងហុងកុង បន្ទាប់មកអាចនឹងធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញវិញបាន ។ យើងខ្ញុំក៏ដឹងផងដែរថាបច្ចុប្បន្ននេះ តម្លៃសំបុត្រយន្តហោះមានការកើនឡើងក្នុងកំឡុងពេលនៃការរាតត្បាតសកលកូវីដ-១៩ នេះ ប៉ុន្តែវាមិនមែនជាមូលហេតុដើម្បីទុកពលករខ្មែរចោលឲ្យនៅក្រៅប្រទេសដោយគ្មានការងារធ្វើ បាត់បង់ប្រាក់ចំណូលនោះទេ ។ ក្រុមហ៊ុន Vega Textile និង Camel Textile ត្រូវតែបំពេញតួនាទីរបស់ខ្លួនស្របតាមច្បាប់ ហើយរៀបចំឲ្យពលករខ្មែរបានត្រឡប់មកស្រុកកំណើតវិញឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។

ជាមួយគ្នានេះដែរ ក្រុមហ៊ុន Vega Textile និង Camel Textile ក៏បានជួលពលករជនជាតិភូមាមួយចំនួនដែរ ។ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ពលករជនជាតិភូមាទាំងនោះក៏បាននិយាយជាសាធារណៈអំពីបញ្ហាប្រឈម និងទុក្ខលំបាករបស់ពួកគាត់នៅប្រទេសហ្ស៊កដានីតាមរយៈ បទសម្ភាសន៍ជាមួយប្រព័ន្ធផ្សព្វផ្សាយ ។ ក្រោយពីមានការលើកឡើងរបស់ពលករជនជាតិភូមា កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ស្ថានទូតសាធារណរដ្ឋមីយ៉ាន់ម៉ាប្រចាំប្រទេសអ៊ីស្រាអែលបានចេញសេចក្តីជូនដំណឹង ស្តីពីការរៀបចំជើងហោះហើរធ្វើមាតុភូមិនិវត្តន៍សម្រាប់ប្រជាពលរដ្ឋភូមាដែលធ្វើការនៅរោងចក្រមួយចំនួននៅប្រទេសហ្ស៊កដានីរួមទាំងក្រុមហ៊ុន Vega Textile និង Camel Textile ផងដែរ ។

លោក **មឿន តុលា** នាយកប្រតិបត្តិការនៃអង្គការសង់ត្រាល់បានលើកឡើងថា ៖ *"អន្តរាគមន៍ភ្លាមៗរបស់រដ្ឋាភិបាលភូមាគួរត្រូវបានសាទរក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋខ្លួនដែលជាប់នៅក្រៅប្រទេស ។ ចំពោះករណីនេះ រាជរដ្ឋាភិបាលកម្ពុជាគួរតែអនុវត្តន៍ដូចរដ្ឋាភិបាលភូមាដែរ ហើយធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុនអាកាសចរណ៍ដើម្បីរៀបចំឱ្យប្រជាពលរដ្ឋខ្មែរដែលជាប់នៅប្រទេសហ្ស៊កដានីដោយគ្មានការងារធ្វើ បាត់បង់ប្រាក់ចំណូលបានត្រឡប់មកប្រទេសកម្ពុជាវិញ ដូចការណ៍ដែលរាជរដ្ឋាភិបាលបានធ្វើនាពេលកន្លងមកសម្រាប់ករណីប្រជាពលរដ្ឋខ្មែរដែលជាប់គាំងនៅប្រទេសម៉ាឡេស៊ីនោះផងដែរ ។"*

អង្គការសង់ត្រាល់ អំពាវនាវសូមឱ្យរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ តាមរយៈស្ថានទូតរបស់ប្រទេសកម្ពុជាប្រចាំនៅប្រទេសអេហ្ស៊ីប និង គុយវ៉ែត ធ្វើអន្តរាគមន៍ភ្លាមៗលើករណីនេះដើម្បីធានាថាក្រុមហ៊ុន Vega Textile និង Camel Textile បំពេញតួនាទីរបស់ខ្លួន ជាពិសេសក្នុងការធ្វើមាតុភូមិនិវត្តន៍ប្រជាពលករខ្មែរ និងការទូទាត់អត្ថប្រយោជន៍ផ្នែកកិច្ចគាំពារសង្គមជូនពួកគាត់អោយបានគ្រប់គ្រាន់ ។

# ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២០

# ការិយាល័យប្រឆាំងការជួញដូរ និងការពារអនីតិជន ចុះបង្ក្រាបទីតាំងម៉ាស្សា បង្កប់សេវាផ្លូវភេទ បម្រើដោយអនីតិជន

http://btv.com.kh/nation-news/ 01/07/2020

ភ្នំពេញ៖ កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនសហការជាមួយនគរបាលមូលដ្ឋានខណ្ឌសែនសុខ បានចុះប្រតិបត្តិការបង្ក្រាបទីតាំងម៉ាស្សាឃីហោ កល្យាណ ម៉ាស្សា មានបង្កប់សេវាផ្លូវភេទ ឃាត់ខ្លួនមនុស្សចំនួន៤នាក់ ក្នុងនោះស្រ្តីម្ចាស់ទីតាំង១ម្នាក់ នារីរងគ្រោះចំនួន៣នាក់ (អនីតិជន ០១នាក់) ។ប្រតិបត្តិការនេះធ្វើឡើងកាលពីវេលាម៉ោង ២និង៣០នាទីរសៀលនាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ស្ថិតនៅនៅផ្ទះលេខ ៨៣Eo សង្កាត់គោគឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ប្រតិបត្តិការនេះ ដោយមានចង្អុលបង្ហាញពី ឯកឧត្តម ឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរងនិងជាស្នងការនគរបាលរាជធានីភ្នំពេញ មានការចុះដឹកនាំបញ្ជាផ្ទាល់ ពីលោក សេង គីមឡាក់ ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ និង លោក ឧត្តមសេនីយ៍ទោ ចាន់ កិត្តិខុម ស្នងការរងទទួលដឹកនាំការងារការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជាធានីភ្នំពេញ។ នគរបាលបានអោយដឹងថា ស្ត្រីម្ចាស់ទីតាំងមាន ឈ្មោះ ប៉ែន គីមស្រ៊ាង ភេទស្រី អាយុ៤៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ បើកហាងម៉ាស្សា ស្នាក់នៅទីតាំងម៉ាស្សានៅផ្ទះលេខ ៨៣Eo សង្កាត់គោគឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនបានឲ្យដឹងថាទីតាំងម៉ាស្សាកោសជប់ ឃីហោ កល្យាណ ម៉ាស្សា មានបង្កប់សេវាផ្លូវភេទ ចាប់ផ្តើមបើកបម្រើសេវាចាប់ពីម៉ោង៩ព្រឹក រហូតដល់យប់ជ្រៅរំលងអាធ្រាតដោយមាននារីក្មេងចំនួន៥នាក់ រងចាំភ្ញៀវ មកម៉ាស្សាធម្មតាតម្លៃ៥$ ម៉ាស្សាប្រេង8$ រយៈពេល១ម៉ោង និងរួមភេទ តម្លៃចាប់ពី ៤០ដុល្លារ ទៅ៥០ដុល្លារ ក្នុងមួយដង។

ក្រោយពេលបញ្ចប់ប្រតិបត្តិការនេះផងដែរកម្លាំងនគរបាលបានឃាត់ខ្លួនមនុស្សចំនួន ៤នាក់ ស្ត្រីម្ចាស់ទីតាំងម្នាក់ ក្នុងនោះនារីរងគ្រោះចំនួន៣នាក់(អនីតិជនម្នាក់) និងដកហូតវត្ថុតាងរួមមានស្រោមអនាម័យប្រើរួច និងមិនទាន់ប្រើប្រាស់មួយចំនួនផងដែរ បាននាំយកមកការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនដើម្បីបន្តការសាកសួរនិងចាត់ការតាមនីតិវិធី៕អត្ថបទ ៖ កុម្ភះ

# នគរបាលប៉ុស្តិ៍គ្រញូងសែនជ័យផ្សព្វផ្សាយអំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ

http://cambodiapolice.com/policekh/ 1:54 pm 1 កក្កដា 2020

ក្រចេះ ៖ ព្រឹកថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំគ្រញូងសែនជ័យ បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន និងបញ្ហាមួយចំនួនៗទៀត នៅចំណុចផ្ទះលោកប្រធានភូមិ ស្ថិតនៅភូមិគ្រញូងសែនជ័យជើង ឃុំគ្រញូងសែន ស្រុកស្នួល ខេត្តក្រចេះ ក្នុងកម្មវិធីចែកមុងជូនដល់ប្រជាពលរដ្ឋ ។ ក្នុងនោះកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលបានធ្វើការផ្សព្វផ្សាយ និងចែកខិត្តប័ណ្ណរួមមាន៖

-ផ្សព្វផ្សាយសេចក្តីអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា។

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន។

-ចែកសារសម្រាប់អប់រំអំពីផល់ប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន។

-ផ្សព្វផ្សាយអនុក្រឹត្យលេខ៣៩អនក្រ,បកចុះថ្ងៃទី១៧ ខែមិនាឆ្នាំ២០២០ស្តីពីការពិន័យអន្តរកាលចំពោះអំពើល្មើសច្បាប់ចរាចរណ៍ផ្លូវគោកថ្មី។

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ។

-ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហិង្សាទាក់ទង នឹងយេនឌ័រ,អំពើជួញដូរស្ត្រីនិងកុមារ ។

-ផ្សព្វផ្សាយគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌគ្រាប់មិនទាន់ផ្ទុះ។

-ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ។

-ផ្សព្វផ្សាយអំពីគ្រោះអគ្គីភ័យ និងផ្សព្វផ្សាយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលស្តីពីវិធីការការពារទប់ស្កាត់នៃការរីករាលដាលអំពីជំងឺកូវីដ១៩ផងដែរ។

នៅក្នុងនោះ កម្លាំងបានធ្វើការផ្សព្វផ្សាយនូវលក្ខណៈសម្បត្តិទាំង៩យ៉ាងរបស់គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ក្នុងយុទ្ធនាការខាងលើ មានអ្នកចូលរួមចំនួន៩៨នាក់ ស្រីចំនួន៦២នាក់ ៕

## វេទិកាផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការបង្ការទប់ស្កាត់ការផ្ទុះរាលដាលនៃជម្ងឺកូវីដ១៩ ជូនដល់ប្រជាពលរដ្ឋ នៅភូមិវត្តថ្មី ឃុំតាដែស ស្រុកកំពង់ត្រឡាច

https://gdlf-kh.com/ Sam Sophearum កំពង់ឆ្នាំង 2020/07/01

ខេត្តកំពង់ឆ្នាំង ៖ នៅព្រឹកថ្ងៃពុធ ១១កើត ខែអាសាឍ ឆ្នាំជូត ឯកស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០នេះ លោកជំទាវ ប៊ន សុភី អភិបាលរងខេត្ត តំណាងឯកឧត្តម ឈួរ ច័ន្ទឿន អភិបាលខេត្តកំពង់ឆ្នាំង និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ខ.ប.ជ ខេត្តកំពង់ឆ្នាំង បានបើកវេទិកាផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការបង្ការទប់ស្កាត់ការផ្ទុះរាលដាលនៃជម្ងឺកូវីដ១៩ ជូនដល់ប្រជាពលរដ្ឋ នៅភូមិវត្តថ្មី ឃុំតាដែស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

សមាសភាពចូលរួមមានលោកស្រី ឧត្តមសេនីយ៍ត្រី មាស សុម៉ាលី ស្នងការរងនគរបាលខេត្ត លោកស្រី ពេជ្រ សុភា ប្រធានមន្ទីរកិច្ចការនារីខេត្ត លោកស្រី អភិបាលរងស្រុកកំពង់ត្រឡាច លោក លោកស្រី ក្រុមលេខា គ.ខ.ប.ជ ខេត្ត កម្លាំងមានសមត្ថកិច្ច មេឃុំ មេភូមិ អាជ្ញាធរ និងប្រជាពលរដ្ឋជាច្រើនទៀតចូលរួមផងដែរ។

គោលបំណងនៃការរៀបចំវេទិកា គឺដើម្បីៈ ១. ឱ្យប្រជាពលរដ្ឋយល់កាន់តែច្បាស់ពីផលប៉ះពាល់ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន បណ្តុះការស្រលាញ់ការងារដាំដំណាំ កសិកម្មនៅមូលដ្ឋាន វិញ។ ២. ចូររួមទប់ស្កាត់ មិនចូលរួមក្នុងចលនាបាស់បោរខុសច្បាប់ និងរាយការណ៍ជាបន្ទាន់ចំពោះ មេខ្យល់អូសទាញតាមគ្រប់រូបភាព។ ៣. ចូលរួមថែរក្សាការពារសន្តិភាព។ ៤. ថែរក្សាកូនចៅ ជៀសវាងការរំលោភបំពានផ្លូវភេទ លើស្ត្រីកុមារ។ ៥. ការពារខ្លួនពីជំងឺផ្សេងៗ ជាពិសេសជំងឺកូវីដ១៩ ដែលកំពុងរីករាលដាលទូទាំងសកលលោក ត្រូវតែប្រុងប្រយ័ត្ន និងអនុវត្តតាមវិធានការ របស់រាជរដ្ឋាភិបាលកម្ពុជា និងតាមគោលការណ៍ ណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានជាប្រចាំ ដើម្បីចូលរួមទាំងអស់គ្នាកុំឱ្យកើតមានជំងឺកូវីដ១៩ នៅក្នុងដំណាក់កាលដែលមានរលកទី២នេះ នៅក្នុងសហគមន៍យើងជាដាច់ខាត។

ក្នុងកម្មវិធីនោះក្នុងនាមឯកឧត្តមប្រធាន គ.ខ.ប.ជ ខេត្ត បានឧបត្ថមថវិកា ដល់ ប្រជាពលរដ្ឋចូលរួមក្នុងកម្មវិធី ក្នុងម្នាក់ៗ ទទួលបាន ថវិកាចំនួន ១០ ០០០រៀល និងក្រម៉ា ៨០នាក់ និងថវិកា ឧបត្ថមក្រុមការងារ ថ្នាក់ស្រុក ៣០០ ០០០រៀល កុមារ ១៤ នាក់ ក្នុងម្នាក់ៗ ៥ ០០០រៀល ថ្លៃមេក្រូ ២មុឺនរៀល សរុបថវិកាចំនួន ១ ១៧០ ០០០រៀល។ ក្នុងនោះក៏មានការចូលរួមពីអង្គការមូលនិធិសប្បុរសធម៌ "ធីជី" បានចូលរួម ឧបត្ថមឃីដ ៥០ ដល់ក្រុមលេខា នៃគណៈកម្មាធិការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស ផងដែរ ៕

## ភាគីថៃចាប់បញ្ជូនពលករខ្មែរ ឆ្លងដែនខុសច្បាប់ ចំនួន ០១នាក់ តាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម

https://www.facebook.com/GDIOfficial 01-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃចាប់បញ្ជូនពលករខ្មែរ ដែនឆ្លងដែនខុសច្បាប់ ចំនួន ០១នាក់ ដោយមានការចូលរួមត្រួតពិនិត្យសុខភាពពីក្រុមចត្តាឡីស័ក។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរនេះ មានឈ្មោះ ប៉ុក ខូវ ភេទប្រុស អាយុ ៤០ឆ្នាំ ទីលំនៅភូមិបក្តេង ឃុំអង្គមោស ស្រុកដងទង់ ខេត្តកំពត។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំ និងណែនាំ រួចបញ្ជូនទៅឲ្យក្រុមចត្តាឡីស័ក ដើម្បីអនុវត្តបន្ត៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៨នាក់

https://www.facebook.com/GDIOfficial 01-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៨នាក់ ស្រី ០៦នាក់ និងកុមារ ០២នាក់។ ក្នុងចំណោមពលករទាំងនោះ ត្រូវបានអាជ្ញាធរថៃបញ្ជូនមកពីខេត្ត ប៉ាត់តានី ភាគខាងត្បូង នៃប្រទេសថៃ និងត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំអំពីច្បាប់ឆ្លងកាត់ព្រំដែន និងរបៀប នៃការទប់ស្កាត់ការពារជម្ងឺឆ្លង covid-19 បន្ទាប់មកប្រគល់ជូនក្រុមចត្តាឡីស័ក យកទៅសម្រាកនៅមន្ទីរពេទ្យបង្អែកប៉ោយប៉ែត ជាបណ្តោះអាសន្ន ដើម្បីពិនិត្យ និងតាមដានសុខភាពពួកគាត់បន្ត ៕

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១៥៤នាក់

https://www.facebook.com/GDIOfficial 01-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១៥៤នាក់ ស្រី ៦៥នាក់ និងកុមារ ២០នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្រ្តីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨៩នាក់

https://www.facebook.com/GDIOfficial 01-07-2020

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ

បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨៩នាក់ ស្រី ៨៨នាក់ និងពលរដ្ឋថៃចាកចេញមានចំនួន ០១នាក់ មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## អង្គការក្រៅរដ្ឋាភិបាលអំពាវនាវឲ្យមានអន្តរាគមន៍ជួយពលករខ្មែរជាប់នៅហ្ស៊ីរកដានីត្រឡប់មកកម្ពុជាវិញ

https://khmer.voanews.com/ 01 កក្កដា 2020 សាយ មុន្នី

វ៉ាស៊ីនតោន៖ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស ហៅកាត់ថាសង់ត្រាល់ នៅថ្ងៃពុធនេះ បានអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជា ធ្វើអន្តរាគមន៍ជួយនាំយកពលករចំណាកស្រុកខ្មែរ ដែលកំពុងជាប់នៅក្នុងប្រទេសហ្ស៊ីរកដានី បានវិលត្រឡប់មកកម្ពុជាវិញ។ សេចក្តីថ្លែងការណ៍របស់អង្គការក្រៅរដ្ឋាភិបាលនេះ ដែលចេញផ្សាយ ថ្ងៃទី១ ខែកក្កដា បានរៀបរាប់ថា ពលករខ្មែរយ៉ាងហោចណាស់ ២១នាក់ ដែលកំពុងស្ថិតនៅប្រទេសក្នុងតំបន់មជ្ឈិមបូព៌ានោះ បានជាប់នៅទីនោះ ៣ខែមកហើយ ក្រោយពីកិច្ចសន្យាការងាររបស់ពួកគេត្រូវបានបញ្ចប់ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។ ពលរដ្ឋចំណាកស្រុកខ្មែរទាំងនេះធ្វើការក្នុងរោងចក្រកាត់ដេរចំនួនពីរ គឺក្រុមហ៊ុន Vega Textile Co., Ltd និងក្រុមហ៊ុន Camel Textile International Corporation នៅក្នុងទីក្រុងអាលការ៉ាក់ប្រទេសហ្ស៊ីរកដានី។ អង្គការសង់ត្រាល់បានបញ្ជាក់ថា ចាប់តាំងពីបាត់បង់ការងារពីរោងចក្រ ពលករខ្មែរទាំងនេះបានជាប់នៅក្នុងប្រទេសនោះដោយគ្មានការងារធ្វើ និងគ្មានប្រាក់ចំណូល។

កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ ពលរដ្ឋខ្មែរជាង ២០០នាក់ ត្រូវបានស្ថានទូតខ្មែរប្រចាំប្រទេសម៉ាឡេស៊ី ជួយសម្របសម្រួលបញ្ជូនត្រឡប់មកកម្ពុជាវិញ ក្រោយពីពួកគេបានជាប់នៅក្នុងប្រទេសនោះ ចាប់តាំងពីខែមេសា ឆ្នាំ២០២០មក ដោយសាររដ្ឋាភិបាលកម្ពុជាបានហាមឃាត់មិនឲ្យពួកគេធ្វើដំណើរចូលប្រទេសវិញនៅគ្រានោះ ពីព្រោះតែការព្រួយបារម្ភអំពីការឆ្លងរាលដាលនៃជំងឺកូវីដ១៩៕

## បុរសអាមេរិកាំងម្នាក់ធ្លាប់បៀតបៀនផ្លូវភេទលើកុមារីកម្ពុជា២រូប ហើយរត់គេចខ្លួនទៅអាមេរិក ពេលនេះត្រូវតុលាការអាមេរិកកាត់ទោសឲ្យជាប់គុក ២១ ឆ្នាំ

https://khmernote.com.kh/ អន្តរជាតិ July 2, 2020 lyda

អាមេរិក៖ បុរសជនជាតិអាមេរិកម្នាក់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសឲ្យជាប់គុករយៈពេល ២១ ឆ្នាំ ពីបទបានបៀតបៀនផ្លូវភេទមកលើកុមារីកម្ពុជាចំនួន ២រូបក្នុងអំឡុងពេលដែលគាត់បានមកធ្វើការនៅក្នុងប្រទេសកម្ពុជា។ បុរសរូបនោះត្រូវបានសារព័ត៌មាន nextshark រាយការណ៍ថា មានឈ្មោះ Micky Rife អាយុ៣៦ឆ្នាំធ្លាប់មករស់នៅនិងប្រកបរបរជាគ្រូបង្រៀនភាសានៅក្នុងប្រទេសកម្ពុជានាពេលកន្លងមក។

ប្រភពខាងលើបន្តថា លោក Micky Rife បានប្រព្រឹត្តិសកម្មភាពបៀតបៀនផ្លូវភេទមកលើកុមារីកម្ពុជាចំនួន ២ ដង គឺនៅក្នុងឆ្នាំ ២០១៣ និងឆ្នាំ ២០១៨ ហើយក្មេងស្រីរងគ្រោះគឺជាកូនសិស្សរបស់គាត់ផ្ទាល់តែម្តង ដែលពួកនាងមានអាយុ ៤ ឆ្នាំ និង ៥ ឆ្នាំ បើគិតក្នុងពេលកើតហេតុនោះ។ បន្ទាប់ពីបានប្រព្រឹត្តិអំពើស្មោគគ្រោកនេះនៅក្នុងប្រទេសកម្ពុជាទាំង ២ ដងរួច លោក Micky Rife បានព្យាយាមរត់គេចខ្លួនពីការចាប់ខ្លួនរបស់អាជ្ញាធរកម្ពុជា ហើយរូបគាត់បានត្រលប់មកដល់ទឹកដីអាមេរិកវិញនៅចុងឆ្នាំ ២០១៨។

យ៉ាងណាក្តី មិត្តស្រីរបស់លោក Micky Rife បានខ្នះខ្នែងយ៉ាងខ្លាំងក្នុងការដាក់ពាក្យបណ្តឹងតាមរយៈស្ថានទូតអាមេរិកទៅកាន់តុលាការឲ្យចាត់ការករណីមួយនេះ ព្រោះមិត្តស្រីរបស់លោក Micky Rife បារម្ភថា ថ្ងៃណាមួយលោក Micky Rife អាចនឹងប្រព្រឹត្តិអំពើស្មោគគ្រោកនេះទៀតមកកាន់កូនស្រីចិញ្ចឹមរបស់ពួកគាត់ម្នាក់ ដែលទើប

មានអាយុពីរឆ្នាំម្នាក់ផងដែរ។ បើទោះជាជនល្មើសព្យាយាមរត់គេចខ្លួនយ៉ាងណាក្តី ទីបំផុត ប៉ូលិសនៅតែអាចតាមចាប់ខ្លួនគាត់បានដដែល ហើយកាលពីពេលថ្មីៗនេះតុលាការអាមេរិកបានសម្រេចកាត់ទោសឲ្យលោក Micky Rife ជាប់គុករយៈពេល២១ឆ្នាំ នៅក្នុងទឹកដីអាមេរិកជុំវិញបទល្មើសដែលរូបគាត់បានប្រព្រឹត្តិឡើងនៅក្នុងប្រទេសកម្ពុជា៕

## ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០

## វេទិកាផ្សព្វផ្សាយអំពីផលប៉ះពាល់ការធ្វើចំណាកស្រុក ការទប់ស្កាត់អំពើជួញដូរមនុស្ស និងបង្ការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ដល់ប្រជាពលរដ្ឋ ក្នុងស្រុកបរិបូណ៌

https://grandnewsasia.com/ 03-07-2020

កំពង់ឆ្នាំង៖ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) អញ្ជើញជាអធិបតីក្នុងវេទិកាផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ការទប់ស្កាត់អំពើជួញដូរមនុស្ស និងផ្សព្វផ្សាយពីវិធានការ បង្ការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ដល់បងប្អូនប្រជាពលរដ្ឋ មកពីឃុំខុនរ៉ែង ក្នុងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ ដោយមានការអញ្ជើញចូលរួមពី លោកស្រីវេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ក្រសួងមហាផ្ទៃ លោកស្រី ប៊ិន សុភី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ ខេត្ត លោក លោកស្រី អភិបាលរងស្រុកបរិបូណ៌ ក្រុមការងារថ្នាក់ស្រុក ថ្នាក់ឃុំ ថ្នាក់ភូមិ និងក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត។

ក្នុងឱកាសនោះក៏មានការចែកអំណោយដល់ចាស់ជរា ស្ត្រីមេម៉ាយមានកូនច្រើន និងគ្រួសារជនងាយរងគ្រោះ ចំនួន ៥០គ្រួសារផងដែរ ដោយក្នុង១គ្រួសារទទួលបានរួមមាន៖ អង្ករ ចំនួន ១០ គីឡូក្រាម, សាប៊ូដុំ ចំនួន ២ ដុំ, សារ៉ុង ចំនួន ២, ក្រមា ចំនួន ២, ដែលលាងដៃ ចំនួន ២ ដប, សាប៊ូបោកខោអាវ ចំនួន ២ កញ្ចប់។ បន្ទាប់មកលោកស្រី រួមជាមួយក្រុមការងារបាននាំយកបច្ច័យ ប្រគេនដល់ព្រះសង្ឃគង់ចាំព្រះវស្សានៅវត្ត ទួលព្រះស្រីពិជ័យសួរ្យវង្សកំពង់ព្រះ ហៅវត្តកំពង់ព្រះ ស្ថិតនៅភូមិកំពង់ព្រះ ឃុំធ្នុកទ្រូ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ៕

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ២៤០នាក់

https://www.facebook.com/GDIOfficial 02-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ២៤០នាក់ ស្រី ១០៥នាក់ និងកុមារ៣៦ នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៧នាក់

https://www.facebook.com/GDIOfficial 02-07-2020

នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិន

អនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៧នាក់ ស្រី ៦៥នាក់ និងពលរដ្ឋថៃចាកចេញមានចំនួន ០២នាក់ មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលរដ្ឋខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 02-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈេីនៅប្រទេសថៃ ដែលចេញតាមច្រកគ១ ស្រុកជាំក្សាន ខេត្តព្រះវិហារ៕

## សម្តេចតេជោបញ្ជាឲ្យកាត់ឆ្វៀលដីជូនពលរដ្ឋនៅតំបន់អភិរក្ស តំបន់សត្វព្រៃ និងតំបន់ការពារផ្សេងៗរបស់រដ្ឋ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០២០ ម៉ោង ១០:១៨ Kian Sokheak

រាជធានីភ្នំពេញ ៖ នៅថ្ងៃទី ៣ កក្កដា ២០២០ នេះ ក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីពេញអង្គ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានចេញបទបញ្ជា និងបញ្ជាក់ច្បាស់ៗជូន រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រសួងកសិកម្ម និងក្រសួងដែនដី គឺត្រូវតែកាត់ឆ្វៀលដីជូនបងប្អូនប្រជាពលរដ្ឋដែលបានមករស់នៅលើទីតាំងដីដែលជាគម្របព្រៃឈើ ឬជាតំបន់ការពារ ឬតំបន់អភិរក្សសត្វព្រៃរបស់រដ្ឋ ដូចជានៅកោះកុង ព្រះវិហារជាដើម...ដែលមានពលរដ្ឋបានមកធ្វើផ្ទះរស់នៅជាងដប់ម្ភៃឆ្នាំមកហើយ។ នេះបើយោងតាមផេកសម្តេចតេជោចេញផ្សាយនាព្រឹកថ្ងៃទី ០៣ ខែកក្កដានេះ ។ សម្តេចតេជោបានបញ្ជាក់ថា ព្រោះកន្លងមក រដ្ឋមានតែដីក្នុងផែនទីទេ តាមពិតមានបងប្អូនប្រជាពលរដ្ឋបានកសាងលំនៅដ្ឋានរស់នៅបង្កើតកូនចៅរាប់សិបឆ្នាំមកហើយនៅលើទីតាំងដីទាំងនោះ។ នេះជាការដោះស្រាយកង្វល់ជូនពលរដ្ឋពិតប្រាកដ។ កុំទុកប្រជាពលរដ្ឋអោយភ័យខ្លាច អត់ឃ្លាន រត់ទៅចំណាកស្រុកគេតទៅទៀត។ ទន្ទឹមនឹងនេះ សូមកុំអោយពលរដ្ឋពង្រីកថែមទៀត ព្រោះត្រូវការរក្សាទុកព្រៃសហគមខ្លះនៅជិតៗដើម្បីជាប្រយោជន៍សហគមរស់នៅផងដែរ។ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម និងក្រសួងដែនដី ត្រូវដោះស្រាយអោយដាច់ស្រេចក្នុងតែប៉ុន្មានខែខាងមុខដើម្បីចេញប្លង់កម្មសិទ្ធិជូនពលរដ្ឋ ហើយកិច្ចការនេះត្រូវធ្វើអោយបានហ្មត់ចត់ និងត្រឹមត្រូវបំផុត ៕

## អ្នកទោសខ្មែរ២នាក់ ត្រូវបានក្រុមអាជ្ញាធរថៃដោះលែងឲ្យមានសេរីភាពវិញ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០២០ ម៉ោង ២០:២៦ ឌិម សារឿន

ខេត្តឧត្តរមានជ័យ ៖ ក្រុមអាជ្ញាធរថៃបានធ្វើការកាត់ទោសពលរដ្ឋខ្មែរ២នាក់ពីបទឆ្លងដែនខុស ច្បាប់កាប់ឈើគ្រញូងឱ្យរួចផុតពីសំណាញ់ច្បាប់ និងបញ្ជូនខ្លួនយកមកប្រគល់ឱ្យក្រុមអាជ្ញាធរ កម្ពុជាតាមមាត់ច្រកទ្វារអន្តរជាតិជាំកាលពីវេលាម៉ោង១រសៀល ថ្ងៃទី២ កក្កដា ២០២០នេះ។ ហេតុ ការណ៍នេះកើតឡើងនៅក្នុងភូមិជាំ ឃុំ

ត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ អ្នកទោសខ្មែរ២នាក់ដែលក្រុមអាជ្ញាធរថៃកាត់ទោសឱ្យរួចពីសំណាញ់ច្បាប់៖

១-ឈ្មោះ រុន សំណាង ភេទប្រុស អាយុ៣៥ឆ្នាំ និងម្នាក់ទៀតឈ្មោះ ពេញ ដួយ ភេទប្រុស អាយុ៣៧ឆ្នាំ ទាំង២នាក់ រស់នៅភូមិត្រាំប៉ោង ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដែលខាងថៃ ចាប់ខ្លួនថ្ងៃទី២៦ កញ្ញា ២០១៧ ជាប់គុកនៅស្រុកខាន់តាឡាក់ ខេត្តស៊ីសាកេតប្រទេសថៃ។

មន្ត្រីដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំបានឱ្យដឹងថា អ្នកទោសខ្មែរ២នាក់ដែល ក្រុមអាជ្ញាធរថៃនាំយកមកប្រគល់ឱ្យ ខាងសមត្ថកិច្ចបានធ្វើការអប់រំ និងឱ្យធ្វើកិច្ចសន្យាបញ្ឈប់ឆ្លងដែនខុសច្បាប់បន្តទៀតរួចឱ្យវិលត្រឡប់ទៅជួបជុំប្រពន្ធកូននៅក្នុងថ្ងៃដដែល។ គួរំលឹក ថាអ្នកទោសខ្មែរក្រុមអាជ្ញាធរថៃបញ្ជូនខ្លួនយកមកប្រគល់ឱ្យជាញឹកញាប់ផងដែរនេះមិនមែន ជាលើកទីមួយនោះទេ៕ ដោយ ៖ ឱម សារឿន

# ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូងចំនួន ១០២ នាក់

https://www.facebook.com/GDIOfficial 05-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១០២ នាក់ ស្រី ៤៥នាក់ និងកុមារ ១៤នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៥នាក់

https://www.facebook.com/GDIOfficial 05-07-2020

នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៥នាក់ ស្រី ៣០នាក់៕

# អាជ្ញាធរខេត្តសៀមរាប ទទួលប្រជាពលរដ្ឋខ្មែរ ត្រឡប់មកពីប្រទេសថៃ បាន៣៦នាក់បន្ថែមទៀត

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 3 ខែ កក្កដា ឆ្នាំ 2020

APP ភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០៖ (សៀមរាប)៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់អាជ្ញាធរខេត្តសៀមរាបនៅថ្ងៃសុក្រ ទី០៣ ខែកក្កដា ឆ្នាំ២០២០នេះ នៅតែទៅបន្តរង់ចាំទទួលប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដដែល។ នៅថ្ងៃនេះដែរទទួលបានចំនួនសរុប៣៦នាក់ ស្រីចំនួន១៧នាក់ ដែលចូលមកតាមច្រកដូង ខេត្តបាត់ដំបង, តាមច្រកប៉ោយប៉ែតក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ។ គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០នេះ សម្រាប់ខេត្តសៀមរាប តួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរ ចូលតាមច្រកទាំងបីខាងលើមានចំនួន១៥,២២៣នាក់ ស្រីចំនួន៦,៦២៨នាក់ ក្នុងនោះបានពិនិត្យសុខភាពបឋមបានចំនួន១៥,២២៣នាក់ ស្រី ៦,៦២៨នាក់ គឺពិនិត្យសុខភាពបានទាំងអស់។

សូមបញ្ជាក់ជូនថា ប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃក្នុងមួយថ្ងៃៗ មានចន្លោះពីជាង ១០០នាក់រហូតដល់ជាង ៣០០នាក់ សម្រាប់ទូទាំងប្រទេសកម្ពុជា ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

# ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូងចំនួន ០២ នាក់

https://www.facebook.com/GDIOfficial 05-07-2020

នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី មានពលរដ្ឋខ្មែរវិលត្រឡប់មកពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ តាមច្រករបៀង (ស្លាបឆ្វេង) របស់ប៉ុស្តិ៍ ចំនួន ០២នាក់ ស្រី ០២នាក់។ កម្លាំងនគរបាលប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានសហការជាមួយមន្ត្រីចត្តាឡីស័កធ្វើការពិនិត្យកម្តៅពួកគាត់ និងបានធ្វើលិខិតប្រគល់-ទទួល ពលរដ្ឋទាំង ០២នាក់ខាងលើនេះ ជូនទៅមន្ត្រីចត្តាឡីស័ក ដើម្បីអនុវត្តតាមជំនាញបន្ត។ ដោយឡែកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ខាងភាគីថៃពុំមានបើកច្រកទ្វារព្រំដែនអនុញ្ញាតឲ្យនាំចូល-ចេញទំនិញនោះទេ គឺអនុញ្ញាតតែចន្លោះពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រតែប៉ុណ្ណោះ៕

# ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលរដ្ឋខ្មែរចំនួន ០១នាក់

https://www.facebook.com/GDIOfficial 05-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរចំនួន០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកតាសឹម ស្រុកជាំក្សាន ខេត្តព្រះវិហារ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីអាជ្ញាធរថៃចំនួន ៣៥នាក់

https://www.facebook.com/GDIOfficial 04-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៥នាក់ ស្រី ១១នាក់។ ដោយឡែកពលករខាងលើ ដែលអាជ្ញាធរថៃចាប់បញ្ជូនមកពី ខេត្តប៉ាត់តានី ភាគខាងត្បូង ប្រទេសថៃ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំអំពីច្បាប់ឆ្លងកាត់ព្រំដែន និងការទប់ស្កាត់ការពារជម្ងឺឆ្លង Covid-19 បន្ទាប់មកប្រគល់ជូនក្រុមចត្តាឡីស័កយកទៅសម្រាកនៅមន្ទីរពេទ្យបង្អែកប៉ោយប៉ែតជាបណ្តោះអាសន្ន ដើម្បីពិនិត្យ និងតាមដានសុខភាពពួកគាត់បន្ត៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៥នាក់

https://www.facebook.com/GDIOfficial 04-07-2020

នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៥នាក់ ស្រី ៣០នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០១នាក់ អាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 03-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០ មានជនជាតិខ្មែរចំនួន ០២នាក់ បានចូលប្រទេស និងពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ០១នាក់។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញត និងអ្នកបើកបររថយន្តចំនួន ០២នាក់ បានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ យ៉ាងត្រឹមត្រូវ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៤៨នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 03-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៤៨នាក់ ស្រី ១៦នាក់ និងកុមារ ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិន

ទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៤នាក់

https://www.facebook.com/GDIOfficial 03-07-2020

នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៤នាក់ ស្រី ២៨នាក់៕

## អាជ្ញាធរឃាត់ខ្លួនពលរដ្ឋ ១៩នាក់ ដោយសារតែពួកគេលួចឆ្លងដែនទៅថៃខុសច្បាប់

https://www.rfa.org/khmer/ ដោយ ជាតិ ចំណាន 2020-07-04

មន្ត្រីសង្គមស៊ីវិលស្នើឱ្យរដ្ឋាភិបាលគិតគូរដល់ជីវភាពរបស់ពលរដ្ឋខ្មែរ ដើម្បីបញ្ចៀសកុំឱ្យពួកគេធ្វើចំណាកស្រុក ស្វែងរកការងារធ្វើដោយខុសច្បាប់។ អ្នកនាំពាក្យសមាគមអាដហុក (Adhoc) លោក ស៊ឹង សែនករុណា ប្រាប់អាស៊ីសេរីថា រដ្ឋាភិបាលគួរតែសិក្សាពីមូលហេតុដែលធ្វើឱ្យពលករខ្មែរទាំងអស់នោះ ដែលបង្ខំចិត្តធ្វើចំណាកស្រុកដោយខុសច្បាប់។ លោកបន្ថែមថា ដោយសារតែគ្មានការងារធ្វើ ការជំពាក់បំណុលធនាគារ និងមីក្រូហិរញ្ញវត្ថុ គួបផ្សំនឹងវិបត្តិសេដ្ឋកិច្ច ដោយសារការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ទើបធ្វើឱ្យពួកគេលួចធ្វើចំណាកស្រុកដោយខុសច្បាប់បែបនេះ៖ «យើងឃើញហើយថា ពួកគាត់ភាគច្រើនមានការលំបាក គួបផ្សំនឹងវិបត្តិកូវីដនេះផង ហើយវិបត្តិកូវីដនេះធ្វើឱ្យពួកគាត់កាន់តែប្រឈមខ្លាំង និងអត់ការងារធ្វើ មានជាប់ជំពាក់ខាងមីក្រូហិរញ្ញវត្ថុ ឬធនាគារទៅទៀត អ៊ីចឹងប្រសិនជាពួកគាត់មិនស្វះស្វែងរកការងារធ្វើទេ តើពួកគាត់ដោះស្រាយបញ្ហាទាំងអស់នោះដោយរបៀបម៉េច។ រដ្ឋាភិបាលគួរសិក្សាពីបញ្ហាទាំងនោះឱ្យបានច្បាស់ ហើយរកដំណោះស្រាយទៅជូនពលរដ្ឋរបស់ខ្លួន ជាជាងយើងប្រើវិធានការផ្លូវច្បាប់នានា ដែលធ្វើឱ្យប៉ះពាល់ដល់ពួកគាត់រងនូវទុក្ខលំបាកបន្តទៀត»។

សំណើនេះធ្វើឡើងដោយសារតែ កាលពីថ្ងៃទី២ ខែកក្កដា អាជ្ញាធរខេត្តឧត្តរមានជ័យបានឃាត់ខ្លួនពលរដ្ឋ ១០នាក់ និងមេខ្លោង ២នាក់ នៅពេលដែលពួកគេបម្រុងនឹងឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ។ អធិការនគរបាលក្រុងសំរោង លោក ហម ភិរម្យ បានប្រាប់អាស៊ីសេរីកាលពីថ្ងៃទី០៣ ខែកក្កដា ថា ពលករខ្មែរទាំង១០នាក់នោះ មកពីខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ បម្រុងលួចឆ្លងដែនខុសច្បាប់ទៅធ្វើការនៅខេត្តសុរិន្ទ និងទីក្រុងបាងកក ប្រទេសថៃ។ លោក ហម ភិរម្យ ថា អាជ្ញាធរបានអប់រំដល់ពលរដ្ឋទាំងនោះ ហើយឱ្យពួកគេត្រលប់ទៅផ្ទះរបស់ពួកគេវិញអស់ហើយ ចំណែកមេខ្លោង អាជ្ញាធរបានកសាងសំណុំរឿង ដើម្បីបញ្ជូនទៅតុលាការ។ ចំណែកនៅឯខេត្តបន្ទាយមានជ័យឯណោះវិញ អាជ្ញាធរខេត្តនេះបានឃាត់ខ្លួនពលរដ្ឋខ្មែរ និងថៃ ៧នាក់ នៅច្រកអន្តរជាតិប៉ោយប៉ែត កាលពីថ្ងៃទី០៣ ខែកក្កដា។ សមត្ថកិច្ចខេត្តនេះបានអប់រំពលរដ្ឋខ្មែរ ២នាក់ និងថៃ ៥នាក់នោះ ហើយឱ្យពួកគេត្រលប់ទៅផ្ទះរបស់គេវិញ។ ចាប់តាំងពីមានវិធានការទប់ស្កាត់នៃការរីករាលដាលនៃជំងឺកូវីដ-១៩ របស់ប្រទេសថៃ

មក ពលករខ្មែររាប់ម៉ឺននាក់បានសម្រុកចេញពីប្រទេសថៃទៅកម្ពុជាវិញ ហើយពលរដ្ឋខ្មែរមួយចំនួនទៀតត្រូវបានថៃចាប់បញ្ជូនមកកម្ពុជាវិញ ដោយសារតែពួកគេលួចចូលទឹកដៃថៃ ដោយខុសច្បាប់៕

## ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២០

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់អាជ្ញាធរខេត្តសៀមរាប

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 6 ខែ កក្កដា ឆ្នាំ 2020

សៀមរាប៖ នៅថ្ងៃចន្ទ ទី០៦ ខែកក្កដា ឆ្នាំ២០២០នេះ នៅតែទៅបន្តរង់ចាំទទួលប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដដែល។ នៅថ្ងៃនេះដែរទទួលបានចំនួនសរុប ៥៦នាក់ ស្រីចំនួន ២៦នាក់ ដែលចូលមកតាមច្រកដូង ខេត្តបាត់ដំបង, តាមច្រកប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ។ គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០នេះ សម្រាប់ខេត្តសៀមរាប តួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរ ចូលតាមច្រកទាំងបីខាងលើមានចំនួន ១៥,៣៩៣នាក់ ស្រីចំនួន ៦,៧០៧នាក់ ក្នុងនោះបានពិនិត្យសុខភាពបឋមបានចំនួន១៥,៣៩៣នាក់ ស្រី ៦,៧០៧នាក់ គឺពិនិត្យសុខភាពបានទាំងអស់។ សូមបញ្ជាក់ជូនថា ប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃក្នុងមួយថ្ងៃៗ មានចន្លោះពីជាង ១០០ នាក់រហូតដល់ជាង ៣០០នាក់ សម្រាប់ទូទាំងប្រទេសកម្ពុជា ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

## អភិបាលស្រុក ៖ ត្រូវចាប់មេខ្យល់បោកពលរដ្ឋធ្វើចំណាកស្រុកដោយខុសច្បាប់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០២០ ម៉ោង ០៩:៣៤ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ «សមត្ថកិច្ចត្រូវស្រាវជ្រាវរកចាប់ខ្លួនមេខ្យល់ដែលបោកប្រាស់ប្រជាពលរដ្ឋនាំទៅធ្វើចំណាកស្រុកដោយខុសច្បាប់ ដែលប្រឈមនឹងគ្រោះថ្នាក់គ្រប់ពេល» លោកអភិបាលស្រុកអូរជ្រៅបានលើកឡើងបែបនេះក្នុងពេលចុះចែកអំណោយដល់ប្រជាពលរដ្ឋក្រីក្រ ចំនួន៣០គ្រួសារ កាលពីព្រឹកថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០២០ ស្ថិតឃុំចង្ហា ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅ បានមានប្រសាសន៍ថា នៅពេលដែលថៃបិទច្រកព្រំដែនកម្ពុជា-ថៃ គេសង្កេតឃើញពលករខ្មែរត្រូវបានភាគីថៃចាប់បញ្ជូនមកវិញតាមច្រកអូរបីជាន់ ស្រុកអូរជ្រៅរាល់ថ្ងៃ ព្រោះតែពួកគាត់ចាញ់បោកមេខ្យល់អស់លុយ ហើយត្រូវថៃចាប់បញ្ជូនមកវិញទៀត ដូច្នេះសូមសមត្ថកិច្ចដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវទប់ស្កាត់ និងស្រាវជ្រាវរកចាប់ខ្លួនមេខ្យល់ដែលបោកប្រាស់ប្រជាពលរដ្ឋដើម្បីចាត់ការតាមច្បាប់អោយខាងតែបាន។ លោកបានបញ្ជាក់ថា ក្នុងឱកាសកូវីដ១៩នេះរាជរដ្ឋាភិបាលកម្ពុជាបានឧបត្ថម្ភថវិការជួយដល់ប្រជាពលរដ្ឋក្រីក្រជួបការលំបាកនេះជាការយកចិត្តទុកដាក់ចំពោះបងប្អូនប្រជាពលរដ្ឋ ហើយដាក់ស្តែងប្រជាពលរដ្ឋចំនួន៣០គ្រួសារត្រូវបានសមាគមចលនាយុវជនកម្ពុជាក្រុម១៥៧ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ចែកជូននៅក្នុងឃុំចង្ហា ស្រុកអូរជ្រៅ។

លោក ម៉ាន់ ចាន់ឌី អនុប្រធានសមាគមចលនាយុវជនកម្ពុជាក្រុម១៥៧សាខាខេត្តបន្ទាយមានជ័យបានមានប្រសាសន៍ថា ក្នុងនាមរូបលោកតំណាងអោយលោក ចៅ ជីអាន ប្រធានសមាគមចលនាយុវជនកម្ពុជាក្រុម១៥៧សាខាខេត្ត រួមជាមួយក្រុមការងារ បាននាំយកអំណោយមកចែកជូនប្រជាពលរដ្ឋចំនួន៣០គ្រួសារ ដែលកំពុងជួបការលំបាកក្នុងពេលផ្ទុះជំងឺកូវីដ១៩ នៅឃុំចង្ហា ស្រុកអូរជ្រៅ នាពេលនេះរួមមាន អង្ករចំនួន៧៥០គីឡូក្រាម មីចំនួន៣០កេស ត្រីខចំនួន៣០យួរ ទឹកត្រីចំនួន៣០យួរ ទឹកស៊ីអ៊ីវចំនួន៣០យួរ ប្រេងឆចំណុះ៣០លីត្រចំនួន៣០ដប ស្កសរចំនួន៣០គីឡូក្រាម អំបិលអ៊ីយ៉ូដចំនួន៣០គីឡូក្រាម ប៊ីចេងចំនួន៣០ថង់ស្មើនឹងទម្ងន់៣០

គីឡូក្រាម សាប៊ូចំនួន៣០ថង់ស្មើនឹងទំងន់៣០គីឡូក្រាម សារ៉ុងចំនួន៣០ ភេជ្ជៈចំនួន៣៥កេស ទឹកបរិសុទ្ធចំនួន ១៥០យួរ ថវិការចំនួន១.៥០០.០០០រៀល និងឧបត្ថម្ភនគរបាលប៉ុស្តិ៍ និងប្រជាការពារភូមិមានថវិកាចំនួន ៣០០.០០០រៀល។

លោក តាន់ ស្វាង ប្រធានក្រុមប្រឹក្សាស្រុកអូរជ្រៅ បានមានប្រសាសន៍ថា សូមបងប្អូនប្រជាពលរដ្ឋត្រូវ ចូលរួមបង្ការ និងទប់ស្កាត់ជំងឺកូវីដ១៩ ព្រោះយើងអាចភ្លេចកូវីដ១៩ តែកូវីដ១៩មិនអាចភ្លេចយើងឡើយគឺត្រូវធ្វើអនាម័យជាប្រចាំ និងហូបស្អាតផឹកស្អាត ត្រូវលាងដៃជាមួយសាប៊ូ ឬអាកុល ត្រូវពាក់ម៉ាស់អោយបានគ្រប់គ្នា ។ លោកក៏បានថ្លែងអំណរគុណចំពោះសមាគមចលនាយុវជនក្រុម១៥៧ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលបាននាំយកអំណោយមកចែកជូនដល់ប្រជាពលរដ្ឋចំនួន៣០គ្រួសារក្នុងឃុំចង្ហា ស្រុកអូរជ្រៅ កំពុងជួបការលំបាកក្នុងពេលផ្ទុះជំងឺកូវីដ១៩ ៕ (កែសម្រួលដោយ ៖ ធីតា)

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១នាក់

https://www.facebook.com/GDIOfficial 0៦-07-2020

នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១នាក់ ស្រី ១៦នាក់៕

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូងចំនួន ៥៦នាក់

https://www.facebook.com/GDIOfficial 0៦-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៥៦នាក់ ស្រី ៣២នាក់ និងកុមារ ០៨នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

# ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០

## ស្ត្រីពលករខ្មែរអ្នកស្រុកបាកានម្នាក់ធ្លាក់ពីលើអគារការដ្ឋានសំណង់នៅថៃរងរបួសធ្ងន់

https://www.rasmeinews.com/ July 7, 2020, 8:26 PM

ដោយៈប.ជ័យ/បាងកក-ពោធិសាត់៖ កាលពីថ្ងៃទី៦ កក្កដា ២០២០មានស្ត្រីពលករខ្មែរម្នាក់ធ្វើការសំណង់នៅក្រុងបាងកកប្រទេសថៃបានធ្លាក់ពីលើអគារ៣៥ជាន់បណ្តាលឱ្យជងបន្ថែមនឹងដែកជង់ចំមាត់ផ្លុះម្ខាងទៅម្ខាង។

មិត្តនៅការដ្ឋាននិងសមត្ថកិច្ចថៃបានឱ្យដឹងថា ពលករខ្មែររងគ្រោះនោះមានឈ្មោះ ស្រី រីម ភេទស្រីរស់នៅភូមិអង្កាញ់ ឃុំមេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់។ ករណីនេះសូមបងប្អូនមេត្តាជួយជូនដំណឹង និងស្វែងរកសាច់ញាតិគាត់ឱ្យបានដឹងផង។ តែលទ្ធភាពទៅសួរសុខទុក្ខនឹងមិនអាចទេព្រោះប្រទេសថៃ ក៏ដូចកម្ពុជា នៅបិទប្រទេសដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩នៅឡើយ ៕ទ/

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបធ្វេង-ស្លាបស្ដាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូងចំនួន ៥៧នាក់

https://www.facebook.com/GDIOfficial 0៧-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបធ្វេង-ស្លាបស្តាំចំនួន ៥៧នាក់ ស្រី ២៨នាក់ និងកុមារ ១៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៦នាក់

https://www.facebook.com/GDIOfficial 0៧-07-2020

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៦នាក់ ស្រី ៣៧នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលរដ្ឋខ្មែរ ដែលឆ្លងដែនខុសច្បាប់ចំនួន ០៤នាក់

https://www.facebook.com/GDIOfficial 0៧-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៣និង៥០នាទី ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ២០២០ បានទទួលពលរដ្ឋខ្មែរ ដែលឆ្លងដែនខុសច្បាប់ចំនួន ០៤នាក់ និងមានការចូលរួមត្រួតពិនិត្យសុខភាព ពីក្រុមចត្តាឡីស័កប្រចាំមាត់ច្រក។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង ០៤នាក់នេះមាន ១-ឈ្មោះ ព្រំសូត្រ ភេទប្រុស អាយុ ៣៦ឆ្នាំ, ២-ឈ្មោះ ម៉ី សាមាង ភេទប្រុស អាយុ ៣០ឆ្នាំ, ៣-ឈ្មោះ ប៉ក នឿន ភេទស្រី អាយុ ៣៦ឆ្នាំ, ៤-ឈ្មោះ រី ស្រីណែត ភេទស្រី អាយុ ២០ឆ្នាំ ដែលអ្នកទាំង ០៤នាក់នេះ មានទីលំនៅបច្ចុប្បន្ន ភូមិតាទ្រៃ ឃុំរៀប ស្រុករមាសហែក ខេត្តស្វាយរៀង។ បន្ទាប់មកពលរដ្ឋខាងលើនេះ ត្រូវកម្លាំងនគរបាលប៉ុស្តិ៍ធ្វើការអប់រំណែនាំ រួចប្រគល់ជូនក្រុមចត្តាឡីស័ក ដើម្បីអនុវត្តន៍នីតិវិធីបន្ត។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យ

អ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មាន COVID-19៕

## អ្នកទោសម្នាក់ត្រូវអាជ្ញាធរថៃដោះលែង

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០២០ ម៉ោង ០៩:១៦ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ អ្នកទោសវ័យក្មេងម្នាក់ត្រូវបានក្រុមអាជ្ញាធរថៃបញ្ជូនខ្លួនយកមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជាវិញ តាមមាត់ច្រកទ្វារអន្តរជាតិជាំ កាលពីវេលាម៉ោង១០ព្រឹកថ្ងៃទី៥ កក្កដា ឆ្នាំ២០២០ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ អ្នកទោសវ័យក្មេងខាងលើឈ្មោះតំ ខេន ភេទប្រុស អាយុ១១ ឆ្នាំ រស់នៅភូមិចារ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ត្រូវបានទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី៣ មីនា ឆ្នាំ ២០២០ ពីបទឆ្លងដែនកាប់ឈើគ្រញូង ចូលតាមច្រកតាសឹម បានជាប់ពន្ធនាគារនៅខេត្តស៊ីសាកេត ប្រទេសថៃ ។ មន្ត្រីដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំបានឱ្យដឹងថា អ្នកទោសវ័យក្មេងម្នាក់ដែលក្រុមអាជ្ញាធរថៃដាក់ការចោទប្រកាន់ពីបទឆ្លងដែនដោយខុសច្បាប់ខាងលើនោះ ក្រោយពីសមត្ថកិច្ចទទួលបានហើយក៏ធ្វើការអប់រំណែនាំ និងឱ្យធ្វើកិច្ចសន្យាបញ្ឈប់ឆ្លងដែនដោយខុសច្បាប់ជាបន្តទៀត និងបានអនុញ្ញាតឱ្យវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារវិញនៅក្នុងថ្ងៃដដែល ។ គួរបញ្ជាក់ថា អ្នកទោសដែលជាប់គុកពីបទឆ្លងដែនកាប់ឈើគ្រញូងក្នុងទឹកដីថៃដោយខុសច្បាប់ ត្រូវបានក្រុមអាជ្ញាធរថៃដោះលែងជាបន្តបន្ទាប់ផងដែរ នេះមិនមែនជាលើទីមួយនោះទេ៕ (កែសម្រួលដោយ ៖ ធីតា)

## ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២០

## ពលករខ្មែរបន្តជ្រៀតចូលទៅប្រទេសថៃដោយបង់លុយឱ្យមេខ្យល់នាំផ្លូវ

https://www.rasmeinews.com/ July 8, 2020, 7:56 PM

ដោយ៖ ប.ជ័យ/បន្ទាយមានជ័យ៖ ពលករខ្មែរបន្តជ្រៀតចូលទៅប្រទេសថៃដោយបង់លុយឱ្យមេខ្យល់នាំផ្លូវក្នុងម្នាក់ៗពី២.៥០០ទៅ៣.០០០បាតប្រាក់ថៃ។ ប្រភពព័ត៌មានពីកងកម្លាំងកម្ពុជានិងថៃនៅព្រំដែនបានឱ្យដឹងថា៖ ពលករខ្មែរ២៩នាក់ត្រូវបានសមត្ថកិច្ចចម្រុះថៃឃាត់ខ្លួន។ ក្នុងភូមិ/ឃុំនិងស្រុកតាប្រាយ៉ាក្រោយពីឆ្លងព្រំដែនចេញពីកម្ពុជាកាលពីវេលាម៉ោង២រំលងអធ្រាត្រឈានចូលព្រឹកថ្ងៃទី៧ កក្កដាកន្លងមក។ ពលករទាំង២៩នាក់/ មានស្រី ១២នាក់នោះគេមិនទាន់ស្គាល់អត្តសញ្ញាណនៅឡើយទេ។ ពលករទាំងនេះក៏មិនព្រមបានប្រាប់សមត្ថកិច្ចថៃថាពួកគេចេញពីចំណុចណាឆ្លងកាត់ពីកម្ពុជានៅក្នុងភូមិសាស្ត្រណាទេ។ តែប្រាប់ថា ការឆ្លងព្រំដែន គឺតាមរយៈមេខ្យល់នាំទៅឱ្យឡើងជិះរថយន្ត ក្នុងទឹកដីថៃ ប្រុងទៅរកការងារធ្វើ និងចំណាយប្រាក់ឱ្យមេខ្យល់ ម្នាក់ ៣. ០០០ បាតប្រាក់ថៃ ។

សូមរំលឹកថាកាលពីក្នុងខែមិថុនាឆ្នាំ២០២០សមត្ថកិច្ចថៃបានចាប់ឡានដឹកជំឡូងមីដែលបានបង្កប់ខាងក្នុងនូវពលករខ្មែរលួចឆ្លងដែនខុសច្បាប់។ ទាក់ទិនពលករខ្មែរនៅប្រទេសថៃ កាលពីរំលងអាធ្រាត្រនាចុងខែមិថុនាដែរ ពលករខ្មែរធ្វើការខេត្តរ៉ាក់យ៉ងប្រទេសថៃ បានបើកលុយថ្លៃឈ្នួលរួចបាននាំគ្នាផឹកស៊ីក៏កើតមានការឈ្លោះគ្នារវាងពលករខ្មែរគ្នាឯង។ ពលករថៃហើយបានយកកាំភ្លើងបាញ់ពលករខ្មែរស្លាប់ម្នាក់និងជនជាតិថៃស្លាប់ម្នាក់និងរងរបួសធ្ងន់២នាក់៕S/

## អភិបាលរងខេត្តកំពង់ឆ្នាំង នាំយកអំណោយទៅចែកជូនគ្រួសារងាយរងគ្រោះ និងជនចាស់ជរា ចំនួន ០៥គ្រួសារ ក្នុងស្រុករលាប្អៀរ

https://grandnewsasia.com/ 08-07-2020

កំពង់ឆ្នាំង៖ រសៀលថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ លោកស្រី ប៊ិន សុភី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ.) ខេត្តកំពង់ឆ្នាំង លោកស្រី ឧត្តមសេនីយ៍ត្រី មាស សុម៉ាលី ស្នងការរងនគរបាលខេត្ត និងសហការី បានចុះជួបសំណេះសំណាលសាកសួរសុខទុក្ខបងប្អូនជួបការលំបាក មិនបានចេញធ្វើចំណាកស្រុកក្រៅប្រទេស និងបងប្អូនដែលចេញទៅធ្វើការក្រៅបន្សល់ទុកម្តាយឪពុកចាស់ជរានៅចាំផ្ទះ សរុបចំនួន ០៥គ្រួសារ។ ក្នុងឱកាសនោះដែរ លោកស្រីអភិបាលរងខេត្ត ក៏បាននាំយកអំណោយរបស់លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោក ឈួរ ច័ន្ទឿន អភិបាលខេត្តកំពង់ឆ្នាំង និងជាប្រធាន គ.ខ.ប.ជ. ខេត្ត ជូនគ្រួសារងាយរងគ្រោះ ចំនួន ០៥គ្រួសារ ក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មាន៖

១. ស្ថិតក្នុងភូមិទួលខ្សាច់ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំនួន ០២គ្រួសារ៖

-លោកស្រី រស់ ម៉ិច ទទួលបាន អង្ករចំនួន ២០គីឡូក្រាម ឃីត ១កញ្ចប់ និងថវិកាចំនួន ៥០.០០០រៀល។

-លោកស្រី ឃឹន ទទួលបាន អង្ករចំនួន ២០គីឡូក្រាម ឃីត១ កញ្ចប់ និងថវិកាចំនួន ៥០.០០០រៀល។

២.ស្ថិតក្នុងភូមិក្រាំងប្រស្វាយ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ចំនួន ០៣គ្រួសារ៖

-លោកស្រី ជឹម សឹង ពិការជើងមិនរួចទទួលបាន អង្ករចំនួន ២០គីឡូក្រាម ឃីត ១កញ្ចប់ និងថវិកាចំនួន ៥០.០០០រៀល។

-លោក ជឹម យឿន ពិការជើងមិនរួចទទួលបាន អង្ករចំនួន ២០គីឡូក្រាម ឃីត ១កញ្ចប់ និងថវិកាចំនួន ៥០.០០០ រៀល។

-លោក ចាន់ សុផា ជាចាស់ជរា និងមានជំងឺប្រចាំកាយ ទទួលបាន អង្ករចំនួន ២០គីឡូក្រាម ឃីត ១កញ្ចប់ និងថវិកាចំនួន ៥០.០០០រៀល៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៨នាក់

https://www.facebook.com/GDIOfficial 0៨-07-2020

នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆងចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៨នាក់ ស្រី ៤៣នាក់៕

## ប្រជាពលរដ្ឋខ្មែរ ចំនួន ៧៤នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 0៨-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៧៤នាក់ ស្រី ៣៥នាក់ និងកុមារ ០៨នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលករខ្មែរចំនួន ០៤នាក់ ឆ្លងដែនខុសច្បាប់ចូលប្រទេស តាមស្លាបស្តាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម

https://www.facebook.com/GDIOfficial 0៨-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាព្រឹកថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ បានចុះល្បាតក្នុងភូមិសាស្ត្រ ស្លាបស្តាំ ពិនិត្យឃើញពលករខ្មែរ ឆ្លងដែនខុសច្បាប់ ចូលប្រទេសចំនួន ០៤នាក់ និងជនជាតិថៃដែលបាកចេញមានចំនួន ០៤នាក់ ដោយមានលិខិតបញ្ជាក់ពីស្ថានទូតថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា និងលិខិតបញ្ជាក់សុខភាព។ ចំពោះពលករខ្មែរទាំង ៤នាក់នេះ មានទីលំនៅបច្ចុប្បន្នភូមិកោះស្តេច ឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង និងត្រូវបានធ្វើការសាកសួរ អប់រំណែនាំ រួចប្រគល់ជូនមន្ត្រីចត្តាឡីស័កមាត់ច្រក ដើម្បីអនុវត្តនីតិវិធីបន្ត នូវវិធានការរបស់ក្រសួងសុខាភិបាល។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនឲ្យអ្នកដំណើរចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មានកូវីដ-១៩៕

## សម្រាប់ឆមាសទី១ឆ្នាំ២០២០នេះ រាជធានីភ្នំពេញមានបទល្មើសព្រហ្មទណ្ឌជាង៣០០លើក ថយចុះជិត៦០ករណីស្លាប់មនុស្ស៣០នាក់

http://nokorwatnews.com/ 09-07-2020

ភ្នំពេញ៖ សម្រាប់ឆមាសទី១ឆ្នាំ២០២០នេះ នៅរាជធានីភ្នំពេញ បទល្មើសព្រហ្មទណ្ឌបានកើតមានឡើង ៣៤៨/៤០៧លើក ថយចុះ៥៩លើក ស្លាប់មនុស្ស៣០នាក់/១៥នាក់ របួស៩០នាក់/៧៤នាក់។ បង្ក្រាបបទល្មើសព្រហ្មទណ្ឌបាន៣០ករណី ឃាត់ខ្លួនមនុស្ស៤៦៥នាក់ និងបង្ក្រាបតាមដីកា២៦ដីកា ឃាត់ខ្លួនមនុស្ស២៧នាក់។ ជនសង្ស័យនិងវត្ថុតាងបានបញ្ជូនទៅសាលារាជធានីភ្នំពេញចាត់ការតាមផ្លូវច្បាប់។ នេះបើតាមការបញ្ជាក់ឲ្យដឹងពីនាយករដ្ឋបាលរាជធានីភ្នំពេញលោក សេង វណ្ណៈ នៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី១៤របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២០នៅសាលារាជធានីភ្នំពេញ ក្រោមវត្តមានលោក ប៉ា សុជាតិវង្ស ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញនិង លោកឃួង ស្រេង អភិបាលរាជធានីភ្នំពេញ។

លោក សេង វណ្ណៈ បានបញ្ជាក់ថា កម្លាំងរបស់សមត្ថកិច្ចបានបង្ក្រាបក្មេងទំនើងបាន៣៤៧ករណី ឃាត់ខ្លួន៥២១ នាក់ ក្នុងនោះពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌ១០០ករណី ឃាត់ខ្លួន ២១៤នាក់ស្រី ១៤នាក់ កសាងសំណុំរឿងបញ្ជូនទៅកាន់តុលាការរាជធានីភ្នំពេញ និងករណីអុកឡុក បង្កការបាត់បង់សណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន២៤៧ករណីឃាត់ខ្លួនមនុស្ស៣០៧នាក់ ស្រី១១នាក់ បានអនុវត្តវិធានការរដ្ឋបាលដោយធ្វើកិច្ចសន្យាអប់រំបញ្ឈប់

សកម្មភាព ។ បង្ក្រាបបទល្មើសគ្រឿងញៀនបានចំនួន១.១៥៣ករណី បើប្រៀបធៀបនឹងឆមាសទី១ឆ្នាំ២០១៩ បង្ក្រាបបាន១.០៩៦ករណី កើនឡើង៥៧ករណី ឃាត់ខ្លួនមនុស្ស ២.០៧៨/២.២៦៣ នាក់ ស្រី១២៤នាក់ កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ។ បង្ក្រាបល្បែងស៊ីសងបាន៥៤ករណី ឃាត់ខ្លួនមនុស្ស១៩៦នាក់ ក្នុងចំនួននេះ បានបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញចំនួន៣៤នាក់និងធ្វើកិច្ចសន្យាអប់រំ ១៦២នាក់។

ការងារប្រឆាំងការជួញដូរនិងការពារអនីតិជន បង្ក្រាបបាន១៤ករណី ឃាត់ខ្លួនមនុស្ស១៦នាក់ ស្រី ២នាក់ ជនបរទេសម្នាក់។ ជនសង្ស័យ និងវត្ថុតាងបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ និងដោះលែងជនរងគ្រោះបាន១៧នាក់ បញ្ជូនទៅសង្គមកិច្ចរាជធានី៦នាក់ និងប្រគល់ជូនគ្រួសារជនរងគ្រោះ១១នាក់។ សម្រាប់ឆមាសទី១ ឆ្នាំ២០២០នេះដែរ គ្រោះថ្នាក់ចរាចរណ៍បានកើតមានឡើងចំនួន៨០៤ករណី បើប្រៀបធៀបឆមាសទី១ឆ្នាំ ២០១៩ កើនឡើង២៣៣លើកក្នុងនោះស្លាប់ ១៥៩នាក់/១៧១នាក់ របួស៧២៥នាក់/៧៥១នាក់ ខូចខាតរថយន្ត៧២០គ្រឿង ។

ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ លោក ប៉ា សុជាតិវង្ស ក្នុងឱកាសនោះ បានសម្តែងនូវការកោតសរសើរចំពោះអាជ្ញាធរនិងកងកម្លាំងមានសមត្ថកិច្ចទាំងអស់ ដែលបានអនុវត្តនូវការងារ ក្នុងកិច្ចការពារសន្តិសុខនិងសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋបានល្អប្រសើរ ។ ប៉ុន្តែទោះបីជាយ៉ាងណាក្តីប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញក៏បានស្នើដល់អាជ្ញាធររាជធានីភ្នំពេញនិងកងកម្លាំងសមត្ថកិច្ច បន្តការខិតខំប្រឹងប្រែងលើការរឹតបន្តឹងច្បាប់ចរាចរណ៍ផ្លូវគោកបន្ថែមទៀត ខណៈដែលបទល្មើសចរាចរណ៍នៅតែជាកង្វល់មួយរបស់រាជធានីភ្នំពេញ៕ដោយៈសំរិត

## ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០

## នគរបាលប៉ុស្តិ៍ស្រែចារ ស្រុកស្នួល ផ្សព្វផ្សាយអប់រំអំពីគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព

http://cambodiapolice.com/policekh/ 6:35 pm 9 កក្កដា 2020

ភ្នំពេញ ៖ នាព្រឹកថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំស្រែចារ សហការជាមួយលោកមេឃុំ និងលោកមេភូមិ បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន នៅចំណុចថ្មសំពៅ ភូមិរហារ ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ ក្នុងកម្មវិធីដាំកូនឈើរបស់ប្រធានមន្ទីរធនធានទឹកខេត្តក្រចេះ ។ ក្នុងនោះកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលបានធ្វើការផ្សព្វផ្សាយនិងចែកខិតប័ណ្ណរួមមាន៖

-ផ្សព្វផ្សាយសេចក្តីចូលរួមអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន។

-ចែក សារសម្រាប់អប់រំអំពីផល់ប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន។

-ផ្សព្វផ្សាយអនុក្រិត្យលេខ៣៩អនក្រ,បកចុះថ្ងៃទី១៧ ខែមិនាឆ្នាំ២០២០ស្តីពីការពិន័យអន្តរកាលចំពោះអំពើល្មើសច្បាប់ចរាចរណ៍ផ្លូវគោកថ្មី។

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ។

-ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហឹង្សាទាក់ទង នឹងយេនឌ័រ,អំពើជួញដូរស្ត្រីនិងកុមារ ។

-ផ្សព្វផ្សាយគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌគ្រាប់មិនទាន់ផ្ទុះ។

-ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ។

-ផ្សព្វផ្សាយអំពីគ្រោះអគ្គីភ័យ និងផ្សព្វផ្សាយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលស្តីពីវិធីការការពារទប់ស្កាត់នៃការរីករាលដាលអំពីជំងឺកូវីដ១៩ផងដែរ។

-នៅក្នុងនោះ កម្លាំងកម្លាំងបានធ្វើការផ្សព្វផ្សាយនូវលក្ខណៈសម្បត្តិទាំង៩យ៉ាងរបស់គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព មានអ្នកចូលរួមចំនួន៥៧នាក់/ស្រីចំនួន១២នាក់ ៕

## នៅព្រឹកថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប បានសហការជាមួយអង្គការWe World /GVC បានរៀបចំកម្មវិធី ផ្តល់ជូនស្បៀងដល់គ្រួសារពលរដ្ឋចំណាកស្រុកក្រីក្រ ចំនួន៤៥គ្រួសារ នៅឃុំរើល ស្រុកពួក ខេត្តសៀមរាប

https://www.facebook.com/deputygovernoryousophear/ 09-07-2020

កម្មវិធីនេះ ដឹកនាំដោយលោក អ៊ឹម ចំរើន អនុប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាប្រធានក្រុមការងារកិច្ចការទេសន្តរប្រវេសន៍និងជាតំណាង លោកជំទាវ យូ សុភា អភិបាលរងខេត្ត និងប្រធានលេខាធិការដ្ឋាន គ ខ ប ជ និងមានការអញ្ជើញចូលរួមពីលោកស្រី ឆែម សុធា អភិបាលរងស្រុកពួក លោកប្រធានក្រុមប្រឹក្សាឃុំរើល ស្រុកពួក បានចុះជួបសំណេះសំណាល និងចែកស្បៀងជូនប្រជាពលរដ្ឋគ្រួសារពលករក្រីក្រ នៅឃុំរើល ចំនួន៤៥គ្រួសារ ដែលរៀបចំដោយអង្គការ វីវើល/ជីវីស៊ី ដែលរៀបចំឡើងដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់ជូនដល់ប្រជាពលរដ្ឋក្រីក្រ ក្នុងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ១៩។

ថ្លែងនៅក្នុងកម្មវិធីខាងលើ ក្រុមការងារលេខាធិការដ្ឋាន បានធ្វើការផ្សព្វផ្សាយ និងជំរុញដល់បងប្អូនប្រជាពលរដ្ឋខាងលើ ឲ្យចូលរួមសហការជាមួយរដ្ឋាភិបាលកម្ពុជា លើការងារទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ដោយបងប្អូនត្រូវតែធ្វើចាត្តាឡីស័ករយៈពេល១៤ថ្ងៃបន្ទាប់ពីបងប្អូនត្រឡប់ពីក្រៅប្រទេស, ត្រូវរក្សាគម្លាត ធ្វើអនាម័យឲ្យបានជាប់ជាប្រចាំតាមការណែនាំរបស់ក្រសួងសុខាភិបាល, បងប្អូនត្រូវផ្អាកការធ្វើចំណាកស្រុកទៅក្រៅប្រទេសមួយរយៈសិន ពិសេសត្រូវបញ្ឈប់ការធ្វើចំណាកស្រុកខុសច្បាប់តាមរយៈមេខ្យល់ ដោយប្រថុយប្រថានដែលជាហានិភ័យនាំមកនូវគ្រោះថ្នាក់ដោយថាហេតុណាមួយដល់បងប្អូន។ បន្ថែមពីនោះក្រុមការងារបានលើកទឹកចិត្ត ដល់ពលរដ្ឋទាំងអស់ថា ដោយស្ថានភាពនៃការរីករាលនៃជំងឺកូវីដ១៩ កំពុងតែកើតឡើងនៅលើពិភពលោក ដូចនេះសូមឲ្យបងប្អូន រស់នៅក្នុងមូលដ្ឋានរបស់ខ្លួនជាមួយនឹងការដាំដុះសម្រាប់បរិភោគ និងសម្រាប់លក់ដូរផង។ ក្រុមការងារបានថ្លែងអំណរគុណដល់ អាជ្ញាធរឃុំ ស្រុក សមត្ថកិច្ច និងអង្គការវីវើលជីវីស៊ី ដែលបានខិតខំ និងយកចិត្តទុកដាក់ខ្ពស់លើការងារមនុស្សធម៌ ពិសេសការងារទប់ស្កាត់ការីករាលដាលនៃជំងឺកូវីដ១៩នៅកម្ពុជា។

នៅក្នុងកម្មវិធីនេះផងដែរ អង្គការវីវើល ជីវីស៊ី បាននាំមកនូវស្បៀងជូនពលរដ្ឋទាំង៤៥គ្រួសារ ដោយមួយគ្រួសារ ទទួលបានអង្ករ ២៥គីឡូក្រាម ទឹកត្រីមួយយួរ ប្រេងឆាមួយដប និងថវិកាចំនួន ប្រាំបីពាន់រៀលសម្រាប់ ជាមធ្យោបាយធ្វើដំណើរផងដែរ។

## រដ្ឋបាលខេត្តក្រចេះបើកវគ្គផ្សព្វផ្សាយច្បាប់មួយចំនួនស្តីពីវិធីសាស្ត្រធ្វើចំណាកស្រុកដោយសុវត្ថិភាព

http://ppd-news.net/ ថ្ងៃចេញផ្សាយៈ July 9, 2020

**ខេត្តក្រចេះ** ៖ ព្រឹកថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ លោកជំទាវ ខាំ សុភាព អភិបាលរងខេត្តក្រចេះ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តក្រចេះបានអញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គផ្សព្វផ្សាយច្បាប់មួយចំនួន ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពច្បាប់ការទប់ស្កាតអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ កិច្ចការពារជនរងគ្រោះ និងអន្តរាគមន៍ជួយជនរងគ្រោះស្ត្រី និងកុមារដោយការបំពានផ្លូវភេទ។ ពិធីនេះរៀបចំឡើងដោយ លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តក្រចេះ

នៅវត្តកសាង ស្ថិតនៅភូមិកសាង ឃុំចង្រ្កង់ ស្រុកចិត្របុរី និងមានការអញ្ជើញចូលរួមពីលោកស្រីអភិបាលរងស្រុកចិត្របុរី សមាជិកក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត មន្ត្រីរាជការរដ្ឋបាលស្រុក កងកម្លាំងប្រដាប់អាវុធ មេឃុំ ប្រជាពលរដ្ឋ សរុបប្រមាណជាង ១០០នាក់ ផងដែរ។

លោកស្រី ធីន សុធី អភិបាលរងស្រុកចិត្របុរី និងជាសមាជិកគណៈកម្មាធិការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តក្រចេះ មានប្រសាសន៍ ស្វាគមន៍ និងរាយការណ៍ស្ថានភាពនៃវឌ្ឍនៈភាពក្នុងស្រុក ពិសេសការរីកចំរើនលើវិស័យកិច្ចការនារី ដែលបានអនុវត្តភារកិច្ចរបស់ខ្លួនបានយ៉ាងខ្ជាប់ខ្ជួន តាមផែនការយុទ្ធសាស្ត្រចតុកោណរបស់ប្រមុខរាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី និងសូមបងប្អូនប្រជាពលរដ្ឋយកចិត្តទុកដាក់ស្តាប់នូវការផ្សព្វផ្សាយច្បាប់ទាំងនេះ ព្រោះវាមានសារៈសំខាន់ណាស់ចំពោះយើងទាំងអស់គ្នា។

លោកជំទាវ ខាំ សុភាព មានប្រសាសន៍លើកឡើងដែរថាកម្មវិធីផ្សព្វផ្សាយច្បាប់ថ្ងៃនេះមានសារៈសំខាន់ណាស់ចំពោះយើងទាំងអស់គ្នា ហើយនេះជាគោលបំណងដើម្បីកសាងសមត្ថភាពដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងភូមិឃុំគោលដៅឲ្យមានការយល់ដឹងក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានាតាមរូបភាព និងកាត់បន្ថយការធ្វើចំណាកស្រុកប្រកបដោយប្រថុយប្រថាន ។ និងដោយសង្កេតឃើញថា ប្រជាពលរដ្ឋសព្វថ្ងៃនេះធ្វើការចំណាកស្រុកច្រើនដោយមិនស្របច្បាប់ តាមរយៈមេខ្យល់ ធ្វើឲ្យបងប្អូនពិបាកក្នុងការឆ្លងដែន និងរកទីកន្លែងធ្វើការ ក៏ដូចជាកន្លែងស្នាក់នៅជាដើម។ ដូច្នេះប្រសិនបើបងប្អូនចង់ទៅធ្វើការនៅក្រៅប្រទេស គឺត្រូវទៅដោយស្របច្បាប់ រកក្រុមហ៊ុនឲ្យបានច្បាស់លាស់។ ក្នុងឱកាសនោះលោកជំទាវ ខាំ សុភាព បានផ្តាំផ្ញើដល់ប្រជាពលរដ្ឋត្រូវចេះពិចារណាឲ្យបានត្រឹមត្រូវមុន និងសម្រេចចិត្តធ្វើចំណាកស្រុកទៅរកការងារនៅក្រៅស្រុក ឬក្រៅប្រទេស និងត្រូវមានការផ្តល់កិច្ចសហការជាមួយអាជ្ញាមូលដ្ឋានរបស់ខ្លួន។ ម្យ៉ាងវិញទៀតសូមបងប្អូនត្រូវបន្តចូលរួមធ្វើអនាម័យជាប្រចាំ ដោយអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលអោយបានត្រឹមត្រូវ និងត្រូវអនុវត្តអោយបានម៉ឺងម៉ាត់នូវវិធានការបង្ការ ការពារ និងទប់ស្កាត់ ការរីករាលដាលនៃជំងឺ COVID-១៩ នៅក្នុងមូលដ្ឋានរបស់ខ្លួន និងត្រូវបន្តចូលរួម រិតបន្តឹងបញ្ហាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ភូមិស្ថានគ្មានល្បែងស៊ីសង ក្រុមក្មេងទំនើង ខិតខំដោះស្រាយបញ្ហាគ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ បទល្មើសគ្រប់រូបភាព ដើម្បីឲ្យភូមិ ឃុំ មានសុវត្ថិភាព៕ ដោយ ៖ ស៊ាន ចន្ទ័ដា

## ទាហានថៃឃាត់ពលករខ្មែរ៥៩នាក់ដែលលួចឆ្លងចូលតាមច្រករបៀងនៅស្រុកតាព្រាយ៉ា

https://www.rasmeinews.com/ July 9, 2020, 6:23 PM

ដោយ៖ប.ជ័យ/ស្រះកែវថៃ៖តម្រួតទាហានថៃបានឃាត់ខ្លួនពលករខ្មែរ៥៩នាក់ដែលលួចចូលថៃតាមច្រករបៀងនៅស្រុកតាប្រាយ៉ាទល់មុខស្រុកថ្មពួក។ ប្រភពព័ត៌មានបានឱ្យកាសែតរស្មីកម្ពុជាដឹងកាលពីព្រឹកថ្ងៃទី៩ ខែកក្កដានេះថា៖ ពលករខ្មែរទាំងនោះជួបការលំបាកជីវភាពគ្មានការងារធ្វើក្នុងអំឡុងមាតុភូមិនិវត្តន៍ហើយស្នាក់នៅផ្ទះនាប្រទេសកម្ពុជាអំឡុងនៃការរីករាលដាលជំងឺកូវីដ១៩។ ហេតុនេះដើម្បីរស់និងអាចដោះស្រាយជីវភាពគឺមានតែឆ្លងដែនទៅធ្វើការនៅតំបន់មួយក្នុងប្រទេសថៃ ដែលម្ចាស់ការងារត្រូវការកម្លាំងពលកម្មជាខ្លាំង។ហេតុនេះពួកគាត់ត្រូវបង់លុយឱ្យអ្នកជូនផ្លូវគឺឆ្លងព្រំដែនត្រូវបង់លុយចំនួន ៣.០០០ បាតប្រាក់ថៃ/ ក្នុងម្នាក់ៗ កាលពីថ្ងៃទី៨ខែកក្កដា ឆ្នាំ២០២០ ។ ប្រភពព័ត៌មានបានបន្តថា៖វាសនាពលករខ្មែរត្រូវបានអង្គភាពកម្លាំងតាផាព៉ាការិយាល័យអន្តោប្រវេសន៍ស្រះកែវកងតម្រួតយោធាថៃល្បាតព្រំដែន២ និងកងយោធាថៃចាប់ខ្លួនពលករខ្មែរចំនួន៥៩នាក់ ចូលក្នុងតំបន់ព្រំដែននៃស្រុកតាប្រាយ៉ាខេត្តស្រះកែវ ។S/

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០២នាក់

https://www.facebook.com/GDIOfficial 09-07-2020

នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៦និង៣០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០២នាក់ និងមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កមាត់ច្រកផងដែរ។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករទាំង ០២នាក់នេះ មាន ១-ឈ្មោះ ហាយ បញ្ញា ភេទប្រុស អាយុ ៣១ឆ្នាំ មានទីលំនៅភូមិឈើទាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល, ២-ឈ្មោះ សារឿន ហុង ភេទប្រុស អាយុ ២៣ឆ្នាំ មានទីលំនៅភូមិសំព័រ ឃុំព្រៃទទឹង ស្រុកមេសាង ខេត្តព្រៃវែង និងបានធ្វើការអប់រំណែនាំ រួចប្រគល់ជូនមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក ដើម្បីអនុវត្តនីតិវិធីបន្ត នូវវិធានការរបស់ក្រសួងសុខាភិបាល។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញត និងអ្នកបើកបរថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មានកូវិដ-១៩៕

## ពលរដ្ឋខ្មែរចំនួន ៥៤នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 09-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៥៤នាក់ ស្រី ១៧នាក់ និងកុមារ ០៧នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៤នាក់

https://www.facebook.com/GDIOfficial 09-07-2020

នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៤នាក់ ស្រី ២៩នាក់៕

## ពលករខ្មែរចំនួន ០២នាក់ ឆ្លងដែនខុសច្បាប់ ចូលប្រទេស តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម

https://www.facebook.com/GDIOfficial 09-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាព្រឹកថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ បានចុះល្បាតក្នុងភូមិសាស្រ្ត ស្លាបឆ្វេង ពិនិត្យឃើញពលករខ្មែរឆ្លងដែនខុសច្បាប់ ចូលប្រទេស ចំនួន ០២នាក់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករទាំង ០២នាក់នេះនេះ មាន ១-ឈ្មោះ ឈឹម គម ភេទស្រី អាយុ ៣៨ឆ្នាំ, ២-ឈ្មោះ ឈឹម មុំ ភេទស្រី អាយុ ៤៣ឆ្នាំ ហើយអ្នកទាំង ០២នាក់ មានទីលំនៅបច្ចុប្បន្នភូមិសំពោង ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ និងបានធ្វើការសាកសួរ អប់រំណែនាំ រួចប្រគល់ជូនមន្ត្រីចត្តាឡីស័ក្តមាត់ច្រក ដើម្បីអនុវត្តនីតិវិធីបន្ត នូវវិធានការរបស់ក្រសួងសុខាភិបាល។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មានកូវីដ-១៩៕

# ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

## ប្រជាពលរដ្ឋខ្មែរចំនួន៨៣នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 12-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៨៣នាក់ ស្រី ៣៤នាក់ និងកុមារ ០៥នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៣នាក់

https://www.facebook.com/GDIOfficial 12-07-2020

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន៦៣នាក់ ស្រី៣១នាក់៕

## ឃាត់ខ្លួនជនជាតិខ្មែរចំនួ ០៤នាក់ ដែលត្រូវបានមេខ្យល់ នាំឆ្លងដែនចេញទៅប្រទេសថៃ

https://www.facebook.com/GDIOfficial 11-07-2020

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ០៩និង០០នាទី កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានពិនិត្យឃើញ និងឃាត់ខ្លួនជនជាតិខ្មែរចំនួ ០៤នាក់ ដែលត្រូវបានមេខ្យល់ នាំឆ្លងដែនចេញទៅប្រទេសថៃ នៅចំណុចមាត់អូរក្រោមស្ពានមិត្តភាពកម្ពុជា-ថៃ ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់-ក្រុង ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ជនជាតិខ្មែរទាំង ០៤នាក់នេះ មាន ១-ឈ្មោះ តន ស្រីម៉ៅ ភេទស្រី អាយុ ៣០ឆ្នាំ, ២-ឈ្មោះ កែវ ចិន្តា ភេទស្រី អាយុ ៤០ឆ្នាំ, ៣-ឈ្មោះ ប៊ុន ចាន់រិទ្ធ ភេទប្រុស អាយុ ១៦ឆ្នាំ និង៤-ឈ្មោះ លី សាំងវ៉ាន់ ភេទស្រី អាយុ៨ឆ្នាំ ហើយអ្នកទាំង ០៤នាក់នេះ មានស្រុកកំណើតនៅខេត្តពោធិ៍សាត់។

តាមការបំភ្លឺរបស់ជនរងគ្រោះ មុនកើតហេតុពួកគាត់បានធ្វើដំណើរ មកពីខេត្តពោធិ៍សាត់ ក្នុងគោលបំណងចេញទៅរកការងារធ្វើនៅប្រទេសថៃ លុះមកដល់ចំណុចរង្វង់មូលប៉ោយប៉ែត ក៏បានជួបនឹងជនមិនស្គាល់អត្តសញ្ញាណពិតប្រាកដម្នាក់ ភេទប្រុស អាយុប្រហែល៣០ឆ្នាំ បានបបួលគាត់ឆ្លងដែនតាមផ្លូវកាត់ ដោយគិតសេវាក្នុងម្នាក់ ៣,០០០បាត បន្ទាប់ពីគាត់បានយល់ព្រមទៅជាមួយ នៅពេលដែលធ្វើដំណើរដល់មាត់អូរទឹកដីថៃ វាក៏យកប្រាក់ពីពួកគាត់ចំនួន ៨,០០០បាត រួចទុកពួកគាត់ចោលនៅទីនោះ ហើយគេចខ្លួនបាត់។

ក្រោយកើតហេតុកម្លាំងផ្នែកត្រួតពិនិត្យចល័ត បានចុះអន្តរាគមន៍ និងនាំជនរងគ្រោះមកអង្គភាព ធ្វើការសួរនាំពីមូលហេតុ និងបានអប់រំណែនាំ រួចទិញម្ហូបអាហារជូនពួកគាត់ពិសារ ព្រមទាំងបានឧបត្ថម្ភប្រាក់មួយចំនួនដល់ពួកគាត់ ដើម្បីធ្វើជាសាហ៊ុយត្រឡប់ទៅលំនៅស្ថានវិញ។ បច្ចុប្បន្នប៉ុស្តិ៍កំពុងដាក់កម្លាំងតាមដាន រកជនសង្ស័យខាងលើ ដើម្បីចាត់វិធានការតាមនីតិវិធីនៃច្បាប់៕

## ពលរដ្ឋខ្មែរចំនួន ៧២នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 11-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៧២នាក់ ស្រី ៤៧នាក់ និងកុមារ ១៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ០៦នាក់ ពីភាគីថៃ

https://www.facebook.com/GDIOfficial 10-07-2020

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៧និង០០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៦នាក់ និងមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កមាត់ច្រកផងដែរ។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករទាំង ០៦នាក់នេះ មាន ១-ឈ្មោះ វ៉ាន វ៉ាត ភេទប្រុស អាយុ ២៤ឆ្នាំ, ២-ឈ្មោះ រិ រួត ភេទប្រុស អាយុ ៣៥ឆ្នាំ, ៣-ឈ្មោះ ចក់ ព្រំ ភេទប្រុស អាយុ ២៦ឆ្នាំ, ៤-ឈ្មោះ យ៉ា ដើម ភេទស្រី អាយុ ២៤ឆ្នា មានទីលំនៅភូមិ០១ ឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង, ៥-

ឈ្មោះ ឌី ណូ ភេទប្រុស អាយុ ១៧ឆ្នាំ មានទីលំនៅភូមិ០៥ សង្កាត់បឹងកក ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ, ៦-ឈ្មោះ មួង លីវ ភេទស្រី អាយុ ៤៥ឆ្នាំ មានទីលំនៅភូមិនាងកុក ឃុំ បាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង និងបានធ្វើការអប់រំណែនាំ រួចប្រគល់ជូនមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក ដើម្បីអនុវត្តនីតិវិធីបន្ត នូវវិធានការរបស់ក្រសួងសុខាភិបាល។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មានកូវីដ-១៩៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤៥នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 10-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៥នាក់ ស្រី ១៩នាក់ និងកុមារ ០៥នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ៦ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤២នាក់

https://www.facebook.com/GDIOfficial 10-07-2020

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤២នាក់ ស្រី ២១នាក់៕

## ពលរដ្ឋកម្ពុជាជាប់ឃុំចំនួន 132 នាក់ ត្រូវបានរដ្ឋាភិបាលម៉ាឡេស៊ី បញ្ជូនតាមជើងយន្តហោះពិសេសរបស់ក្រុមហ៊ុនអាកាសចរណ៍ម៉ាឡេស៊ី លេខ MH754 ត្រឡប់ត្រឡប់ទៅប្រទេសកម្ពុជាវិញ

https://www.facebook.com/tvkchannel7/ 11-07-2020

នៅព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០ នេះ ពលរដ្ឋកម្ពុជាជាប់ឃុំចំនួន 132នាក់ ត្រូវបានរដ្ឋាភិបាលម៉ាឡេស៊ីបញ្ជូនតាមជើងយន្តហោះពិសេសរបស់ក្រុមហ៊ុនអាកាសចរណ៍ម៉ាឡេស៊ីលេខ MH754 ត្រឡប់ទៅប្រទេសកម្ពុជា ដោយបានចាកចេញពីទីក្រុងគូឡាឡាំពួ នៅវេលាម៉ោង 09:00 ហើយនឹងទៅដល់ទីក្រុងភ្នំពេញ នៅវេលាម៉ោង 09:50 ថ្ងៃដដែល។

ឯកឧត្តម ចឺយ វិចិត្ត ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានបញ្ជាក់ប្រាប់ថា៖ រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ីបានព្រមព្រៀងចំពោះការបញ្ជូន និងការទទួលយកពលរដ្ឋកម្ពុជាជាប់ឃុំដែលភាគច្រើនជាប់ទោសពីបទរស់នៅ និងធ្វើការខុសច្បាប់នៅក្នុងប្រទេសម៉ាឡេស៊ី នៅក្នុងអំឡុងពេលដែលប្រទេសរៀងៗខ្លួនកំពុងប្រយុទ្ធទប់ទល់នឹងការរីករាលដាលនៃជំងឺកូវីដ១៩។ "មុនការបញ្ជូននេះ គឺត្រូវបានឆ្លងកាត់ការសម្ភាសន៍រួចរាល់ពីមន្ត្រីស្ថានទូតយើង ហើយអ្នកទាំងអស់ត្រូវបានអាជ្ញាធរសុខាភិបាលម៉ាឡេស៊ីពិនិត្យធ្វើ CPR Test រកមើលជំងឺកូវីដ១៩ទាំងអស់គ្នា ដោយមានវិញ្ញាបនបត្របញ្ជាក់ថា អវិជ្ជមានកូវីដ១៩ទាំងអស់គ្នា ដែលមានសុពលភាព 72 ម៉ោង ហើយនេះគឺលក្ខខណ្ឌដែលរដ្ឋាភិបាលទាំងពីរព្រមព្រៀងមុននឹងធ្វើការបញ្ជូន។ ប្រសិនបើពិនិត្យទៅឃើញមានឆ្លងជំងឺកូវីដ១៩ រដ្ឋាភិបាលម៉ាឡេស៊ីនឹងទទួលបន្ទុកព្យាបាលឱ្យបានជាសះស្បើយជាមុនសិនទើបធ្វើការបញ្ជូន។" គិតមកដល់ពេលនេះ ពលរដ្ឋកម្ពុជាដែលត្រូវបានចាប់ខ្លួនពីបទល្មើសផ្សេងៗមានចំនួនសរុប 227 នាក់ ដែលកំពុងជាប់នៅតាមមន្ទីរឃុំឃាំងនានានៅទូទាំងប្រទេសម៉ាឡេស៊ី។

ឯកឧត្តមឯកអគ្គរាជទូតបានឱ្យដឹងផងដែរថា វិធានការចាប់បញ្ជូននេះ បានធ្វើឡើងជាបន្តបន្ទាប់នៅក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩ ចំពោះជនបរទេសដែលស្នាក់នៅ និងធ្វើការខុសច្បាប់ ក្នុងនោះរួមមានជនជាតិឥណ្ឌូណេស៊ី បង់ក្លាដែស ប៉ាគីស្ថាន មីយ៉ាន់ម៉ា ហ្វីលីពីន វៀតណាម និងថៃផងដែរ។ ចាប់តាំងពីការរីករាលដាលនៃជំងឺកូវីដ១៩រហូតមកដល់ពេលនេះ ស្ថានទូតកម្ពុជាបានសម្របសម្រួល និងជួយរៀបចំការវិលត្រឡប់ទៅប្រទេសវិញរបស់ប្រជាពលរដ្ឋ ពលករ ពលការនី និងសិស្សនិស្សិតកម្ពុជា បានចំនួន 5 លើក សរុបមានចំនួន 623 នាក់ និងសហការបញ្ជូនពលរដ្ឋកម្ពុជាជាប់ឃុំឃាំងបាន 1 លើក មានចំនួន 132នាក់។

## អាសូរពលករខ្មែរ១០៧នាក់ ចាញ់បោកមេខ្យល់ឆ្លងដែនចូលដីថៃខុសច្បាប់ ត្រូវអាជ្ញាធរថៃក្របួចចាប់បានទាំងអស់

https://kbn.news/archives/ July 10, 2020

**ខេត្តស្រះកែវ៖** នាយប់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរយើងជាច្រើន បានឆ្លងដែនចូលក្នុងប្រទេសថៃ ខុសច្បាប់តាមរយៈមេខ្យល់ដោយត្រូវបានអជ្ញាធរថៃចាប់បានហើយត្រៀមបញ្ជូនមកប្រទេសកម្ពុជាវិញ។ យោងតាមប្រភពព័ត៌មានបានឲ្យដឹងថា ពលករខ្មែរយើងបានឆ្លងដែនចូលក្នុងប្រទេសថៃតាមរយៈមេខ្យល់ ដោយបានឲ្យលុយទៅមេខ្យល់នោះក្នុងម្នាក់៣.៥០០បាត ដោយពលករនៅក្នុងនោះមានស្រី៤៩នាក់ ប្រុស៥៨នាក់។ ដោយត្រូវបានអាជ្ញាធរថៃចាប់បាននៅព្រំដែនថៃ-កម្ពុជានៅក្នុងឃុំទ័ពសៀម ស្រុកតាបយ៉ា ខេត្តស្រះកែវ ប្រទេសថៃ ៕

## អាជ្ញាធរថៃចាប់ខ្លួនពលរដ្ឋខ្មែរចំនួន៥៩នាក់ឆ្លងដែនខុសច្បាប់

https://vodkhmer.news/ សៅរ៍ ឧត្តម ១១ កក្កដា ២០២០ ម៉ោង ១៣:៤៤

សមត្ថកិច្ចការពារព្រំដែនខេត្តស្រះកែវរបស់ថៃ បានចាប់ខ្លួនពលរដ្ឋខ្មែរចំនួន៥៩នាក់ កាលពីថ្ងៃទី១០ខែកក្កដាម្សិលមិញ ដោយចោទពួកគេថា ព្យាយាមលួចឆ្លងកាត់ព្រំដោយខុសច្បាប់ដើម្បីស្វែងរកការងារធ្វើ។ អនុប្រធានក្រុមប្រឹក្សារដ្ឋបាលខេត្តស្រះកែវ និងជាអតីតមេបញ្ជាការកងពលថៃ ប្រចាំខេត្តស្រះកែវ លោក ថោងវ៉ាំម៉ាក ម៉ាខុន បានផ្តល់បទសម្ភាសន៍ជាមួយអ្នកសារព័ត៌មានវិអូឌីនៅថ្ងៃនេះថា ប្រជាពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ទាំងអស់នោះត្រូវបានអជ្ញាធរថៃបន្តឃុំឃាំងនៅអធិការដ្ឋានខេត្តស្រះកែវនៅឡើយ។ លោក បន្តថាខាងអាជ្ញាធរកម្ពុជាមិនទាន់បានទំនាក់ទំនងមកអាជ្ញាធរថៃដើម្បីដោះស្រាយនិងធ្វើកិច្ចព្រមព្រៀងគ្នាជាមួយប្រជាជនដែលឆ្លងព្រំដែនខុសច្បាប់នៅឡើយមកដល់ពេលនេះ។

នៅព្រឹកថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២០ កាសែតបាងកកប៉ុស្តិ៍របស់ថៃបានចុះផ្សាយថា ប្រជាពលរដ្ឋខ្មែរចំនួន៥៩នាក់ត្រូវអាជ្ញាធរថៃចាប់ខ្លួន ក្រោយពីពួកគេទាំងអស់នោះបានប្រមូលផ្តុំគ្នានៅក្នុងស្រុកតាប្រាយ៉ា នៃខេត្តស្រះកែវរបស់ប្រទេសថៃ ដោយពួកគេកំពុងធ្វើដំណើរទៅធ្វើការនៅក្នុងប្រទេសថៃដោយខុសច្បាប់។ ការចុះផ្សាយដដែលនោះបានឲ្យដឹងថា ក្នុងចំណោមពលរដ្ឋខ្មែរចំនួន៥៩នាក់ខាងលើ មានស្ត្រីចំនួន ២៥ នាក់។ ប្រជាពលរដ្ឋខ្មែរដែលត្រូវបានអាជ្ញាធរថៃចាប់ខ្លួននោះ បានរៀបរាប់ថា ការចូលមកនេះ គឺពួកគេបានបង់ប្រាក់ឲ្យក្រុមជួយរត់ការ (មេខ្យល់) ចំនួន៣ពាន់បាត ក្នុងម្នាក់ដើម្បីបានចូលទឹកដីថៃរកការងារធ្វើ។

ឧត្តមសេនីយ៍ទោ Tharapong Malakham បានថ្លែងក្នុងកាសែតបាងកកប៉ុស្តិ៍ថា ប្រជាពលរដ្ឋខុសច្បាប់ទាំងនេះប្រហែល ចេញពីចក្រប៉ោយប៉ែត ខេត្តបន្ទាយមានជ័យតាមខ្សែបន្ទាត់ព្រំដែនរវាងកម្ពុជាថៃ ត្រង់ចំណុចត្រួតពិនិត្យបន្ទាត់ព្រំដែនលេខ ១៤ និង១៥។

## អាជ្ញាធរថៃធ្វើការឃាត់ខ្លួនពលករខ្មែរចំនួន ៨៨នាក់ និងជនជាតិថៃចំនួន៥នាក់

http://peoplenews.asia/ ថ្ងៃទី ១៣ ខែ០៧ ឆ្នាំ២០២០ ម៉ោង ១០ និង ២០ ដោយ សុខ សាន្ត

ភ្នំពេញ៖ កាលពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០២០ កន្លងទៅអាជ្ញាធរថៃធ្វើការឃាត់ខ្លួនពលករខ្មែរចំនួន ៨៨ នាក់ និងជនជាតិថៃ ចំនួន ៥នាក់ និងរថយន្តម៉ាកនីសាន់ ចំនួន ៥គ្រឿង ដែលជាមធ្យោបាយដឹកជញ្ជូនពលករខ្មែរចូលទៅធ្វើការខុសច្បាប់នៅក្នុងប្រទេសថៃ។ សេចក្តីរាយការណ៍បានឲ្យដឹងថា ពលករខ្មែរចំនួន ៨៨នាក់ ទាំងប្រុសទាំងស្រីមានទាំងកូនតូច និងកូនង៉ាបានព្យាយាមឆ្លងដែនដោយថ្មើជើងរយៈពេលជាង ៨ម៉ោងចូលទៅប្រទេសថៃតាមស្រុកតាព្រះយ៉ា និងស្រុកអារញ្ញ ខេត្តស្រះកែវ ពលករទាំងអស់នោះ ត្រូវបានធ្វើដំណើរដឹកជញ្ជូនតាមរថយន្តជនជាតិថៃយកទៅស្តុកទុកនៅខេត្តឆាក់ឈើងសៅ និងបន្តដំណើរទៅកាន់តំបន់ផ្សេងៗទៀត នៅក្នុងប្រទេសថៃដើម្បីការងារ តែត្រូវបានសមត្ថកិច្ចខេត្តចម្រុះថៃធ្វើការឃាត់ខ្លួនបាននៅត្រង់ចំណុចខេត្តឆាក់ឈើងសៅនោះតែម្តង ហើយក្នុងនោះផងដែរបានធ្វើការឃាត់ខ្លួនជនជាតិថៃចំនួន ៥នាក់ និងរថយន្តចំនួន ៥គ្រឿងបន្ថែមទៀត ដែលជាមធ្យោបាយសម្រាប់ដឹកជញ្ជូនពលករខុសច្បាប់ចូលធ្វើការនៅក្នុងប្រទេសថៃ តាមសេចក្តីរាយការណ៍បានឲ្យដឹងទៀតថា ពលករទាំងអស់នោះត្រូវចំណាយអស់ ៣៦០០បាត លុយថៃ (បីពាន់ ប្រាំមួយរយបាតថៃ) ក្នុងម្នាក់ៗដើម្បីសម្រាប់ធ្វើដំណើរទៅបម្រើការងារ (ថ្លៃផ្លូវ)។

# ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០

## ឧត្តមសេនីយ៍ទោ អាត់ ខែម ស្នងការនគរបាលខេត្ត ដាក់ផែនការដល់កងកម្លាំងនគរបាលការពារព្រំដែនគោកទាំង៤ក្នុងការការពារសន្តិសុខ សុវត្ថិភាពជូនពលរដ្ឋ

http://cambodiapolice.com/policekh/ 11:29 pm 13 កក្កដា 2020

បន្ទាយមានជ័យ ៖ ដើម្បីរក្សាបាននូវសន្តិសុខ សុវត្ថិភាព តាមបន្ទាត់ព្រំដែន កាន់តែប្រសើរឡើងថែមទៀតនោះ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ លោកឧត្តមសេនីយ៍ទោ អាត់ ខែម ស្នងការនគរបាលខេត្តបន្ទាយមានជ័យ បានបើកកិច្ចប្រជុំនៅទីបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨៩១ ដោយមានការចូលរួមពីលោកមេបញ្ជាការ មេបញ្ជាការរង នាយផ្នែក នាយរងផ្នែក នាយប៉ុស្តិ៍ការពារព្រំដែននៃវរសេនាតូចទាំង០៤ គឺវរសេនាតូចការពារព្រំដែនគោកលេខ ៨៩១,៩១១,៨០៧ និង៨១៥ ។ កិច្ចប្រជុំនេះក្នុងគោលបំណងដើម្បីពង្រឹងការងារការពារសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋ នៅតាមបន្ទាត់ព្រំដែន ក៏ដូចជាការទប់ស្កាត់នូវការលួចឆ្លងដែនរបស់ពលករខ្មែរចូលទៅរកការងារធ្វើប្រទេសថៃដោយខុសច្បាប់ ។

មានមតិសំណេះសំណាល ក៏ដូចដាក់ផែនការមួយចំនួនដល់កងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកទាំង០៤នាឱកាសនោះ លោកឧត្តមាសេនីយ៍ទោ អាត់ ខែម ស្នងការនគរបាលខេត្ត បន្ទាយមានជ័យ បានថ្លែងនូវការកោតសរសើរដល់កងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកទាំង០៤ ដែលបានខិតខំបំពេញភារកិច្ចរបស់ខ្លួនក្នុងតួនាទីការពារព្រំដែន ក៏ដូចជាការសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋបានល្អប្រសើរ ក្នុងដែនភូមិសាស្ត្រដែលខ្លួនគ្រប់គ្រង ពិសេសគឺបានល្បាតត្រួតពិនិត្យជាប្រចាំតាមព្រំដែន ដើម្បីទប់ស្កាត់នូវរាល់បទល្មើសឆ្លងដែនខុសច្បាប់ ។ ជាមួយគ្នានោះដែរ លោកឧត្តមសេនីយ៍ស្នងការ បានជំរុញដល់កងកម្លាំងនគរបាលការពារព្រំដែនគោកទាំង០៤ ត្រូវខិតខំពង្រឹងការពារសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋ រស់នៅតាមបន្ទាត់ព្រំដែន ត្រូវទប់ស្កាត់ឲ្យខាងតែបាននូវរាល់បទល្មើសឆ្លងដែនខុសច្បាប់ ដូចជាបទល្មើសគ្រឿងញៀន ការលួចនាំចូលនូវទំនិញខូចគុណភាព និងទប់ស្កាត់ពលករខ្មែរយើងដែលចាញ់បោកលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ ដែលពេលនេះប្រទេសថៃកំពុងប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនូវជំងឺកូវីដ-១៩ ហើយនៅមិនទាន់មានការបើកច្រកព្រំដែននោះនៅឡើយ ។

ជាចុងក្រោយ លោកឧត្តមសេនីយ៍ទោ អាត់ ខែម បានផ្តាំផ្ញើដល់កងកម្លាំងនគរបាលទាំងអស់ត្រូវមានសាមគ្គីភាពផ្ទៃក្នុងឲ្យបានល្អ និងមានកិច្ចសហការជាមួយល្អជាមួយអាជ្ញាធរ និងបណ្តាកងកម្លាំងនៅតាមព្រំដែន និងមានកិច្ចសហប្រតិបត្តិការល្អជាមួយកងកម្លាំងនៃប្រទេសជិតខាង ដើម្បីឲ្យព្រំដែននៃប្រទេសយើងទាំង០២ ជាព្រំដែនសន្តិភាព សហប្រតិបត្តិការនិងការអភិវឌ្ឍន៍ ។ នាឱកានោះដែរ លោកឧត្តមសេនីយ៍ស្នងការក៏បានចែកសារុងដល់កងកម្លាំងនគរបាលដែលបានចូលរួមប្រជុំនោះផងដែរ ៕

## កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាល២ធ្នូផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

http://cambodiapolice.com/policekh/ 3:33 pm 13 កក្កដា 2020

ក្រចេះ ៖ នាព្រឹកថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាល២ធ្នូ បានធ្វើការផ្សព្វផ្សាយដល់លោកគ្រូ-អ្នកគ្រូ អំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន នៅចំណុចវិមាន២ធ្នូ ភូមិជើងឃ្លូ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ក្នុងកម្មវិធីស្តីពី "ការផ្សព្វផ្សាយសេចក្តីណែនាំប្រតិបត្តិការគាំទ្រអនុវត្តការសិក្សាពីចម្ងាយ" ។ ក្នុងនោះកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលបានធ្វើការផ្សព្វផ្សាយនិងចែកខិតប័ណ្ណរួមមាន៖

-ផ្សព្វផ្សាយសេចក្តីអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា។

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន។

-ចែកសារសម្រាប់អប់រំអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន។

-ផ្សព្វផ្សាយអនុក្រឹត្យលេខ៣៩អនក្រ,បកចុះថ្ងៃទី១៧ ខែមិនាឆ្នាំ២០២០ស្តីពីការពិន័យអន្តរកាលចំពោះអំពើល្មើសច្បាប់ចរាចរណ៍ផ្លូវគោកថ្មី។

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ។

-ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហឹង្សាទាក់ទង នឹងយេនឌ័រ,អំពើជួញដូរស្ត្រីនិងកុមារ ។

-ផ្សព្វផ្សាយគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌគ្រាប់មិនទាន់ផ្ទុះ។

-ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ។

-ផ្សព្វផ្សាយអពីគ្រោះអគ្គីភ័យ និងផ្សព្វផ្សាយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលស្តីពីវិធីការការពារទប់ស្កាត់នៃការរីករាលដាលអំពីជំងឺកូវីដ១៩ផងដែរ។

នៅក្នុងនោះកម្លាំងយើងបានធ្វើការផ្សព្វផ្សាយនូវលក្ខណៈសម្បត្តិទាំង០៩យ៉ាងរបស់គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដែលមានលោកគ្រូ-អ្នកគ្រូចំនួន១៣៨នាក់/ស្រីចំនួន៨៦នាក់ ៕

## អាជ្ញាធរខេត្តស្វាយរៀង នៅតែយកចិត្តទុកដាក់ធ្វើចត្តាឡីស័កពលករមកពីក្រៅប្រទេស

http://btv.com.kh/ 13/07/2020

ស្វាយរៀង ៖ មកទល់ពេលនេះ មិនមានពលករវិលចូលស្រុកណាម្នាក់ មានសញ្ញាបញ្ជាក់ផ្ទុកកូវីដ១៩នោះទេ តែវិធានការទប់ស្កាត់ការឆ្លងរាលដាលកូវីដ១៩ របស់អាជ្ញាធរខេត្តស្វាយរៀង នៅតែបន្ត ខណៈដែលពលករ នៅតែបន្តវិលត្រឡប់មកពីប្រទេសក្រៅវិញ ដោយកង្វះទីផ្សារការងារ ព្រោះវិបត្តិកូវីដ–១៩ ។

លោក ស៊ូ ម៉ុល អភិបាលស្រុករមាសហែក ខេត្តស្វាយរៀង បានប្រាប់BTV នៅថ្ងៃនេះថា នៅទូទាំងស្រុក បន្ទាប់ពីពិភពលោក និងនៅកម្ពុជាបានជួប និងបញ្ហាកូវីដ១៩ រហូតមកដល់ពេលនេះ ស្រុកមានពលករ និងពលរដ្ឋ បានវិលមកពីប្រទេសក្រៅមួយចំនួន និងខេត្តនានា ចូលមករួមជីវភាពជាមួយ គ្រួសារ ចំនួនជាង១ពាន់នាក់។ លោក បានបញ្ជាក់ថា ក្នុងចំណោមពលករ និងពលរដ្ឋ ចំនួនជាង១ពាន់នាក់ ដែលចូលមករួមរស់ ជាមួយគ្រួសារ រដ្ឋបាលឃុំស្រុក និងមន្ទីរសុខាភិបាលខេត្ត ស្រុក បានចុះណែនាំធ្វើចត្តាឡីស័កដោយស្ម័គ្រចិត្ត រួចបញ្ជូនឱ្យទៅរួមជីវភាពជាមួយគ្រួសារ នៅពេលត្រូវបានបញ្ជាក់ថា សុខភាពរបស់ពួកគេ គឺល្អប្រសើរនោះ។

មានពលករវិលចូលស្រុក ស្ទើររៀងរាល់ថ្ងៃ ដោយសារពួកគេប្រឈមនឹងវិបត្តិអត់ការងារធ្វើ ដោយសារបញ្ហាកូវីដ១៩។ លោក បានបញ្ជាក់ទៀតថា អំឡុងពេល នៃវិបត្តិកូវីដ–១៩នេះ រដ្ឋបាលខេត្តស្រុក ក្រុមការងារចុះ ជួយឃុំ ស្រុក និងសាខាកាកបាទក្រហមកម្ពុជាខេត្ត បានយកចិត្តទុកដាក់ជួយឧបត្ថម្ភដល់ពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ដើម្បីបំណិនជីវភាព បន្តនិរន្តភាពក្នុងការប្រកបអាជីវកម្មដាំដុះចិញ្ចឹមសត្វ នៅតាមគ្រួសារ ពិសេសក្រុមការងារស្រុក បាននឹងកំពុងសិក្សាស្វែងយល់ពីជីវភាពដើម្បីសុំគោលការណ៍ឧបត្ថម្ភ សាច់ប្រាក់ពីរាជរដ្ឋាភិបាលជូនពួកគេ នៅពេលខាងមុខផងដែរ ។

យោងតាមរបាយការណ៍គណៈកម្មការទប់ស្កាត់ជំងឺកូវីដ–១៩ ខេត្តស្វាយរៀង គិតពីថ្ងៃទី១៥ ខែ មីនា ដល់ដើមខែកក្កដា ឆ្នាំ២០២០ មានពលករ និងពលរដ្ឋ មកពីប្រទេសនានា និងនៅក្នុងខេត្តមួយ ចំនួន ចូលមកខេត្តស្វាយរៀង ចំនួនជាងពីរពាន់នាក់ ក្នុងនោះស្រុករមាសហែក មានចំនួន ជាងមួយពាន់ នាក់៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៥៨នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 13-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៥៨នាក់ ស្រី ២៣នាក់ និងកុមារ ០៩នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧១នាក់

https://www.facebook.com/GDIOfficial/ 13-07-202

នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧១នាក់ ស្រី ៣៩នាក់ និងពលរដ្ឋថៃចាកចេញ មានចំនួន ០២នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## តម្រួតថៃ ឃាត់ខ្លួនពលករខ្មែរប្រុស-ស្រី៧នាក់បំរុង លួចឆ្លងដែនចូលតាមច្រករបៀងមួយកន្លែង

https://www.facebook.com/VD7news 13-07-2020

ប្រទេសថៃ ៖ សមត្ថកិច្ចចម្រុះរបស់ថៃរួមមានទាហាននឹងតម្រួត បានចាប់ឃាត់ខ្លួនពលករខ្មែរ លួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ចំនួន៧នាក់ ក្នុងនោះប្រុស៥នាក់ ស្រី២នាក់កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ ត្រង់ចំណុចត្រួតពិនិត្យលេខ220ដល់ចំណុចត្រួតពិនិត្យលេខ221 នឹងមានមេខ្យល់នាំផ្លូវ ។ ក្រោយពីធ្វើការសាកសួរ ពួកគេបានឲ្យដឹង ថា ដោយសារចង់ឆ្លងទៅធ្វើការនៅផ្សារ ថៃ ភូមិដង ងូ ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ តែនៅមិនមានថៅកែមិន មកទទួលទើបពួកគាត់សម្រេចចិត្តធ្វើដំណើរដោយខ្លួនឯងដូច្នេះ ។ ពលករខ្មែរទាំង៧នាក់ខាងលើ រួមមានឈ្មោះដូចខាងក្រោម ៖

ទី១-ឈ្មោះ ថង ផាន្នី ភេទប្រុស អាយុ២៩ឆ្នាំ សញ្ជាតិខ្មែរ

ទី២-ឈ្មោះ កួ អេម ភេទប្រុស អាយុ២៩ឆ្នាំ សញ្ជាតិខ្មែរ

ទី៣-ឈ្មោះ ហន សាឡោះ ភេទប្រុស អាយុ២៧ឆ្នាំ សញ្ជាតិខ្មែរ

ទី៤-ឈ្មោះ ពៀន ថង ភេទប្រុស អាយុ២២ឆ្នាំ សញ្ជាតិខ្មែរ

ទី៥-ហេង ឡៃណេត ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ

ទី៦-ថេត ឡៃតេង ភេទស្រី អាយុ២៣ឆ្នាំ សញ្ជាតិខ្មែរ

ទី៧-មុត សាក់ណា ភេទស្រី អាយុ១៦ឆ្នាំ សញ្ជាតិខ្មែរ

ដោយសមត្ថកិច្ចចោទពីបទ ជាបុគ្គលបរទេសលួចចូលមក នឹងស្នាក់នៅក្នុងប្រទេសដោយខុសច្បាប់ ព្រមទាំងនាំទៅអនុវត្តតាមនិតិវិធី ច្បាប់បន្ត៕ ដោយ-ភិរម្យ ឥទ្ធិពល

## ថៃដាក់ពង្រាយលួសបន្លា តាមខ្សែបន្ទាត់ការពារពលករខ្មែរដែលលបឆ្លងដែនខុសច្បាប់

https://www.facebook.com/neakmeasnews/ ចេញផ្សាយថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ ដោយ ជីវ័ន្ត

ព័ត៌មានអន្តរជាតិ ប្រទេសថៃ ៖ លួសបន្លារាប់សិបគីឡូម៉ែត្រ ត្រូវបានភាគីថៃដាក់ពង្រាយនៅតាមខ្សែបន្ទាត់ព្រំដែនជាប់ព្រំដែនប្រទេសកម្ពុជាដោយក្រុមយោធាថៃបានអះអាងថា ការដាក់ពង្រាយបែបនេះគឺជាការការពារ និង

ទប់ស្កាត់ទៅលើពលករខ្មែរដែលតែងតែលបលួចឆ្លងដែនចូលទៅក្នុងទឹកដីថៃដោយគ្មានការអនុញ្ញាត។ នៅពាក់កណ្តាលយប់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២០នេះ លោកថូវ៉ាផុង ម:ឡ:ខាំ មេបញ្ជាការតម្រួតការពារព្រំដែនបានដឹកនាំកម្លាំងចុះពិនិត្យតាមខ្សែបន្ទាត់ព្រំដែនខេត្តស្រះកែវត្រង់ចំណុច ដែលពលករខ្មែរតែងតែលបលួចឆ្លងដែនចូលទៅក្នុងទឹកដីថៃដោយខុសច្បាប់នាពេលកន្លងមកក្នុងនោះក៏មានវត្តមានលោក កិត្តិយ៉ា កៀតឈុតមេបញ្ជាការកងការពារព្រំដែនគោកលេខ១២ផងដែរ។នៅពេលនោះដែរសមត្ថកិច្ចថៃបាននិយាយថាខ្សែបន្ទត់ព្រំដែនខេត្តស្រះកែវ។ ដែលមានរយ:ចម្ងាយ១៦៥គីឡូម៉ែត្រគឺមានផ្ទៃដីដែលគ្មានអូរ និងគ្មានភ្នំប្រវែង១៤គីឡូម៉ែត្រ ស្ថិតក្នុងភូមិសាស្ត្រស្រុកប៉ារ៉ៃហើយក៏ជាតំបន់ដែលពលករខ្មែរតែងតែលបឆ្លងដែនជាញឹកញាប់ផងដែរ ដើម្បីចូលទៅរកការងារធ្វើនៅក្នុងប្រទេសថៃ ដោយខុសច្បាប់។ដោយសារតែបញ្ហានេះ ទើបសមត្ថកិច្ចថៃបានចាប់ផ្តើមដាក់ពង្រាយលួសបន្លាចំនួន៣ជាន់នៅក្នុងភូមិសាស្ត្រខាងលើ ក៏ដូចជាក្នុងស្រុកអារញ្ញប្រាថេតដើម្បីទប់ស្កាត់នូវការលបឆ្លងរបស់ពលករខ្មែរចូលទៅក្នុងទឹកដីថៃ ចុងក្រោយលោកមេបញ្ជាការរូបនេះបានសង្កត់ធ្ងន់ថា កម្លាំងសមត្ថកិច្ចថៃទាំងអស់ត្រូវបង្កើននូវការប្រុងប្រយ័ត្ន និងឃាត់ខ្លួនពលករណា ដែលលបឆ្លងដែនចូលទៅក្នុងទឹកដីថៃ ដោយគ្មានការអនុញ្ញតដើម្បីបញ្ជូនខ្លួនទៅកាន់តុលាការក្នុងការអនុវត្តតាមនីតិវិធីច្បាប់ដោយឡែក ចំពោះមន្ត្រីយោធឬមន្ត្រីតម្រួតណាមួយដែលមានការពាក់ព័ន្ធត្រូវដាក់ទោសទណ្ឌកម្រិតធ្ងន់ឬត្រូវបណ្តេញចេញពីក្របខណ្ឌមន្ត្រីរាជការ ៕

## ទីបំផុតអ៊ីស្រាអែលព្រមទទួលពលករពីប្រទេសថៃ ២៥,០០០នាក់ ឲ្យមកបម្រើវិស័យកសិកម្ម

http://www.freshnewsasia.com/ 2020-07-13 06:08pm

**(ហ្សេរុយសាឡឹម)៖** ទីបំផុតរដ្ឋាភិបាលអ៊ីស្រាអែល និងថៃបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរួមគ្នាមួយហើយ ដោយក្នុងនោះភាគីអ៊ីស្រាអែល បានយល់ព្រមទទួលពលករបម្រើការងារ លើវិស័យកសិកម្មប្រមាណ ២៥,០០០នាក់ពីប្រទេសថៃ។ នេះបើតាមការចេញផ្សាយ ដោយទីភ្នាក់ងារព័ត៌មានចិនស៊ីនហួរ នាល្ងាចថ្ងៃចន្ទ ទី ១៣ ខែកក្កដា ឆ្នាំ២០២០។ ពិធីចុះហត្ថលេខាខាងលើនេះ ត្រូវបានធ្វើឡើងរវាងរដ្ឋមន្ត្រីការបរទេសអ៊ីស្រាអែល លោក ហ្គាប៊ី អាសកេណាហ្ស៊ី (Gabi Ashkenazi) និងឯកអគ្គរាជទូតថៃលោកស្រី ផាន់ណាផា ចន្ទ្រារ៉ាយម៉ា (Pannabha Chandrarayma)។ លោករដ្ឋមន្ត្រីអ៊ីស្រាអែល បានលើកឡើងនាឱកាសនោះថា កិច្ចព្រមព្រៀងនេះមានសារ:សំខាន់ ហើយវាក៏ចាំបាច់សម្រាប់កសិករ អ៊ីស្រាអែលរាប់ពាន់នាក់ផងដែរ។ បន្ថែមពីនេះភាគីអ៊ីស្រាអែលក៏បានសន្យា ការពារសិទ្ធិនៃពលករថៃ ដែលមកធ្វើការនៅក្នុងទឹកដីអ៊ីស្រាអែលផងដែរ។

គួរបញ្ជាក់ថា កិច្ចព្រមព្រៀងរវាងអ៊ីស្រាអែល និងថៃខាងលើនេះ បានកើតមានឡើងក្រោយភាគីទាំងពីរបានព្យាយាមចរចាគ្នាអស់ជាច្រើនខែ បើទោះបីជាពិភពលោក កំពុងរងគ្រោះដោយជំងឺ COVID-19 ក៏ដោយ។ បច្ចុប្បន្នវិស័យកសិកម្មអ៊ីស្រាអែល មានការពឹងផ្អែកខ្លាំងបំផុត លើពលករមកពីប្រទេសថៃបន្ទាប់ពីប្រទេសទាំងពីរបានចុះហត្ថលេខាមួយកាលពីឆ្នាំ២០១២៕

## ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០

## លោក ហ៊ុន សែន ប្រកាសផ្តល់ទុនចិញ្ចឹមត្រី ឲ្យកម្មករ និងពលករ ដែលបាត់បង់ការងារ ដោយសារវិបត្តិជំងឺកូវីដ១៩

https://www.rfa.org/khmer/ ដោយ ជាតិ ចំណាន 2020-07-14

រដ្ឋាភិបាល ប្រកាសផ្តល់ទុន សម្រាប់ចិញ្ចឹមត្រី ដោយឥតគិតថ្លៃ ឲ្យកម្មករ និងពលករ ដែលរងវិបត្តិបាត់បង់ការងារធ្វើដោយសារវិបត្តិជំងឺកូវីដ១៩ (Covid-19)។ សហជីព និង អ្នកចិញ្ចឹមត្រី ស្វាគមន៍គម្រោងនេះ និង ស្នើសុំឲ្យជួយផ្តល់ទុន ដល់ក្រុមអ្នកនេសាទផង។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រាប់ឲ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ថែមថវិការដ្ឋចំនួនប្រាំលាន (៥លាន) ដុល្លារថែមទៀត សម្រាប់ជួយជំរុញឲ្យកម្មករ និងពលករ ងាកមកប្រកបមុខរបរចិញ្ចឹមត្រីវិញ។ លោក ហ៊ុន សែន ប្រាប់ថា ដើមទុន ដែលត្រូវឲ្យកម្មករ និងពលករ ដោយមិនគិតថ្លៃនោះមានដូចជា កូនត្រី តង់សម្រាប់ចិញ្ចឹមត្រី និងការជួយបង្ហាត់បង្រៀនពីរបៀបចិញ្ចឹមត្រី ជាដើម៖ «ខ្ញុំក៏អំពាវនាវកម្មករ កម្មការិនី និងបងប្អូនត្រឡប់មកពីថៃ ចូលរួមនៅក្នុងវិស័យកសិកម្ម ជំរុញវិស័យកសិកម្ម។ ឥឡូវបង្កើតមុខរបររបៀបចិញ្ចឹមត្រី។ ឥឡូវ បើថា ៥០ម៉ឺនដុល្លារហ្នឹង វាមិនគ្រប់ យើងបន្ថែមដើម្បីឲ្យអ្នកទាំងនោះ ចិញ្ចឹមត្រី ត្រីអណ្តែង ឲ្យពួកគាត់មានដើមទុនមានដើមទុន។ អាហ្នឹង យើងឲ្យទទេហ្មង ឲ្យទទេ កូនត្រី ក៏យើងឲ្យទទេ អាតង់ក៏យើងឲ្យទទេ ហើយយើងទៅជួយបង្ហាត់បង្ហាញ ជួយឲ្យគាត់មានមុខរបរ»។

លោក ហ៊ុន សែន អះអាងថា រដ្ឋាភិបាល បានបញ្ចេញថវិការដ្ឋ ចំនួនហាសិបម៉ឺន (៥០ម៉ឺន)ដុល្លាររួចហើយ សម្រាប់ជួយដល់ការចិញ្ចឹមត្រីកន្លងមក។ លោកបន្តថា បច្ចុប្បន្នមានកសិករជាងបួនម៉ឺន ប្រាំមួយពាន់ (៤៦.០០០) គ្រួសារ កំពុងប្រកបរបរចិញ្ចឹមត្រីក្នុងស្រះ។ លោក ហ៊ុន សែន បន្តណែនាំឲ្យរដ្ឋមន្ត្រីក្រសួងកសិកម្មជំរុញឲ្យមានការចិញ្ចឹមត្រីបន្ថែមទៀត ឲ្យបានយ៉ាងហោចណាស់ ឲ្យបានចំនួនប្រាំម៉ឺន (៥០.០០០) គ្រួសារ។ លោក ថ្លែងបែបនេះ នៅមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជត្រី នៅស្រុកពាមរ ខេត្តព្រៃវែង នៅថ្ងៃទី១៤ កក្កដា ក្នុងពេលលោកជួបសំណេះសំណាលជាមួយកសិករចិញ្ចឹមត្រី។ ជុំវិញការប្រកាសផ្តល់ទុនចិញ្ចឹមត្រីឲ្យកម្មករ និងពលករនេះដែរ ប្រធានសហភាពការងារកម្ពុជា លោក អាត់ ធន់ យល់ថា កម្មករដែលបាត់បង់ការងារនៅរោងចក្រទំនងពិបាកក្នុងការ ងាកមកចាប់អាជីពចិញ្ចឹមត្រី នៅពេលភ្លាមៗនេះ ព្រោះកម្មករគ្មានជំនាញ និងគ្មានបទពិសោធន៍ខាងចិញ្ចឹមត្រី។ លោក អាត់ ធន់ ជំរុញឲ្យរដ្ឋាភិបាលជួយផ្តល់ទុន ផ្នែកផ្សេង ក្នុងវិស័យកសិកម្ម ក្រៅពីការចិញ្ចឹមត្រី ដូចជាការធ្វើស្រែ ដាំដំណាំ និងចិញ្ចឹមសត្វគ្រប់ប្រភេទ តាមចំណូលចិត្ត ជំនាញ និងបទពិសោធន៍របស់កម្មករ ដែលរស់នៅតាមខេត្ត។ ឯកម្មកររស់នៅរាជធានីភ្នំពេញវិញ លោក អាត់ ធន់ ជំរុញឲ្យរដ្ឋាភិបាល ជួយរកការងារថ្មី ដូចជា ការងារនៅសិប្បកម្មដេរម៉ាស់ ទីតាំងផលិតសម្ភារៈពេទ្យ ជាដើម៖ «ហើយអ្នកខ្លះ ក៏គាត់ មិនជាអ្នកដែលចង់ធ្វើការផ្នែកកសិកម្មហ្នឹង ប៉ុន្មានដែរ។ អ៊ីចឹង មិនដឹងថា គាត់ហ្នឹង អាចទៅចាប់ នូវទីផ្សារ ឬក៏ចាប់ផ្នែកកសិកម្មហ្នឹង បានឬក៏អត់ទេ? តាមខ្ញុំមើល បើសិនជាឪពុកម្តាយគាត់ ប្រហែលជាអាចទៅរួចជាងក្មេងៗ ហ្នឹង»។

ចំណែកប្រធានសម្ព័ន្ធប្រជានេសាទកម្ពុជា លោក ឡុង សូថែត ស្វាគមន៍ការបង្កើតមុខរបរចិញ្ចឹមត្រីឲ្យពលរដ្ឋ ព្រោះលោក សង្កេតឃើញថា ត្រីនៅទន្លេសាបកាន់តែខ្សត់ទៅៗ ហើយនៅឆ្នាំនេះ ត្រីទំនង ជាក្សត់ជាងឆ្នាំមុនទៀត ព្រោះគ្មានទឹកភ្លៀង។ លោក ឡុង សូថែត យល់ថា នៅពេលផ្តល់ទុនឲ្យហើយ រដ្ឋាភិបាលចាំបាច់ត្រូវយកចិត្តទុកដាក់ លើការបង្ហាត់បង្រៀនបច្ចេកទេសចិញ្ចឹមត្រី ដល់កម្មករ និងពលករទាំងនោះ ឲ្យបានទៀងទាត់ ព្រោះបើហ៊ានតែធ្វេសប្រហែល ខកខានការបង្ហាត់នោះ ត្រីដែលចិញ្ចឹមមិនអាចធំធាត់បានទេ។ ទោះយ៉ាងណា អ្នកជំនាញខាងចិញ្ចឹមត្រីរូបនេះ ក៏ចង់ឲ្យរដ្ឋាភិបាល ជួយផ្តល់ទុន និងបច្ចេកទេស ដល់អ្នកនេសាទ និងអ្នកកំពុងប្រកបមុខរបរចិញ្ចឹមត្រីរាល់ថ្ងៃ បន្ថែមទៀតផងដែរ ព្រោះពួកគេ ក៏រងផលប៉ះពាល់ខ្លាំង ពីវិបត្តិជំងឺកូវីដ១៩ ដែរ។ លោក

ឡុង សូចែត យល់ថា បើមានការជួយទុន និងបច្ចេកទេសដល់អ្នកនេសាទ និងអ្នកកំពុងចិញ្ចឹមត្រី នឹងធ្វើឲ្យទិន្នផលត្រីទទួលបានផលច្រើន និងជាការបង្កើនកំណើនត្រីឡើងវិញ៖ «បើគ្មានផ្ទត់គំនិតក្នុងការចិញ្ចឹមទេ បើសិនយើង (រដ្ឋាភិបាល) ផ្តល់ឲ្យគាត់ទៅហើយគាត់អត់សមត្ថភាពទៀត អត់ជំនាញទៀត អាហ្នឹងគឺដូចអត់ប្រយ័ត្នអ៊ីចឹងណា។ ប៉ុន្តែបើត្រឡប់អាហ្នឹងវិញ ដូចនិយាយមិញអ៊ីចឹង ត្រឡប់អាហ្នឹង បើសិនជាយើងមកជួយផ្គត់ផ្គង់ដល់អ្នកនេសាទ ដូចថា វាមិនមានជំនាញច្បាស់លាស់ទេ ប៉ុន្តែក៏គាត់មានការយល់ដឹងខ្លះដែរ ព្រោះគាត់មានបទពិសោធន៍ចិញ្ចឹមខ្លះដែរ។ ទោះជាវាមិនច្បាស់ទែង តែគាត់មានការយល់ដឹងខ្លះ វាល្អម្យ៉ាងដែរ....ប្រហែលជាអ្នកទទួលផលជាងអ្នកដែលធ្លាប់តែធ្វើការនៅតាមរោងចក្រ គ្នាអត់ជំនាញសោះ វាអត់រលីងបណ្តោយណា»។

របាយការណ៍របស់រដ្ឋបាលជលផល បង្ហាញថា ផលនេសាទទឹកសាបក្នុងឆ្នាំ២០១៩ មានចំនួនជាង ៤៧ម៉ឺនតោន ធ្លាក់ចុះជាងឆ្នាំ២០១៨ ចំនួនជាង ៥ម៉ឺនតោន (ឆ្នាំ២០១៨ ជាង ៥៣ម៉ឺនតោន) ដោយសារ ការប្រែប្រួលអាកាសធាតុ បណ្តាលឲ្យធ្លាក់ភ្លៀងតិច ដែលជាមូលហេតុនាំឲ្យត្រីធ្លាក់ចុះ៕

## រដ្ឋមន្រ្តីមហាផ្ទៃ ណែនាំដល់ភាគីពាក់ព័ន្ធ ត្រូវប្រើប្រាស់ថវិកាមូលនិធិ ១លានដុល្លារបស់អង្គការសហប្រជាជាតិ ឲ្យមានប្រសិទ្ធភាព

https://dap-news.com/national/ ByVNT108 Posted on July 15, 2020

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានលើកឡើងថា អង្គការសហប្រជាជាតិ បានផ្តល់មូលនិធិចំនួន១លានដុល្លា ដើម្បីជួយដល់ ជនទេសន្តរប្រវេសន៍កម្ពុជា ដូចនេះ ភាគីពាក់ព័ន្ធទាំងអស់ ដែលរួមមាន ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការដៃគូទាំងអស់ ត្រូវចាត់ចែងប្រើប្រាស់ថវិកានេះ ឲ្យចំគោលដៅ ដើម្បីប្រសិទ្ធភាព និងមានតម្លាភាពផងដែរ ។

ក្រោយបញ្ចប់កិច្ចប្រជុំជាន់ខ្ពស់ រវាងស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិនៅកម្ពុជា ស្តីពីកម្មវិធីរួមគ្នា ដើម្បីគាំទ្រជនទេសន្តប្រវេសន៍ ដែលវិលត្រឡប់ក្នុងស្ថានភាព នៃការរាតត្បាតជំងឺកូវីដ-១៩ និងផលប៉ះពាល់ នាព្រឹកថ្ងៃពុធ ទី១៥ ខែកក្កដា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ សម្តេច ស ខេង មានប្រសាសន៍ថា «អង្គការសហប្រជាជាតិបានផ្តល់មូលនិធិ ដើម្បីជួយដល់ទេសន្តរប្រវេសន៍ ចំនួនទឹកប្រាក់១លានដុល្លារ ហើយកិច្ចប្រជុំថ្ងៃនេះ គឺយើងជួបជុំគ្នា រវាងភាគីពាក់ព័ន្ធរបស់ភាគីកម្ពុជា និងភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីរៀបចំកម្មវិធីរួមគ្នា ក្នុងការចាត់ចែង និងប្រើប្រាស់ថវិកានេះឲ្យមានប្រសិទ្ធភាព និងតម្លាភាព ហើយបានដល់មុខសញ្ញា និងគោលដៅ ជាពិសេសគឺពលករចំណាកស្រុក ឬជនទេសន្តរប្រវេសន៍ ដែលជួបបញ្ហា»។ សម្តេចបានបន្ថែមថា ទឹកប្រាក់នេះ គឺសម្រាប់ការចំណាយលើកិច្ចការទូទៅ សម្រាប់ខេត្តគោល ដៅចំនួន៣ រួមមាន ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តសៀមរាប ហើយក្នុងនោះអាចមាន ការជ្រើសរើសទៅតាមទីតាំង និងគោលដៅជាក់ស្តែង នៃខេត្តទាំង៣នេះផងដែរ ចំណែកក្រុមការងារ ពាក់ព័ន្ធនានានឹងខិតខំប្រឹងប្រែង ធ្វើការងារនេះឲ្យបានសមស្រប និងមានប្រសិទ្ធភាព។

សម្តេចក៏បានលើកឡើងថា «កន្លងទៅ រាជរដ្ឋាភិបាលបានប្រកាស នូវគោលនយោបាយគាំពារសង្គម ដែលយើងកំពុងអនុវត្តរៀងរាល់ថ្ងៃ ក្នុងនោះយើងមិនមែនអនុវត្ត តែសម្រាប់ប្រជាពលរដ្ឋក្រីក្រទេ ក៏មានបងប្អូន ជាជនទេសន្តរប្រវេសន៍ផងដែរ បានន័យថាពួកគាត់ ក៏ទទួលបានកម្មវិធីនេះដែរ ហើយនេះគឺជាកម្មវិធីដោយឡែកមួយ»។ ជាងនេះទៀត សម្តេចក្រឡាហោម ស ខេង បានបង្ហាញក្តីសង្ឃឹមថា ប្រសិនបើយើងអាចអនុវត្តកម្ម វិធីដែលមានរយៈពេល៦ខែនេះបានល្អ ហើយការប្រើប្រាស់ ថវិកាមូលនិធិដែលអង្គការ សហប្រជាជាតិ ផ្តល់ឲ្យ មានប្រសិទ្ធភាព នោះយើង នឹងមានការ គាំទ្របន្ថែម ទៀតពីអង្គការសហប្រជាជាតិផងដែរ៕ ដោយ៖ អេង ប៊ូ ឆេង

## ក្រសួងមហាផ្ទៃ៖ មកទល់ពេលនេះ ពលរដ្ឋខ្មែរវិលត្រឡប់ មកស្រុកកំណើតវិញ ជាង១០ម៉ឺននាក់

https://dap-news.com/national/ ByVNT108 Posted on July 15, 2020

ភ្នំពេញ ៖លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស មានប្រសាសន៍ថា រហូតមកដល់ពេលនេះ មានប្រជាពលរដ្ឋខ្មែរវិលត្រឡប់មកប្រទេសកម្ពុជាវិញ ជាង១០ម៉ឺននាក់ ហើយការវិលត្រឡប់មកវិញនេះ ដោយសារជំងឺកូវីដ-១៩ បានរីករាលដាលពេញសាកលលោក ធ្វើឲ្យមានការបិទប្រទេសជាដើម។

ក្នុងកិច្ចប្រជុំជាន់ខ្ពស់ រវាងស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិនៅកម្ពុជា ស្តីពីកម្មវិធីរួមគ្នា ដើម្បីគាំទ្រជនទេសន្តប្រវេសន៍ ដែលវិលត្រឡប់ក្នុងស្ថានភាព នៃការរាតត្បាតជំងឺកូវីដ-១៩ និងផលប៉ះពាល់ នាព្រឹកថ្ងៃពុធ ទី១៥ ខែកក្កដា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ លោកស្រី ជូ ប៊ុនអេង បានឲ្យដឹងថា ស្ថានភាពជំងឺកូវីដ-១៩ មិនទាន់បានស្ងប់ស្ងាត់នៅឡើយទេ ហើយប្រទេសជិតខាងក្នុងតំបន់ នៅតែបន្តឆ្លងជំងឺកូវីដ-១៩ ជាពិសេស បន្តរឹតត្បិតក្នុងការបិទព្រំដែន និងកាត់បន្ថយចរាចរណ៍ផលិតផល ដែលជាប្រភពនៃសេដ្ឋកិច្ចរបស់ខ្លួន។ លោកស្រីបន្តថា រោងចក្រសហគ្រាស និងអាជីវកម្មជាច្រើន ត្រូវបានផ្អាក ដែលធ្វើឲ្យពលករបាត់បង់ការងារ និងបានរុញច្រានឲ្យពលករទេសន្តរប្រវេសន៍មួយចំនួន សម្រេចចិត្តវិលត្រឡប់មកស្រុកទេសរបស់ខ្លួនវិញ ទោះបីជាប្រឈមនឹងការហាមឃាត់ និងបិទព្រំដែនក៏ដោយ។ លោកស្រី មានប្រសាសន៍ថា «គិតចាប់ពីថ្ងៃទី២១ ខែមិនា ឆ្នាំ២០២០ ក្រោយការប្រកាសបិទព្រំដែន របស់រាជរដ្ឋាភិបាលថៃ មកដល់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២០ ដែលមានរយៈពេល៣ខែ ១៩ថ្ងៃ មានប្រជាពលរដ្ឋកម្ពុជា ដែលវិលត្រឡប់ពីការធ្វើទេសន្តប្រវេសន៍ នៅក្រៅប្រទេស ជាពិសេស ប្រទេសថៃ សរុបចំនួន ជាង១០០.៥៦៨នាក់»។

ឆ្លៀតឱកាសនោះដែរ លោកស្រីលើកឡើងថា ក្នុងទស្សនវិស័យរួម នៃការឆ្លើយតបទៅនឹងវិបត្តិការរាតត្បាតជំងឺកូវីដ-១៩ និងផលប៉ះពាល់លើវិស័យសេដ្ឋកិច្ច និងសង្គមជាសាកល អង្គការសហប្រជាជាតិ នៅកម្ពុជា បានចូលរួមគាំទ្រ ការអនុវត្តផែនការជាតិ របស់រាជរដ្ឋាភិបាល ក្នុងការឆ្លើយតប ទៅនឹងវិបត្តិនៃការរាតត្បាតជំងឺកូវីដ-១៩ ដោយផ្តោតលើការទប់ស្កាត់ការចម្លង និងការឆ្លងក្នុងចំណោមក្រុម ប្រជាពលរដ្ឋ ដែលទើបនឹងវិលត្រឡប់ ពីការធ្វើទេសន្តប្រវេសន៍ ដែលអាចបង្កើតស្ថានភាព រាលដាលទ្រង់ទ្រាយធំ នៅតាមសហគមន៍ និងរក្សាស្ថានភាព នៃការរស់នៅប្រកបដោយស្ថេរភាព នឹងភាពចុះសម្រុង ជាមួយសហគមន៍មូលដ្ឋាន ក្នុងតំណាក់កាល នៃធ្វើសមាហរណកម្ម៕ ដោយ៖ អេង ប៊ូ ឆេង

## អង្គការសុខភាពពិភពលោកកោតសរសើរភាពជោគជ័យដ៏អស្ចារ្យរបស់កម្ពុជា ក្នុងការឆ្លើយតបមេរោគកូវីដ

http://btv.com.kh/nation-news/ 15/07/2020

ភ្នំពេញ៖ តំណាងអង្គការសុខភាពពិភពលោក WHO លោកស្រីវេជ្ជបណ្ឌិត លី អៃឡាន បានសន្យាបន្តសហការជាមួយកម្ពុជាជានិច្ច ក្នុងកិច្ចការទប់ស្កាត់មេរោគកូវីត១៩ ហើយបានកោតសរសើរចំពោះភាពជោគជ័យដ៏អស្ចារ្យរបស់កម្ពុជាដែលបានឆ្លើយតបយ៉ាងឆាប់រហ័សនិងប្រកបដោយសាមគ្គីភាពនូវមេរោគដ៏កាចសាហាវមួយនេះ។ ការលើកឡើងរបស់លោកស្រីវេជ្ជបណ្ឌិត លី អៃឡាននេះ គឺបានលើកឡើងនៅក្នុងកិច្ចប្រជុំជាន់ខ្ពស់ រវាងស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិនៅកម្ពុជា ស្តីពី កម្មវិធីរួមគ្នា ដើម្បីគាំទ្រជនទេសន្តប្រវេសន៍ដែលវិលត្រឡប់ក្នុងស្ថានភាពនៃការ រាតត្បាត ជំងឺកូវីដ–១៩ និងផលប៉ះពាល់ នាព្រឹកថ្ងៃពុធ ទី១៥ ខែកក្កដា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ ដែលដឹកនាំដោយសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី

ក្រសួងមហាផ្ទៃ។ លោកស្រីវេជ្ជបណ្ឌិត បានបន្តថា ការរៀបចំរបស់រាជរដ្ឋាភិបាលកម្ពុជា ទាំងថ្នាក់ក្រោមជាតិ បានឆ្លើយតប ទៅនឹងជំងឺកូវីដ–១៩ ប្រកបដោយភាពជោគជ័យដ៏ធំ ហើយការខិតខំនេះ គឺពិតជាធ្វើឲ្យអ្នកស្រីអគុណដ៏ស្មោះស្ម័គ្រចំពោះរាជរដ្ឋាភិបាលនិងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានរួមគ្នានាពេលកន្លងទៅនោះ។ លោកស្រី បន្តថា ការត្រៀមលក្ខណៈ និងការឆ្លើយតបក្នុងមូលដ្ឋាននេះ មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីទទួលបានជោគជ័យ។ លោកស្រីបានឃើញ រួចមកហើយនូវវឌ្ឍនភាពដ៏សម្បើម និងតម្លៃនៃកិច្ចសហការពហុវិស័យ ព្រោះមានសារៈសំខាន់ខ្លាំងណាស់ក្នុងការវិនិយោគទៅលើទំនាក់ទំនងដ៏រឹងមាំ និងប្រកបដោយភាពជឿជាក់ រវាងដៃគូនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

យ៉ាងណាក៏ដោយអ្នកស្រី លី អៃឡាន បានលើកឡើងផងដែរថា ដរាបណាមេរោគកូវីដ១៩ នៅតែបន្តរាលដាលដូចភ្លើងឆេះព្រៃនៅទូទាំងពិភពលោក វានៅតែបន្តការគំរាមកំហែងឥតឈប់ឈរចំពោះប្រទេសកម្ពុជាដដែល ដូចជា ករណីនាំចូលនាពេលថ្មីៗនេះ បានបង្ហាញឲ្យឃើញជាភស្តុតាងស្រាប់។ ដូចនេះ បងប្អូនប្រជាពលរដ្ឋគប្បីបន្តមានការប្រុងប្រយ័ត្នដោយកុំប្រហែសឲ្យសោះ ហើយត្រូវធ្វើទៅតាមការណែនាំរបស់រាជរដ្ឋាភិបាល ក៏ដូចជាអង្គការសុខភាពពិភពលោក ដែលបានបង្ហាញ និងណែនាំនាពេល កន្លងទៅឲ្យបានជាប់ជានិច្ច៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរ ដែលឆ្លងដែន ខុសច្បាប់ចំនួន ០៥នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ 14-07-202

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាមនាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ បានទទួលពលករខ្មែរដែលឆ្លងដែនខុសច្បាប់ចំនួន០៥នាក់ពីសមត្ថកិច្ចថៃ ដោយមានការចូលរួមត្រួតពិនិត្យសុខភាពពីក្រុមចត្តាឡីស័ក។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៥នាក់នេះ មាន ១-ឈ្មោះ ស៊ិន ពិសិត ភេទប្រុស អាយុ ៣០ ឆ្នាំ មានទីលំនៅភូមិអង្គរជ្ជូល ឃុំអង្គជ័យ ស្រុកអង្គជ័យ ខេត្តកំពត, ២-ឈ្មោះ កែន ស្រ៊ន ភេទស្រី អាយុ ៤១ឆ្នាំ មានទីលំនៅភូមិកោះសង្កែ ឃុំទូកមាស ស្រុកបន្ទាយមាស ខេត្តកំពត, ៣-ឈ្មោះ មាស ប៊ុនថា ភេទស្រី អាយុ ៣១ឆ្នាំ មានទីលំនៅភូមិ១ ឃុំស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង, ៤-ឈ្មោះ ឆោម គឹមឈាន់ ភេទស្រី អាយុ ១៥ ឆ្នាំ មានទីលំនៅភូមិកោះសែ ឃុំទូក មាសស្រុកទូកមាស ខេត្តកំពត និង៥-ឈ្មោះ យ៉ិន ម៉ី ភេទស្រី អាយុ ២២ឆ្នាំ មានទីលំនៅភូមិអង្គរជ្ជូល ឃុំអង្គជ័យ ស្រុកអង្គជ័យ ខេត្តកំពត។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការសាកសួរ អប់រំណែនាំ និងមានការចូលរួមត្រួតពិនិត្យសុខភាព រួមទាំងការអនុវត្តនីតិវិធី របស់មន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែន ខុសច្បាប់ ពីអាជ្ញាធរថៃ ចំនួន ៣៩នាក់

https://www.facebook.com/GDIOfficial/ 14-07-202

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៩នាក់ ស្រី ០៩នាក់ និងកុមារ ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៣នាក់

https://www.facebook.com/GDIOfficial/ 14-07-202

នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវនិងពលរដ្ឋខ្មែរឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន១០៣នាក់ ស្រី៤៥នាក់៕

## សមត្ថកិច្ចថៃបញ្ជូនពលករខ្មែរ ដែលឆ្លងដែនខុសច្បាប់ចំនួន៤៤នាក់ មកឲ្យកម្ពុជាវិញ

http://kampucheathmey.com/ 14/7/2020 7:15 Pm

ភ្នំពេញ ៖ សមត្ថកិច្ចអគ្គនាយកដ្ឋានអន្តោប្រវេសន៍បានឲ្យដឹងនៅល្ងាចថ្ងៃទី១៤ ខែកក្កដា នេះថា នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០នេះ សមត្ថកិច្ចអាអាជ្ញាធរថៃបានបញ្ជូនពលករខ្មែរ ដែលឆ្លងដែនខុសច្បាប់ចំនួន៤៤នាក់ មកឲ្យកម្ពុជាវិញតាមច្រកចំនួន២ គឺប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម និងច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត។

ក្នុងនោះនៅច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ទទួលពលករខ្មែរ ដែលឆ្លងដែនខុសច្បាប់ចំនួន០៥នាក់ ពីសមត្ថកិច្ចថៃ ហើយក៏មានការចូលរួមត្រួតពិនិត្យសុខភាពពីក្រុមចត្តាឡីស័កផងដែរ។ បើតាមនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនបានឲ្យដឹងថា ពលករខ្មែរទាំង០៥នាក់នោះ មាន ១-ឈ្មោះ ស៊ិន ពិសិត ភេទប្រុស អាយុ៣០ ឆ្នាំ មានទីលំនៅភូមិអង្គវ៉ែង្គល ឃុំអង្គជ័យ ស្រុកអង្គជ័យ ខេត្តកំពត, ២-ឈ្មោះ កែន ស្រ៊ន ភេទស្រី អាយុ៤១ឆ្នាំ មានទីលំនៅភូមិកោះសង្កែ ឃុំទូកមាស ស្រុកបន្ទាយមាស ខេត្តកំពត, ៣-ឈ្មោះ មាស ប៊ុនថា ភេទស្រី អាយុ ៣១ឆ្នាំ មានទីលំនៅភូមិ១ ឃុំស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង, ៤-ឈ្មោះ ឆោម គឹមឈាន់ ភេទស្រី អាយុ ១៥ឆ្នាំ មានទីលំនៅភូមិកោះសែ ឃុំទូកមាស ស្រុកទូកមាស ខេត្តកំពត និង៥-ឈ្មោះ យ៉ិន ម៉ី ភេទស្រី អាយុ២២ឆ្នាំ មានទីលំនៅភូមិអង្គវ៉ែង្គល ឃុំអង្គជ័យ ស្រុកអង្គជ័យ ខេត្តកំពត។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការសាកសួរ អប់រំណែនាំ និងមានការចូលរួមត្រួតពិនិត្យសុខភាព រួមទាំងការអនុវត្តនីតិវិធី របស់មន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រកនូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។

ចំណែកនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត មានពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន៣៩នាក់ (ស្រី០៩នាក់ និងកុមារ០៣នាក់) ត្រូវបានអាជ្ញាធរថៃបញ្ជូនមកវិញ ពលករទាំងនេះត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ចក្រក ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតបានឲ្យដឹងដែរថា រហូតមកដល់ពេលនេះ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឲ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយទេ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធុនធំ ដំណើរការជាធម្មតា៕ កោះកែវ

## ថៃបញ្ជាឲ្យបង្កើនសន្តិសុខនៅតាមព្រំដែនជុំវិញការភ័យខ្លាចឆ្លងកូវីដ១៩ជាថ្មី

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 14/07/2020

ថៃ៖ ប្រទេសថៃបានបញ្ជាឲ្យបង្កើនសន្តិសុខនៅតាមព្រំដែនគោករបស់ខ្លួន បន្ទាប់ពីក្តីបារម្ភលើការកើនឡើងរលកទីពីរ នៃការឆ្លងវីរុសកូរ៉ូណាក្រោយការចាប់ខ្លួនជនចំណាកស្រុកខុសច្បាប់រាប់ពាន់នាក់កាលពីខែមុន។ អ្នកនាំពាក្យក្រុមការងារថៃលោក Taweesin Wisanuyothin បាននិយាយថា ចាប់តាំងពីដើមខែមិថុនាអាជ្ញាធរបានចាប់ខ្លួនពលករចំណាកស្រុកចំនួន ៣ ពាន់នាក់ពីបទប៉ុនប៉ងចូលមកប្រទេសតាមព្រំដែនដីគោក។ លោក Taweesin ក៏បានលើកឡើងពីការព្រួយបារម្ភអំពីបទប្បញ្ញត្តិខ្សោយសម្រាប់ការមកដល់របស់ភ្ញៀវទេសចរបរទេសតាមអាកាស បន្ទាប់ពីអ្នកទេសចរ ២ នាក់តេស្តវិជ្ជមានដោយម្នាក់បានបំពានច្បាប់ធ្វើចត្តាឡីស័ក ។ រដ្ឋាភិបាលបានកំណត់អត្តសញ្ញាណនារីកអាយុ ៤៣ ឆ្នាំម្នាក់នៃយន្តហោះយោធាអេហ្ស៊ីប និងក្មេងស្រីអាយុ ៩ឆ្នាំនៅក្នុងគ្រួសារអ្នកការទូតស៊ូដង់ថាជាករណីថ្មីដែលអាចបង្កជារលកទីពីរ ។ លោក Taweesin បាននិយាយថា "នេះបង្ហាញពីចំណុចខ្សោយ ប៉ុន្តែមិនទាន់មានការខូចខាតណាមួយទេប្រសិនបើយើងអាចគ្រប់គ្រង ហើយកែតម្រូវចំណុចខ្សោយ និងចេញបទបញ្ជាហ្មត់ចត់ជាងនេះ" ។

ទាហានអេហ្ស៊ីប និងក្រុមគ្រួសារអ្នកការទូតបរទេសស្ថិតក្នុងចំណោមក្រុមជនបរទេសមួយចំនួនដែលត្រូវបានអនុញ្ញាតឲ្យចូលក្នុងប្រទេសចាប់តាំងពីខែមីនាក្នុងលក្ខខណ្ឌធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ ។ ទោះបីជាប្រទេសថៃបានដកបម្រាមរបស់ខ្លួនលើជនបរទេសរួមទាំងអ្នកស្នាក់នៅជាអចិន្ត្រៃយ៍ អ្នកធ្វើដំណើរអាជីវកម្ម និងអ្នកទេសចរវេជ្ជសាស្ត្រក៏ដោយក៏ប្រទេសនេះនៅតែរារាំងភ្ញៀវទេសចរធម្មតា និងកម្មករចំណាកស្រុកដដែរ ។ ដោយគ្មានករណីឆ្លងក្នុងស្រុកត្រូវបានគេរាយការណ៍អស់រយៈពេលជាង ៦ សប្តាហ៍មកហើយនោះចាប់តាំងពីខែមករាមកប្រទេសថៃមានករណីឆ្លងកូវីដ ១៩ ចំនួន ៣,២២០ នាក់ និង ៥៨ នាក់បានស្លាប់ ៕

## ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០

## សម្តេច ស ខេង ជំរុញឲ្យស្រង់ឈ្មោះគ្រួសារក្រីក្រ និងជនទេសន្តរប្រវេសន៍ ទទួលប្រាក់ពីកម្មវិធីផ្ទេរប្រាក់ ជូនគ្រួសារក្រីក្រ ដោយតម្លាភាព

https://dap-news.com/national/ ByPH104 Posted on July 15, 2020

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានជំរុញឲ្យក្រសួងផែនការ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវស្រង់ឈ្មោះគ្រួសារក្រីក្រ និងជនទេសន្តរប្រវេសន៍ ឲ្យបានច្បាស់លាស់ ដើម្បីទទួលសាច់ប្រាក់ពីកម្មវិធី «ឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋក្រីក្រ» ដែលរាជរដ្ឋាភិបាលប្រកាសដាក់ឲ្យប្រើប្រាស់ នាពេលថ្មីៗនេះ ប្រកបដោយតម្លាភាព ។ ក្នុងកិច្ចប្រជុំជាន់ខ្ពស់រវាងស្ថាប័ន ពាក់ព័ន្ធរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិនៅកម្ពុជា ស្តីពីកម្មវិធីរួមគ្នា ដើម្បីគាំទ្រជនទេសន្តប្រវេសន៍ វិលត្រឡប់ក្នុងស្ថានភាព នៃការរាតត្បាតជំងឺកូវីដ-១៩ នាថ្ងៃពុធ ទី១៥ ខែកក្កដា ឆ្នាំ២០២០ សម្តេច ស ខេង មានប្រសាសន៍ថា រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគ្រប់គ្រងឲ្យបានល្អ ចំពោះសន្តិសុខសណ្តាប់ធ្នាប់ក្នុងសង្គម ជាពិសេសគ្រប់គ្រងចលនាជនទេសន្តរប្រវេសន៍ព្រមទាំងផ្តល់សេវាសាធារណៈនានា ឲ្យមានភាពឆ្លើយតបទាន់ពេលវេលា និងលើកកម្ពស់របស់ប្រជាពលរដ្ឋផងដែរ។ សម្តេចបន្ថែមទៀត «ក្រសួងផែនការ និងរដ្ឋបាលថ្នាក់ក្រោម គប្បីត្រូវខិតខំធ្វើបច្ចុប្បន្នភាពជន ក្រីក្រពិតប្រាកដ ជាពិសេស ជនទេសន្តរប្រវេសន៍ដែលត្រឡប់មកពីប្រទេសជិតខាងវិញ ដើម្បីទទួលបានសេវាពីកម្មវិធីផ្ទេរសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងកិច្ចគាំពារផ្នែកសេដ្ឋកិច្ចផ្សេងៗ ទៀតរបស់រាជរដ្ឋាភិបាល»។

ឆ្លៀតឱកាសនោះ សម្តេចស ខេង ក៏បានស្នើទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា សម្របសម្រួលជាមួយទីភ្នាក់ងារអង្គការប្រជាជាតិ ប្រចាំប្រទេសនានាក្នុងតំបន់ ដើម្បីរកដំណោះស្រាយ ក្នុងការគ្រប់គ្រងលំហូរឆ្លងកាត់ព្រំដែន ពលករទេសន្តរប្រវេសន៍រវាងប្រទេសបញ្ជូន និងប្រទេសទទួល។ សម្តេចបន្តថា ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកទៅលើកម្មវិធីសន្តិសុខ ស្បៀង និងអាហាររូបឧបត្ថម្ភ របស់ប្រជាពលរដ្ឋ ហើយទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងភាគីពាក់ព័ន្ធមួយចំនួនទៀត ត្រូវសម្របសម្រួលគៀងគរធនធានសម្រាប់ដោះស្រាយ ផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ហើយត្រូវបន្តសហការរៀបចំប្រព័ន្ធគ្រប់គ្រងជនចំណាក់ស្រុកដែលបានវិលត្រឡប់មកកម្ពុជាវិញ ។ សម្តេចក្រឡាហោម ក៏បានអំពាវនាវឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តពង្រឹងការគ្រប់គ្រងពលករចំណាកស្រុក ដែលត្រឡប់មកកម្ពុជាវិញ ព្រមទាំងពង្រឹងវិធានការគ្រប់គ្រងព្រំដែន ហើយត្រូវសហការជាមួយប្រទេសជិតខាង ដើម្បីធ្វើការស្រាវជ្រាវ និងបង្ក្រាបមេខ្យល់ដែលនាំពលករ ឆ្លងដែនខុសច្បាប់ផងដែរ៕ ដោយ អេង ប៊ូឆេង

## រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ រួមគ្នាគាំទ្រដល់ជនទេសន្តរប្រវេសន៍ ដែលវិលត្រឡប់ក្នុងស្ថានភាពជំងឺកូវីដ-១៩ និងផលប៉ះពាល់

http://nokorwatnews.com/archives/ 15-07-2020

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំជាន់ខ្ពស់រវាងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ស្តីពីកម្មវិធីរួមគ្នាដើម្បីគាំទ្រជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់ក្នុងស្ថានភាពជំងឺកូវីដ-១៩ និងផលប៉ះពាល់ កាលពីព្រឹកថ្ងៃទី១៥ ខែកក្កដាឆ្នាំ២០២០នៅទីស្តីការក្រសួងមហាផ្ទៃ ។ សម្តេចក្រឡាហោមបានមានប្រសាសន៍ថា កិច្ចប្រជុំនេះបានរៀបចំឡើងក្នុងបរិការណ៍ដែលពិភពលោកកំពុងជួបវិបត្តិសង្គម និងសេដ្ឋកិច្ច បង្កឡើងដោយជំងឺកូវីដ-១៩។ ដើម្បីប្រយុទ្ធនិងដោះស្រាយផលប៉ះពាល់បណ្តាលមកពីវិបត្តិនេះ រាជរដ្ឋាភិបាល បានបង្កើតយន្តការ និងដាក់ចេញវិធានការជាបន្តបន្ទាប់។ ជាក់ស្តែងនៅថ្ងៃនេះរាជរដ្ឋាភិបាលបានបន្តកិច្ចប្រជុំក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ ដើម្បីរួមគ្នាជួយពលរដ្ឋជាជនទេសន្តរប្រវេសន៍ក្នុងស្ថានភាពលំបាកនៃជំងឺកូវីដ១៩។

សម្តេចបានសន្និដ្ឋានថា មកដល់ពេលនេះប្រទេសកម្ពុជាអាចគ្រប់គ្រងស្ថានភាពជំងឺកូវីដ១៩បានល្អប្រសើរ ដោយបានធ្វើឱ្យផលិតកម្មកសិកម្មងើបឡើងវិញនិងសកម្មភាពសេដ្ឋកិច្ចនានាមានសកម្មភាពឡើងវិញ។ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក ឈរលើមូលដ្ឋានអនាម័យ និងវិធានការការពារការរីករាលដាលជំងឺកូវីដ១៩គ្រប់ទីកន្លែង។ សម្តេចឧបនាយករដ្ឋមន្ត្រីបានចាត់ទុកលទ្ធផលនេះ គឺជាស្នាដៃកើតចេញពីការដឹកនាំដ៏ត្រឹមត្រូវរបស់សម្តេចតេជោ និងការចូលរួមគាំទ្រពីក្រសួងស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ បណ្តាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ ក្នុងនោះក៏មានភ្នាក់ងារអង្គការសហប្រជាតិផងដែរ។ សម្តេចបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការសហប្រជាជាតិ ដែលបានអនុម័តគម្រោងថវិកាចំនួន១លានដុល្លារអាមេរិក ដើម្បីអនុវត្តកម្មវិធីរួមគ្នាមួយរវាងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាល ក្នុងគោលបំណងជួយការពារពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ និងការពារការចម្លងជំងឺដល់សហគមន៍។ សម្តេចសង្ឃឹមថាភាគីទាំងពីរនឹងចូលរួមមតិយោបល់ល្អៗដើម្បីជួយឱ្យការអនុវត្តគម្រោងនេះទទួលបានលទ្ធផលល្អប្រសើ។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីបានសម្តែងការគាំទ្រចំពោះផែនការសកម្មភាពនេះ និងបានស្នើឱ្យស្ថាប័នពាក់ព័ន្ធចូលរួមគាំទ្រឱ្យបានល្អ។ សម្តេចក៏បានស្នើឱ្យក្រុមការងារបច្ចេកទេសជាន់ខ្ពស់រវាងក្រសួងស្ថាប័នពាក់ព័ន្ធ បន្តកិច្ចសហការឱ្យបានជិតស្និតជាមួយភ្នាក់ងារតំណាងអង្គការសហប្រជាតិ និងត្រូវប្រជុំឱ្យបានទៀងទាត់ដើម្បីតាមដានការអនុវត្តគម្រោងនេះ។

គួរកត់សំគាល់ថា ក្នុងរយៈពេលជាង៣ខែ ដែលប្រទេសថៃបិទព្រំដែនជាមួយកម្ពុជា មានប្រជាពលរដ្ឋជាពលករទេសន្តរប្រវេសន៍ បានវិលត្រឡប់ប្រមាណជាជាង១០ម៉ឺននាក់ ក្នុងនោះស្ត្រីប្រមាណ៥០ភាគរយ និងកុមារ៣ភាគរយ។ នេះបើតាមរបាយការណ៍របស់លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ដែលបានលើកឡើងអង្គប្រជុំនេះ។

នាឱកាសនោះដែរ លោកស្រី ផូលីន ថាម៉េស៊ីស ប្រធានសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានថ្លែងកោតសរសើររាជរដ្ឋាភិបាលកម្ពុជា ពិសេសក្រសួងមហាផ្ទៃ សម្រាប់ការប្ដេជ្ញាចិត្ត និងការដឹកនាំក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ជនទេសន្តរប្រវេសន៍មាតុភូមិនិវត្តន៍ក្នុងនាមជាក្រុមងាយរងគ្រោះមួយដ៏សំខាន់ ដែលរងផលប៉ះពាល់ពីការរាតត្បាតនៃជំងឺកូវីដ១៩។ ក្នុងនាមតំណាងអង្គការសហប្រជាជាតិ លោកស្រីរួមទាំងបណ្ដាតំណាងអង្គការអន្តរជាតិនានារបស់អង្គការសហប្រជាជាតិ បានបង្ហាញការពេញចិត្តក្នុងការបន្តកិច្ចសហប្រតិបត្តការ ជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីជួយសម្រួលការលំបាករបស់ពលរដ្ឋជាពលករទេសន្តរប្រវេសន៍ និងពលរដ្ឋងាយរងគ្រោះផ្សេងៗទៀត។

សូមជម្រាប់ថា រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មាធិការជាតិការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ និងបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដោយបានបែងចែកក្រុមការងារប្រតិបត្តិការចំនួនពីរដើម្បីទប់ទល់នឹងវិបត្តិជំងឺឆ្លងសាកលនេះ គឺទី១ ក្រុមការងារប្រតិបត្តិការបច្ចេកទេស និងផ្គត់ផ្គង់ និងទី២ ក្រុមការងារប្រតិបត្តិការអប់រំបណ្ដុះបណ្ដាល និងអប់រំសាធារណៈ។ ក្នុងស្ថានភាពប្រឈមនេះ រាជរដ្ឋាភិបាលក៏បានបង្កើតក្រុមការងារចំពោះកិច្ចចំនួន៤ទៀត រួមមាន៖ ក្រុមការងារចំពោះកិច្ចគ្រប់គ្រងការផ្គត់ផ្គង់ និងថ្លៃទំនិញយុទ្ធសាស្ត្រ, ក្រុមការងារចំពោះកិច្ចគ្រប់គ្រងយន្តការជំនួយសង្គម, ក្រុមការងារចំពោះកិច្ចរៀបចំគោលនយោបាយថវិកា និងជំនួយសង្គម, ក្រុមការងារបចច្ចេកទេសចម្រុះចំពោះកិច្ចដើម្បីគ្រប់គ្រងរៀបចំដាក់ចេញនូវកញ្ចប់ថវិកាខាងរូបិយវត្ថុ និងធនាគារដើម្បីគ្រប់គ្រង និងដោះស្រាយផលប៉ះពាល់នៃជំងឺកូវីដ១៩ ៕ ដោយៈហេង សូរិយា

## កូវីដ-១៩៖ UN ផ្ដល់ថវិកា១លានដុល្លារលើគម្រោងការពារពលករខ្មែរដែលធ្វើមាតុភូមិនិវត្តន៍

https://thmeythmey.com/ 15, Jul 2020 ,  3:43 pm  ដោយ: អ៊ូ សុខមាន

ភ្នំពេញ៖ អង្គការសហប្រជាជាតិ(UN)ប្រចាំកម្ពុជា បានអនុម័តគម្រោងថវិកា១លានដុល្លារ ដល់កម្ពុជា ដើម្បីជួយការពារពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ និងការពារការចម្លងជំងឺដល់សហគមន៍។ គម្រោងថវិកាសម្រាប់គាំពារដល់ពលករនេះ ត្រូវបានសម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកឡើងក្នុងកិច្ចប្រជុំជាន់ខ្ពស់រវាងស្ថាប័នពាក់ព័ន្ធដើម្បីគាំទ្រជនទេសន្តប្រវេសន៍ ដែលវិលត្រឡប់ក្នុងស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩ នៅទីស្ដីការក្រសួងមហាផ្ទៃ នាថ្ងៃទី១៥ កក្កដា ឆ្នាំ២០២០។ សម្តេចឧបនាយករដ្ឋមន្ត្រី ស ខេង បានបញ្ជាក់ថា គម្រោងថវិកា១លានដុល្លារអាមេរិកនេះ សម្រាប់រយៈពេល៦ខែដែលនឹងអនុវត្តឡើងនៅក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង និងខេត្តសៀមរាប ដែលមានពលករខ្មែរត្រឡប់មកពីបរទេសច្រើនជាងគេនៅកម្ពុជា ពិសេសគឺមកពីប្រទេសថៃ។ បើតាមប្រសាសន៍សម្តេច ក្នុងរយៈពេល៦ខែនេះប្រសិនបើកម្ពុជាពិសេសក្រសួងមហាផ្ទៃប្រើប្រាស់ថវិកាសម្រាប់ជួយដល់ពលករទេសន្តរប្រវេសន៍ មានប្រសិទ្ធភាពបានល្អ និងចំគោលដៅ នោះនឹងទទួលបានថវិកាគាំទ្របន្ថែមទៀតពីអង្គការសហប្រជាជាតិ។ យ៉ាងណាមិញរដ្ឋមន្ត្រីក្រសួងមហាផ្ទៃរូបនេះ មិនទាន់អាចបញ្ជាក់ពីពេលវេលាក្នុងការប្រើប្រាស់កញ្ចប់ថវិកា១លានដុល្លារ សម្រាប់ជួយដល់ពលករនៅឡើយ ដោយកំពុងសិក្សាអំពីលទ្ធភាពនៃការប្រើប្រាស់កញ្ចប់ថវិកានេះ ជាមួយស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា។

បច្ចុប្បន្ន មានពលរដ្ឋខ្មែរចំនួន១០០,៥៦៨នាក់ ដែលបម្រើការងារនៅប្រទេសថៃបានវិលត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីកម្ពុជាប្រកាសបិទព្រំដែនថៃ ដោយសារតែការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ក្នុងពិភពលោក។ នេះបើយោងតាមរបាយការណ៍របស់អ្នកស្រីជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដែលបានលើកឡើងក្នុងកិច្ចប្រជុំជាន់ខ្ពស់ខាងលើ។ អ្នកស្រីជូ ប៊ុនអេង បញ្ជាក់ថា ចំនួនពលរដ្ឋខ្មែរដែលបានត្រឡប់មកពីប្រទេសថៃទាំងជាង១០ម៉ឺននាក់នេះ គឺគិតចាប់ពីថ្ងៃទី២១មីនា ក្រោយការប្រកាសបិទព្រំដែនរបស់រាជរដ្ឋាភិបាលថៃ មកដល់ថ្ងៃទី៧កក្កដា ឆ្នាំ២០២០។ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរូបនេះ បានបន្តថាក្នុងចំណោមពលរដ្ឋខ្មែរដែលបានត្រឡប់ពីថៃនោះ មានជិត ៦០ភាគរយ ជាអ្នករស់នៅក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប។

គិតត្រឹមថ្ងៃទី១៥កក្កដា ឆ្នាំ២០២០ ប្រទេសថៃ មានអ្នកឆ្លងកូវីដ-១៩ចំនួន៣,២២៧នាក់ ដោយមានអ្នកជាសះស្បើយ៣,០៩១នាក់ និងស្លាប់៥៨នាក់។ កម្ពុជាបានរកឃើញអ្នកឆ្លងជំងឺកូវីដចំនួន១៦៥នាក់ ក្នុងនោះ ១៣៣នាក់បានជាសះស្បើយ និង៣២នាក់ទៀតកំពុងសម្រាកព្យាបាលជំងឺនេះនៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត និងនៅមណ្ឌលសុខភាពចាក់អង្រែ៕

## អាជ្ញាធរថៃដាក់លួសបន្លាតាមព្រំដែនទប់ស្កាត់ពលករខ្មែរឆ្លងដែនសុខច្បាប់ដើម្បីការពារកុំឱ្យឆ្លងជំងឺកូវីដ១៩

https://www.rfa.org/khmer/ ដោយ សេក បណ្ឌិត 2020-07-15

អាជ្ញាធរថៃ ដាក់លួសបន្លាតាមព្រំដែនជាប់កម្ពុជាទប់ស្កាត់ពលករខ្មែរឆ្លងដែនចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ និងដើម្បីការពារកុំឱ្យឆ្លងជំងឺកូវីដ១៩។ មន្ត្រីសង្គមស៊ីវិលយល់ថា ពលរដ្ឋឆ្លងដែនអំឡុងពេលអាជ្ញាធរថៃរឹតបន្តឹងតាមព្រំដែននេះ ជាការប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិតខ្លាំងជាងពេលមុនៗ។

ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកការពារព្រំដែន លោក អ៊ុំ សុផល ឱ្យដឹងនៅថ្ងៃទី១៥កក្កដាថា អាជ្ញាធរថៃបានដាក់ពង្រាយលួសបន្លាជាច្រើនកន្លែងនៅតំបន់ព្រំដែនខាងដីថៃជាប់ខេត្តបន្ទាយមានជ័យ ជាពិសេសតំបន់ដាច់ស្រយាលពុំមានមនុស្សរស់នៅ និងមិនសូវមានទាហានថៃប្រចាំការ ដូចជានៅព្រំដែនជាប់ឃុំអូរបីជាន់ស្រុកអូរជ្រៅ ស្រុកម៉ាឡៃ និងនៅទីតាំងមួយចំនួនក្នុងសង្កាត់ប៉ោយប៉ែតជាដើម។ លោកបញ្ជាក់ទៀតថា អាជ្ញាធរថៃដាក់លួសបន្លានេះ ដើម្បីទប់ស្កាត់ពលករខ្មែរឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ ដើម្បីទប់ស្កាត់កុំឱ្យការរាតត្បាតជំងឺកូវីដ១៩ (Covid19)៖ «ខ្ញុំបានសួរគាត់ហើយ ប៉ុន្តែគាត់ដាក់ក្នុងដីថៃទេមិនមែនដាក់ព្រំប្រទល់ដីខ្មែរទេ គាត់ចម្ងាយពីផ្លូវជាតិរបស់ថៃប្រមាណ ៣០ម៉ែត្រ នៅកន្លែងណាដែលគាត់ខ្វះកម្លាំងយាមកាម ការពារបទល្មើសឆ្លងដែន។ខ្មែរយើងក៏ការពារដែរ អីចឹងអាជ្ញាធរគាត់ដាក់កម្លាំងដូចខ្មែរយើងអីចឹង កន្លែងខ្វះគាត់ខ្វះកម្លាំងគាត់ដាក់បន្លាលួសទៅ»។ លោក អ៊ុំ សុផលឱ្យដឹងទៀតថា សព្វថ្ងៃក្រុមមេខ្យល់នៅតែបន្តនាំពលករខ្មែរជាច្រើននាក់ឆ្លងដែនទៅប្រទេសថៃតាមច្រករបៀងព្រំដែនជារៀងរាល់ថ្ងៃ។ លោកថា ពួកគេច្រើននាំគ្នាឆ្លងដែននៅពេលយប់ គឺចន្លោះពេលដែលអាជ្ញាធរកម្ពុជានិងថៃពុំបានយាមការពារជិតដល់។លោកបន្ថែមថា ក្រុមពលករទាំងនោះភាគច្រើនត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញស្ទើរតែរាល់ថ្ងៃ ក៏ប៉ុន្តែលោកមិនចាំតួលេខមានពលករប៉ុន្មាននាក់ក្នុងមួយថ្ងៃនោះទេ។

នាយករដ្ឋមន្ត្រីថៃ លោក ប្រាយុទ្ធ ចាន់អូចារ (Prayut Chan-o-Cha) មានប្រសាសន៍នៅក្នុងសន្និសីទកាសែតនៅទីក្រុងបាងកកកាលពីថ្ងៃទី១៤ កក្កដាថា រដ្ឋាភិបាលថៃបានបន្ថែមកងកម្លាំងជាច្រើននាក់ដាក់ពង្រាយការពារតាមព្រំដែន ជាពិសេស តំបន់ព្រំដែនខេត្តស្រះកែវ(Sra Kao)និងខេត្តសុរិន (Surin) ដែលពលករខ្មែរលួចឆ្លងដែនច្រើនជាងគេ ដើម្បីការពារកុំឱ្យរាលដាលជំងឺកូវីដ១៩ ឆ្លងចូលប្រទេសថៃតាមរយៈពលករទាំងនោះ។

ប្រជាពលរដ្ឋនៅតំបន់ព្រំដែនស្រុកអូរជ្រៅម្នាក់ លោកស្រី ឡុង សុគន្ធី ថ្លែងថា ពលករជាច្រើននាក់លួចឆ្លងដែនចូលទៅប្រទេសថៃតាមច្រករបៀងព្រំដែនក្បែរផ្ទះរបស់លោកស្រីជារៀងរាល់ថ្ងៃ។ លោកស្រីបន្តថា ពលករលួចឆ្លងដែនទៅបានដោយសារអាជ្ញាធរខ្មែរប្រចាំនៅតំបន់នោះអនុវត្តច្បាប់ធូររលុង៖ «ដែលយ៉ាប់ដែលអ្នកចេញចូលទៅថៃហើយ គេចាប់ទៀត គាត់មិនមានលុយដោះបំណុលគេ។ខ្ញុំមានការអាណិតអាសូរគាត់ណាស់ដល់ពេលទៅលីគេចាប់គេអីអីចឹង បើទៅបានការងារធ្វើមិនអីទេ ដល់ពេលគេចាប់អីចឹងទៅអាណិតអ្នកនៅផ្ទះ អ្នកនៅផ្ទះឯនេះណេះដែលសង្ឃឹមថា កូនចៅទៅរកស៊ីមកដោះបំណុលគេថាបានអីចឹងទៅ»។

ចំណែកមន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្ស អាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា កត់សំគាល់ថា ពលករឆ្លងដែនអំឡុងពេលមានវិបត្តិជំងឺកូវីដ១៩ នេះ ដោយសារតែពួកគេមានជីវភាពក្រីក្រ និងគ្មានការងារធ្វើនៅក្នុងស្រុករកប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារ។ ទោះជាយ៉ាងណា លោកយល់ថា ពលករឆ្លងដែនអំឡុងពេលអាជ្ញាធរថៃរឹតបន្តឹងតាមព្រំដែននេះ គឺជាការប្រថុយប្រថាននឹងគ្រោះថ្នាក់ដល់អាយុជីវិតផង និងប្រឈមទាហានថៃចាប់ដាក់គុកផង។ លោកសំណូមពរឱ្យពលរដ្ឋកុំឆ្លងដែនទៅប្រទេសថៃអំឡុងពេលការពតត្បាតជំងឺរលកផ្លូវដង្ហើមថ្មីនេះ ហើយគួរតែនាំគ្នាដាំដុះ ឬរកការងារធ្វើនៅក្នុងស្រុកមួយរយៈប្រសើរជាងធ្វើចំណាកស្រុក៖ «អីចឹងនៅថៃនៅមានទីផ្សារការងារមានសំណង់មានអីហើយ គេដាក់ប្រទេសក្នុងគ្រាមានអាសន្នមែនប៉ុន្តែរោងចក្រសហគ្រាសរបស់គេឱ្យធ្វើការដោយមានការប្រុងប្រយ័ត្ន អីចឹងហើយការងារគេមានដំណើរការចំណែកកម្ពុជាយើងថ្មីៗ នេះ មានរោងចក្របិទទ្វាររាប់រយរោងចក្រ ហើយមនុស្សសល់គរដើងច្រើន អីចឹងគេមានការប្រុងប្រយ័តមានការអីទាំងអស់ហ្នឹង»។

របាយការណ៍ប៉ូលិសអន្តោប្រវេសន៍ថៃឱ្យដឹងថា ចាប់តាំងពីចុងខែមីនាដល់មិថុនា មានពលករខ្មែរប្រមាណ ៣.០០០នាក់ ហើយត្រូវបានអាជ្ញាធរថៃចាប់ខ្លួន ដោយសារតែពួកគេឆ្លងដែនចូលទៅធ្វើការងារនៅប្រទេសថៃដោយខុសច្បាប់។ ក្រុមពលករទាំងនោះត្រូវបានអាជ្ញាធរថៃបញ្ជូនត្រឡប់ទៅកម្ពុជាវិញ បន្ទាប់ពីធ្វើពួកគេកិច្ចសន្យាឱ្យឈប់ឆ្លងដែនខុសច្បាប់នៅថ្ងៃក្រោយទៀត៕

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង ពិនិត្យសេចក្តីព្រាងផែនការសកម្មភាពឆ្លើយតប អំពើកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធ Internet

http://www.freshnewsasia.com/ 2020-07-15 05:48pm

**(កោះកុង)៖** អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង OCSE ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការសកម្មភាព ឆ្លើយតបអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធ Internet ដោយមានការឧបត្ថម្ភពីអង្គការ Terre des Hommes។ កិច្ចប្រជុំនេះ ត្រូវធ្វើឡើងរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី១៥-១៦ ខែកក្កដា ឆ្នាំ២០២០នៅខេត្តកោះកុង ក្រោមអធិបតីភាពលោកស្រី ញ៉េប សុភាព អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងដោយមានការអញ្ជើញចូលរួមពីលោក លោកស្រី ដែលជាសមាជិក សមាជិកា ក្រុមការងារបច្ចេកទេសអន្តរក្រសួង OCSE៕

## ថៃបញ្ជូនពលរដ្ឋខ្មែរ៣នាក់ត្រឡប់មកកម្ពុជាវិញ ក្រោយជាប់ទោសជិត២ឆ្នាំ ពីបទឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2020-07-15 02:46pm

**(ឧត្តរមានជ័យ)៖** អាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន៣នាក់ទៀតហើយ ឱ្យមកអាជ្ញាធរកម្ពុជាវិញ តាមច្រកអន្តរជាតិជាំ ស្ថិតក្នុងភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ

២០២០នេះ បន្ទាប់ពីពួកគេត្រូវសមត្ថកិច្ចថៃចាប់ឃុំខ្លួនជិត២ឆ្នាំ នៅខេត្តឧប៊ុន ប្រទេសថៃ ពីបទឆ្លងដែនខុសច្បាប់។ តាមរបាការណ៍របស់ស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ បានបញ្ជាក់ឱ្យដឹងថា នៅរសៀលថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០នេះ អាជ្ញាធរថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរ ចំនួន៣នាក់ តាមច្រកអន្តរជាតិជាំ ដែលត្រូវទាហានថៃចាប់ខ្លួន កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ពីបទឆ្លងដែនចូលកាប់ឈើគ្រញូង ចូលតាមច្រកអានសេះ និងបានយកទៅឃុំខ្លួននៅខេត្តឧប៊ុន ប្រទេសថៃ។ ពលរដ្ឋខ្មែរទាំង៣នាក់រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជយ័ និងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ក្រោយពីបានស្តែនកំដៅស្វែងរកជំងឺកូវីដ១៩ និងសម្អាតខ្លួនប្រាណដោយទឹកអាល់កុលរួចមក សមត្ថកិច្ចបានធ្វើការអប់រំណែនាំ ឱ្យបញ្ឈប់ការឆ្លងដែនដោយខុសច្បាប់ទៀត និងបានឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញរៀងៗខ្លួន៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៨៧នាក់ មកឲ្យប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial/ 15-07-202

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៨៧នាក់ ស្រី ២៩នាក់ និងកុមារ ០៧នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរ ដែលឆ្លងដែនខុសច្បាប់ចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ 15-07-202

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ បានទទួលពលករខ្មែរដែលឆ្លងដែនខុសច្បាប់ចំនួន០៣នាក់ ពីសមត្ថកិច្ចថៃដោយមានការចូលរួមត្រួតពិនិត្យសុខភាពពីក្រុមចត្តាឡីស័ក។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់នេះ មាន ១-ឈ្មោះ យិន ប៊ីភេទ ប្រុស អាយុ ២៤ឆ្នាំ, ២-ឈ្មោះ យិន ប៊ិន ភេទប្រុស អាយុ ២៧ឆ្នាំ និង៣-ឈ្មោះ យិន កាន ភេទប្រុស អាយុ ២០ឆ្នាំ ហើយអ្នកទាំង ០៣នាក់ មានទីលំនៅបច្ចុប្បន្នភូមិស្នាំគោ ឃុំស្នាំគោ ស្រុកកំពង់ត្រាច ខេត្តកំពត និងបានធ្វើការសាកសួរ អប់រំណែនាំដោយមានការចូលរួមត្រួតពិនិត្យសុខភាព អនុវត្តនីតិវិធី ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ៧៥នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial/ 15-07-202

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ នាវេលាម៉ោង ១២និង១៥នាទី ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមកចំនួន ៧៥នាក់ ក្នុងនោះមានស្រី ៤៣នាក់ និងកុមារ

១១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារចត្តាឡីស័ក ខេត្តប៉ៃលិន ដើម្បីធ្វើការបន្ត។ ដោយឡែកខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលនោះទេ ចំណែកមធ្យោបាយដឹកទំនិញ គឺចេញ-ចូលធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន៤៦នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial/ 15-07-202

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៦នាក់ ស្រី ១៣នាក់ និងកុមារ ០៦នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៩នាក់

https://www.facebook.com/GDIOfficial/ 15-07-202

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យមានចំនួន៤៩នាក់ ស្រី២២នាក់៕

# ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០

## បង្ក្រាបទីតាំងអាជីវកម្មបនពេស្យាចារ( អាជីកម្មផ្លូវភេទ ) ខុសច្បាប់ ចំនួន ៣ទីតាំង ឃាត់ខ្លួនមនុស្សចំនួន ៣១នាក់ នៅក្រុងព្រះសីហនុ

https://www.cen.com.kh/ July 17, 2020

ក្រុងព្រះសីហនុ ៖ នគរបាលក្រុងព្រះសីហនុ បានធ្មក់ចូលធ្វើប្រតិបត្តិការបង្ក្រាប ទីតាំងអាជីវកម្មបនពេស្យាចារ(អាជីកម្មផ្លូវភេទ)ខុសច្បាប់ចំនួន៣ទីតាំងឃាត់ខ្លួនមនុស្សចំនួន៣១នាក់(ប្រុស ១៦នាក់ និងស្រី១៥នាក់)។ លោកឧត្តមសេនីយ៍ទោជួន ណារិន្ទ ស្នងការនគរបាលខេត្តព្រះសីហនុ បានឲ្យដឹងថា នៅមុនពាក់កណ្តាលអធ្រាត្រយប់ថ្ងៃទី១៦ កក្កដា ២០២០ ដោយមានការសម្របសម្រួលពីលោក លឹម ប៊ុនហេង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូង ខេត្តព្រះសីហនុ កម្លាំងនគរបាលជំនាញប្រឆាំងការជួញដូរផ្លូវភេទ និងការពារអនីតិជន ព្រមទាំងកម្លាំងអធិការដ្ឋាននគរបាលក្រុងព្រះសីហនុ បានធ្មក់ចូលធ្វើប្រតិបត្តិការបង្ក្រាប ទីតាំងអាជីវកម្មបនពេស្យាចារ(អាជីកម្មផ្លូវភេទ) ខុសច្បាប់ ចំនួន០៣ទីតាំង ស្ថិតនៅផ្ទះសំណាក់ ឃីហោ យិងប៊ិន ពូអៀក អ៊ីចាន់ ស្ថិតក្នុង ក្រុម៣ ភូមិ១ សង្កាត់លេខ២ ក្រុងព្រះសីហនុ (ភ្នំខៀវ) ឃាត់ខ្លួនជនពាក់ពន្ធ័ ក្នុងករណីនេះចំនួន ៣១នាក់ (ប្រុស ១៦

នាក់ និងស្រី ១៥នាក់) ក្នុងនោះមានជនជាតិចិន ជនជាតិវៀតណាម និងជនជាតិរុស្ស៊ី ព្រមទាំងដកហូតបានសម្ភារ វត្ថុតាងសម្រាប់បម្រើសេវាផ្លូវភេទមួយចំនួនធំ។

បច្ចុប្បន្ន ជនពាក់ពន្ធ័ទាំង៣១នាក់ខាងលើ កំពុងឃាត់ខ្លួននៅអធិការដ្ឋាននគរក្រុងព្រះសីហនុ ដើម្បីសាកសួរ និងចាត់ការទៅតាមផ្លូវច្បាប់៕ **ដោយៈកូឡាប**

## ពលរដ្ឋបន្តលួចចូលប្រទេសថៃស្វែងរកការងារធ្វើ សងបំណុលធនាគារក្នុងវិបត្តិជំងឺកូវីដ-១៩

https://www.rfa.org/khmer/ ដោយ ខៃ សុណង 2020-07-16

សង្គមស៊ីវិលដែលធ្វើការផ្នែកសិទ្ធិពលករមើលឃើញថា មានកត្តាពីរសំខាន់ដែលជំរុញឱ្យពលរដ្ឋខ្មែរបន្តប្រថុយប្រថានឆ្លងដែនចូលប្រទេសថៃ ក្នុងអំឡុងវិបត្តិនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ (Covid19)។ មន្ត្រីជំនាញអះអាងថា រដ្ឋាភិបាលកំពុងអប់រំផ្សព្វផ្សាយនិងផ្ដល់ការងារផ្នែកកសិកម្មឱ្យពលរដ្ឋ ខណៈអាជ្ញាធរប្រទេសថៃ ប្រើវិធានការព័ទ្ធល្វសបន្លាតាមព្រំដែនដើម្បីទប់ស្កាត់ពលករខ្មែរ កុំឱ្យចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ និងដើម្បីការពារជំងឺឆ្លងកូវីដ១៩។ កត្តាពីរសំខាន់ដែលជំរុញឱ្យពលករខ្មែរប្រថុយប្រថានគ្រោះថ្នាក់និងខាតបង់ប្រាក់ដើម្បីបានចូលទៅរកការងារធ្វើនៅប្រទេសថៃនោះ គឺកត្តាជីវភាព និងការអូសទាញពីមេខ្យល់ ក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩។

មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសក៍នៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ (CENTRAL) លោក ឌី ថេហូយ៉ា ថ្លែងថា ទោះបីប្រឈមស្លាប់រស់យ៉ាងណាក្ដី ក៏ពលរដ្ឋប្រថុយឆ្លងចូលដីថៃវិញដោយសារតែពួកគាត់ខ្វះខាតជីវភាព និងជំពាក់បំណុលគេដែលជាបញ្ហាដែលត្រូវដោះស្រាយជាចាំបាច់។ ជាមួយគ្នានេះ មេខ្យល់បានឆ្លៀតឱកាសអូសទាញឱ្យពួកគាត់បានត្រឡប់ចូលប្រទេសថៃវិញ ដោយផ្សងប្រថុយប្រថានបើទោះជាមានហានិភ័យខ្ពស់ក្ដី ឬដឹងថា នឹងត្រូវប្រឈមជាប់ពន្ធនាគារ គ្រោះថ្នាក់ដល់ជីវិត ឬពិន័យប្រាក់ក៏ដោយចុះ៖ «យើងអត់អាចហាមឃាត់គាត់អត់ឱ្យចំណាកស្រុកទេ កាលណាយើងអត់មានគោលនយោបាយគាំពារឱ្យគាត់អាចរស់បានជាអ្នកត្អូម៉ាទិចគឺគាត់ត្រូវតែភៀសខ្លួនហើយ»។ ការអះអាងរបស់មន្ត្រីសិទ្ធិការងារបែបនេះ បន្ទាប់ពីពលករខ្មែររាប់ម៉ឺននាក់ វិលត្រឡប់ចេញពីប្រទេសថៃ កាលពីចុងខែមិថុនា ដោយអាជ្ញាធរថៃ ដាក់ប្រទេសក្នុងគ្រាអាសន្នដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

អាជ្ញាធរថៃកាលពីថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០២០ បានប្រកាសឱ្យពលករចាកចេញទៅប្រទេសកំណើតរៀងៗខ្លួនវិញ។ ពលករខ្មែរបានចាប់ផ្ដើមធ្វើដំណើរចេញជាបណ្ដើរៗមុនថ្ងៃកំណត់ ពោលគឺតាំងពីថ្ងៃទី២១ ខែមិថុនា តាមច្រកអន្តរជាតិប៉ោយប៉ែត។ លំហូរនៃអ្នកចំណាកស្រុកវិលចូលកម្ពុជាវិញរាប់ម៉ឺននាក់ នៅពេលនោះ ធ្វើឱ្យកកស្ទះណែនណាន់តាន់តាប់ស្ទើរទប់មិនជាប់។

មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃអះអាងថា រយៈពេលជិត៤ខែ ចាប់ពីថ្ងៃទី២១ ខែមិនា រហូតដល់ថ្ងៃទី១៣ ខែកក្កដា មានពលរដ្ឋខ្មែរត្រឡប់ពីប្រទេសថៃជាង ១០ម៉ឺននាក់ (១០១ ២១៧)។ ប៉ុន្តែមន្ត្រីសិទ្ធិការងារប៉ាន់ប្រមាណថា មានប្រមាណ ១២ម៉ឺននាក់។ ទោះបើតួលេខនេះល្មៀងគ្នាបន្តិចក្ដី ប៉ុន្តែបញ្ហាសំខាន់នៅពេលនេះ គ្រង់ថា ពលករទាំងនោះបានប្រថុយត្រឡប់ទៅប្រទេសថៃវិញស្ទើរទាំងអស់ទៅហើយ។

ពលរដ្ឋថា ដោយភាពអត់ឃ្លាន ខ្វះខាតជីវភាព និងជំពាក់ប្រាក់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផង បានតម្រូវឱ្យពួកគាត់លួចប្រថុយឆ្លងទៅប្រទេសថៃវិញ ដោយខុសច្បាប់។ ពលកររោងចក្រអេតចាយនៅខេត្តបថុមថានីប្រទេសថៃ លោក ជឹម សុផាត ឱ្យដឹងថា ក្នុងចំណោមពលករខ្មែរនៅក្នុងរោងចក្រជាមួយលោកជាង ៣រយនាក់មានជាងពាក់កណ្ដាលបានត្រឡប់ទៅស្រុកខ្មែរវិញ ប៉ុន្តែពួកគាត់ក៏បានវិលមកដល់ប្រទេសថៃវិញស្ទើរទាំងអស់ហើយដែរ។ លោកថា ពួកគាត់ត្រូវចំណាយលុយឱ្យទៅមេខ្យល់ និងថ្លៃធ្វើដំណើរម្នាក់ពី ៤ពាន់បាត ទៅ៦ពាន់បាត

ឬប្រមាណ២រយដុល្លារ ដើម្បីវិលមកដេករង់ចាំក្រែងមានការងារធ្វើ និងខ្លះបានធ្វើការ ប៉ុន្តែអ្នកខ្លះខាតបង់ប្រាក់ទាំងស្រុងនៅពេលប៉ូលិសអន្តោប្រវេសន៍ចាប់បញ្ជូនទៅវិញ៖ «ដល់តែទៅខ្មែររយៈពេល២ខែលីថា ថៃបិទមិនឱ្យចូល គាត់គ្មានជម្រើសទេ បើនៅយូរគាត់ជំពាក់លុយធនាគារផង ស្បៀងអាហារខ្វះខាតក៏សម្រេចចិត្តមកវិញ អ្នកខ្លះនៅពេលទៅទិញម៉ូតូទុកជិះដល់តែត្រឡប់មកវិញលក់ម៉ូតូទៀត អ៊ីចឹងម៉ូតូមួយគ្រាន់តែថ្លៃធ្វើដំណើរពីនាក់ប្ដីប្រពន្ធអស់បាត់ហើយ។ គ្មានជម្រើសទេមិនអាចឱ្យគាត់នៅស្រុកខ្មែរបានកើតតទៅទៀតទេ បើនៅស្រុកខ្មែរប្រឈមធនាគាររឹបអូសផ្ទះ ធ្វើដំណើរមកវិញក៏ប្រឈមអស់លុយច្រើន»។

ទោះបើប្រាក់ក៏បង់ថង់ក៏ដាច់ ក៏ពួកគាត់ស៊ូប្ដូរចេញរកការងារនៅប្រទេសថៃយ៉ាងប្រថុយ។ ពលករធ្វើការផ្នែកជាងជួសជុលរថយន្តនៅខេត្តរ៉ាក់យ៉ង ប្រទេសថៃ លោក ផុន ពេជ្រ អំពាវនាវឱ្យរដ្ឋាភិបាលយកចិត្តទុកដាក់ដល់ពលរដ្ឋខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃ៖ «ចូលវិញដោយសារគ្មានលុយបង់ធនាគារគេរឹបអូសយកទ្រព្យសម្បត្តិគាត់ដីធ្លីគាត់ ជួលឡានផ្លូវកាត់ចូលតាមច្រករបៀង ច្រករ៉ុងក្លឿ ច្រកប៉ោយប៉ោយប៉ែតចូលមកក៏គេចាប់ចងត្រឡប់ទៅវិញគួរឱ្យខ្មាសគេ។ សូមផ្ដាំទៅរដ្ឋាភិបាលគួរយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋខ្មែរផង មកធ្វើការឆ្លងកាត់មកប្រទេសគេ ខ្មាសជាតិសាសន៍គេដទៃណាស់»។ សន្ទុះនៃការបន្តលួចឆ្លងដែនចូលប្រទេសថៃ និងក្ដីបារម្ភពីការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ អាជ្ញាធរថៃបាន ដាក់ពង្រាយលួសបន្លាជាច្រើនកន្លែងនៅតំបន់ព្រំដែនក្នុងទឹកដីថៃជាប់ខេត្តបន្ទាយមានជ័យ ពិសេសនៅតំបន់ដាច់ស្រយាលពុំមានមនុស្សរស់នៅ និងមិនសូវមានទាហានថៃប្រចាំការដូចជានៅព្រំដែនជាប់ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ស្រុកម៉ាឡៃ និងនៅទីតាំងមួយចំនួនក្នុងសង្កាត់ប៉ោយប៉ែតជាដើម។

នាយករដ្ឋមន្ត្រីថៃ លោក ប្រាយុទ្ធ ចាន់អូចា (Prayut Chan-o-Cha) កាលពីថ្ងៃទី១៤ កក្កដា ថា រដ្ឋាភិបាលថៃបានបន្ថែមកងកម្លាំងជាច្រើននាក់ដាក់ពង្រាយការពារតាមព្រំដែន ជាពិសេសតំបន់ព្រំដែនខេត្តស្រះកែវ (Sra Kao) និងខេត្តសុរិន្ទ (Surin) ដែលពលករខ្មែរលួចឆ្លងដែនច្រើនជាងគេ។

ប៉ូលិសអន្តោប្រវេសន៍ថៃឱ្យដឹងថា ចាប់តាំងពីចុងខែមីនា ដល់ខែមិថុនា មានពលករខ្មែរប្រមាណ ៣ពាន់នាក់ ដែលត្រូវបានអាជ្ញាធរថៃចាប់ ដោយសារតែពួកគេឆ្លងដែនចូលទៅធ្វើការងារនៅប្រទេសថៃដោយខុសច្បាប់។ ក្រុមពលករទាំងនោះត្រូវបានអាជ្ញាធរកម្ពុជានិងថៃឱ្យធ្វើកិច្ចសន្យាឈប់ឆ្លងដែនខុសច្បាប់នៅថ្ងៃក្រោយទៀតមុននឹងដោះលែងវិញ។

ជុំវិញបញ្ហានេះ អនុប្រធានអចិន្ត្រៃយ៍គណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង មានប្រសាសន៍ថា រលកនៃការជំរុញឱ្យពលរដ្ឋខ្មែរត្រឡប់ទៅវិញគឺដោយសារការអូសទាញពីមេខ្យល់ ពុំមែនជារឿងខ្វះខាតជីវភាពតែមួយជ្រុងនោះទេ។ អ្នកស្រីថា ដោយសារអ្នកចំណាកស្រុកទាំងនោះពុំមានភាពនឹងនរក្នុងការរស់នៅក្នុងសហគមន៍ចេះតែចល័តចុះឡើង នាំឱ្យរដ្ឋាភិបាលពិបាកក្នុងការដាក់បញ្ចូលពួកគាត់ទៅក្នុងក្រុមមនុស្សដែលកំពុងយកចិត្តទុកដាក់ លើបញ្ហាជីវភាព និងរៀបចំនីតិវិធីត្រឡប់ទៅវិញដោយស្របច្បាប់នៅពេលប្រទេសទទួល បើកឡើងវិញ ដែលជាគម្រោងរបស់អង្គការសហប្រជាជាតិសហការជាមួយរដ្ឋាភិបាល៖ «យើងបានដឹងតាំងពីដំបូងជំងឺកូវីដនេះ មិនងាយមានពេលដែលឈានទៅធម្មតាវិញទេ អ៊ីចឹងយ៉ាងហោចក៏គាត់ត្រៀមខ្លួនរស់នៅស្រុកខ្មែរ ៣ខែ ឬអាច៦ខែ ១ឆ្នាំ ឬជាង១ឆ្នាំ អាស្រ័យលើស្ថានភាពជំងឺនៅទូទាំងពិភពលោក ឬមួយនៅប្រទេសគោលដៅបាននឹងនរ ឬថយចុះបានដែរឬអត់? អ្វីដែលយើងគិតគឺមិនខុសទេ ពួកគាត់មិនអាចត្រឡប់ទៅវិញបាន គាត់ត្រូវតែមូលអារម្មណ៍ដាក់ចិត្តដាក់ថ្លើមថា យើងនឹងនៅទីនេះដែលជាភូមិកំណើតរបស់យើងហ្នឹង គាត់ត្រូវតែអត់ធ្មត់ប្រឈមការលំបាកដូចអ្នកនៅក្នុងស្រុកអ៊ីចឹងគឺយើងយកចិត្តទុកដាក់ដូចគ្នា»។

ទោះរដ្ឋាភិបាលអះអាងពីវិធានការរបស់ខ្លួនយ៉ាងនេះក្ដី មន្ត្រីសិទ្ធិការងារស្នើឱ្យរដ្ឋាភិបាល គួររៀបចំផែនការឱ្យបានច្បាស់លាស់ ដើម្បីឆ្លើយតបបញ្ហាប្រឈមទាំងនេះ ដូចជា ផ្សព្វផ្សាយបញ្ហាប្រឈមពីការចំណាកស្រុកខុសច្បាប់ឱ្យបានទូលំទូលាយដល់ពលរដ្ឋនៅតំបន់ជនបទ បង្ហាញគោលនយោបាយគាំពារពីតម្រូវការចាំបាច់ នូវពេល

វេលាដាក់លាក់ និងស្នើឱ្យរដ្ឋាភិបាលដាក់បម្រាមកំណត់ចំពោះការផ្អាកបង់សងបំណុល រួមទាំងជំរុញផលិតផលដាំដុះក្នុងស្រុកទប់ស្កាត់ការនាំបន្លែចូលពីប្រទេសជិតខាង ទើបអាចឱ្យពលរដ្ឋមានភាពនឹងនរក្នុងការរស់នៅ។

ក្នុងគ្រាដែលប្រជាពលរដ្ឋបន្តលួចឆ្លងចូលទៅប្រទេសថៃអំឡុងវិបត្តិជាសាកលនៃជំងឺកូវីដ-១៩ មិនប្រាកដទេថា ពួកគាត់មានការងារធ្វើនោះឡើយ។ ពលករដែលកំពុងធ្វើការនៅប្រទេសថៃឱ្យដឹងថា ប្រទេសថៃបច្ចុប្បន្នមិនសំបូរការងារដូចមុនទេ ពួកគាត់ខ្លះនៅមានការងារធ្វើតែខ្សត់ជាងមុន ខ្លះបន្តដេករង់ចាំការងារព្រោះរោងចក្រ សហគ្រាស ពួកគេខ្លះមិនទាន់បើកដំណើរការឡើងវិញនៅឡើយ។

សារព័ត៌មានថៃប៉ុស្ដិ៍ (Thai post) បានចុះផ្សាយការពីដើមខែកក្កដាថា ក្នុងត្រីមាសទី២ ឆ្នាំ២០២០ ពលរដ្ឋថៃបានបាត់បង់ការងារធ្វើប្រមាណ ៨លាន ៣សែននាក់ ហើយគោលនយោបាយថៃក៏នឹងត្រៀមកាត់បន្ថយការនាំចូលពលករដែលមានកិច្ចព្រមព្រៀងអនុស្សារណៈ ឬ(MOU)។

របាយការណ៍របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ កាលពីឆ្នាំ២០១៩ បានឱ្យដឹងថា ពលករខ្មែរប្រមាណជាង ១លាន ២សែននាក់ កំពុងធ្វើការងារស្របច្បាប់នៅប្រទេសថៃ។ ប៉ុន្តែរបាយការណ៍របស់អង្គការសង់ត្រាល់ថា ពលករខ្មែរដែលធ្វើការនៅប្រទេសថៃ ទាំងស្របច្បាប់ និងខុសច្បាប់ មានប្រមាណ ២លាននាក់៕

## ភាគីកម្ពុជាអះអាងថា ភាគីថៃវាយបន្លាលួសក្នុងដែនដីរបស់ថៃ មិនប៉ះដល់ដែនដីកម្ពុជាទេ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 16 July 2020 | 09:38 ICT

**បាត់ដំបង/បន្ទាយមានជ័យ:** អាជ្ញាធរខេត្តបាត់ដំបង និងបន្ទាយមានជ័យនៃប្រទេសកម្ពុជាតាមបណ្ដោយព្រំដែនអះអាងថា ការវាយរបងបន្លាលួសរបស់ភាគីថៃ គឺធ្វើឡើងនៅលើទឹកដីថៃតែប៉ុណ្ណោះ និងនៅឆ្ងាយពីព្រំដែននៃប្រទេសទាំង ២ មិនប៉ះពាល់ដល់ដែនដីកម្ពុជានោះឡើយ។

ស្នងការនគរបាលខេត្តបន្ទាយមានជ័យលោក អាត់ ខែម បានប្រាប់ភ្នំពេញប៉ុស្ដិ៍កាលពីថ្ងៃទី ១៤ កក្កដា ថា តាមរយៈការផ្សព្វផ្សាយនៅលើបណ្ដាញព័ត៌មាន និងបណ្ដាញសង្គមហ្វេសប៊ុកកាលពីថ្ងៃទី ១៣ និង ១៤ ខែកក្កដា ពីការវាយបន្លាលួសនេះគឺជាព័ត៌មានពិតមែន។ ប៉ុន្តែការវាយបន្លាលួសនេះគឺភាគីថៃបានវាយនៅលើតែទឹកដីរបស់ខ្លួននៅតាមថ្នល់ជាតិ និងច្រកចេញចូលរបៀងមួយចំនួនដើម្បីការពារពលរដ្ឋលួចចេញចូលខុសច្បាប់។ លោកបានថ្លែងថា៖ «គេវាយនៅផ្លូវកៅស៊ូរបស់គេ។ គេមិនមែនយកមកវាយតាមព្រំដែនទេ។ នៅច្រកណាដែលគេយាមមិនដល់គេដាក់បន្លាលួសនេះ។ គេធ្វើនៅលើដីគេ នៅឆ្ងាយពីព្រំដែនឆ្ងាយណាស់នៅថ្នល់កៅស៊ូរបស់គេឯណោះមិនមានរឿងអ្វីត្រូវរាយការណ៍មកយើងទេ»។ លោកស្នងការបានបញ្ជាក់ថា សមត្ថកិច្ចខេត្តបន្ទាយមានជ័យបានខិតខំទប់ស្កាត់មិនឱ្យពលរដ្ឋខ្មែរលួចធ្វើចំណាកស្រុកតាមច្រកព្រំដែនទៅកាន់ប្រទេសថៃទេ។ ប៉ុន្តែមានពលរដ្ឋមួយចំនួននៅតែលួចចូលទៅនៅពេលយប់ ដែលបង្កការលំបាកក្នុងការទប់ស្កាត់។ លោក អាត់ ខែម ថ្លែងថា៖ «តាមដំណឹងពីខាងក្នុងមក(ប្រទេសថៃ) មានការណាត់ពលរដ្ឋខ្មែរឱ្យទៅធ្វើការងារនៅទីនោះចេះតែមាន។ ខាងព្រំដែនទីនេះមានការលំបាកក្នុងការទប់ស្កាត់ពួកគាត់ ពិសេសពីចំណុចព្រំដែនប៉ោយប៉ែតទៅកាន់ជួរភ្នំដងរែកតាមភាគខាងជើង»។

លោក សឿម ប៊ុនរិទ្ធិ អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង បានបញ្ជាក់កាលពីថ្ងៃទី ១៤ កក្កដា ដែរថា ពលរដ្ឋខ្មែរនៅតែលួចធ្វើចំណាកស្រុកទៅតាមច្រកព្រំដែនបាត់ដំបង ពិសេសលួចចូលទៅពេលយប់ដូចនៅខេត្តបន្ទាយមានជ័យដែរ ប៉ុន្តែមិនមានចំនួនច្រើនទេ។ លោកបានថ្លែងថា៖ «យើងបានសុំការយោគយល់គ្នាជាមួយខេត្តជាប់ព្រំដែនជាមួយភាគីថៃលើរឿងនេះក្នុងការសហការគ្នា។ បើចាប់បានពលរដ្ឋខ្មែរលួចធ្វើចំណាកស្រុកឱ្យជួយចាប់បញ្ជូនមកកម្ពុជាវិញ រួចយើងក៏ធ្វើចត្តាឡីស័កពួកគាត់តាមការណែនាំរបស់រដ្ឋាភិបាល»។ លោកអភិបាលរងបានថ្លែងថា នៅតាមក្បែរបណ្ដោយព្រំដែនក្នុងខេត្តបាត់ដំបងមិនទាន់ឃើញមានការវាយបន្លាលួសរបស់ភាគីថៃនោះទេ

។ លោកអះអាងថា លោកបានទៅព្រំដែននៅតំបន់ភ្នំព្រឹកកាលពីពេលថ្មីៗក៏បានទទួលព័ត៌មាន និងមិនឃើញមានការវាយបន្លាលួសរបស់ភាគីថៃនៅក្បែរបន្ទាត់ព្រំដែនក្នុងដែនដីខេត្តបាត់ដំបងនោះដែរ។

លោក តូច រ៉ា នាយសេនាធិការរងយោធភូមិភាគទី ៥ និងជាប្រធានការិយាល័យទំនាក់ទំនងកិច្ចការព្រំដែនប្រចាំច្រកព្រំដែនអន្តរជាតិដាំបានឱ្យដឹងកាលពីម្សិលមិញដែរថា នៅច្រកព្រំដែននេះប្រជាពលរដ្ឋកម្ពុជា-ថៃនៅមានការធ្វើចរាចរណ៍ពាណិជ្ជកម្មដោយដឹកទំនិញទៅវិញទៅមក។ ប៉ុន្តែមិនមានការបើកឱ្យប្រជាពលរដ្ឋចេញចូលនោះទេ។ លោកបានថ្លែងថា៖ «នៅតាមច្រកព្រំដែន យើងនិយាយគ្នាជាមួយភាគីថៃហើយថា អ្វីក៏ដោយ គឺមិនត្រូវឱ្យមានការប្រែប្រួលខុសពីសភាពដើមឡើយ ពីមុនយ៉ាងម៉េចគឺរក្សាដដែល»។

លោក ប៉ា ចន្ទរឿន ប្រធានវិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជាលើកឡើងថា សកម្មភាពវាយបន្លាលួសនេះគឺស្ថិតក្នុងទិដ្ឋភាព ២ គឺទី១ ប្រទេសថៃ មានការបារម្ភអំពីបញ្ហាជំងឺកូវីដ ១៩។ ព្រោះពិបាកកំណត់ថាអ្នកណាម្នាក់មានឆ្លងមេរោគនេះឬអត់ព្រោះកន្លងមកពលរដ្ឋខ្មែរមួយចំនួនប្រើផ្លូវកាត់ចូលទៅធ្វើការនៅប្រទេសថៃ។ ដូច្នេះការវាយបន្លាលួសនេះអាចជារបងការពារ។ លោកបន្តថា៖ «ទី២ ក្នុងនាមយើងជាខ្មែរយើងក៏ត្រូវដឹងដែរថា ការវាយបន្លាលួសនោះក្នុងន័យការពារប្រជាពលរដ្ឋយើងក្នុងការឆ្លងដែនខុសច្បាប់ទៅស្រុកគេមែន ឬក៏ជាលេសមួយដើម្បីដាក់លួសនេះទាមទាររឿងអ្វីផ្សេង ដូចដែលយើងបានឃើញកន្លងមកដែលខ្មែរយើងបានប្រឈមមុខ»៕

## ការទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ និងចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ នៅតាមសហគមន៍ ក្នុងស្រុកពួក ខេត្តសៀមរាប

https://www.facebook.com/deputygovernoryousophear/ 16-07-2020

ខេត្តសៀមរាប ៖ នៅព្រឹកថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ រដ្ឋបាលស្រុកពួក បានធ្វើការផ្សព្វផ្សាយអំពីការទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេស និងការទប់ស្កាត់ការីករាលដាលជំងឺកូវីដ១៩ នៅក្នុងសហគមន៍ ដល់ប្រជាពលរដ្ឋ នៅភូមិឈូក ឃុំត្រីញ័រ ស្រុកពួក ដោយមានកិច្ចសហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) និងមណ្ឌលសុខភាពផងដែរ។ ការកិច្ចប្រជុំផ្សព្វផ្សាយនេះ លោកស្រី អភិបាលរងស្រុក ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្រុកពួក បានធ្វើការណែនាំពន្យល់ដល់ប្រជាពលរដ្ឋ អំពីហានិភ័យនៃការឆ្លងដែនខុសច្បាប់ទៅក្រៅប្រទេស (តាមរយៈមេខ្យល់) ដូចជាប្រទេសថៃជាដើម ដែលប្រទេសគោលដៅមួយនេះ បាននឹងកំពុងបន្តដាក់ប្រទេសស្ថិតិក្នុងគ្រាសមានអាសន្ននៅឡើយ ដើម្បីធ្វើការទប់ស្កាត់ការីករាលនៃជំងឺកូវីដ១៩។ ដូចនេះពុំទាន់មានចរាចរណ៍ទីផ្សារការងារទូរលំលាយ ហើយការចេញចូលក្នុងប្រទេសរបស់គេ ក៏ត្រូវបានរឹតបន្តឹងផងដែរ។

មួយវិញទៀត ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់ការកើតមានជំងឺកូវីដ១៩ នៅក្នុងសហគមន៍ សូមបងប្អូន ចូលរួមសំអាតបរិស្ថានជុំវិញគេហដ្ឋាន ការហូបស្អាត ការធ្វើអនាម័យ ការលាងសំអាតដៃជាមួយសាប៊ូ អាកុល ឬជេល ឲ្យញឹកញាប់ និងអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល ជៀសវាងការជុំគ្នាច្រើន ដោយពុំមានការវិធានការការពារ (ដូចជាការពាក់ម៉ាស ការរក្សាគម្លាត ឲ្យបានត្រឹមត្រូវ) ។ ជាមួយនឹងស្ថានភាពបែបនេះ ក្រុមការងារក៏បានជំរុញឲ្យបងប្អូនប្រជាពលរដ្ឋ បែបមកប្រកបរបរកសិកម្ម តាមរយៈការដាំដុះដំណាំរួមផ្សំផ្សេងៗ ការចិញ្ចឹមសត្វ ជាលក្ខណៈគ្រួសារ មកជំនួសពីការប្រថុយប្រថាន ក្នុងការចំណាកស្រុកខុសច្បាប់ ទៅក្រៅប្រទេស។ នៅក្នុងកិច្ចជំនួបនេះផងដែរ អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM)បាននាំមកនូវសាប៊ូសម្រាប់លាងដៃ ដល់ប្រជាពលរដ្ឋ ម្នាក់មួយដុំផងដែរ។ (ប្រភពពី លេខាធិការដ្ឋាន គឌបជសៀមរាប)

# ថៃបញ្ជូនប្រជាជនខ្មែរចំនួន៤នាក់មកស្រុកវិញ

https://www.rasmeinews.com/ July 16, 2020, 7:14 PM

ដោយបាយ័ន+អូរស្មាច់/ឧត្តរមានជ័យៈ ប្រជាជនខ្មែរចំនួន៤នាក់ ដែលក្នុងនោះមានអ្នកទោសចំនួន២នាក់ និងពលករចំនួន២នាក់ត្រូវបានភាគីថៃបានបញ្ជូនមកស្រុកកំណើតវិញ។ ពិធីប្រគល់និងទទួលបានធ្វើឡើងកាលពីវេលាម៉ោង១០និង៥៨នាទី ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០នេះស្ថិតនៅច្រកអន្តរជាតិជាំស្រង៉ាំ ក្នុងទឹកដីស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។

សមត្ថកិច្ចនគរប្រចាំច្រកអន្តរជាតិជាំស្រង៉ាំ បាននិយាយថា អាជ្ញាធរថៃបានបញ្ជូនប្រជាជនខ្មែរចំនួន៤នាក់ឱ្យត្រឡប់មកស្រុកកំណើតវិញ។ ក្នុងនោះមានអ្នកទោសចំនួន២នាក់ ត្រូវបានដោះលែងពីពន្ធនាគារពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើក្រញូង។ ដោយចូលតាមច្រកអូរចាក ហើយយកទៅដាក់ពន្ធនាគារនៅខេត្តស៊ីសាកេតប្រទេសថៃកាលពីថ្ងៃទី១០ខែតុលាឆ្នាំ២០១៧កន្លងទៅ។ពលករចំនួន២នាក់ ដែលធ្វើការខុសច្បាប់នៅប្រទេសថៃរយៈពេល៥ខែ នៅខេត្តអយុធ្យា។ សមត្ថកិច្ចបានបន្តថា ប្រជាជនខ្មែរចំនួន៤នាក់ដែលត្រូវបានថៃបញ្ជូនមកស្រុកកំណើតវិញគឺមានទី១, ឈ្មោះសុទ្ធណាភេទប្រុសអាយុ៣២ឆ្នាំ( ពលករ ),ទី២,ឈ្មោះសោមឡាភេទប្រុសអាយុ៣៨ឆ្នាំ( ពលករ )។ អ្នកទាំងពីររស់នៅភូមិអូរុនឃុំថ្លាតស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។ ទី៣,ឈ្មោះហ៊ឹមជាតិភេទប្រុសអាយុ២០ឆ្នាំ, ទី៤,ឈ្មោះចាន់តៃភេទប្រុសអាយុ២០ឆ្នាំ អ្នកទាំងពីររស់នៅភូមិអូរជើកឃុំផ្អាវស្រុកត្រពាំងប្រាសាទខេត្តឧត្តរមានជ័យ៕ទ/

# អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ១៨នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial/ 16-07-202

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៨នាក់ ស្រី ០៣នាក់ និងកុមារ ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

# ប្រជាពលរដ្ឋខ្មែរចំនួន៣១នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial/ 16-07-202

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣១នាក់ ស្រី ១៥នាក់ និងកុមារ ០២នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយ

ស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពរស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៣នាក់

https://www.facebook.com/GDIOfficial/ 16-07-202

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន៩៣នាក់ ស្រី៤៣នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលរដ្ឋខ្មែរចំនួន០២នាក់ ពីសមត្ថកិច្ចថៃពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial/ 16-07-202

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈេើនៅប្រទេសថៃ ដែលចេញតាមច្រកអូរបារ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

# ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០

## មានក្ដីបារម្ភពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ប្រើទូរស័ព្ទសិក្សាតាមប្រព័ន្ធអនឡាញ

https://m.postkhmer.com/ សុទ្ធ គឹមសឿន 17 July 2020 | 13:37 ICT

**ភ្នំពេញៈ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ លោកស្រី ញ៉េប សុភាព បង្ហាញក្ដីបារម្ភចំពោះអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត ដោយសារមួយរយៈចុងក្រោយកុមារភាគច្រើនកាន់ទូរស័ព្ទ ឬនៅជាមួយអ៊ីនធឺណិត ដើម្បីសិក្សាតាមប្រព័ន្ធអនឡាញ ប៉ុន្តែក្រៅពីសិក្សាមិនដឹងកុមារបានប្រព្រឹត្តអ្វីខ្លះតាមប្រព័ន្ធអ៊ីធឺណិត។

លោកស្រី ញ៉េប សុភាព ប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា លោកស្រីមានការបារម្ភចំពោះអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត ព្រោះកុមារភាគច្រើនបានកាន់ទូរស័ព្ទស្មាតហ្វូន ដើម្បីធ្វើការសិក្សាតាមប្រព័ន្ធអ៊ីធឺណិត។ ប៉ុន្តែគេមិនដឹងច្បាស់ថា ក្រៅពីការរៀនសូត្រពួកគាត់បានប្រព្រឹត្តអ្វីដែលងាយចាញ់បោកជនខិលខូចមួយចំនួន។ លោកស្រីបន្តថា ក្រុមការងារអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារដែលមានសមាសភាពជំនាញពីអន្តរក្រសួងបាន និងកំពុងពិភាក្សាដាក់ចេញនូវផែនការមួយចំនួន ដើម្បីទប់ស្កាត់រាល់អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនេះ។ ក្នុងនោះក្រុមការងារបានដាក់ចេញផែនការសំខាន់ៗមួយចំនួន ដើម្បីយកទៅអនុវត្តសម្រាប់ទប់ស្កាត់បទល្មើសទាំងនេះឲ្យមានប្រសិទ្ធភាពខ្ពស់។ លោកស្រី ញ៉េប សុភាព បានបញ្ជាក់ថា៖ «ចំណុចសំខាន់ដែលយើងកំពុងគិតពិចារណានេះគឺពង្រឹងអភិបាលកិច្ចមូលដ្ឋានដោយធ្វើការផ្សព្វផ្សាយពីផល

ប៉ះពាល់ទាំងអស់នេះឲ្យអាណាព្យាបាល ឬឪពុកម្តាយគាត់បានដឹង ហើយតាមដានសកម្មភាពកូនឲ្យបានច្រើនជាងមុន»។ លោកស្រីបានបន្តថា៖ «ជាក់ស្តែងក្នុងអំឡុងពេលជំងឺកូវីដនេះគឺក្មេងៗរៀនតាមអនឡាញ ហើយប្រព័ន្ធវាទូលំទូលាយណាស់។ បើយើងសិក្សាស្រាវជ្រាវតាមមេរៀន គឺវាផ្តល់ផលប្រយោជន៍ច្រើនប៉ុន្តែយើងខ្លាចគាត់មិនរៀនសូត្រ ហើយបែរទៅជាប្រព្រឹត្តរឿងផ្សេងដែលពាក់ព័ន្ធអំពើកេងប្រវ័ញ្ចផ្លូវភេទ។ ដូច្នេះបញ្ហានេះគឺជារឿងដែលត្រូវតែយកចិត្តទុកដាក់បន្ទាន់»។

លោក James McCabe នាយកប្រតិបត្តិអង្គភាពការពារកុមារ (CPU) បានថ្លែងពីម្សិលមិញថា ជាវិធានការដើម្បីទប់ស្កាត់អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនេះ អាណាព្យាបាលត្រូវតែតាមដានពីសកម្មភាពកូនៗរបស់ខ្លួនតាមរយៈការសង្កេតសកម្មភាពប្លែកៗរបស់ពួកគាត់។ ប៉ុន្តែប្រសិនមានបញ្ហាអ្វីដែលគួរឲ្យកត់សម្គាល់ ឪពុកម្តាយត្រូវតែប្រញាប់រាយការណ៍ ឬប្តឹងសមត្ថកិច្ចជំនាញដែលនៅជិតបំផុត។ លោកបន្តថា ក្មេងៗភាគច្រើនដឹងពីរបៀបប្រើប្រាស់អ៊ីនធឺណិត ឬប្រព័ន្ធអនឡាញ។ ដូច្នេះពួកគេងាយស្រួលនឹងចាញ់កលល្បិចជនខិលខូចមួយចំនួន ហើយសមត្ថកិច្ចជំនាញ និងអ្នកពាក់ព័ន្ធត្រូវដឹងឲ្យបានច្បាស់ពីសកម្មភាពកូនៗ និងល្បិចកលរបស់ជនខិលខូចដែលមានបំណងមិនល្អមកលើអនីតិជន។ ពិសេសអាណាព្យាបាលត្រូវតែធ្វើការសហការជាមួយមន្ត្រីជំនាញឲ្យបានជិតស្និទ្ធ ដើម្បីបង្ក្រាបបទល្មើសទាំងអស់នេះ។ លោកបានបញ្ជាក់ទៀតថា៖«CPUមានមោទនភាពដែលបានក្លាយជាដៃគូយ៉ាងជិតស្និទ្ធជាមួយនគរបាលកម្ពុជា ដើម្បីការពារកុមារ និងស្រាវជ្រាវលើបទល្មើសទាក់ទងកុមារ។ ជាពិសេសបទល្មើសអនឡាញទៅលើកុមារយើងត្រូវតែចូលរួមទាំងអស់គ្នា ដើម្បីសុខសុវត្ថិភាពរបស់កុមារ។ បទល្មើសដែលកើតឡើងមកលើកុមារមានទំហំធំធេងនៅលើសកលលោក ប៉ុន្តែសម្រាប់ CPU ដែលកំពុងធ្វើការនៅកម្ពុជា គឺឆ្នាំនេះយើងរកឃើញចំនួន៩ករណី ដែលបានកើតឡើងលើកុមារតាមប្រព័ន្ធអនឡាញ»៕

## គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០នេះ ខេត្តសៀមរាប បានទទួលប្រជាពលរដ្ឋខ្មែរ ចូលតាមច្រកទាំងបី ចំនួន ១៥,៧៣៨នាក់

https://www.facebook.com/tvkchannel7 18-07-2020

ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់អាជ្ញាធរខេត្តសៀមរាប នៅថ្ងៃសៅរ៍ ទី១៨ ខែកក្កដា ឆ្នាំ២០២០នេះ នៅតែទៅបន្តរង់ចាំទទួលប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដដែល។ នៅថ្ងៃនេះដែរទទួលបានចំនួនសរុប ៧នាក់ ស្រីចំនួន ២នាក់ ដែលចូលមកតាមច្រកដូងខេត្តបាត់ដំបង, តាមច្រកប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ។

គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០នេះ សម្រាប់ខេត្តសៀមរាប តួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរចូលតាមច្រកទាំងបីខាងលើមានចំនួន១៥,៧៣៨នាក់ស្រីចំនួន៦,៨៦២នាក់ក្នុងនោះបានពិនិត្យសុខភាពបឋមបានចំនួន១៥,៧៣៨នាក់ ស្រី៦,៨៦២នាក់ គឺពិនិត្យសុខភាពបានទាំងអស់។ សូមបញ្ជាក់ជូនថា ប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃក្នុងមួយថ្ងៃៗ មានចន្លោះពីជាង ១០០ នាក់ រហូតដល់ជាង ៣០០នាក់ សម្រាប់ទូទាំងប្រទេសកម្ពុជា៕ ប្រភព: របាយការណ៍រដ្ឋបាលខេត្តសៀមរាប កែសម្រួលដោយ លីវ សុខុន

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន២៩នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 19-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ២៩នាក់ ស្រី ១០នាក់ និងកុមារ ០១នាក់។ ចំពោះពលករ

ខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៣២នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបធ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 19-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិចេញ-ចូលបាននោះទេ។ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបធ្វេង-ស្លាបស្តាំចំនួន ៣២នាក់ ស្រី ១៦នាក់ និងកុមារ ០១នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៧នាក់

https://www.facebook.com/GDIOfficial 19-07-2020

នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៧នាក់ ស្រី ៤៧នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៥៩នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 18-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៥៩នាក់ ស្រី ១៩នាក់ និងកុមារ ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិន

ទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៦នាក់

https://www.facebook.com/GDIOfficial 18-07-2020

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន៤៦នាក់ ស្រី១៨នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ២០នាក់ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 17-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ២០នាក់ ស្រី ០៩នាក់ និងកុមារ ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៣២នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 17-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣២នាក់ ស្រី ១១នាក់ និងកុមារ ០១នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៣នាក់

https://www.facebook.com/GDIOfficial 17-07-2020

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៣នាក់ ស្រី ៣១នាក់៕

## ត្រឹមតែ1ថ្ងៃ ថៃចាប់ពលករលួចឆ្លងដែនដោយមិនខ្លាចបន្លាលួស

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០២០ ម៉ោង ១៧:៤០ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ យោងការចុះផ្សាយដាច់ដោយឡែក របស់គេហទំព័រក្នុងស្រុកថៃចំនួន២បានឲ្យដឹងថា ត្រឹមរយៈពេល១ថ្ងៃចុងក្រោយនៃខែកក្កដា ២០២០ នេះ ពលករខ្មែរជាង៤០នាក់ ត្រូវសមត្ថកិច្ចចម្រុះថៃក្នុងខេត្តស្រះកែវ ចាប់ខ្លួនក្រោយលួចឆ្លងព្រំដែនចូលទឹកដីថៃ និងមួយចំនួនកំពុងធ្វើដំណើរត្រឡប់ពីប្រទេសថៃវិញ ។

គេហទំព័រមួយបានឲ្យដឹងថា កាលពីថ្ងៃទី១៦ កក្កដា ពលករខ្មែរចំនួន១៤នាក់ ស្រី២នាក់ ត្រូវបានសមត្ថកិច្ចចម្រុះថៃធ្វើការឃាត់ខ្លួន នៅចំណុចភូមិ១ ឃុំថាខាម ស្រុកអារញ្ញ ឈមនឹងទឹកដីកម្ពុជា ក្រុងប៉ោយប៉ែត( ខាងត្បូងផ្លូវជាតិលេខ៥ ) ក្រោយពេលឆ្លងព្រំដែន បំណងទៅរកការងារធ្វើលើទឹកដីថៃ ។

ដោយឡែកគេហទំព័រមួយផ្សេងទៀតបានឲ្យដឹងថា នៅថ្ងៃដដែល១៦ កក្កដា ២០២០ សមត្ថកិច្ចចម្រុះថៃក្នុងស្រុកគោកធ្យូង និងស្រុកតាប្រាយ៉ា រួមជាមួយកម្លាំងជំនាញខេត្តស្រះកែវ បានធ្វើការឃាត់ខ្លួនពលករខ្មែរទើបវិលត្រឡប់ពីថៃ និងទើបឆ្លងព្រំដែនពីកម្ពុជាចំនួន២៨នាក់ ស្រី១៣នាក់ ។ ប្រភពថា ពលករខ្មែរ១៦នាក់ ស្រី៦នាក់ និងមេខ្យល់ថៃ២នាក់ ឡាវម្នាក់ ត្រូវបានឃាត់ខ្លួននៅភូមិគោកសារ៉ាំង ឃុំណងមួង ស្រុកគោកធ្យូង ជាមួយរថយន្តពាក់ស្លាកលេខថៃ៣គ្រឿង ដែលកំពុងដឹកពលករមកពីខេត្តឆាក់ធឹនសៅ ប្រុងឲ្យឆ្លងដែនចូលកម្ពុជាវិញ ។

ចំណែកពលករខ្មែរ១២នាក់ ស្រី៦នាក់ និងមេខ្យល់ថៃ២នាក់ រថយន្តផ្លាកលេខថៃ១គ្រឿង ត្រូវបានគេឃាត់នៅចំណុចភូមិគោករៀន ឃុំនិង ស្រុកតាប្រាយ៉ា ខណៈមេខ្យល់ថៃកំពុងយករថយន្តដឹកពលករទាំងនេះ ទៅរកការងារធ្វើនៅក្រុងបាងកក ។ សរុបពលករទាំង៣ទីតាំង ដែលសមត្ថកិច្ចចម្រុះថៃចាប់នៅក្នុងខេត្តស្រះកែវ មានចំនួន៤២នាក់ ស្រី១៥នាក់ មិនបានគិតរួមជាមួយមេខ្យល់ថៃឡាវ៥នាក់ទេ ។

គួរបញ្ជាក់ថា ករណីពលករខ្មែរលួចឆ្លងដែនខុសច្បាប់ ទៅមកប្រទេសថៃមួយរយៈចុងក្រោយនេះ ស្ទើរក្លាយជារឿងសាមញ្ញ និងដដែលទៅហើយ ព្រោះជំនាញពាក់ព័ន្ធក្នុងខេត្តបន្ទាយមានជ័យ មិនសាកសួរលម្អិតពីពលករដើម្បីដឹងថា ពួកគេឆ្លងតាមច្រកណា ហើយមន្ត្រី ឬសមត្ថកិច្ចណាខ្លះ ដែលជាប់ពាក់ព័ន្ធនឹងរឿងផលប្រយោជន៍ ខណៈប្រទេសថៃនៅពេលនេះមានប្រភពថា កំពុងរឹតបណ្ដឹងយ៉ាងខ្លាំងនោះឡើយ ។ រហូតចំណុចខ្លះនៅបន្ទាត់ព្រំដែនក្នុងខេត្តស្រះកែវមានប្រភពថា សមត្ថកិច្ចថៃដាក់បន្លាលួស៣ជាន់ និងដាក់សញ្ញាបន្លឺសម្លេងពេលណាមានមនុស្សលួចឆ្លងដែនទៀតផង ។ មិនតែប៉ុណ្ណោះចំពោះមន្ត្រី ឬសមត្ថកិច្ចរបស់គេណាមួយ រកឃើញពាក់ព័ន្ធនឹងពលករឆ្លងដែនខុសច្បាប់ នឹងដកហូតតំណែងហើយដាក់ទោសទណ្ឌថែមទៀត ខុសពីសមត្ថកិច្ចខ្មែរបានរួចខ្លួនយ៉ាងរំភើយ ៕

# ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០

## ពលករខ្មែរឆ្លងដែនខុសច្បាប់ ២៤នាក់ត្រូវបានសមត្ថកិច្ចថៃចាប់បញ្ជូន

https://www.facebook.com/VD7news/ 20-07-2020

បាត់ដំបង ៖ សមត្ថកិច្ចថៃបានចាប់ឃាត់ពលករខ្មែរសរុប ២៤ នាក់ប្រុស១៣នាក់ស្រី៩នាក់ និងកុមារ ២ នាក់ត្រូវសមត្ថកិច្ចថៃចាប់ឃាត់ បញ្ជូនត្រឡប់ឲ្យមកសមត្ថកិច្ចខ្មែរ តាមច្រកល្មៀងមួយកន្លែង បានឲ្យដឹងពីសាព័ត៌មានអន្តរជាតិ (ប្រទេសថៃ)។

មេបញ្ជាការកងអនុសេនាធំលោកវីរ៉ាគូណាមេបញ្ជាការកងពលតូចកាយរឹទ្ធិទ័ពជើងគោកលេខ ៥៤៤ មូលដ្ឋានដុងឈឹក ស្រុកផុងណាំរ៉ន ខេត្តច័ន្ទបូរី ថ្ងៃអាទិត្យ ១៤ រោច ខែអាសាឍ ឆ្នាំជូតទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ ត្រូវបានដំណឹងថា មានជនជាតិខ្មែរ១ក្រុមគេសង្ស័យថា បានលាក់ខ្លួននៅក្នុងខ្សែព្រៃមួយនៅមុខរោងម៉ាស៊ីនកិនថ្ម នៅតាមបណ្តោយចន្ទាបុរី - ផ្លូវស្រះកែវ Ban Thung Krang ភូមិលេខ ៤ ឃុំតាសាយសាយរង ហេតុដូច្នេះហើយទើបនាំឱ្យចុះទៅពិនិត្យនៅអ៊ីស៊្យាស៊ូមេរ៉េសរ៉ុនលេខចុះបញ្ជីលេខ ៦K-២៩៦ នៅទីក្រុងបាងកក មួយចតនៅក្នុងព្រៃ ទំនងជាឡានដឹកកម្មករខុសច្បាប់ មន្ត្រីប៉ូលីសអនុរក្សបានបង្កើនល្បឿនម៉ាស៊ីនហើយបើក និងបើកផ្លូវរត់គេចខ្លួន បន្ទាប់មកមន្ត្រីបើកឡានដោយប្រើសញ្ញាឱ្យឈប់តែមិនមានប្រសិទ្ធភាព។ បានសម្រេចចិត្តបាញ់កាំភ្លើងកង់ឡាន មុខខាងស្តាំបំបែកដើម្បីបញ្ឈប់ ប៉ុន្តែអ្នកបើកបរនៅតែព្យាយាមរត់គេចខ្លួនចូលទៅក្នុងសួនច្បារឡុងដែលមានចម្ងាយប្រហែល ១ គីឡូម៉ែត្រចតទុកឡានឱ្យរត់ហើយបាត់ ប្រជាពលរដ្ឋខ្មែរដែលអង្គុយនៅក្នុងឡានមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលរត់ទៅជ្រកក្នុងព្រៃត្រូពិករហូតដល់ឃោជាត្រូវបែកខ្ញែកគ្នាហើយស្វែងរកដោយខ្លាចថាគ្មានសុវត្ថិភាពព្រោះមានដំរីព្រៃជាច្រើននៅតំបន់នោះ ។

នៅចុងបញ្ចប់មានមនុស្សសរុប ២៤ នាក់ប្រុស ១៣ នាក់ស្រី ៩ នាក់និងកុមារ ២ នាក់ ។ ពិនិត្យដោយគ្មានឯកសារបង្ហាញ ដូច្នេះត្រូវបានឃាត់ខ្លួនដើម្បីធ្វើការស៊ើបអង្កេតបឋម សរុបចំនួន៣៥០០ បាតក្នុងម្នាក់ៗដោយជនជាតិថៃបើកឡានដឹកអីវ៉ាន់ទៅយកឥវ៉ាន់មុន ចំណែកពួកគេវិញពួកគេនឹងដើរកាត់ព្រៃរហូតដល់ចំណុចប្រជុំដល់កន្លែងមួយ ទើបមានរថយន្តទៅទទួល ៕ ប្រភព ពត៌មាន f/b ដោយ-ភិរម្យ ឥទ្ធិពល

## ប្រជាពលរដ្ឋខ្មែរចំនួន ៤៣នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 20-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៣នាក់ ស្រី ២០នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧៣នាក់

https://www.facebook.com/GDIOfficial 20-07-2020

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ចំនួន៧៣នាក់ ស្រី៣១នាក់៕

## ពលករខ្មែរនៅតែបន្តចេញពីប្រទេសថៃ ខណៈព្រំដែនប្រទេសនេះ នៅតែបន្តបិទមិនទាន់មានសញ្ញាណាមួយថាបើក នៅឡើយ

http://peoplenews.asia/ 20-07-2020

ខេត្តបន្ទាយមានជ័យ៖ ស្របពេលដែលប្រទេសថៃនៅបន្ទាត់ព្រំដែនពាក់ព័ន្ធបញ្ហាកូវីដ១៩ ហើយពលករខ្មែរនៅតែ បន្តចាកចេញពីប្រទេសនេះជាបន្តបន្ទាប់ ដោយសារប្រទេសថៃមិនទទួលស្វាគមន៍ភ្ញៀវទេសចរណ៍ណាមួយឡើយ។ ជាកើស្តែងនៅប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ ម្សិលមិញ បានឲ្យដឹងថា មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ២៩នាក់ ស្ត្រី១០នាក់ និងកុមារ ០១នាក់។ ហើយនៅថ្ងៃដដែលនេះដែរ ក៏មានពលរដ្ឋខ្មែរដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិ អូរស្មាច់ ខេត្តឧត្តរមានជ័យចំនួន ១០៧នាក់ ក្នុងនោះស្ត្រី ៤៧នាក់។ រីឯនៅប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិដូង មានប្រជាពលរដ្ឋខ្មែរបានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ចំនួន៣២ ស្រី១៦នាក់ និងកុមារ០១នាក់។

សូមជម្រាបថា ភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ គេមើលឃើញ ទន្ទឹមនឹងពលករខ្មែរចាកចេញពីប្រទេសថៃ ជបន្តបន្ទាប់ក្នុងនោះក៏មានក៏មានពលករខ្មែរមួយចំនួននៅតែបន្តព្យាយាមចូលទៅប្រទេសថៃផងដែរ ប៉ុន្តែនៅពេលធ្វើដំណើរចូលទៅប្រទេសថៃដោយខុសច្បាប់ ត្រូវបានអជ្ញាធរ និងសមត្ថកិច្ចថៃធ្វើការបង្ក្រាប និងបញ្ជូនមកវិញជាបន្តបន្ទាប់។

# ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ១៨នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 21-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៨នាក់ ស្រី ០៦នាក់ និងកុមារ ០០នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិន

ទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៣នាក់

https://www.facebook.com/GDIOfficial 21-07-2020

នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃបានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ចំនួន ១០៣នាក់ ស្រី ៤៩នាក់៕

## ពលករជាប់ពន្ធនាគារស្រុកថៃពីបទឆ្លងដែនខុសច្បាប់កាប់ឈើគ្រញូងត្រូវបានប្រគល់អោយភាគីកម្ពុជាវិញ

http://nokorwatnews.com/ 21-07-2020

ខេត្តឧត្តរមានជ័យ៖ ពលករលបលួចឆ្លងដែនដោយខុសច្បាប់ចូលកាប់ឈើគ្រញូងក្នុងទឹកដីថៃចំនួន៣នាក់ ត្រូវបាន ជាប់ពន្ធនាគារម្នាក់ៗ២ឆ្នាំទៅ៣ឆ្នាំ ត្រូវបានអាជ្ញាធរថៃ បញ្ជូនប្រគល់អោយភាគីកម្ពុជាវិញ នៅថ្ងៃទី២១ខែកក្កដាឆ្នាំ២០២០ តាមច្រកអន្តរជាតិជាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានអោយដឹងថា វេលាម៉ោង ១២៖២៤នាទី អាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែរ ០៣នាក់ តាមច្រកអន្តរជាតិជាំ មានឈ្មោះ ដូចខាងក្រោម៖

ទី១. ឈ្មោះ កង តូង ភេទប្រុស អាយុ ៤៤ឆ្នាំរស់នៅភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ (ចាប់ខ្លួនកាលពីថ្ងៃទី ១៤.១០.២០១៨)។

ទី២. ឈ្មោះ ឈុន ចាន់រី ភេទប្រុស អាយុ ៣២ឆ្នាំ រស់នៅភូមិបរក្នុង ឃុំអង្គរមាស ស្រុកជងទង់ ខេត្តកំពត (ចាប់ខ្លួនកាលពីថ្ងៃទី ១៣.០៣.២០១៨)។

ទី៣. ឈ្មោះ ឈឿម កាយ ភេទប្រុស អាយុ ៣១ឆ្នាំ រស់នៅភូមិជាយសំពៅ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ (ចាប់ខ្លួនកាលពីថ្ងៃទី ២៧.០៨.២០១៧)។

អ្នកទាំង០៣ ជាប់គុកនៅខេត្តស៊ីសាកេតប្រទេសថៃ ពីបទឆ្លងដែនខុសច្បាប់កាប់ឈើគ្រញូងក្នុងទឹកដីថៃចូលតាមច្រកវាលខ្សាច់។ដោយសមត្ថកិច្ចលម្ពជាបានធ្វើការអប់រំរួចអោយត្រឡប់ទៅស្រុកកំណើតរាងៗខ្លួន៕
ដោយ៖ប៉ែន នួន

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលរដ្ឋខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 21-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកវាលខ្សាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ពលរដ្ឋខ្មែរម្នាក់អាជ្ញាធរថៃបញ្ជូនមកស្រុកវិញបន្ទាប់ដោះលែងពីពន្ធនាគារ

https://www.rasmeinews.com/ July 21, 2020, 7:59 PM

ដោយបាយ័ន/ឧត្តរមានជ័យ៖ ពលរដ្ឋខ្មែរម្នាក់ត្រូវភាគីអាជ្ញាធរថៃបានបញ្ជូនមកស្រុកវិញបន្ទាប់ពីដោះលែងពីពន្ធនាគារពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើគ្រញូងក្នុងទឹកដីថៃ។ ពិធីប្រគល់នឹងទទួលប្រជាពលរដ្ឋខ្មែរនេះបានធ្វើឡើងនៅច្រកអន្តរជាតិជាំស្រងាំក្នុងទឹកដីស្រុកអន្លង់វែងខេត្តឧត្តរមានជ័យកាលពីវេលាថ្ងៃត្រង់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០។ សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំបាននិយាយថាពលរដ្ឋខ្មែរម្នាក់ដែលអាជ្ញាធរថៃបញ្ជូនមកស្រុកកំណើតវិញនោះគឺមានឈ្មោះ កង តួង ភេទប្រុស អាយុ៤៤ឆ្នាំ រស់នៅភូមិថ្នល់កែង ឃុំផ្អាវស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ឈ្មោះ កង តួង ត្រូវបានចាប់ខ្លួនថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៨ កន្លងទៅពីបទឆ្លងដែនកាប់ឈើក្រញូង។ ឈ្មោះនេះដោយចូលតាមច្រកវាលខ្សាច់ហើយត្រូវបានយកទៅដាក់ពន្ធនាគារនៅខេត្តស៊ីសាកេតប្រទេសថៃចាប់តាំងពីពេលនោះរហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ នេះទើបដោះលែងឱ្យមានសេរីភាព ហើយបញ្ជូនមកស្រុកកំណើតវិញ៕S/

## ពលករ១៣នាក់ ចាញ់បោកមេខ្យល់កុំតែបាន វរសេនាតូចព្រំដែនគោក ៨១៥ ឃាត់ទាន់ពេល

---

http://kampucheathmey.com/ 21/7/2020 10:47 Pm

បន្ទាយមានជ័យ ៖ តើមកពីល្បិចមេខ្យល់ខ្ពស់ ឬ យ៉ាងណាទើបធ្វើឲ្យពលករចំនួន១៣នាក់ មានស្រី៦នាក់ក្នុងនោះមានក្មេងផងដែរនោះ ត្រូវបានមេខ្យល់ប្រើល្បិចថានឹងយកទៅរកការងារកន្លែងល្អៗធ្វើនៅស្រុកថៃទាំងប្រទេសគេបិទតាមព្រំដែនសូម្បីតែសត្វចូលមិនបានផងនោះ កុំតែបាននគរបាលវរសេនាតូចព្រំដែនគោក ៨១៥ ឃាត់កំពុងធ្វើដំណើរឆ្លងកាត់តាមព្រំដែនក្នុងភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យពលករទាំង១៣នាក់ នោះបំរុងទៅរកការងារធ្វើដោយខុសច្បាប់ នៅប្រទេសថៃ ល្ងាច ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០នេះ។

លោក សួង សៅ មេបញ្ជាការ វរសេនាតូចព្រំដែនគោក ៨១៥ បានប្រាប់ឲ្យដឹងថា ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ ទោ អាត់ខែម ស្នងការនគរបាលខេត្តបន្ទាយមានជ័យ បានឲ្យកម្លាំងវរសេនាតូចព្រំដែនគោក៨១៥ទាំងអស់ ត្រូវបង្រ្កាបបទល្មើសផ្សេងៗ ពិសេសពលករលួចឆ្លងដែនតាមរយៈមេខ្យល់ទៅរកការងារខុសច្បាប់នៅស្រុកថៃឲ្យបានតឹងរ៉ឹង និងរួមគ្នាធ្វើការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីត១៩ ផងដែរ។

គួរបញ្ជាក់ផងដែរថា ដោយសារជំងឺកូវីត១៩ រាតបាតពេញពិភពលោកពិសេសប្រទេសថៃ ធ្វើឲ្យជនជាតិថៃកើតជំងឺនេះមានស្លាប់ មានឆ្លង បង្ខំឲ្យនាយករដ្ឋមន្ត្រីថៃប្រកាសប្រទេសគ្រាមានអាសន្ន រោងចក្រត្រូវបិតទាំងស្រុងពលករខ្មែរបង្ខំចិត្តចាកចេញពីស្រុក ថៃស្ទើរអស់ រហូតមកដល់សព្វថ្ងៃនេះប្រទេសថៃមិនទាន់ដំណើរការដូចមុននោះឡើយព្រោះសំអាងថា ជំងឺកូវីដ១៩ មិនទាន់បានធូរស្បើយនៅឡើយប្រជាជនថៃនៅតែមានការប្រុងប្រយ័ត្នទាំងអស់គ្នាជានិច្ច។ អ្វីៗមិនទាន់ដំណើរការនៅឡើយដូច្នេះពលករខ្មែរទាំងអស់ចង់មកធ្វើការនៅថៃប្រយ័ត្នចាញ់

បោកមេខ្យល់។ សព្វថ្ងៃនេះ សមត្ថកិច្ចថៃធ្វើការទប់ស្កាត់ពលករខ្មែរដែលលបលួចចូលឆ្លងដែនទៅធ្វើការក្នុងប្រទេសថៃខុសច្បាប់ខ្លាំងសំបើមណាស់ ដើម្បីការពារទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីឌ១៩ នេះ។

លោក សួង សៅ បានបញ្ជាក់ឲ្យដឹងទៀតថា ពលករទាំងចំនួន ១៣នាក់ស្រី ៦នាក់ ក្នុងនោះក៏មានកុមារផងពួកគាត់មកពីខេត្តចំនួន៥ គឺបន្ទាយមានជ័យ ម្នាក់បាត់ដំបង៧នាក់ ស្រី០៤នាក់ កំពង់ធំ ៣នាក់ ស្រីម្នាក់ ស្វាយរៀងម្នាក់ កំពង់ឆ្នាំងម្នាក់ ស្រីម្នាក់ និងបានបញ្ជូនពួកគាត់ទៅទីបញ្ជាការប៉ុស្តិ៍ដើម្បីសួរនាំ។ កម្លាំងប៉ុស្តិ៍ចំបក់សហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលបឹងបេង និងកម្លាំងផ្នែកសឹករងស្រុកម៉ាឡៃ បានធ្វើការអប់រំណែនាំស្តីអំពីការឆ្លងរាលដាលរបស់ COVID-19 ផលប៉ះពាល់ការធ្វើចំណាកស្រុកខុសច្បាប់ និងបានធ្វើកិច្ចសន្យាពួកគាត់បញ្ឈប់ការឆ្លងដែលខុសច្បាប់ទៀត រួចបានបញ្ជូនពួកគាត់ទៅមណ្ឌលចត្តាឡីស័កទី១ វិទ្យាល័យម៉ាឡៃ ដើម្បីពិនិត្យសុខភាពផងដែរ៕ គង្គា

## ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០

### មួយថ្ងៃពលករយ៉ាងតិច៣០នាក់ ត្រូវថៃចាប់ខ្លួននៅ៣ទីតាំងផ្សេងគ្នា

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២០ ម៉ោង ១០:៣៧ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ បើតាមសេចក្តីរាយការណ៍បានឱ្យដឹងថា ពលករខ្មែរយ៉ាងតិច៣០នាក់ត្រូវបានសមត្ថកិច្ចចម្រុះក្នុងខេត្តស្រះកែវថៃ ធ្វើការចាប់ខ្លួននៅ៣ទីតាំងផ្សេងគ្នាក្នុងស្រុកចំនួន២ កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ តើពលករទាំងនេះចេញពីកម្ពុជាតាមច្រករបៀងណា? ហើយសមត្ថកិច្ចជួរមុខកម្ពុជាធ្វើអ្វី?

បើយោងតាមការចុះផ្សាយលើគេហទំព័រកាសែតក្នុងស្រុកថៃមួយបានឲ្យដឹងថា ពលករខ្មែរចំនួន៣០នាក់ ក្នុងនោះស្រី១២នាក់ និងប្រុស១៨នាក់ ត្រូវសមត្ថកិច្ចថៃចាប់នៅស្រុកអារញ្ញ និងស្រុកតាប្រាយ៉ា ក្រោយឆ្លងព្រំដែនពីកម្ពុជា ហើយប្រុងទៅរកការងារធ្វើលើទឹកដីថៃក្រុងបាងកក, ឈុនបូរី, ប៉ាធុមថានី និងសាប៉ាក់បូរី ដែលចំណាយប្រាក់ឲ្យមេខ្យល់ម្នាក់៣០០០បាត។ ប្រភពដដែលថា ពលករចំនួន១៥នាក់ ក្នុងនោះស្រី៦នាក់ ត្រូវសមត្ថកិច្ចថៃចាប់ពី២ទីតាំងផ្សេងគ្នាក្នុងឃុំនិងស្រុកតាប្រាយ៉ា ខេត្តស្រះកែវឈមទឹកដីកម្ពុជា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

ដោយឡែកពលករចំនួន១៥នាក់ ក្នុងនោះប្រុស៩នាក់ ត្រូវសមត្ថកិច្ចថៃចាប់បាននៅចំណុចផ្លូវបំបែកខ្លងហាតវ៉ាត់ថាណាណាក់ខន ក្នុងស្រុកខ្លងហាត ខេត្តស្រះកែវ បន្ទាប់ពីទាហានព្រានថៃ បានប្រទះឃើញក្រុមពលករទាំងនេះរត់ឆ្លងផ្លូវជាប់ព្រំដែនក្នុងឃុំថាប់គ្រិក ស្រុកអារញ្ញ ខេត្តស្រះកែវ ហើយក៏រាយការណ៍ឲ្យសមត្ថកិច្ចដាក់បារ៉ាស់ត្រួតពិនិត្យរថយន្តសង្ស័យ ក៏ឃាត់បានពលករទាំងនេះ និងរថយន្តពាក់ស្លាកលេខថៃ១គ្រឿង ព្រមទាំងឃាត់ខ្លួនអ្នកបើកបររថយន្តជាស្ត្រីជនជាតិថៃម្នាក់ផងដែរ។

យ៉ាងណាក៏ដោយ ពលករទាំងអស់ និងអ្នកបើកបររថយន្តជាស្ត្រីជនជាតិថៃ ក្រោយពីឃាត់ខ្លួនបាន ត្រូវបញ្ជូនទៅស្ថានីយតម្រួតក្នុងស្រុកកើតហេតុទាំង២ខាងលើ ដើម្បីធ្វើការសាកសួរលម្អិតបន្ត៕ (កែសម្រួល៖ បុប្ផា)

### នគរបាលឃុំ២ធ្នូផ្សព្វផ្សាយអំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កម្មករចំការកៅស៊ូ

http://cambodiapolice.com/policekh/ 2:46 pm 22 កក្កដា 2020

ក្រចេះ ៖ ព្រឹកថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ២ធ្នូ សហការជាមួយលោកប្រធានភូមិ បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន នៅចំណុចចំការ

កៅស៊ូក្រុមហ៊ុន ភូមិជើងឃ្លូ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ។ ក្នុងនោះកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលបានធ្វើការផ្សព្វផ្សាយនិងចែកខិតប័ណ្ណរួមមាន៖

-ផ្សព្វផ្សាយសេចក្តីចូលរួមអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា ។

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន។

-ចែកសារសម្រាប់អប់រំអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន។

-ផ្សព្វផ្សាយអនុក្រឹត្យលេខ៣៩អនក្រ,បកចុះថ្ងៃទី១៧ ខែមិនាឆ្នាំ២០២០ស្តីពីការពិន័យអន្តរកាលចំពោះអំពើល្មើសច្បាប់ចរាចរណ៍ផ្លូវគោកថ្មី។

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ។

-ផ្សព្វផ្សាយរួមគ្នាបង្ការការប្រើអំពើហឹង្សាទាក់ទង នឹងយេនឌ័រ,អំពើជួញដូរស្ត្រីនិងកុមារ ។

-ផ្សព្វផ្សាយគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌគ្រាប់មិនទាន់ផ្ទុះ។

-ផ្សព្វផ្សាយអំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ។

-ផ្សព្វផ្សាយអំពីគ្រោះអគ្គីភ័យ និងផ្សព្វផ្សាយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលស្តីពីវិធីការការពារទប់ស្កាត់នៃការរីករាលដាលអំពីជំងឺកូវីដ១៩ផងដែរ។

នៅក្នុងនោះកម្លាំងយើងបានធ្វើការផ្សព្វផ្សាយនូវលក្ខណៈសម្បត្តិទាំង០៩យ៉ាងរបស់គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដែលមានអ្នកចូលរួមចំនួន១៨៨នាក់/ស្រីចំនួន៩៧នាក់ ៕

## តុលាការខេត្តព្រះសីហនុសម្រេចឃុំខ្លួនជនជាតិចិន ៤នាក់ និងជនជាតិរុស្ស៊ីម្នាក់ ពីបទ "សញ្ចារកម្ម"

https://www.rfa.org/khmer/ ដោយ ហេង រស្មី 2020-07-22

តុលាការខេត្តព្រះសីហនុ សម្រេចឃុំខ្លួនជនជាតិចិនចំនួន ៤នាក់ និងជនជាតិរុស្ស៊ី ម្នាក់ នៅពន្ធនាគារខេត្ត ពីបទសង្ស័យថា ពាក់ព័ន្ធ "សញ្ចារកម្ម" ក្រោយពីសមត្ថកិច្ចឆ្មក់ចូលបង្ក្រាបកន្លែងរកស៊ីផ្លូវភេទមួយកន្លែងកាលពីសប្តាហ៍មុន។

អ្នកនាំពាក្យតុលាការខេត្តព្រះសីហនុ លោក លឹម ប៊ុនហេង ប្រាប់អាស៊ីសេរី នៅថ្ងៃម្សិលមិញថា ចៅក្រមស៊ើបសួរបានសម្រេចបញ្ជូនជនសង្ស័យទាំង ៥នាក់ទៅឃុំឃាំងបណ្តោះអាសន្ន ដើម្បីរង់ចាំការជំនុំជម្រះ ហើយសមត្ថកិច្ចបានដោះលែងស្ត្រីបម្រើសេវាកម្ម និងភ្ញៀវដែលមករកសេវាកម្ម ។ សមត្ថកិច្ចខេត្តព្រះសីហនុកាលពីថ្ងៃទី ១៦ ខែកក្កដា បានឆ្មក់ចូលបង្ក្រាបទីតាំងលួចលាក់ប្រកបអាជីកម្មជួញដូរផ្លូវភេទមួយកន្លែងដែលគ្រប់គ្រងដោយជនបរទេស មានទីតាំងនៅ ក្នុងសង្កាត់លេខ២ ក្រុងព្រះសីហនុ។ក្រោយពីការបង្ក្រាបសមត្ថកិច្ចបានចាប់ខ្លួនមនុស្សចំនួន ៣០នាក់ រួមមានជនជាតិចិន ជនជាតិវៀតណាម និងជនជាតិរុស្ស៊ី។ ស្របពេល តុលាការក្រុងព្រះសីហនុ សម្រេចឃុំខ្លួនជនជាតិចិន និងរុស្ស៊ី នៅក្នុងទីក្រុងភ្នំពេញឯណោះវិញ តុលការកំពុងសាកសួរជនជាតិចិនចំនួន ១១នាក់ពាក់ព័ន្ធ នឹងករណីចាប់ជំរិតមិនបានសម្រេចទៅលើជនជាតិចិនដូចគ្នា។

សមត្ថកិច្ច នៃក្រសួងមហាផ្ទៃកាលពីថ្ងៃទី១៧ កក្កដា បានចាប់ខ្លួនជនជាតិចិនចំនួន ១១នាក់ ក្រោយពីពួកគេបានចាប់បុរសជនជាតិចិនដូចគ្នា បង្ខាំងទុកដើម្បីជំរិតទារប្រាក់ចំនួន ៣០ម៉ឺនដុល្លារ មិនបានសម្រេចពីក្រុមគ្រួសារជនរងគ្រោះ។ ប្រធានការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់នៃនាយកដ្ឋានព្រហ្មទណ្ឌក្រសួងមហាផ្ទៃ លោក ហែម ប៊ុនណា និយាយថា ជនរងគ្រោះត្រូវជនល្មើសយកបង្ខាំងទុកនៅក្នុងបន្ទប់ផ្ទះជួលមួយកន្លែងដែលមានទីតាំងនៅសង្កាត់និរោធ ខណ្ឌច្បារអំពៅ ក្រុងភ្នំពេញ។

ចាប់ពីខែមិថុនា ដល់ខែកក្កដានេះ ករណីជំរិតទារប្រាក់រវាងជនជាតិចិន និងជនជាតិចិនដូចគ្នានេះបានកើតមានឡើងចំនួនចំនួន ៣ករណីហើយគឺពីរករណីកើតមានឡើងនៅក្នុងខេត្តព្រះសីហនុ និងករណីចុងក្រោយកើតមានឡើងនៅក្នុងទីក្រុងភ្នំពេញ។ កាលពីឆ្នាំ២០១៩ សមត្ថកិច្ចខេត្តព្រះសីហនុក៏ បានចាប់បញ្ជូនខ្លួនជនជាតិចិនចំនួន ១២៧នាក់ពាក់ព័ន្ធទៅកាន់ប្រទេសចិនវិញក្រោយពីបានចាប់ខ្លួនពាក់ព័ន្ធនឹងការចាប់ជំរិតទារប្រាក់តាមប្រព័ន្ធអ៊ីនធឺណិត៕

## ភាគីថៃចាប់បញ្ជូនពលករខ្មែរ ដែលឆ្លងដែនខុសច្បាប់ចំនួន ០៤នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម

https://www.facebook.com/GDIOfficial 22-07-2020

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៦និង០០នាទី ភាគីថៃចាប់បញ្ជូនពលករខ្មែរ ដែលឆ្លងដែនខុសច្បាប់ចំនួន ០៤នាក់ មកឲ្យប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ខេត្តកោះកុង។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៤នាក់នេះ មាន ១-ឈ្មោះ មួន សុខម ភេទប្រុស អាយុ ២៩ឆ្នាំ, ២-ឈ្មោះ រុន ល័ក្ខ ភេទប្រុស អាយុ ២៥ឆ្នាំ, ៣-ឈ្មោះ គ្រឿន ក្រេង ភេទប្រុស អាយុ ២៥ឆ្នាំ ហើយអ្នកទាំង ០៣នាក់នេះ មានទីលំនៅភូមិឡ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ និង៤-ឈ្មោះ ជៀង ចាន់រិទ្ធ ភេទប្រុស អាយុ ៣៩ឆ្នាំ មានទីលំនៅភូមិត្រពាំងរាំង ឃុំល្អាង ស្រុក ឈូក ស្រុកទូកមាស ខេត្តកំពត។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការសាកសួរ អប់រំណែនាំ និងប្រគល់ឲ្យមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក ដើម្បីអនុវត្តនីតិវិធីបន្ត នូវវិធានការណ៍របស់ក្រសួងសុខាភិបាល៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៦នាក់

https://www.facebook.com/GDIOfficial 22-07-2020

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃបានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យមានចំនួន៨៦នាក់ ស្រី៣៧នាក់៕

## លោកស្រី សុំ ចិន្តា ដឹកនាំកិច្ចប្រជុំប្រចាំឆមាសទី១របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលាខេត្តបាត់ដំបង

https://www.battambang.gov.kh/ ថ្ងៃអង្គារ, 21 ខែកក្កដា, 2020ដោយ Sotheavyចំនួនទស្សនា ( 172 )

នៅរសៀលថ្ងៃអង្គារ ១កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០២០ លោកស្រី សុំ ចិន្តា អភិបាលរង នៃគណៈអភិបាលខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលហៅថា គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំប្រចាំឆមាស

ទី១ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលាខេត្តបាត់ដំបង ដែលមានការអញ្ជើញចូលរួមពីលោក លោកស្រី ប្រធាន អនុប្រធាមន្ទីរ អង្គភាពនានាជុំវិញខេត្ត លោក លោកស្រី អភិបាលរង ក្រុង ស្រុក និងអង្គការដៃគូរនានាផងដែរ ។

លោកស្រី ឈួន ផារិន អនុប្រធានមន្ទីរកិច្ចការនារីខេត្ត និងជាសមាជិកលេខាធិកាដ្ឋាន គ.ខ.ប.ជ បានអានរបាយការណ៍សង្ខេបអំពីសកម្មភាពការងារប្រចាំឆមាស ដែលបានអនុវត្តកន្លងមក ដើម្បីឱ្យអង្គពិធីពិនិត្យ និងពិភាក្សាផងដែរ។

លោកស្រី សុំ ចិន្តា បានផ្តាំផ្ញើដល់មន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុក និងអង្គការដៃគូនានា បន្តខិតខំផ្សព្វផ្សាយ និងមានវិធានការនានា ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយការលួចឆ្លងដែនខុសច្បាប់ និងការរីករាលដាលនៃការឆ្លងជំងឺកូវីដ ១៩ ចំពោះពលករ ដែលបានចំណាកស្រុកទៅក្រៅប្រទេសផងដែរ៕

## កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំស្វាយជ្រះ ចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន

http://cambodiapolice.com/policekh/ 12:15 pm 23 កក្កដា 2020

ខេត្តក្រចេះ ៖ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង៨ និង០០នាទី កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំស្វាយជ្រះ បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន នៅចំណុចសាមគ្គីភូមិថ្មល់ ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ (ក្នុងកម្មវិធីចែកមុងជូនប្រជាពលរដ្ឋរបស់មណ្ឌលសុខភាពស្វាយជ្រះ) ។ កន្លងនោះកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលបានធ្វើការផ្សព្វផ្សាយនិងចែកខិតប័ណ្ណរួមមាន ៖

១.ផ្សព្វផ្សាយសេចក្តីចូលរួមអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា។

២.ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ។

៣.ចែកសារសម្រាប់អប់រំអំពីផល់ប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន ។

៤.ផ្សព្វផ្សាយអនុក្រិត្យលេខ៣៩អនក្រ,បកចុះថ្ងៃទី១៧ ខែមិនាឆ្នាំ២០២០ស្តីពីការពិន័យអន្តរកាលចំពោះអំពើល្មើសច្បាប់ចរាចរណ៍ផ្លូវគោកថ្មី ។

៥.ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ ។

៦.ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហឹង្សាទាក់ទង នឹងយេនឌ័រ,អំពើជួញដូរស្ត្រីនិងកុមារ ។

៧.ផ្សព្វផ្សាយគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌគ្រាប់មិនទាន់ផ្ទុះ ។

៨.ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ។

៩.ផ្សព្វផ្សាយអំពីគ្រោះអគ្គីភ័យ និងផ្សព្វផ្សាយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលស្តីពីវិធីការការពារទប់ស្កាត់នៃការរីករាលដាលអំពីជំងឺកូវីដ១៩ផងដែរ ។

នៅក្នុងនោះផងដែរកម្លាំងក៏បានធ្វើការផ្សព្វផ្សាយនូវលក្ខណៈសម្បត្តិទាំង០៩យ៉ាង របស់គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ។ ដែលមានអ្នកចូលរួមចំនួន២៥៧នាក់/ស្រីចំនួន២១០នាក់ ៕

ប្រភព: ស្នងការដ្ឋាននគរបាលខេត្តក្រចេះ សម្រួលដោយ: អ.ទោ.រឿង សុវណ្ណដែត

# ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០

## សម្តេចក្រឡាហោម ស ខេង អនុញ្ញាតឱ្យ ឯកអគ្គរដ្ឋទូតប្រទេសអូស្ត្រាលីប្រចាំ នៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសហការី ចូលជួបពិភាក្សាការងារ

http://cambodiapolice.com/policekh/ 9:17 pm 23 កក្កដា 2020

**ភ្នំពេញ៖** នៅរសៀលថ្ងៃព្រហស្បតិ៍ ៣កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឱ្យឯកឧត្តម Pablo Chiho Kang ឯកអគ្គរដ្ឋទូតប្រទេសអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសហការីចូលជួបពិភាក្សាការងារ នៅទីស្តីការក្រសួងមហាផ្ទៃ។

ជាកិច្ចចាប់ផ្តើម សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលអូស្ត្រាលីដែលបានផ្តល់ការគាំទ្រតាមរយៈការចាត់បញ្ជូនអ្នកបច្ចេកទេសមកជួយក្នុងដំណើរការកសាងច្បាប់សំខាន់ៗចំនួន២ គឺច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលព្រះមហាក្សត្របានចេញព្រះរាជក្រមប្រកាសឱ្យប្រើកាលពីពេលថ្មីៗនេះ។ សម្តេចបានមានប្រសាសន៍ទៀតថា ក្រោយពីច្បាប់នេះត្រូវបានប្រកាសឱ្យប្រើហើយ គឺនៅសល់លិខិតបទដ្ឋានគតិយុត្តិក្រោមច្បាប់នេះមួយចំនួនទៀតដែលរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ ត្រូវបន្តសហការរៀបចំ ដើម្បីឈានទៅអនុវត្តច្បាប់ទាំងពីរនេះឱ្យបានពេញលេញ។

ឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលី បានសម្តែងក្តីរីករាយ ដែលរាជរដ្ឋាភិបាលកម្ពុជា សម្រេចបាននូវសមិទ្ធផលច្បាប់ចំនួនពីរនេះ និងបានជម្រាបសម្តេចទៀតថា កន្លងមករដ្ឋាភិបាលអូស្ត្រាលីក៏ធ្លាប់បានជួយលើកិច្ចការមួយចំនួនផងដែរ ជាពិសេសនៅក្នុងកាលៈទេសៈ នៃការរីករាលដាលជំងឺកូវីដ-១៩នេះ អូស្ត្រាលីបានផ្តល់ជំនួយវិស័យសុខាភិបាល និងវិស័យកសិកម្មជួយកម្ពុជា តាមរយៈអង្គការក្រៅរដ្ឋាភិបាលរបស់អូស្ត្រាលី។ ឆ្លៀតក្នុងឱកាសនេះដែរ ឯកឧត្តមបានជម្រាបជូនសម្តេចថា ជាការពិត នៅក្នុងស្ថានភាពប្រឈមនឹងជំងឺកូវីដ-១៩នេះ វិស័យមួយចំនួនដូចជាទេសចរណ៍ ឧស្សាហកម្មវាយណភ័ណ្ឌពិតជាទទួលរងផលប៉ះពាល់ ប៉ុន្តែឯកឧត្តមសូមសម្តែងនូវការកោតសរសើរចំពោះគោលនយោបាយរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់វិស័យកសិកម្ម ធ្វើយ៉ាងណាជួយជំរុញបន្ថែមដល់សេដ្ឋកិច្ចជាតិ។ ឯកឧត្តមបានបន្តថា ក្នុងនាមជាឯកអគ្គរដ្ឋទូតអូស្ត្រាលី ឯកឧត្តមពិតជារីករាយដែលបានចូលរួមអមដំណើរសម្តេចតេជោនាយករដ្ឋមន្ត្រី ចុះទៅកាន់ខេត្តតាកែវកាលពីពេលថ្មីៗនេះ ដើម្បីពិនិត្យមើលដោយផ្ទាល់ក្នុងដំណើរការជំរុញវិស័យកសិកម្មនៅក្នុងខេត្តមួយនេះ។ ឯកឧត្តមបន្តថា តាមរយៈអង្គការក្រៅរដ្ឋបាលភិបាល អូស្ត្រាលីកំពុងបន្តជួយគាំទ្រដល់វិស័យកសិកម្មនៅកម្ពុជា ពាក់ព័ន្ធនឹងការធ្វើទំនើបកម្មការប្រើប្រាស់គ្រឿងយន្ត ការបណ្តុះពូជ និងការកម្ចាត់សត្វល្អិតជាដើម ដើម្បីឈានទៅបង្កើនទិន្នផលកសិកម្មស្រូវ និងជំរុញការនាំចេញអង្ករក្រអូបទៅកាន់អូស្ត្រាលីឱ្យកាន់តែច្រើន។ ក្រៅពីកិច្ចការទាំងនេះឯកឧត្តមឯកអគ្គរដ្ឋទូតបានជម្រាបសម្តេចទៀតថា រដ្ឋាភិបាលអូស្ត្រាលី ក៏បានសហការជាមួយក្រសួងផែនការ ក្នុងការគាំទ្រដល់ដំណើរការរៀបចំបញ្ជីប្រជាជនក្រីក្រ ដែលកិច្ចការនេះកំពុងតែប្រព្រឹត្តទៅយ៉ាងប្រសើរ។

ដោយឡែកពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការកម្លាំងអនុវត្តច្បាប់ ឯកឧត្តមឯកអគ្គរដ្ឋទូតបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន រួមមានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្នុងនោះក៏មានការផ្តល់ជំនួយបណ្តុះបណ្តាលដល់មន្ត្រីអន្តោប្រវេសន៍កម្ពុជាពាក់ព័ន្ធនឹងការងារត្រួតពិនិត្យឯកសារលិខិតឆ្លងដែនដែរ។ ឯកឧត្តមបានបង្ហាញភាពរីករាយចំពោះវឌ្ឍនភាព និងលទ្ធផលដែលទទួលបានតាមរយៈកិច្ចសហប្រតិបត្តិការដែលមានលើវិស័យនគរបាលនេះហើយសម្រាប់ច្បាប់ទាំងពីរដែលរាជរដ្ឋាភិបាលសម្រេចបាននោះ ឯកឧត្តមពិតជាចង់ឃើញការអនុវត្តច្បាប់បានពេញលេញ។ ឯកឧត្តមក៏បានបង្ហាញឆន្ទៈបន្តគាំទ្រ

ដល់ការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ ដើម្បីឈានទៅអនុវត្តច្បាប់នេះរួមទាំងផ្តល់ការបណ្តុះបណ្តាលមន្ត្រីកម្ពុជាក្នុងការចាត់តាំងអនុវត្តភាពកិច្ចស្របតាមច្បាប់ទាំងពីរនេះផងដែរ។

ជាការឆ្លើយតបសម្តេចក្រឡាហោមបានមានប្រសាសន៍ថ្លែងអំណរគុណជាថ្មីម្តងទៀតដល់រដ្ឋាភិបាលអូស្រ្តាលី ដែលបានផ្តល់អ្នកបច្ចេកទេសរៀបចំច្បាប់ទាំងពីរនេះ ពីព្រោះច្បាប់ទាំងពីរនេះមានសារៈសំខាន់ណាស់សម្រាប់កម្ពុជា និងក៏ជាការចូលរួមចំណែកជាលក្ខណៈអន្តរជាតិក្នុងការងារទប់ស្កាត់ហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងការរីកសាយភាយអាវុធមហាប្រល័យដែរ។ សម្តេចបានបង្ហាញការស្វាគមន៍បន្តទៀតចំពោះក្រុមអ្នកជំនាញអូស្រ្តាលីសម្រាប់ការចូលរួមដល់កិច្ចការកសាងឯកសារគតិយុត្តក្រោមច្បាប់ទាំងពីរនេះ និងបានឯកភាពចំពោះការវាយតម្លៃរបស់ឯកឧត្តមពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការរវាងកម្លាំងអនុវត្តច្បាប់ នៃប្រទេសទាំងពីរនាពេលកន្លងមក។ សម្តេចបានស្នើឱ្យភាគីអូស្រ្តាលីបន្តជួយពង្រឹងដល់សមត្ថភាពមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំសង្កាត់ និងអធិការដ្ឋាននគរបាលឱ្យកាន់តែមានសមត្ថភាពរឹងមាំក្នុងការបំពេញភារកិច្ច ខណៈភាគីអូស្រ្តាលីធ្លាប់ជួយការងារជាបន្តបន្ទាប់។ សម្តេចសង្ឃឹមថាកម្លាំងនគរបាលប្រទេសទាំងពីរនឹងបន្តកិច្ចសហប្រតិបត្តការល្អជាមួយគ្នាបន្ថែមទៀត ដើម្បីការពារបន្តទៀតនូវប្រយោជន៍របស់ប្រជាពលរដ្ឋ និងប្រទេសទាំងពីរ៕

## ឯកឧត្តម នាក់ ណេរ៉ុន ចុះសួរសុខទុក្ខ និងចែកអំណោយដល់ប្រជាពលរដ្ឋកំពុងស្នាក់នៅមណ្ឌលចត្តាឡីស័កចំនួន ០២ស្រុក

http://cambodiapolice.com/policekh/ 5:00 pm 23 កក្កដា 2020

**សៀមរាប៖** នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ ឯកឧត្តម នាក់ ណេរ៉ុន អភិបាលរងខេត្ត តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ទៀ សីហា អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងប្រតិភូអមដំណើរបានចុះសួរសុខទុក្ខ និងចែកអំណោយដល់បងប្អូនប្រជាពលរដ្ឋដែលកំពុងស្នាក់នៅមណ្ឌលចត្តាឡីស័ក ចំនួន០២ស្រុក បានទទួលអំណោយក្រោមការយកចិត្តទុកដាក់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល ក៏ដូចអាជ្ញាធរខេត្តសៀមរាប ចំពោះបងប្អូនដែលបានវិលត្រឡប់មកពីក្រៅប្រទេស ចំនួន៤៦នាក់ បានកំពុងស្នាក់នៅមណ្ឌលចត្តាឡីស័ក នៅវិទ្យាល័យក្រឡាញ់ ស្រុកក្រឡាញ់ ចំនួន៣៣នាក់ និង នៅមណ្ឌលចត្តាឡីស័កសាលាបឋមសិក្សាប្រិយ៍ ឃុំប្រិយ៍ ស្រុកស្រីស្នំ ចំនួន១៣នាក់ ក្នុងរយៈពេល១៤ថ្ងៃ នៅកន្លែងពីរផ្សេងគ្នានាថ្ងៃតែមួយ ក្រោមកិច្ចសហការជាមួយអង្គការ IOM។

តាមសេចក្តីរាយការណ៍របស់លោកអភិបាលរងស្រុកក្រឡាញ់ បានឲ្យដឹងថា ចាប់ពីការផ្ទុះឡើងនៃជំងឺកូវីដ-១៩នេះ ប្រជាពលរដ្ឋធ្វើចំណាកស្រុក បានវិលត្រឡប់មកស្រុកកំណើតវិញមកដល់ពេលនេះ មានចំនួនសរុប ៣ពាន់៧៤៥នាក់ ស្រី ចំនួន១ពាន់៧១៦នាក់ ហើយបានកំពុងធ្វើចត្តាឡីស័ក ចំនួន៣៣នាក់ ស្រី១៣នាក់ និងបានឆ្លងកាត់ធ្វើចត្តាឡីស័ក វិលទៅកាន់ភូមិដ្ឋាន មានចំនួន៨៣០នាក់។

ចំពោះសេចក្តីរាយការណ៍របស់លោកអភិបាលស្រុកស្រីស្នំក៏បានឲ្យដឹងផងដែរថាចាប់ពីមានការផ្ទុះឡើងនៃជមងឺកូវីដ១៩នេះ ប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅក្រៅប្រទេសមានចំនួនសរុប៤ពាន់៥៨០នាក់ ហើយបានវិលមកកាន់ភូមិដ្ឋានខ្លួនវិញ មានចំនួនសរុប១ពាន់៨៧០នាក់ និងកំពុងធ្វើចត្តាឡីស័ក នៅតាមបណ្តាឃុំ ចំនួន៣៣នាក់ ដោយឡែកនៅក្នុងមណ្ឌលចត្តាឡីស័កសាលាបឋមសិក្សាប្រយ៍ ចំនួន១៣នាក់ ស្រី៧នាក់ផងដែរ។

មានប្រសាសន៍សំណេះសំណាលនាឱកាសនោះឯកឧត្តម នាក់ ណេរ៉ុន ក៏បានកោតសរសើរចំពោះបងប្អូនដែលចូលមកក្នុងប្រទេសវិញនាពេលនេះ ដោយសហការល្អជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីដាក់ខ្លួនឲ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ ក្នុងការបង្ការការពារជម្ងឺឆ្លងកូវីដ១៩ កុំឲ្យមានការឆ្លងទៅអ្នកដទៃ និងសហគមន៍ខ្លួន។ ទន្ទឹមនឹងនេះឯកឧត្តម ក៏បានផ្សព្វផ្សាយ ពីសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ១៣៩៦ សជណ ស្តីពីការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរ កុំឲ្យឆ្លងដែនដោយខុសច្បាប់ ចូលទៅប្រទេសជិតខាង តាមច្រករបៀងនានា ជូនដល់បង

ប្អូនទាំងអស់ដែលកំពុងធ្វើចត្តាឡីស័ក នៅតាមមណ្ឌលនៃស្រុកក្រឡាញ់ និងស្រីស្នំនេះ សុំឲ្យបងប្អូនកុំឲ្យចាញ់ឧបាយកលបោកប្រាស់របស់មេខ្យល់ ដោយបាននាំឆ្លងដែរខុសច្បាប់ទៅប្រទេសជិតខាងដោយខុសច្បាប់ក្នុងខណៈពេលដែលប្រទេសជិតខាងបានកំពុងដាក់ប្រទេសក្នុងគ្រាអាសន្ន ដើម្បីបង្កាទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ ១៩។

ឯកឧត្តម នាក់ ណេរ៉ុន ក៏បានលើកឡើងថា បច្ចុប្បន្ននេះ បញ្ហាជម្ងឺកូវីដ១៩ នៅកម្ពុជា បានកំពុងនាំចូលមកពីក្រៅប្រទេស តាមរយៈការវិលត្រឡប់របស់បងប្អូនប្រជាពលរដ្ឋមួយចំនួន ក្នុងពេលថ្មីៗនេះ ហើយក៏ជាភាពក្តៅគគុកនៅលើពិភពលោកនៅតែបន្តរីករាលដាល។ ទោះបីនៅកម្ពុជាយើងពុំមានអ្នកស្លាប់ដោយជម្ងឺឆ្លងកូវីដ១៩ក៏ដោយ ក៏យើងទាំងអស់គ្នាសហការគ្នាប្រយុទ្ធប្រឆាំងបង្កាទប់ស្កាត់នូវជំងឺឆ្លងកូវីដ១៩ តាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ព្រមទាំងសូមឲ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់ មិនត្រូវបន្ធូរបន្ថយនោះឡើយ គឺបង្កើននូវការប្រុងប្រយ័ត្នខ្ពស់ចំពោះរលកទី២នៃជម្ងឺកូវីដ១៩ កុំឲ្យមានការរីករាលដាល់នៅក្នុងសហគមន៍ខ្លួន។ ឯកឧត្តម ក៏បានផ្តាំផ្ញើដល់បងប្អូនទាំងអស់ ដើម្បីជៀសនូវជំងឺឆ្លងនេះបាន ចូលយើងរាល់គ្នាត្រូវតែសម្អាតអនាម័យ និងថែរក្សាសុខភាពរបស់ខ្លួនឲ្យបានជាប្រចាំ ស្របតាមការណែនាំរបស់ក្រសួងសុខាភិបាល គឺត្រូវលាងដៃនឹងទឹកសាប៊ូ អាល់កុល ដែលនិងត្រូវពាក់ម៉ាស់ឲ្យបានត្រឹមត្រូវ ព្រមទាំងរក្សាឲ្យបាននូវគម្លាតពីគ្នានិងអនុវត្តទៅតាមការណែនាំរបស់ក្រសួងសុខាភិបាលឲ្យបានជាប្រចាំផងដែរ។

អំណោយដែលនាំយកទៅចែកជូនបងប្អូនកំពុងស្នាក់នៅមណ្ឌលចត្តាឡីស័កទាំងពីរស្រុក ដោយម្នាក់ៗទទួលបាន ចំនួន១៣មុខ មាន ប្រាសដុសធ្មេញ, ថ្នាំដុសធ្មេញ, សាប៊ូលុច្ស, សាប៊ូកក់សក់Clear, សាប៊ូម្សៅLix Lemon, កន្ទេល, មុង ភួយ, អាវយឺត, ខោខ្លី, កន្សែងពោះគោ, ស្បែកជើងផ្ទាត់ និង សំឡីអនាម័យផងដែរ ៕

## កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលជ្រោយបន្ទាយ ចុះធ្វើការផ្សព្វផ្សាយប្រជាពលរដ្ឋ ស្តីពី គោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព

http://cambodiapolice.com/policekh/ 3:57 pm 23 កក្កដា 2020

ខេត្តក្រចេះ៖ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលជ្រោយបន្ទាយ បានចុះធ្វើការផ្សព្វផ្សាយនៅតាមខ្នងផ្ទះចំណុចអូរអង្គុញក្រោយភូមិខ្សាច់ទប់ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។ ដោយការចុះផ្សព្វផ្សាយនោះរួមមាន ៖

១.ច្បាប់ចរាចរណ៍លេខ៣៩អនក្រ

២.ផលប៉ះពាល់នៃគ្រឿងញៀន៩ចំណុច

៣.ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ

៤.គ្រោះអគ្គីភ័យផ្សេងៗ

៥.ការជួញដូរស្ត្រីភេទ និងកុមារ

៦.គ្រោះថ្នាក់អាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៧.អ្នកដែរមានគោយន្តកន្ត្រៃ និងយានយន្តគ្រប់ប្រភេទពេលបើកបរត្រូវប្រុងប្រយ័ត្នដល់ផ្លូវបត់ ឬផ្លូវកោងត្រូវបន្ថយល្បឿន(ពិសេសពេលស្រវឹងស្រាហាមមិនឱយធ្វើដំណើរ)ជៀសវាងកុំឱយមានគ្រោះថ្នាក់ចរាចរណ៍ហើយត្រូវប្រុងប្រយ័ត្នអំពីជំងឺកូវីត១៩នៅពេលខាងមុខ និងបានណែនាំពួកគាត់ឱយថែរក្សារទ្រព្យសម្បត្តិផ្ទាល់ខ្លួនដូចជាសត្វគោក្របី និងសម្ភារះផ្សេងៗឲ្យបានត្រឹមត្រូវជៀសវាងចោរលួចហើយបានពន្យល់ណែនាំពួកគាត់ឲ្យមានអនាម័យល្អដើម្បីជៀសវាងកើតជំងឺផ្សេងៗទៀត ។

កម្លាំងបានចំនួន ០៩ខ្នងផ្ទះ មានមនុស្សចូលរួម ២៧នាក់ ស្រី១៦នាក់ បានចែកខិតប័ណ្ណជូនពួកគាត់ចំនួន ២៧សន្លឹក ៕ ប្រភព: ស្នងការដ្ឋាននគរបាលខេត្តក្រចេះ សម្រួលដោយ: អ.ទោ.រឿង សុវណ្ណដែត

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានពលករខ្មែរឆ្លងដែនខុសច្បាប់ ពីអាជ្ញាធរថៃចំនួន ២៩នាក់

https://www.facebook.com/GDIOfficial 23-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ២៩នាក់ ស្រី ០៤នាក់ និងកុមារ ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរ ចំនួន ៤៨នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 23-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៨នាក់ ស្រី ២០នាក់ និងកុមារ ០៤នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្រ្តីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៨នាក់

https://www.facebook.com/GDIOfficial 23-07-2020

នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃបានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ចំនួន ៦៨នាក់ ស្រី ៣០នាក់៕

## ពលករជាង២ម៉ឺននាក់បញ្ជូនមកវិញ ក្រោយថៃបិទព្រំដែនដោយសារកូវីដ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០២០ ម៉ោង ១០:៤០ មុំត សារុន

ខេត្តបន្ទាយមានជ័យ ៖ ភាគីថៃបានបញ្ជូនពលករខុសច្បាប់ដែលចាប់លើទឹកដីគេប្រគល់ឲ្យភាគីកម្ពុជាតាមច្រកអន្តរជាតិ, ច្រកតំបន់ និងច្រកកិច្ចព្រមព្រៀង(ច្រកអូរបីជាន់)ក្នុងខេត្តបន្ទាយមានជ័យជាង២ម៉ឺននាក់គិតចាប់ពីពេលដែលភាគីថៃបិទព្រំដែនទប់ស្កាត់មេរោគកូវី១៩ កាលពីចុងខែមីនា រហូតដល់ថ្ងៃទី២២ កក្កដា ឆ្នាំ២០២០នេះ។ ពលករខុសច្បាប់ដែលភាគីថៃបញ្ជូនត្រឡប់ឲ្យអាជ្ញាធរនិងសមត្ថកិច្ចកម្ពុជាក្នុងខេត្តបន្ទាយមានជ័យភាគច្រើនតាមច្រកកិច្ចព្រមព្រៀងរវាងខេត្តបន្ទាយមានជ័យនិងខេត្តស្រះកែវ គឺច្រកអូរបីជាន់ ស្ថិតក្នុងភូមិឃុំអូរបីជាន់ ស្រុកអូរជ្រៅ និងមួយចំនួនតូចបញ្ជូនតាមច្រកអន្តរជាតិប៉ោយប៉ែតនិងច្រកតំបន់ម៉ាឡៃ ។ នេះបើតាមកាឲ្យដឹងពីសមត្ថកិច្ចជំនាញ។

លោកវរសេនីយ៍ទោ ជា លាងហួរ នាយរងការិយាល័យប្រឆាំងកាជួញដូរនិងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តប្រាប់តាមទូរស័ព្ទថា ចំនួនពលករបញ្ជូនពីថៃក្នុងអំឡុងពេលផ្ទុះជំងឺកូវីដ១៩ ពោលគឺចាប់តាំងពីភាគីថៃបិទព្រំដែនទប់ស្កាត់មេរោគកូវីត១៩ រហូតមកដល់ថ្ងៃទី២២ កក្កដា ឆ្នាំ២០២០ មានចំនួន២៥.៧៨៧នាក់ ក្នុងនោះស្ត្រីមានចំនួន១០.១១៨នាក់ និងកុមារចំនួន២.៤១១នាក់។ នាយរងការិយាល័យរូបនេះបានបញ្ជាក់ថា ចំនួនពលករទាំងនេះបញ្ជូនពីថៃតាមច្រករបៀងអូរបីជាន់ ដែលជាច្រកកិច្ចព្រមព្រៀងរវៀងខេត្តទាំង២កម្ពុជា-ថៃ បន្ទាយមានជ័យ-ស្រះកែវ ច្រើនជាងគេ និងមួយចំនួនបញ្ជូនតាមច្រកតំបន់ម៉ាឡៃ និងច្រកអន្តរជាតិប៉ោយប៉ែត៕ (កែសម្រួលដោយ ៖ ធីតា)

## ថៃចាប់ពលករខ្មែរ-អ៊ិស្លាម២៦នាក់ ចោទទៅមានច្បាប់ មកវិញម៉ាង!

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០២០ ម៉ោង ០៩:២៨ មុំត សារុន

បន្ទាយមានជ័យ ៖ ខ្មែរអ៊ិស្លាម២៦នាក់ ត្រូវសមត្ថកិច្ចថៃចាប់ខ្លួននៅបន្ទាត់ព្រំដែនក្រោយធនាគារថៃផានីតសាខាផ្សាររុងក្លឿ ស្ថិតនៅផ្សាររុងក្លឿ ស្រុកអារញ្ញ ខេត្តស្រះកែវ កាលពីរសៀលថ្ងៃទី២៣ កក្កដា ២០២០ ។ ក្រោយពីវិលត្រឡប់ពីម៉ាឡេស៊ី ព្រោះសម័យកូវីតអត់ការងារធ្វើ ។ ជនជាតិខ្មែរអ៊ិស្លាម មានប្រុស៧នាក់ ស្រី១២នាក់ កុមារ៧នាក់ នេះបើយោងតាមកាចុះផ្សាយរបស់គេហទំព័រកាសែតក្នុងស្រុកថៃមួយ។

តាមកាសាកសួរ និងពិនិត្យឯកសាជាក់ស្តែងខ្មែរអ៊ីស្លាមទាំងនេះ ប្រើប្រាស់លិខិតឆ្លងដែនត្រឹមត្រូវគ្រប់គ្នា ហើយបានចេញពីកម្ពុជា ទៅធ្វើការសំណង់នៅប្រទេសម៉ាឡេស៊ីអំឡុង ដើមឆ្នាំ២០២០។ ពួកគាត់ប្រាប់ថា ដោយសារមេរោគកូវីត-១៩ ការងារត្រូវបិទជាច្រើនខែ ក៏នាំគ្នាវិលត្រឡប់ពីប្រទេសម៉ាឡេស៊ី ដោយឆ្លងដែនខុសច្បាប់ជិះរថយន្តចូលក្រុងបាងកក និងបន្តដំណើរដោយរថយន្តទូចំនួន២គ្រឿង មកផ្សាររុងក្លឿ ក្នុងបំណងវិលត្រឡប់មកស្រុកកំណើត ប៉ុន្តែខណៈកំពុងអង្គុយសម្រាកក្រោយធនាគារថៃផានីតសាខាផ្សាររុងក្លឿមិនទាន់រកច្រកឆ្លងព្រំដែនផង ត្រូវសមត្ថកិច្ចថៃចាប់ខ្លួនតែម្តង។ ពលករទាំងនេះ ត្រូវគេយកទៅសាកសួរនៅបន្ទាយទាហានព្រាន១២០១ក្បែរផ្សាររុងក្លឿ រួចបញ្ជូនឲ្យស្ថានីយតម្រួតខ្លងលឹក ដើម្បីចាត់ការបន្ត ។ ក្រោយពិនិត្យយ៉ាងល្អិតល្អន់ សមត្ថកិច្ចថៃប្រាប់ពលករអ៊ីស្លាមទាំងនេះថា ដ្បិតគ្រប់គ្នាពេលចេញពីកម្ពុជា ទៅម៉ាឡេស៊ីបានប្រថាប់ត្រាឯកសារនៅព្រំដែនថៃត្រឹមត្រូវ តែការវិលត្រឡប់ពីម៉ាឡេស៊ីវិញ មិនបានប្រថាប់ត្រាឯកសាចូលប្រទេសថៃជាអំពើខុសច្បាប់៕

# ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០

## នគរបាលព្រំដែននៅស្រុកម៉ាឡៃចុះល្បាតទប់ស្កាត់មិនឲ្យពលករខ្មែរឆ្លងដែនចូលប្រទេសថៃខុសច្បាប់ ដោយបានឃាត់ជំណើរពលករជាង១០នាក់

http://peoplenews.asia/ ដោយ សុខ សាន្ត ថ្ងៃទី25 ខែ07 ឆ្នាំ2020 ម៉ោង 1 និង 30នាទី

បន្ទាយមានជ័យ៖ ពលករខ្មែរដែលប៉ុនប៉ងឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់នោះមានក្មេង ចាស់ ប្រុស ស្រី ជាង១០នាក់ ត្រូវបានកម្លាំងនគរបាលវរព្រំដែនគោកលេខ ៨១៥ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បន្តល្បាតឃាត់ និងទប់ស្កាត់ទាន់ពេលវេលា ក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងបានអប់រំឲ្យពួកគេវិលទៅកាន់លំនៅឋានរៀងៗខ្លួនវិញ។

លោក សួង សៅ មេបញ្ជាការនគរបាលវរព្រំដែនគោកលេខ ៨១៥ បានចាត់កងកម្លាំងចុះល្បាតតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ចាប់ពីចំណុច ០២២០០៣១-១៥០០៨៧២ (IN1960) ស្ថិតក្នុងភូមិចាន់គីរី ដល់ចំណុច ០២១៧៧៩៦-១៥០១៣៣៨(IN1960)ស្ថិតក្នុងភូមិកណ្តាល ឃុំអូរស្រឡៅ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ ដោយឡែក កម្លាំងប៉ុស្តិ៍ស្ថានម៉ាឡៃបានចុះល្បាតត្រួតពិនិត្យតាមខ្សែបន្ទាត់ព្រំដែនចាប់ពីចំណុច (IN1960) ០២១៧៨៤៨-១៥០១២៥៦ ក្នុងភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ដល់ចំណុច (IN1960) ០២១៨៩៩៨-១៥០១៦៧៨ កនុងភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ។

លោក សួង សៅ បានគូសបញ្ជាក់ថា ការចុះល្បាតជាប្រចាំរបស់កម្លាំងនគរបាល គឺក្នុងគោលបំណងទប់ស្កាត់បទល្មើសផ្សេងៗ ដែលកើតមានឡើងតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ជាពិសេសទប់ស្កាត់ពលករខ្មែរមិនអនុញ្ញាតឲ្យឆ្លងដែនចូលទៅក្នុងទឹកដីថៃខុសច្បាប់ ខណៈនៅប្រទេសថៃពេលនេះកំពុងទប់ស្កាត់ជម្ងឺកូវីដ-១៩។ ជាមួយគ្នានេះ លោក សួង សៅ ក៏បានផ្តាំផ្ញើដល់ពលករខ្មែរទាំងជាង១០នាក់ កុំឲ្យចាញ់បោកមេខ្យល់បន្តទៀត ខណៈបច្ចុប្បន្នការឆ្លងដែនចូលទៅក្នុងដីថៃ គឺមិនអនុញ្ញាតឡើយ។ បន្ថែមពីនេះរថយន្តតាក់ស៊ីនៅប្រទេសថៃ ក៏មិនហ៊ានដឹកពលករខ្មែរនោះឡើយ ព្រោះបើរថយន្តតាក់ស៊ីណាហ៊ានដឹកបនុស្សដោយគ្មានការពិនិត្យសុខភាពត្រឹមត្រូវនឹងរងនូវការផាកពិន័យ។ លោកមេបញ្ជាការ ក៏មិនភ្លេចផ្តាំផ្ញើដល់កងកម្លាំងត្រូវខំយកចិត្តទុកដាក់ អនុវត្តបទបញ្ជារបស់ថ្នាក់លើដែលបានណែនាំ និងអប់រំដល់ប្រជាពលរដ្ឋ ត្រូវការពារសុខភាព រក្សាអនាម័យ តាមការណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីចៀសផុតពីជម្ងឺកូវីដ-១៩។

## នគរបាលប៉ុស្តិ៍ឃ្សឹមចុះផ្សព្វផ្សាយអប់រំអំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

http://cambodiapolice.com/policekh/ 2:21 pm 25 កក្កដា 2020

ក្រចេះ ៖ ព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃ្សឹម នៃអធិការនៃអធិការដ្ឋាននគរបាលស្រុកស្នួល បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមខ្នងផ្ទះ អំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀននៅចំណុច១០១-១០២ ភូមិមិល ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ។ ក្នុងនោះកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលបានធ្វើការផ្សព្វផ្សាយនិងចែកខិតប័ណ្ណរួមមាន៖

-ផ្សព្វផ្សាយសេចក្តីចូលរួមអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា។

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន។

-ចែកសារសម្រាប់អប់រំអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន។

-ផ្សព្វផ្សាយអនុក្រិត្យលេខ៣៩អនក្រ,បកចុះថ្ងៃទី១៧ ខែមិនាឆ្នាំ២០២០ស្តីពីការពិន័យអន្តរកាលចំពោះអំពើល្មើសច្បាប់ចរាចរណ៍ផ្លូវគោកថ្មី។

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ។

-ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហឹង្សាទាក់ទង នឹងយេនឌ័រ,អំពើជួញដូរស្ត្រីនិងកុមារ ។

-ផ្សព្វផ្សាយគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

-ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ។

-ផ្សព្វផ្សាយអំពីគ្រោះអគ្គីភ័យ និងផ្សព្វផ្សាយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលស្តីពីវិធីការការពារទប់ស្កាត់នៃការរីករាលដាលអំពីជំងឺកូវីដ១៩ផងដែរ ។

-ផ្សព្វផ្សាយនូវលក្ខណៈសម្បត្តិទាំង០៩យ៉ាងនៃគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ។ ក្នុងយុទ្ធនាការនេះ បានចំនួន៣៥ខ្នង ដែលមានប្រជាពលរដ្ឋចូលរួមចំនួន ៨៥នាក់ /ស្រីចំនួន៦០នាក់ ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានពលករខ្មែរឆ្លងដែនខុសច្បាប់ ពីអាជ្ញាធរថៃចំនួន ១០នាក់

https://www.facebook.com/GDIOfficial 26-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១០នាក់ ស្រី ០៧នាក់ និងកុមារ ០០នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរចំនួន ០៣នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមស្លាបស្តាំរបស់ប៉ុស្តិ៍ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្បូងដី

https://www.facebook.com/GDIOfficial 26-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្បូងដី នារសៀលថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរបានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមស្លាបស្តាំរបស់ប៉ុស្តិ៍ចំនួន ០៣នាក់ ស្រី ០២នាក់។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ និងសហការប្រគល់ជូនទៅមន្ត្រីចត្តាលីស័ក ដើម្បីធ្វើការពិនិត្យកំដៅ និងអនុវត្តតាមនីតិវិធីបន្ត។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ និងអន្តរជាតិ ចូល-ចេញ ឆ្លងកាត់នៅឡើយទេ ចំពោះរថយន្តដឹកជញ្ជូនទំនិញ គឺអនុញ្ញាតឲ្យចូល-ចេញ ជាធម្មតា៕

## ៦ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៩នាក់ ស្រី ២៥នាក់

https://www.facebook.com/GDIOfficial 26-07-2020

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ

បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យមានចំនួន៥៩នាក់ ស្រី២៥នាក់៕ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤០នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 25-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤០នាក់ ស្រី ១៤នាក់ និងកុមារ ០៨នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៦នាក់

https://www.facebook.com/GDIOfficial 25-07-2020

នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យមានចំនួន ៨៦នាក់ស្រី ៤២នាក់៕

## ពលរដ្ឋខ្មែរចំនួន ០២នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមស្លាបស្តាំរបស់ប៉ុស្តិ៍ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្នំដី

https://www.facebook.com/GDIOfficial 25-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្នំដី នារសៀលថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរបានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមស្លាបស្តាំរបស់ប៉ុស្តិ៍ចំនួន ០២នាក់ ស្រី ០១នាក់។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ និងសហការប្រគល់ជូនទៅមន្ត្រីចត្តាលីស័ក ដើម្បីធ្វើការពិនិត្យកំដៅ និងអនុវត្តតាមនីតិវិធីបន្ត។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ និងអន្តរជាតិ ចូល-ចេញ ឆ្លងកាត់នៅឡើយទេ ចំពោះរថយន្តដឹកជញ្ជូនទំនិញ គឺអនុញ្ញាតឲ្យចូល-ចេញ ជាធម្មតា៕

## ពលរដ្ឋខ្មែរចំនួន ០៣នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមស្លាបស្ពាំរបស់ប៉ុស្តិ៍ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី

https://www.facebook.com/GDIOfficial 24-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី នារសៀលថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរបានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមស្លាបស្ពាំរបស់ប៉ុស្តិ៍ចំនួន ០៣នាក់ ស្រី ០១នាក់។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ និងសហការប្រគល់ជូនទៅមន្ត្រីចត្តាលីស័ក ដើម្បីធ្វើការពិនិត្យកំដៅ និងអនុវត្តតាមនីតិវិធីបន្ត។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ និងអន្តរជាតិ ចូល-ចេញ ឆ្លងកាត់នៅឡើយទេ ចំពោះរថយន្តដឹកជញ្ជូនទំនិញ គឺអនុញ្ញាតឲ្យចូល-ចេញ ជាធម្មតា៕

## ពលរដ្ឋខ្មែរចំនួន ៧៤នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមស្លាបស្ពាំរបស់ប៉ុស្តិ៍ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី

https://www.facebook.com/GDIOfficial 24-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៧៤នាក់ ស្រី ២៧នាក់ និងកុមារ ១០នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៨នាក់

https://www.facebook.com/GDIOfficial 24-07-2020

នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៨នាក់ ស្រី ៣៤នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

## មេបញ្ជាការរងយោធភូមិភាគទី៥ ពង្រឹងកងកម្លាំងការងារសន្តិសុខតាមព្រំដែន និងដាស់តឿនឲ្យនាំគ្នាទប់ស្កាត់កូវីដ១៩

http://www.freshnewsasia.com/ 2020-07-27 12:47pm

**(បន្ទាយមានជ័យ)៖** ឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការរងយោធភូមិភាគទី៥ ទទួលទិសទី១ ខេត្តខេត្តបន្ទាយ បានថ្លែងប្រាប់ដល់កងកម្លាំង ត្រូវប្រតិបត្តិពង្រឹងការងារសន្តិសុខតាមបណ្តោយព្រំដែន និងដាស់តឿនកងកម្លាំង ឲ្យយកចិត្តដាក់នាំគ្នាទប់ស្កាត់កូវីដ១៩។ លោកថ្លែងបែបនេះ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ក្នុងពិធីចុះទស្សនកិច្ចសិក្សាការងារកសាងពង្រឹងក្នុងអង្គភាពតំបន់ប្រតិបត្តិការផ្នែកសឹករងក្រុងប៉ោយប៉ែត។ ពិធីនេះធ្វើឡើងនៅភូមិទួលពង្រ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយមានការចូលរួមពីឧត្តមសេនីយ៍ត្រី ជឹម ប៊ុនអាន មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តបន្ទាយមានជ័យ, ឧត្តមសេនីយ៍ត្រី យូន ជឿន មេបញ្ជាការកងការពារព្រំដែន៥០៣ យោធភូមិភាគទី៥, លោក គាត់ ហ៊ុល អភិបាលក្រុងប៉ោយប៉ែត, វរៈសេនីយ៍ទោ ឡេង ហុងលៀង មេបញ្ជាការសឹងរងក្រុងប៉ោយប៉ែត, និងមន្ត្រីរាជការ ស្ថាប័នពាក់ព័ន្ធកងកម្លាំងកងកម្លាំងជាច្រើនរូបទៀត។

ក្នុងឱកាសនោះឧត្តមសេនីយទោ ឈុន ម៉ៅ បានសំណូមពរឲ្យកងកម្លាំងត្រូវខិតខំយកចិត្តទុកដាក់អនុវត្តន៍បន្តចំពោះការងារថ្នាក់លើបានដាក់ចេញ ត្រូវចេះសាមគ្គីភាពគ្នាក្នុងអង្គភាព គោរពបទបញ្ជាផ្ទៃក្នុងរបស់អង្គភាព។ ជាពិសេស ត្រូវចេះសហការជាមួយប្រទេសជិតខាង នាំគ្នាទប់ស្កាត់កូវីដ១៩ ទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ ពេលយប់ និងពេលថ្ងៃឲ្យខានតែបាន នាំគ្នាទប់ស្កាត់រាល់បទល្មើសផ្សេងៗ ដែលកើតមានឡើងតាមបណ្តោយព្រំដែនកម្ពុជាថៃ និងជួយសម្រួលដល់កសិករ ការនាំកសិផលយកទៅលក់តាមច្រកតំបន់ផ្សេងៗផងដែរ។

វរៈសេនីយ៍ទោ ឡេង ហុងលៀង បានឡើងអានរបាយការ ការងាររបស់អង្គភាពដែលបានអនុវត្តរយៈកន្លងមកឃើញថា ចំពោះការងារនៅក្នុងអង្គភាពផ្នែកសឹករងក្រុងប៉ោយប៉ែត មានការរីកចម្រើនលើគ្រប់វិស័យអង្គភាពបានអនុវត្តន៍សារាចរណែនាំរបស់ក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន បញ្ជារការដ្ឋានកងទ័ពជើងគោក ពិសេសការងារ កសាងពង្រឹងអង្គភាពរឹងមាំ លើគ្រប់វិស័យយោធភូមិភាគទី៥ អនុវត្តន៍តួនាទីភារកិច្ចចំពោញអង្គភាពឲ្យកាន់តែរឹងមាំ តាមបន្ទាត់ព្រំដែន។ គ្រប់គ្រងកម្លាំង ប្រមូលហ្វឹកហ្វឺនរៀនសូត្របង្កបង្កើនផល កងកម្លាំងទំនាកទំនងជាមួយស្ថាប័នពាក់ព័ន អាជ្ញាធរមូលដ្ឋាន ទំនាក់ទំនងជាមួយដៃគូសម្ព័ន្ធមេត្រីភាព និងចុះជួយពលរដ្ឋរងគ្រោះធម្មជាតិ និងជាយថាហេតុផ្សេងៗផងដែរ។

ឧត្តមសេនីយ៍ត្រី ជឹម ប៊ុនអាន បានកោតសសើរដល់អង្គភាពសឹករងក្រុងប៉ោយប៉ែត ដោយសង្កេតឃើញថាមានការរីកចម្រើនលើគ្រប់វិស័យរបស់អង្គភាព ដែលបានអនុវត្តន៍ការងាររយៈកន្លងមក ទាំងការអនុវត្ត ទាំងការបង្ក្រាប និងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់អាជ្ញាធរខេត្តសៀមរាប

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 27 ខែ July ឆ្នាំ 2020

សៀមរាប៖ នៅថ្ងៃចន្ទ ទី២៧ ខែកក្កដា ឆ្នាំ២០២០នេះ នៅតែទៅបន្តរង់ចាំទទួលប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដដែល។ នៅថ្ងៃនេះដែរទទួលបានចំនួនសរុប ២៩នាក់ ស្រីចំនួន ១៧នាក់ ដែលចូល

មកតាមច្រកដូង ខេត្តបាត់ដំបង, តាមច្រកប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ។

គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០នេះ សម្រាប់ខេត្តសៀមរាប តួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរ ចូលតាមច្រកទាំងបីខាងលើមានចំនួន ១៥,៩៩៦នាក់ ស្រីចំនួន ៦,៩៩០នាក់ ក្នុងនោះបានពិនិត្យសុខភាពបឋមបានចំនួន១៥,៩៩៦នាក់ ស្រី ៦,៩៩០នាក់ គឺពិនិត្យសុខភាពបានទាំងអស់។ សូមបញ្ជាក់ជូនថា ប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃក្នុងមួយថ្ងៃៗ មានចន្លោះពីជាង ១០០នាក់រហូតដល់ជាង ៣០០នាក់ សម្រាប់ទូទាំងប្រទេសកម្ពុជា ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

## ព្រោះបញ្ហាជីវភាពសម័យកូវីដ១៩ បង្ខំឆ្លងដែនខុសច្បាប់ត្រូវឃាត់ខ្លួន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០២០ ម៉ោង ០៩:៤២ មុំត សារុន

ខេត្តបន្ទាយមានជ័យ ៖ ដោយសារតែបញ្ហាជីវភាពគ្រួសារសម័យកូវីត១៩ បានធ្វើឲ្យពលករខ្មែរមួយចំនួនសម្រេចចិត្តខុស ហ៊ានឆ្លងដែនខុសច្បាប់ចំណាយទាំងប្រាក់អត់ប្រយោជន៍ខាតទាំងពេលវេលា ព្រោះត្រូវគេចាប់លើទឹកដីថៃបញ្ជូនត្រឡប់ ។ ជាក់ស្តែង ពលករប្រុសស្រី២៦នាក់ មានទាំងកុមារផង ត្រូវបានសមត្ថកិច្ចថៃធ្វើការចាប់ខ្លួនជាប់បន្ទាត់ព្រំដែន ក្នុងឃុំផានស៊ឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ក្រោយឆ្លងព្រំដែនពីកម្ពុជា ឃុំអូរស្រឡៅ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២៦ កក្កដា២០២០។ គេមិនទាន់ស្គាល់អត្តសញ្ញាណពលករទាំងនេះទេ ដឹងត្រឹមតែស្រី១១នាក់ កុមារម្នាក់ និងមកពីតាមបណ្ដាខេត្តក្នុងប្រទេសកម្ពុជានេះបើយោងតាមកាចុះផ្សាយរបស់គេហទំព័រ និងកាសែតក្នុងស្រុកថៃមួយ។

យោងការសាកសួរពលករខាងលើ ប្រាប់សមត្ថកិច្ចថាត្រូវមេខ្យល់ខ្មែរម្នាក់ នាំឆ្លងដែនកណ្ដាលអធ្រាត្រដោយយកប្រាក់ម្នាក់៣០០០បាត។ ក្រុមពលករបន្តទៀតថា កន្លងមកធ្លាប់ធ្វើការនៅស្រុកថៃ ហើយពេលនេះចង់ទៅធ្វើការនៅកន្លែងដើម ព្រោះជីវភាពគ្រួសារក្រីក្រ តែមិនទាន់ដល់គោលដៅផង ក៏ត្រូវគេចាប់ខ្លួន។ ពលករទាំងនេះត្រូវសមត្ថកិច្ចថៃឡោមព័ទ្ធចាប់ក្នុងចំការអំពៅមួយកន្លែងចំណុចកើតហេតុខណៈពួកគេចូលទៅពួននៅទីនោះ។

លោកវរសេនីយ សួង សៅ មេបញ្ជាការនគរបាលការពារព្រំដែនគោកលេខ៨១៥ ប្រចាំនៅបន្ទាត់ព្រំដែនក្នុងស្រុកម៉ាឡៃ ប្រាប់តាមទូរស័ព្ទថា ករណីខាងលើដំបូង ខាងលោកចុះល្បាតប្រទះឃើញមានដានជើងមនុស្សឆ្លងដែន ក៏ទាក់ទងទៅសមត្ថកិច្ចថៃឲ្យជួយទប់ស្កាត់ទើបគេចាប់បានពលករទាំងនេះក្នុងចំការអំពៅថៃ។ ក្រោយពិនិត្យសុខភាពនៅក្នុងបន្ទាយទាហ៊ានថៃ កងវរ១២០៦ពលករទាំងនេះត្រូវគេបញ្ជូនត្រឡប់មកកម្ពុជាតាមច្រករបៀងអូរបីជាន់ ដែលជាច្រកកិច្ចព្រមព្រៀងរវៀងខេត្តទាំង២ កម្ពុជា-ថៃ បន្ទាយមានជ័យ និងស្រះកែវ ។

គួរបញ្ជាក់ថា ពលករខុសច្បាប់ដែលភាគីថៃចាប់ក្រោយពួកគេឆ្លងព្រំដែន និងវិលត្រឡប់ពីតាមបណ្ដាខេត្តក្រុងក្នុងសម័យកូវីតមានរហូតជាង ២៥០០០នាក់នេះ បើយោងរបាយការណ៍របស់សមត្ថកិច្ចជំនាញខេត្តបន្ទាយមានជ័យ៕

## ឃាត់ខ្លួនពលរដ្ឋជិតមួយពាន់នាក់ ដែលព្យាយាមឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

https://www.cen.com.kh/ July 28, 2020

បាត់ដំបង: សមត្ថកិច្ចការពារព្រំដែន បានធ្វើការហាមឃាត់ប្រជាពលរដ្ឋខ្មែរជិតមួយពាន់នាក់ ដែលបានព្យាយាមលួចឆ្លងដែន ដោយខុសច្បាប់ចូលទៅក្នុងប្រទេសថៃនៅតាមច្រករបៀងនានាស្ថិតក្នុងភូមិសាស្ត្រខេត្តបាត់ដំបង ខណៈពេលក្នុងអំឡុងមានការបិទព្រំដែនរវាងកម្ពុជា-ថៃ មិនឲ្យមានអ្នកធ្វើដំណើរឆ្លងកាត់ពីសំណាក់ពលរដ្ឋទាំងពីរប្រទេស ក្រៅពីការដឹកជញ្ជូនទំនិញចេញចូលនោះ ។ ការលើកឡើងបែបនេះ ក្នុងពិធីផ្សព្វផ្សាយ ស្ដីពីការ

បង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងវិធានការទប់ស្កាត់ជំងឺកូវីដ១៩ ដល់ប្រជាពលរដ្ឋនៅស្រុកសំពៅលូន ដែលរៀបចំដោយអាជ្ញាធរខេត្ត និងអង្គការ IOM នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០២០ ក្រោមអធិបតីភាពលោកស្រី ស៊ុំ ចិន្តា អភិបាលរងខេត្តបាត់ដំបង។

លោកស្រី ស៊ុំ ចិន្តា អភិបាលរងខេត្តបាត់ដំបង បានមានប្រសាសន៍ថា អាជ្ញាធរខេត្តបាត់ដំបង នៅតែមានការព្រួយបារម្ភ ចំពោះការព្យាយាមលួចឆ្លងដែន ដោយខុសច្បាប់ពីសំណាក់ពលរដ្ឋខ្មែរ ចូលទៅក្នុងប្រទេសថៃ តាមច្រករបៀងនានា។ ព្រោះកាលពីពេលថ្មីៗនេះ កងកម្លាំងការពារព្រំដែន បានឃាត់ខ្លួនពលរដ្ឋដែលលួចចូលទៅថៃតាមច្រករបៀងនានាចំនួនប្រមាណជិតមួយពាន់នាក់ ដែលក្នុងនោះមានពលរដ្ឋរស់នៅខេត្តបាត់ដំបងផងនិងបណ្ដាខេត្តផ្សេងៗទៀតផង តាមរយៈមេខ្យល់បញ្ចុះបញ្ចូល។ លោកស្រី ស៊ុំ ចិន្តា បានអំពាវនាវយ៉ាងទទូច ដល់ប្រជាពលរដ្ឋទាំងអស់ សូមមានការអត់ធ្មត់ ដោយកុំឲ្យបន្តលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃទៀត ព្រោះទាំងមានហានិភ័យក្នុងការចាប់បញ្ជូនមកវិញ ពីអាជ្ញាធរប្រទេសថៃ ប្រឈមការជួញដូរកម្លាំងពលកម្ម ជួញដូរផ្លូវភេទពិសេសបញ្ហាឆ្លងរីករាលដាលជំងឺកូវីដ១៩ ដែលពិភពលោកកំពុងមានការព្រួយបារម្ភជាខ្លាំង។

គួរបញ្ជាក់ថា សម្រាប់ច្រកព្រំដែនជាប់នឹងខេត្តបាត់ដំបងគឺមានការអនុញ្ញាតឲ្យឆ្លងកាត់ដឹកទំនិញតែ ២ច្រកទ្វារអន្តរជាតិប៉ុណ្ណោះ គឺច្រកទ្វារអន្តរជាតិដូងស្ថិតក្នុងស្រុកកំរៀង និងច្រកទ្វារអន្តរជាតិភ្នំដីស្ថិតក្នុងស្រុកសំពៅលូន ដោយមិនមានការអនុញ្ញាតឲ្យមនុស្សឆ្លងកាត់ដូចមុននោះទេ ៕ **ដោយៈអ៊ុងសារុំ**

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់មក មានចំនួន ១០នាក់

https://www.cen.com.kh/ July 27, 2020

បន្ទាយមានជ័យ៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតនាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន១០នាក់ ស្រី០៧នាក់ និងកុមារ០០នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែនមិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕ **ដោយៈបញ្ញាស័ក្តិ**

## ពលរដ្ឋខ្មែរចំនួន ៥២នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 27-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៥២នាក់ ស្រី ២៥នាក់ និងកុមារ ១២នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦០នាក់

https://www.facebook.com/GDIOfficial 27-07-2020

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦០នាក់ ស្រី ២៦នាក់៕

## ពលរដ្ឋខេត្តបាត់ដំបង ដែលរងគ្រោះដោយកូវីដ-១៩ ស្នើអាជ្ញាធរ ជួយស្វែងរកការងារឲ្យពួកគេធ្វើ

http://btv.com.kh/ 28/07/2020

បាត់ដំបង ៖ ប្រជាពលរដ្ឋនៅខេត្តបាត់ដំបង ដែលបាននឹងកំពុងរងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ដោយសារតែវិបត្តិ កូវីដ១៩ បានស្នើទៅអាជ្ញាធរខេត្ត ឱ្យជួយស្វែងរកការងារ និងផ្សព្វផ្សាយឲ្យទូលំទូលាយពីទីតាំងមានការងារធ្វើ ដើម្បីឲ្យពួកគេបានដឹង និងស្នើសុំធ្វើការ ដើម្បីបានចំណូលដោះស្រាយជីវភាពប្រចាំថ្ងៃ។ ក្នុងពេលចូលរួមក្នុងពិធីផ្សព្វផ្សាយ ស្ដីពីការបង្រ្កាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងវិធានការទប់ស្កាត់កូវីដ១៩ នៅស្រុកសំពៅលូន កាលពីថ្ងៃទី២៧ ខែកក្កដា ប្រជាពលរដ្ឋ បានលើកឡើងថា ពួកគេធ្លាប់បានទៅធ្វើការងារនៅប្រទេសថៃ តែអំឡុងការផ្ទុះ ឡើងនៃជំងឺកូវីដ១៩ ក៏បានត្រឡប់មកស្រុកខ្មែរវិញ ប៉ុន្តែពេលត្រឡប់មកដល់ស្រុកកំណើត ប្រឈមការ អត់ការងារធ្វើ ហើយក៏មិនអាចត្រឡប់ទៅស្រុកថៃវិញ ព្រោះតែមានការបិទព្រំដែន មិនឲ្យពលរដ្ឋឆ្លងកាត់ ក្រៅពីទំនិញ។ ប្រជាពលរដ្ឋ បានបន្តថា បញ្ហាអត់ការងារធ្វើនេះ ធ្វើឲ្យពួកគេបានខិតខំស្វះស្វែង និងស៊ើបរកការងារពីទីកន្លែងផ្សេងៗ ទាំងតាមរយៈការសួរនាំពីអ្នកស្គាល់ តាមប្រព័ន្ធផ្សព្វផ្សាយ និងបណ្ដាញសង្គមហ្វេសប៊ុកជាដើម នៅតែមិនទាន់មានការងារធ្វើទៀត។ ក្រៅពីការស្នើសុំឲ្យជួយរកការងារធ្វើ ពលរដ្ឋក៏បានស្នើអាជ្ញាធរ ជួយប្រាប់ពីទីតាំងនៃការរៀនវគ្គជំនាញខ្លីៗ ដើម្បីអាចបើកអាជីវកម្មផ្ទាល់ខ្លួន និងរកចំណូលបាន សម្រាប់ចិញ្ចឹមជីវភាពប្រចាំថ្ងៃ ចៀសវាង ការធ្វើចំណាកស្រុកទៅក្រៅប្រទេស ។

ពាក់ព័ន្ធសំណើពលរដ្ឋ អ្នកស្រី ស៊ិប ស៊ីសូលី ប្រធានមជ្ឈមណ្ឌលការងារ ខេត្តបាត់ដំបង បានលើកឡើងថា ពលរដ្ឋនៅក្នុងខេត្ត ដែលចង់រកការងារធ្វើ គឺខាងមជ្ឈមណ្ឌលអាចរកការងារជូនពួកគេទៅតាមសមត្ថភាព ហើយនៅពេលមានអ្នកដាក់ពាក្យស្នើសុំ ខាងក្រុមការងារ នឹងបញ្ជូនឈ្មោះទៅខាងនិយោជក ឬស្ថាប័នផ្សេងៗ ដែលត្រូវការជ្រើសរើសបុគ្គលិក ខណៈបច្ចុប្បន្ននៅបាត់ដំបង ក៏មានតម្រូវការបុគ្គលិកច្រើន ។ អ្នកស្រី បានបញ្ជាក់ថា ដោយឡែក វគ្គបណ្ដុះបណ្ដាលខ្លីៗ នៅខេត្តបាត់ដំបង ក៏មានវិទ្យាស្ថាន បណ្ដុះបណ្ដាលវិជ្ជាជីវៈ ចំនួនបីកន្លែង មានបង្រៀនជួសជុលគ្រឿងចក្រ និងការធ្វើកសិកម្ម ជាដើម ដោយខាងសាលា ក៏មានផ្តល់ជាអាហារូបករណ៍ ហើយពលរដ្ឋក៏អាចទាក់ទងស្នើសុំរៀនពីសាលាទាំងបីនោះ ដែលមានទីតាំងនៅក្រុងបាត់ដំបង៕

## ថ្នាក់ដឹកនាំខេត្តបាត់ដំបង ៖ ការឆ្លងដែនទៅថៃ អំឡុងពេលនេះ មានហានិភ័យច្រើនណាស់

http://btv.com.kh/ 27/07/2020

បាត់ដំបង៖ ថ្នាក់ដឹកនាំខេត្តបាត់ដំបង បានធ្វើការអំពាវនាវជាថ្មីទៀតដល់ប្រជាពលរដ្ឋ កុំលួចឆ្លងទៅប្រទេសថៃ ក្នុងអំឡុងពេលនេះ ព្រោះវាមានហានិភ័យច្រើនណាស់ ពិសេស គឺការឆ្លងរាលដាលនៃមេរោគកូវីដ១៩។ ក្នុងពិធីផ្សព្វផ្សាយ ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាក ស្រុកប្រកបដោយសុវត្ថិភាព និងវិធានការទប់ស្កាត់កូវីដ–១៩ នៅក្នុងស្រុកសំពៅលូន កាលពីថ្ងៃទី២៦ ខែកក្កដា ម្សិលមិញ លោកស្រី ស៊ុំ ចិន្ដា អភិបាលរងខេត្តបាត់ដំបង បានថ្លែងថា អាជ្ញាធរខេត្តបាត់ដំបង នៅតែមានការព្រួយបារម្ភចំពោះការព្យាយាមលួចឆ្លងដែនដោយខុសច្បាប់ ពីសំណាក់ពលរដ្ឋខ្មែរ ចូលទៅប្រទេសថៃ តាមច្រករបៀងនានា។ លោកស្រី បានអំពាវនាវយ៉ាងទទូចដល់ប្រជាពលរដ្ឋទាំងអស់ សូមមានការអត់ធ្មត់ កុំបន្តលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃទៀត ព្រោះមានហានិភ័យច្រើន ដូចជាប្រឈមនឹងការជួញដូរកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ពិសេសបញ្ហាឆ្លងរីករាលដាលកូវីដ–១៩ ដែលពិភពលោកកំពុងមាន ការព្រួយបារម្ភជាខ្លាំងនោះ។

កាលពីពេលថ្មីៗនេះ កងកម្លាំងការពារព្រំដែន បានឃាត់ខ្លួនពលរដ្ឋ ដែលលួចចូលទៅថៃតាមច្រក របៀងនានា ចំនួនជាង៨០០នាក់ ដែលក្នុងនោះមានពលរដ្ឋរស់នៅខេត្តបាត់ដំបងផង និងបណ្ដាខេត្ត ផ្សេងៗទៀតផង តាមរយៈមេខ្យល់បញ្ចុះបញ្ចូល ។ សម្រាប់ច្រកព្រំដែនជាប់នឹងខេត្តបាត់ដំបង គឺមានការអនុញ្ញាតឲ្យឆ្លងកាត់ដឹកទំនិញ តែពីរច្រក ទ្វារអន្តរជាតិប៉ុណ្ណោះ គឺច្រកទ្វារអន្តរជាតិដូង ក្នុងភូមិសសាស្ត្រស្រុកកំរៀង និងច្រកទ្វារអន្តរជាតិភ្នំដី ក្នុង ស្រុកសំពៅលូន ដោយមិនមានការអនុញ្ញាតឲ្យមនុស្សឆ្លងកាត់ដូចមុននោះទេ៕

## ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

### លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប បានរៀបចំប្រជុំប្រចាំខែកក្កដា ឆ្នាំ២០២០

https://www.facebook.com/deputygovernoryousophear/ 28-07-2020

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ.ខ.ប.ជ) បានរៀបចំប្រជុំប្រចាំខែកក្កដា ឆ្នាំ២០២០ ក្រោមកិច្ចដឹកនាំរបស់ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប ព្រមទាំងមានការអញ្ជើញចូលរួមពីលោក លោកស្រី សមាជិក សមាជិកា លេខាធិការដ្ឋាន គ.ខ.ប.ជ ពីមន្ទីរអង្គភាពពាក់ព័ន្ធ ព្រមទាំងតំណាងអង្គការ ដៃគូពាក់ព័ន្ធសរុប ៥៥នាក់ ស្រី ៣១នាក់។

អង្គប្រជុំបានពិនិត្យទៅលើកំណត់ហេតុ និងត្រួតពិនិត្យលើផែនការដែលអង្គប្រជុំបានដាក់ចេញកាលពីកិច្ចប្រជុំប្រចាំឆមាសទី១ ឆ្នាំ២០២០ កន្លងទៅ និងបានពិភាក្សាលើបញ្ហាប្រឈមមួយចំនួន ដែលក្រុមការងារបានអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមគ្រប់រូបភាព ដោយមានការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នៅតាមមូលដ្ឋានភូមិ ឃុំ ដូចជា ធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ពាក់ព័ន្ធនានា គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព វេទិកាសាធារណៈ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ស្ប៉តអប់រំ ការផ្សាយតាមវិទ្យុ ទូរទស្សន៍ ជាដើម។ល។ បន្ថែមពីនេះ ក៏មានការស៊ើបអង្កេត និងបង្ក្រាបបទល្មើស ដើម្បីយកទៅផ្តន្ទាទោសតាមនីតិវិធីច្បាប់បានរាល់ករណីផងដែរ ពិសេសការស្រាវជ្រាវស្វែងរកចាប់និងឃាត់ខ្លួនមេខ្យល់ ។

នៅក្នុងកិច្ចប្រជុំនេះផងដែរ ក៏បានលើកយកបញ្ហាជាច្រើនមកពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយរួមគ្នាសម្រាប់ការពារជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឬការរំលោភបំពានផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ បន្ថែមពីនោះ អង្គប្រជុំ

បានក៏បានធ្វើការបង្ហាញជូនអំពីការជ្រើសរើសសិស្សចូលរៀនជំនាញវិជ្ជាជីវៈ និងជំនាញបច្ចេកទេស ដោយឥតបង់ថ្លៃដល់ប្រជាពលរដ្ឋក្រីក្រ ឬពលករដែលទើបត្រឡប់មកពីក្រៅប្រទេស របស់វិទ្យាជាតិស្ថានពហុបច្ចេកទេសអង្គរ និងវិទ្យាស្ថានជាតិពហុបច្ចេកទេសភូមិភាគ តេជោ សែន សៀមរាប។ នេះជាសកម្មភាពភាពដ៏ល្អមួយក្នុងការទប់ស្កាត់ការធ្វើចំណាកស្រុកទៅក្រៅប្រទេស និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

**អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៣៩នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត**

https://www.facebook.com/GDIOfficial 28-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៩នាក់ ស្រី ០៧នាក់ និងកុមារ ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

**ប្រជាពលរដ្ឋខ្មែរចំនួន ៦២នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង**

https://www.facebook.com/GDIOfficial 28-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិចេញ-ចូលបាននោះទេ។ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតាដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៦២នាក់ ស្រី ២៤នាក់ និងកុមារ ០៩នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

**ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៥នាក់**

https://www.facebook.com/GDIOfficial 28-07-2020

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃបានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន៦៥នាក់ ស្រី៣៦នាក់៕

**នគរបាលប៉ុស្តិ៍រដ្ឋបាលចំនួន៤ ចុះអប់រំផ្សព្វផ្សាយប្រជាពលរដ្ឋតាមខ្នងផ្ទះ**

http://cambodiapolice.com/policekh/ 4:47 pm 28 កក្កដា 2020

ក្រចេះ ៖ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ កម្លាំងអធិការដ្ឋាននគរបាលស្រុកព្រែកប្រសព្វខេត្តក្រចេះ បានធ្វើការផ្សព្វផ្សាយច្បាប់នៅគោលដៅអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក និងតាមខ្នងផ្ទះ ចំនួន០៤លើក អំពី ៖

-ផលប៉ះពាល់នៃគ្រឿងញៀន៩ចំណុច

-ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក(អនុក្រឹត្យលេខ៣៩អនក្រ)

-ល្បែងស៊ីសងខុសច្បាប់
-គ្រោះថ្នាក់អាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះ
-គ្រោះអគ្គីភ័យផ្សេងៗ
-គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព
-អំពើហិង្សាក្នុងគ្រួសារ
-ការជួញដូរកុមារ ស្ត្រីភេទ និងបានណែនាំដល់ពួកគាត់ដែលមានសត្វគោ ក្របី សម្ភារៈផ្សេងៗអោយរក្សាទុកដាក់ត្រឹមត្រូវជៀសវាងចោរលួច។

ជាក់ស្តែង ៖

១-ប៉ុស្តិ៍នគរបាលរដ្ឋបាលកោះតាស៊ុយ បានផ្សព្វផ្សាយនៅចំណុចភូមិកណ្តាលកោះ បាន១២ខ្នងផ្ទះ មនុស្សរួម២៩នាក់ ស្រី១៦នាក់ ចែកខិត្តប័ណ្ណ ២៩សន្លឹក ។

២-ប៉ុស្តិ៍នគរបាលរដ្ឋបាលសោប បានផ្សព្វផ្សាយតាមខ្នងផ្ទះ ចំណុចភូមិព្រៃកព្រលូង បាន៧ខ្នងផ្ទះ មនុស្សរួម២១នាក់ ស្រី១៦នាក់ ចែកខិត្តប័ណ្ណ ២១សន្លឹក ។

៣-ប៉ុស្តិ៍នគរបាលរដ្ឋបាលឫស្សីកែវ បានផ្សព្វផ្សាយតាមខ្នងផ្ទះចំណុចភូមិស្រឡៅដំណាក់ បាន៨ខ្នងផ្ទះ មនុស្សរួម២០នាក់ ស្រី១០នាក់ ចែកខិត្តប័ណ្ណ ២០សន្លឹក ។

៤-ប៉ុស្តិ៍នគរបាលរដ្ឋបាលតាម៉ៅ បានផ្សព្វផ្សាយតាមខ្នងផ្ទះនៅចំណុចភូមិតាម៉ោកណ្តាល បាន៦ខ្នងផ្ទះ មនុស្សរួម២៦នាក់ ស្រី១១នាក់ ចែកខិត្តប័ណ្ណ ២៦សន្លឹក ៕

## ខែកក្កដា ឆ្នាំ២០២០ ខេត្តបន្ទាយមានជ័យ ! បទល្មើសឧក្រិដ្ឋថយចុះ៧៥% បទល្មើសមជ្ឈឹមកើនឡើង១៣៣%

http://cambodiapolice.com/policekh/ 7:00 pm 28 កក្កដា 2020

បន្ទាយមានជ័យ ៖ លោកឧត្តមសេនីយ៍ទោ អាត់ ខែម ស្នងការនគរបាលខេត្តបន្ទាយមានជ័យ បានជំរុញដល់កងកម្លាំងនរបាលខេត្តបន្ទាយមានជ័យ ត្រូវពង្រឹងលើការងារការពារសន្តិសុខ សណ្តាបធ្នាប់ សុវត្ថិភាព ជូនប្រជាពលរដ្ឋបន្ថែមទៀត និងបន្តជួយប្រជាពលរដ្ឋដែលរងគ្រោះ និងជួបការលំបាកផ្សេងៗ ដូចដែលយើងបានធ្លាប់ធ្វើកន្លងមក លើវិស័យមនុស្សធម៌នោះ ។

នេះជាការលើកឡើងរបស់លោកឧត្តមសេនីយ៍ស្នងការ ក្នុងឱកាសប្រជុំបូកសរុបសភាពការណ៍ និងលទ្ធផលកិច្ចប្រតិបត្តិការប្រចាំខែកក្កដា ឆ្នាំ២០២០ និងលើកទិសដៅអនុវត្តការងារខែបន្ត នៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ។ កិច្ចប្រជុំនេះមានការចូលរួមពីលោក លោកស្រី ឧត្តមសេនីយ៍ វរសេនីយ៍ស្នងការរង នាយនាយរងការិយាល័យ លោកអធិការ អធិការរង ក្រុង ស្រុក លោកមេបញ្ជាការ ទាំង០៤ នាយប៉ុស្តិ៍រដ្ឋបាល នាយប៉ុស្តិ៍ការពារព្រំដែន ។ ជាមួយគ្នានោះដែរ លោកឧត្តមសេនីយ៍ទោ អាត់ ខែម ស្នងការនរបាលខេត្ត ក៏បានដាក់ចេញនូវផែនការ ដល់នគរបាលប៉ុស្តិ៍រដ្ឋបាល ត្រូវបន្តផ្សព្វផ្សាយពីគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ផ្សព្វផ្សាយពីច្បាប់ចរាចរណ៍ និងផ្សព្វផ្សាយពីវិធានការរបស់ក្រសួងសុខាភិបាល ឲ្យប្រជាពលរដ្ឋចូលរួមធ្វើការសម្អាត អនាម័យ ដើម្បីទប់ស្កាត់នូវជម្ងឺឆ្លងកូវីដ១៩ ។ ទន្ទឹមនោះដែរ ត្រូវបង្កើនកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មានជាមួយភ្នាក់ងារអនុវត្តច្បាប់ ដើម្បីទប់ស្កាត់អំពើភេរវកម្ម បង្ការ ទប់ស្កាត់និងបង្ក្រាបប្រកបដោយប្រសិទ្ធភាព នូវឧក្រិដ្ឋជនឆ្លងដែនគ្រប់ប្រភេទ ពិសេសយកចិត្តទុកដាក់សកម្មភាពបច្ចេកវិទ្យាព័ត៌មាន ក្នុងគោលបំណងបំផ្លិចបំផ្លាញសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សង្គម ។

យោងតាមរបាយការណ៍ប្រចាំខែកក្កដាឆ្នាំ២០២០ របស់ស្នងការដ្ឋាននគរបាលខេត្ត បានបង្ហាញថា៖ បទល្មើសព្រហ្មទណ្ឌកើតឡើងចំនួន០៨/០៧លើក បណ្តាលឲ្យមនុស្សរបួស០២នាក់ និងរងគ្រោះ០៦នាក់ ។ ក្នុងនោះ បទល្មើសឧក្រិដ្ឋ កើតឡើងចំនួន០១/០៤លើក ថយចុះ៧៥% រំលោភសេពសន្ថវៈ បទល្មើសមជ្ឈឹម កើតឡើងចំនួន០៧/០៣លើក កើនឡើង១៣៣% លួច០៤លើក,ហឹង្សាក្នុងគ្រួសារ០១លើក, ឆបោក០១លើក,ហឹង្សាដោយ

ចេតនា០១លើក, ។ បង្ក្រាបបទល្មើសព្រហ្មទណ្ឌដាក់ស្តែងចំនួន០៥លើក ឃាត់ខ្លួន០៥នាក់ ក្នុងនោះជាប់សារជាតុញៀន០២នាក់ ដកហូតសម្ភារះវត្ថុតាង មាស ប្រាក់មួយចំនួន។

បទល្មើសគ្រឿងញៀនខុសច្បាប់ បង្ក្រាបដាក់ស្តែងបានចំនួន៦៧លើក ឃាត់ខ្លួន ១១៩នាក់ ស្រី០៦នាក់ ក្នុងនោះ ៖ករណីជួញដូរ៣២លើក ជនសង្ស័យចំនួន៦៨នាក់ ស្រី០៥នាក់, ករណីរក្សាទុក០១លើក ជនសង្ស័យចំនួន០១នាក់,ករណីប្រប្រាស់៣៤លើក ជនសង្ស័យ៥០នាក់ ស្រីត០១នាក់ ។វត្ថុតាងដហូតបាន មានៈថ្នាំមេតំហ្វេតាមីនគ្រាប់( WY ) ទម្ងន់៥៤៧,៥៦ក្រាម,ថ្នាំមេតំហ្វេតាមីនអាយស៍ (Ice)ទម្ងន់ ២៧៤,១២ក្រាម ,គ្រាប់កាំភ្លើង១៦គ្រាប់,ម៉ូតូ០៥គ្រឿង,ទូរស័ព្ទដៃ៣៨គ្រឿង,ដាវសាម៉ូរ៉ៃ០២ដើម,កាំបិតវែង ០៣ដើម,វិទ្យុទាក់ទង ០២គ្រឿង, កាតធនាគារ០១សន្លឹក,លិខិតឆ្លងដែនសញ្ជាតិថៃ០៤ក្បាល រួមទាំងសម្ភារៈនិងឧបករណ៍សម្រាប់ជក់មួយចំនួន។

គ្រោះថ្នាក់ចរាចរណ៍ចំនួន០៣លើក ស្លាប់មនុស្ស០៣នាក់,របួសធ្ងន់០២នាក់,ស្រាល០២នាក់,ម៉ូតូខូចធ្ងន់០៣គ្រឿង,រថយន្តតូចខូចស្រាល០២គ្រឿង,រថយន្តធំខូចធ្ងន់០១គ្រឿងនិងយានផ្សេងៗ០១គ្រឿង។

ការងារគ្រប់គ្រងទេសន្តប្រវេសន៍ ៖ពលករខ្មែរចំណាកស្រុក ដែលអាជ្ញា ធរថៃបញ្ជូនឬត្រឡប់មកដោយខ្លួនឯងតាមមុខព្រួញគ្រប់គ្រងដោយកម្លាំងតាមខ្សែបន្ទាត់ព្រំដែន សរុបចំនួន ៧,៩៥៩នាក់ ស្រី៣,៦៦៥នាក់,កុមារ៩១១នាក់ ។ ចំពោះពលករខ្មែរចំណាកស្រុកត្រឡប់មកពីក្រៅប្រទេសចូលមកមូលដ្ឋាន ក្នុងខែកក្កដានេះ សរុបចំនួន១,១៤០នាក់ ស្រី៥៦៣នាក់និងកុមារ៣១នាក់។

ក្នុងកិច្ចប្រជុំនេះដែរ លោកឧត្តមសេនីយ៍ទោ អាត់ ខែម ក៏បានប្រគល់ប័ណ្ណសរសើររបស់ក្រសួងមហាផ្ទៃជូនដល់នាយនគរបាលប៉ុស្តិ៍រដ្ឋបាលទាំង៦៥ និងនាយប៉ុស្តិ៍ការពារព្រំដែនចំនួន៣២នាក់ផងដែរ ៕

## អភិបាលខេត្តកំពង់ចាម ផ្តល់អនុសាសន៍ ដើម្បីពង្រឹងលើការងារប្រយុទ្ធ ប្រឆាំងអំពើ ជួញដូរមនុស្ស

https://dap-news.com/national/ ByPH104 Posted on July 28, 2020

កំពង់ចាម ៖ លោក អ៊ុន ចាន់ដា អភិបាលខេត្តកំពង់ចាម និងជាប្រធាន គណៈកម្មាធិការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តកំពង់ចាម បានផ្តល់អនុសាសន៍មួយចំនួន ដល់មន្ត្រីក្រោមឱវាទ ដើម្បីយកទៅអនុវត្ត ក្នុងការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ឲ្យទទួលបានលទ្ធផលល្អ។ ការថ្លែងផ្តល់អនុសាសន៍ របស់លោកអភិបាលខេត្ត បានធ្វើឡើងនៅព្រឹកថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០២០ ក្នុងកិច្ចប្រជុំបូកសរុបការងារ ប្រចាំឆមាសទី ១ របស់គណៈកម្មាធិការខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ បន្ទាប់ពីមានប្រសាសន៍ កោតសរសើរដល់លទ្ធផលការងារ ក្នុងឆមាសទី ១ ដែលគណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សខេត្ត សម្រេចបាន លោកអភិបាលខេត្តបានថ្លែងថា ដើម្បីអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យទទួលបានលទ្ធផលល្អនៅពេលខាងមុខនេះ លោកសូមផ្តល់អនុសាសន៍ ៥ចំណុចដូចខាងក្រោម ៖

ទី១ ៖ សូមឱ្យលេខាធិការដ្ឋាន បន្តការបណ្តុះបណ្តាល ផ្តល់នូវចំណេះដឹង ដើម្បីឲ្យមន្ត្រីនៅមូលដ្ឋាន មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការអនុវត្តការងាររបស់ខ្លួន ។

ទី២ ៖ លេខាធិការដ្ឋាន ត្រូវពិនិត្យនិងអនុវត្តផែនការ សកម្មភាពរបស់ខ្លួនបន្តទៅទៀត ដោយសារយើងកំពុងមានវិបត្តិជំងឺកូវីដ19 ដូច្នេះត្រូវអនុវត្តតាមការណែនាំ របស់ក្រសួងសុខាភិបាល ។

ទី៣ ៖ពាក់ព័ន្ធទៅនិងក្រុមជំនាញទាំង ៦ ត្រូវអនុវត្តការងារ របស់ខ្លួនឲ្យបានសកម្ម ទៅតាមភារកិច្ចរបស់ខ្លួន ដូចដែលបានចែងនៅក្នុងសេចក្តីសម្រេចរួម ។

ទី៤ ៖ សូមថ្នាក់ក្រុង_ស្រុក និងឃុំ-សង្កាត់ បន្តសហការជាមួយប៉ុស្តិ៍នគរបាលរដ្ឋបាល ធ្វើការផ្សព្វផ្សាយតាមរយៈគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព ទាំង ៩ ចំណុច ជូនដល់ប្រជាពលរដ្ឋ ឲ្យបានទូលំទូលាយ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ជៀសផុតពីការចាញ់បោកមេខ្យល់ ដែលអាចឈាន ដល់ការរងគ្រោះដោយអំពើជួញដូរមនុស្ស ។

*ទី៥ ៖ពាក់ព័ន្ធទៅនឹងបញ្ហាកុមារ សម្រាប់ក្រុងកំពង់ចាម លោក សូមឲ្យក្រុមការងារការពារជនរងគ្រោះ ហើយមន្ទីរសង្គមកិច្ច និងអតីតយុទ្ធជនខេត្ត ជាប្រធាន សហការជាមួយអាជ្ញាធរ ក្រុងកំពង់ចាម ចាត់វិធានការតាមនីតិវិធី ដើម្បីគ្រប់គ្រង មុខសញ្ញាទាំងអស់ អោយមានសណ្តាប់ធ្នាប់ និងអាចចៀសផុតពីជម្ងឺកូវីត19 ផងដែរ ៕

## កិច្ចប្រជុំពង្រឹងវិធានការស្តីពីការទប់ស្កាត់ប្រជាពលរដ្ឋឆ្លងដែនដោយខុសច្បាប់ទៅប្រទេសវៀតណាម

https://gdlf-kh.com/ 2020/07/28/ Kao sophy ខេត្តស្វាយរៀង

ខេត្តស្វាយរៀង៖ នៅថ្ងៃចន្ទ ០៧កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ លោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរង នៃគណៈអភិបាលខេត្តស្វាយរៀង បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំពង្រឹងវិធានការ ស្តីពីការទប់ស្កាត់ប្រជាពលរដ្ឋឆ្លងដែន ដោយខុសច្បាប់ទៅប្រទេសវៀតណាម និងពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងពលករឆ្លងដែន ដោយខុសច្បាប់ទៅប្រទេសវៀតណាម និងប្រទេសផ្សេងៗ ទៀត ។

កិច្ចប្រជុំនេះរៀបចំនៅទីស្នាក់ការច្រកទ្វាព្រំដែនអន្តរជាតិបាវិត ដោយមានការអញ្ជើញចូលរួមពី លោកស្រីនាយករងរដ្ឋបាលសាលាខេត្ត លោក លោកស្រីប្រធានមន្ទីរ អង្គភាពជំនាញ លោកស្រីអភិបាលរងក្រុង លោកប្រធានទីស្នាក់ច្រកទ្វារព្រំដែនអន្តរជាតិបាវិត លោកអធិការនគរបាលក្រុងបាវិត លោកនាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ លោកមេបញ្ជាការវរសេនាតូចនគរបាលព្រំដែនគោក៦០៩ លោកបញ្ជាការវរសេនាតូចនគរបាលព្រំដែនគោក៦១១។

លោកជំទាវអភិបាលរងខេត្ត បានលើកឡើងថា បញ្ហានេះជាបញ្ហាមួយដ៏គួរឲ្យព្រួយបារម្ភ ដោយប្រទេសរបស់យើង ស្ថិតក្នុងស្ថានភាព នៃការរាតត្បាតនៃជំងឺកូវីត១៩ ច្រកព្រំដែនត្រូវផ្អាកការចេញចូលហើយ ប៉ុន្តែនៅតែមានប្រជាពលរដ្ឋបន្តការឆ្លងដែន ដោយខុសច្បាប់ចាកចេញទៅប្រទេសជិតខាង ។ ហើយទន្ទឹមនេះ នាពេលកន្លងមកក៏មានពលករមួយចំនួនវិលត្រឡប់មកស្រុកកំណើតវិញ ដែលយើងសង្កេតឃើញថា ពួកគាត់វិលត្រលប់មកវិញជារាងរាល់ថ្ងៃ ដូចនេះយើងត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយដល់ពួកគាត់បានយល់ដឹងពីវិធានការសំខាន់ៗមានជាអាទិ៍៖

-បន្តការការពារខ្លួន និងសហគមន៍ពីការឆ្លង និងចម្លងមេរោគកូវីដ ១៩

-អប់រំផ្លាស់ប្តូរផ្នត់គំនិត "បំណាច់ធ្វើការឲ្យគេ ត្រូវធ្វើឲ្យគេទទួលស្គាល់តម្លៃរបស់ខ្លួនក្នុងនាមជាពលរដ្ឋខ្មែរ"

-លើកទឹកចិត្ត និងផ្តល់ការគាំទ្រ ដល់ការខិតខំផលិត ការប្រើប្រាស់ផលិតផលក្នុងស្រុកនិងប្រើប្រាស់សក្តានុពលដែលមានដើម្បីបង្កើតមុខរបរក្នុងស្រុក ជាជាងការផ្សងព្រេង ដោយគ្មានគោលដៅច្បាស់លាស់នៅក្រៅប្រទេសដែលប្រកបដោយគ្រោះថ្នាក់ខាតពេលវេលានិងមិនមានផលប្រយោជន៍។

លោកជំទាវក៏បានជំរុញឲ្យកងម្លាំងមានសមត្ថកិច្ច នៅតាមតំបន់ព្រំដែន ៖

-ត្រូវស្រាវជ្រាវ កំណត់មុខសញ្ញាបង្ក្រាប និងការចាប់ខ្លួនមេខ្យល់ ដែលមានចលនាអូសទាញប្រជាពលរដ្ឋឆ្លងដែន ដោយខុសច្បាប់ទៅប្រទេសជិតខាង។

-គួរមានវិធានការម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងពលករឆ្លងដែន ព្រឹក ល្ងាច តាមរដូវកាលទៅប្រទេសវៀតណាម ។

-ត្រូវបន្តការយកចិត្តទុកដាក់អនុវត្តនូវវិធានការ និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសុខាភិបាលក្នុងការបង្ការ ទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩ ៕

## ទៀតហើយ! ថៃបញ្ជូន ពលករខ្មែរឆ្លងដែនខុសច្បាប់ជិត៤0នាក់ មកកម្ពុជាវិញតាមច្រកប៉ោយប៉ែត

https://kbn.news/archives/ July 29, 2020

**រាជធានីភ្នំពេញ៖** អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានឲ្យដឹងថា ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមកមាន

ចំនួន ៣៩នាក់ ស្រី៧នាក់ និងកុមារ២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ស្ថានទូតកម្ពុជា នៅវៀតណាម សហការជាមួយអាជ្ញាធរវៀតណាម សង្គ្រោះស្ត្រីខ្មែរម្នាក់ ចាញ់បោកមេខ្យល់ និង សម្របសម្រួលឱ្យវិលមកកាន់មាតុប្រទេសវិញ

http://www.nicetvnewsoffice.com July 29, 2020

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូត
នៃព្រះរាជាណាចក្រកម្ពុជា
ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម

លេខ [illegible]/...... សរកហ

**សេចក្តីជូនព័ត៌មាន**

កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ខេត្តកាវបាងវៀតណាម បានសង្គ្រោះនារីរងគ្រោះ១រូប ដែលចាញ់បោកមេខ្យល់ និងបានបញ្ជូនទៅដាក់មជ្ឈមណ្ឌលដាច់ដោយឡែករយៈពេល១៤ថ្ងៃ ព្រមទាំងបានរៀបចំបែបបទត្រឡប់ទៅកម្ពុជាវិញតាមរថភ្លើងពីទីក្រុងហាណូយ នៅថ្ងៃទី២៧ ខែកក្កដា និងទៅដល់ទីក្រុងហូជីមិញ វេលាម៉ោង ០៥H០០ ព្រឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ ដែលនៅទីនោះស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំក្រុងហូជីមិញ ជួយសម្រួលការធ្វើដំណើរបន្តទៅដល់ច្រកទ្វារព្រំដែនអន្តរជាតិបាវិត។

នារីរងគ្រោះនោះ កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៨ នៅស្រុកដំបែរ ខេត្តកំពង់ចាម។

ស្ថានទូតបានទិញសំបុត្ររថភ្លើង និងឧបត្ថម្ភថវិកា ៥០ ម៉ឺនដុង។

ស្ថានទូតបានផ្តាំផ្ញើដល់នារីរងគ្រោះនោះ ពេលទៅដល់មាតុប្រទេសវិញខិតខំ ប្រកបមុខរបរតាមសមត្ថភាព។

ថ្ងៃអង្គារ ៨កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ទីក្រុងហាណូយ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០២០

Address: 71 Tran Hung Dao, Hoan Kiem District, Hanoi, Viet Nam
Tel: +(84-4) 39424788
Fax: +(84-4) 39423225
Email: camemb.vnm@mfa.gov.kh

# ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០

## សម្តេច ស ខេង អញ្ជើញបើកសិក្ខាសាលាកម្រិតថ្នាក់ដឹកនាំស្តីពី កតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាពនិងស្របច្បាប់

https://dap-news.com/national/ BySS107 Posted on July 30, 2020

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នាព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០២០ នេះនាទីស្តីការក្រសួងមហាផ្ទៃ បានអញ្ជើញបើក សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២កម្រិតថ្នាក់ដឹកនាំ ស្តីពីកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់(GCM)។

សូមជម្រាបថា កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ គឺជាក្របខណ្ឌទូលំទូលាយទីមួយ របស់អង្គការសហប្រជាជាតិ ដែលត្រូវបានអនុម័តតាមរយៈកិច្ចការពិភាក្សា អន្តររដ្ឋាភិបាល ដើម្បីធ្វើឲ្យកិច្ចសហការអន្តរជាតិមានភាពល្អប្រសើរ ក្នុងអភិបាលកិច្ចទេសន្តរប្រវេសន៍ជាសកលនិងត្រូវបានឯកភាពគាំទ្រដោយមហាសន្និបាតអង្គការសហប្រជាជាតិ ដែលប្រារព្ធឡើងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ នៅទីក្រុងញ៉ូយ៉កដែលមានសមាជិកចូលរួមចំនួន១៥២ប្រទេស៕ដោយ ៖ អេង ប៊ូឆេង

## សម្តេចក្រឡាហោម ស ខេង បើកសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរអន្តោប្រវេសន៍ប្រកបដោយសុវត្ថិភាព និងស្របច្បាប់

http://www.freshnewsasia.com/ 2020-07-30 09:22am

**(ភ្នំពេញ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០នេះ បានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ ស្តីពី កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរអន្តោប្រវេសន៍ ប្រកបដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់។ សិក្ខាសាលានេះ ប្រព្រឹត្តធ្វើឡើងនៅទីស្តីការក្រសួងមហាផ្ទៃ និងមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួង ស្ថាប័នព័ន្ធ ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ អភិបាលរាជធានី-ខេត្ត ព្រមទាំងមានការតអញ្ជើញចូលរួមពីសំណាក់លោកស្រីប្រធានបេសកម្មនៃអង្គការ IOM និងជាតំណាងអង្គការសហប្រជាជាតិ ប្រចាំកម្ពុជា។

បើតាមសុន្ទរកថារបស់លោកស្រី គ្រីស្ទីន ផាកូ ប្រធានបេសកកម្ម អង្គការអន្តរជាតិទេសន្តរអន្តោប្រវេសន៍ប្រចាំកម្ពុជា បានឱ្យដឹងថា នៅក្នុងប្រទេសកម្ពុជា ផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ បានធ្វើឱ្យពលករទេសន្តរអន្តោប្រវេសន៍ជាង ១០០,០០០នាក់ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ នៅខែមីនា ឆ្នាំ២០២០។ នៅពេលត្រឡប់ទៅកាន់សហគមន៍របស់ពួកគេវិញ ពលករដែលបានវិញត្រឡប់មកទាំងនោះ អាចកាន់តែប្រឈមនឹងភាពងាយរងគ្រោះជាងមុន ដោយសារតែកង្វះខាតកិច្ចគាំពារសង្គម ការទទួលបានព័ត៌មាននៅមានកម្រិត ព្រមទាំងហានិភ័យនៃការជួញដូរមនុស្ស និងកេងប្រវ័ញ្ចកើនឡើង។ លោកស្រី គ្រីស្ទីន ផាកូ បានបន្តថា កតិការសញ្ញានេះ ជាឱកាសមួយសម្រាប់អនុវត្តការងារ បន្តទាក់ទងនឹងបញ្ហាសំខាន់ៗ នៃទេសន្តរអន្តោប្រវេសន៍ ដែលមាននៅក្នុងរបៀបវារៈឆ្នាំ២០៣០ នៃការអភិវឌ្ឍន៍ដោយចីរភាព ព្រមទាំងធានាថា ជនទេសន្តរប្រវេសន៍នឹងមិនត្រូវបោះបង់ចោលទេ។

សូមជម្រាបថា កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ គឺជាប្រកខណ្ឌទូលំទូលាយទីមួយរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានអនុម័តតាមរយៈកិច្ចការពិភាក្សា អន្តររដ្ឋាភិបាល ដើម្បីធ្វើឱ្យកិច្ចសហការអន្តរជាតិមានភាពល្អប្រសើរ ក្នុងអភិបាលកិច្ចទេសន្តរប្រវេសន៍ជាសកល និងត្រូវ

បានឯកភាពគាំទ្រដោយមហាសន្និបាតអង្គការសហប្រជាជាតិ ដែលបានប្រារព្ធឡើងកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៨ នៅទីក្រុងញូយ៉កដែលមានសមាជិកចូលរួមចំនួន១៥២ប្រទេស។

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តំណាងឱ្យរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី១ នៅទីក្រុងភ្នំពេញក្រោមអធិបតីភាព សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងមានអ្នកតំណាងចូលរួមជាង១០៧នាក់ មកពីក្រសួងពាក់ព័ន្ធ ស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល ជាដើម ក្នុងការចូលរួមចំណែកត្រៀមធ្វើការអនុម័តទៅលើកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅថ្ងៃទី១១-១២ ខែធ្នូ ឆ្នាំ២០២០ នៅទីក្រុងម៉ារ៉ាកិច ប្រទេសម៉ារ៉ុក៕

## ក្រសួងមហាផ្ទៃ ពង្រឹងប្រសិទ្ធភាពការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា ដើម្បីឆ្លើយតបនឹងការវាយតម្លៃ របស់អាមេរិក

https://www.cen.com.kh/ July 29, 2020

ភ្នំពេញ៖ ការប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស ក្រសួងមហាផ្ទៃ ក៏ដូចជាក្រសួងស្ថាប័ន្ធពាក់ព័ន្ធ រួមទាំងអាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ គឺមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការដោះស្រាយបញ្ហានេះ។ ក្រសួងមហាផ្ទៃ ក៏ពង្រឹងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ដើម្បីឆ្លើយតបនឹងការវាយតម្លៃរបស់សហរដ្ឋអាមេរិក។

ទីស្តីការក្រសួងមហាផ្ទៃ នារសៀលថ្ងៃពុធ ទី២៩ ខែកក្កដា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃ បើកកិច្ចប្រជុំពិភាក្សា ក្នុងការពង្រឹងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដើម្បីឆ្លើយតបនឹងការវាយតម្លៃរបស់សហរដ្ឋអាមេរិក ក្រោមអធិបតីភាព ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ និងលោក ជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ដោយមានការអញ្ជើញចូលរួមពី អគ្គលេខាធិការ អគ្គនាយក នៃអគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយដ្ឋានពាក់ព័ន្ធ ព្រមទាំងអង្គភាពនានា ជាច្រើនផងដែរ។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) មានប្រសាសន៍ថា នាពេលកន្លងមក រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានអនុវត្តយ៉ាងសកម្មក្នុងកិច្ចការប្រយុទ្ធប្រឆាំងអំពើជួយដូរមនុស្ស ប៉ុន្តែទោះជាយ៉ាងនេះក្តី ដោយមានការវិវឌ្ឍក្នុងសង្គមនាពេលបច្ចុប្បន្ន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានកំណត់នូវផែនការបន្តសម្រាប់អនុវត្ត ក្នុងការពង្រឹងយុទ្ធនាការសកម្មភាពនេះបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាបន្តកាត់បន្ថយ និងឈានទៅលុបបំបាត់អំពើជួញដូរមនុស្សនេះ។

ជាងនេះទៀត ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា ទាក់ទងទៅនឹងការប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្សនេះ ក្រសួងមហាផ្ទៃ ក៏ដូចជាក្រសួងស្ថាប័ន្ធពាក់ព័ន្ធ រួមទាំងអាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ គឺមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហានេះ។ ហេតុដូចនេះហើយ នៅក្នុងកិច្ចប្រជុំនាថ្ងៃនេះ គឺក្នុងន័យដើម្បី ពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តកិច្ចការងារ និងការរៀបចំរបាយការណ៍ ឲ្យឆ្លើយតបទៅនឹងសកម្មភាពជាក់ស្តែង ដោយបង្ហាញពីការខិតខំប្រឹងប្រែងរបស់កម្ពុជា ទៅលើការគាំទ្រ និងចូលរួមប្រយុទ្ធប្រឆាំង និងអំពើជួញដូរមនុស្សនេះផងដែរ។

ក្នុងឱកាសនោះដែរ ឯកឧត្តម សក់ សេដ្ឋា ក៏បានវាយតម្លៃខ្ពស់ចំពោះលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងសហការី ព្រមជាមួយកងកម្លាំងនគរបាល ដែលបានខិតខំប្រឹងប្រែង ក្នុងកិច្ចការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ឯកឧត្តម បានបន្តថា ចំពោះកិច្ចការនេះ ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុងក្របខ័ណ្ឌជាតិ ក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ដូច្នេះហើយទើបរៀបចំឱ្យមានកិច្ចប្រជុំនេះឡើង ដើម្បីប្រមូលធាតុចូល ព្រមទាំងគំនិតសំខាន់ៗ ជារួមក្នុងការពង្រឹងភាពច្បាស់លាស់ទៅលើការអនុវត្តសកម្មភាពនានា ពាក់ព័ន្ធទៅនឹងការប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស ក្នុងការឆ្លើយតបទៅនឹងការវាយតម្លៃរបស់សហរដ្ឋអាមេរិក។ ជាមួយគ្នានេះដែរ កិច្ចប្រជុំនេះ ក៏នឹងពិនិត្យលើវិធានការនានា ដើម្បីអនុវត្តនៅឆ្នាំបន្តបន្ទាប់ទៀត ដើម្បីធ្វើយ៉ាងណាបង្កើនប្រសិទ្ធភាព ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ ឱ្យមានកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមជាងនេះទៀត៕ **ដោយៈបញ្ញាស័ក្តិ**

## ពីថ្ងៃ២១មីនា ដល់២៣ កក្កដា មានពលករខ្មែរជាង១០ ម៉ឺននាក់ត្រឡប់មក

https://dap-news.com/national/ ByPH104 Posted on July 30, 2020

ភ្នំពេញ ៖ គិតចាប់ពីថ្ងៃទី២១ ខែមិនា រហូតដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ មានពលករកម្ពុជា ដែលវិលត្រឡប់ពីការធ្វើទេសន្តរប្រវេសន៍ក្នុងអំឡុងកូវីដ១៩ ជាង១០ម៉ឺននាក់។ នេះបើតាមសម្តេចក្រឡាហោម ស ខេង ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈ កម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ។

ក្នុងសិក្ខាសាលាពិគ្រោះយោបល់ ថ្នាក់ជាតិលើកទី២ កម្រិតថ្នាក់ដឹកនាំ ស្តីពីកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ សម្តេចក្រឡាហោម ស ខេង បានឲ្យដឹងថា ក្នុងដំណាក់កាលបច្ចុប្បន្នការធ្វើទេសន្តរប្រវេសន៍រឹតតែប្រឈមខ្លាំង ដោយហេតុការរាតត្បាតនៃជំងឺកូវីដ-១៩ នៅមិនទាន់ស្ងប់ស្ងាត់នៅឡើយ មិនតែប៉ុណ្ណោះប្រទេសមួយចំនួនបាន និងកំពុងតែកើនឡើងចំនួនអ្នកឆ្លងថ្មី យ៉ាងច្រើនលើសលប់ជារៀងរាល់ថ្ងៃ។ សម្តេចក្រឡាហោមបន្តថា ស្ថានភាពនេះបានធ្វើឲ្យប្រទេសដែលទទួលពលករ ក៏ប្រឈមខ្លាំងទៅនឹងភាពប្រែប្រួលជាអវិជ្ជមាន នៃចរន្តសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចក្នុងស្រុក ដែលជំរុញឲ្យដំណើរការរោងចក្រសហគ្រាស និងវិស័យសេវាកម្មនានារាំងស្ទះ និងត្រូវផ្អាកដំណើរការជាបន្តបន្ទាប់។ សម្តេចក្រឡាហោមបន្ថែមថា ចំណែកឯវិធានការណ៍ បិទព្រំដែន និងបិទការនាំចូលពលករបរទេស ក៏នៅបន្ត ដែលជាហេតុធ្វើឲ្យពលករ ត្រូវធ្វើការសម្រេចចិត្តឲ្យបានច្បាស់លាស់ តើគួរបន្តស្នាក់នៅក្នុងប្រទេសគោលដៅដោយមិនមានការងារ ប្រាក់ចំណូល ឬក៏ត្រូវត្រឡប់មកភូមិស្រុកវិញ ដើម្បីជួបជុំគ្រួសារ ។

សម្តេចក្រឡាហោម ស ខេង មានប្រសាសន៍ថា «គិត ចាប់ពីថ្ងៃទី២១ ខែមិនា រហូតដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ មានពលករកម្ពុជាដែលវិលត្រឡប់ពីការធ្វើទេសន្តរប្រវេសន៍ ក្នុងអំឡុងខូវីដ ១៩ មានប្រមាណ ១០ម៉ឺន៣ពាន់នាក់ និងស្ត្រី ប្រមាណ ៤៥ភាគរយ។ យើងបាន និងកំពុងទទួលសង្គ្រោះពលករដែលវិលត្រឡប់មកវិញ ដោយគេចវេសពីស្ថានភាពលំបាក ក្នុងប្រទេសគោលដៅ និងព្យាយាមឆ្លងដែនដោយខុសច្បាប់ និងតាមច្រកមិនផ្លូវការ ក្នុងអំឡុងពេលដែលប្រទេសគោលដៅបាន និងកំពុងរឹតបន្តឹង និងបិទប្រទេស ដើម្បីកាត់បន្ថយការឆ្លងទៅមក នូវជំងឺកូវីដ-១៩» ។ សម្តេចក្រឡាហោម បញ្ជាក់ថា ស្ថានភាពបែបនេះ នឹងមិនអាចបញ្ចប់ដោយងាយៗនោះទេ ហើយក៏អាចអូសបន្លាយបន្តទៀតក្នុងរយៈពេលវែង ហេតុនេះកិច្ចការពារពលករទាំងនៅក្នុងប្រទេសដើមទាំងនៅក្នុងប្រទេសគោលដៅ គឺជាភារកិច្ចចាំបាច់គប្បីត្រូវយកចិត្តទុកដាក់ ។ ដោយឡែក រាជរដ្ឋាភិបាលកម្ពុជា ក៏បានយកចិត្តទុកដាក់ចំពោះបញ្ហានេះ ព្រោះប្រជាជនកម្ពុបាន និងកំពុងតែទទួលរងនូវស្ថានភាពទាំងអស់នេះ អស់រយៈពេលជាច្រើនឆ្នាំមកហើយ៕ ដោយ ៖ អេង ប៊ូឆេង

# រដ្ឋមន្ត្រីៈ គោលនយោបាយជាតិការពារកុមារ ជាយុទ្ធសាស្ត្រប្តេជ្ញាចិត្ត របស់រាជរដ្ឋាភិបាល កម្ពុជា

https://www.rasmeinews.com/ July 29, 2020, 11:29 AM

**ដោយៈ មេសា/ភ្នំពេញៈ** លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង ជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បី កុមារ មានប្រសាសន៍ខ្លឹមសារ នៃ គោលនយោបាយថ្មីក្នុងការការពារកុមារ ថា " គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ជាយុទ្ធសាស្ត្របង្ហាញអំពី ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល កម្ពុជា ដែលធ្លាប់អនុវត្តកន្លងមក និងចាំបាច់ត្រូវធ្វើការពង្រឹង និងពង្រីកបន្ថែមទៀត និងជាគោលនយោបាយជាតិ ដែលត្រូវបានរៀបចំឡើងជាលើកដំបូងសម្រាប់រយៈពេល១០ឆ្នាំ ២០១៩-២០២៨ ដែលអាចប្រមូលផ្តុំការវិនិយោគ ទៅលើកុមារ ទាំងស្មារតី ទាំងធនធាន ឱ្យមានលក្ខណៈជាប្រព័ន្ធគ្រប់ជ្រុងជ្រោយជាងមុន ដើម្បីឱ្យកុមារគ្រប់រូបមាន ឱកាសស្មើៗគ្នា និងក្លាយជាធនធានមនុស្សដែលអាចរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ " ។ លោក វង សូត ថ្លែងយ៉ាងដូច្នេះនៅក្នុងពិធីផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ នៅទីស្តីការក្រសួងសង្គម កិច្ច នាព្រឹកថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០២០ រៀបចំដោយ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បី កុមារ (ក.ជ.ក) ដោយមានការសហការគាំទ្រពី អង្គការភ្លែនអន្តរជាតិកម្ពុជា និង អង្គការឆោលហ្វាន់កម្ពុជា ។

ប្រព័ន្ធកិច្ចការពារកុមារ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តនាថ្ងៃនេះ មានលក្ខណៈជាប្រព័ន្ធ៥ ចំណុចគឺៈ

១. ភាពចាំបាច់ក្នុងការវិនិយោគបន្ថែម លើមន្ត្រីសង្គមកិច្ចឬបុគ្គលិកសង្គមនៅថ្នាក់ក្រោមជាតិ ដើម្បីជំរុញ សេវាការពារកុមារប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល សង្គតិភាព និងទាន់ពេលវេលាដល់កុមារ និងគ្រួសារនៅ តាមសហគមន៍។

២. ការបន្តធានាឱ្យកុមារទទួលបាននូវសេវាផ្លូវច្បាប់ និងសមធម៌សង្គម តាមរយៈការផ្តល់នូវកញ្ចប់អប្បបរមា នៃសេវាសង្គមកិច្ចសម្រាប់កុមារ និងគ្រួសារដែលត្រូវការកិច្ចការពារ។

៣. ការឆ្លើយតបចំពោះគ្រោះមហន្តរាយ ដែលបណ្តាលឱ្យមានផលប៉ះពាល់ដល់កុមារ និងគ្រួសារកុមារ។

៤. ការបន្តប្រមូលផ្តុំ ពង្រឹង និងពង្រីកកម្មវិធីដែលមានស្រាប់សម្រាប់កិច្ចការពារកុមារ សំដៅបង្កើនប្រសិទ្ធ ភាព តម្លាភាព និងសង្គតិភាពឱ្យបានទូលំទូលាយ។

៥. ការធានានូវសង្គតិភាពនៃនីតិវិធី វិធានការ និងយន្តការដែលមានស្រាប់ក្នុងការដោះស្រាយបញ្ហារបស់ កុមារ ដើម្បីបំពេញនូវតម្រូវការនិងធានាការពារកុមារ ប្រកបដោយបរិយាកាសគ្រួសារ សេចក្តីស្រឡាញ់ ការយកចិត្ត ទុកដាក់មានលក្ខណៈកុមារមេត្រី និងធានាឧត្តមប្រយោជន៍របស់កុមារ ។

ប្រព័ន្ធកិច្ចការពារកុមារ ក៏គឺជាបណ្តុំ នៃវិធានបង្កើតឡើងក្នុងគោលបំណងជំរុញ និងលើកកម្ពស់ការការពារ កុមារពីការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់រូបភាព ហើយវិធានទាំងនេះមាន ៤ ចំណុច គឺ ៖ ១- ក្របខណ្ឌ ច្បាប់និងគោលនយោបាយ , ២ -ការផ្តល់ជំនួយនិងសេវា , ៣ -ធនធានមនុស្សនិងហិរញ្ញវត្ថុ និង ៤ -ការផ្លាស់ប្តូរ ឥរិយាបថសង្គមក្នុងការប្រព្រឹត្តទៅលើកុមារ ដែលវិធានទាំងនេះត្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសវិស័យសុខុមាលភាពសង្គម អប់រំសុខភាព សន្តិសុខ និងយុត្តិធម៌ ក្នុងការគាំទ្រដល់ការបង្ការទប់ស្កាត់និង ឆ្លើយតប ដើម្បីការពារកុមារពីហានិភ័យផ្សេងៗ។

ក្របខណ្ឌគោលនយោបាយជាតិមួយនេះ ផ្អែកលើសសរស្តម្ភ៣ គឺ ៖ ១. ការបង្ការទប់ស្កាត់ , ២. ការអន្តរា គម និង ៣. ការផ្តល់សេវា និងការឆ្លើយតប ដែលយើងត្រូវបំពេញជាលក្ខណៈប្រព័ន្ធមួយ ។

លោកស្រី ញ៉េប សុភាព អគ្គលេខាធិការ នៃ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ បាន លើកឡើងថា គោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ គឺជាគោលនយោបាយមួយដែលបានបង្ហាញ យ៉ាងច្បាស់ ពីឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិ និងការការពារកុមារ ព្រមទាំងការដោះស្រាយបញ្ហា

កុមារនៅកម្ពុជា ក្នុងនាមជាប្រទេសហត្ថលេខី នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ហើយជាពិសេសគោលនយោបាយនេះ ជាស្នាដៃតាក់តែងចងក្រងរួមគ្នាដោយ ក្រុមការងារអន្តរក្រសួង នៃគណៈកម្មការការពារកុមារថ្នាក់ជាតិ ។

គប្បីរំឭកថា ដើម្បីឈានមកដល់ថ្ងៃនេះដំណើរការ នៃការផ្តួចផ្តើមគំនិត និងចងក្រងគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារនេះ បានចាប់ផ្តើមកាលពី ៣ ឆ្នាំមុនពេលគឺក្នុងឆ្នាំ២០១៧ ហើយនាយិកាប្រចាំប្រទេស នៃ អង្គការភ្លែនអន្តរជាតិកម្ពុជា អ្នកស្រី គ្វីននេត វ៉ង មានប្រសាសន៍ថា អង្គការភ្លែនអន្តរជាតិកម្ពុជា អង្គការឆាលហ្វាន់ និងដៃគូរទាំងអស់ពិតជាមានសេចក្តីសោមនស្សរីករាយដែលបានចូលរួមគាំទ្រក្នុងដំណើរការនៃ ការចងក្រងគោលនយោបាយជាតិដ៏មានសារសំខាន់នេះ ក៏ដូចជាបានចូលរួមផ្សព្វផ្សាយ និង ដាក់ឲ្យប្រើប្រាស់ ដើម្បី ធានាឱ្យកុមារគ្រប់រូបទទួលបាននូវសិទ្ធិ ស្មើៗគ្នា ដើម្បីសមធម៌ និង យុត្តិធម៌សង្គម ៕ Kh

## រាជរដ្ឋាភិបាល កំពុងសហការជាមួយប្រទេសក្នុងពិភពលោក ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នៅកម្ពុជា

http://www.freshnewsasia.com/ 2020-07-30 11:02am

**(ភ្នំពេញ)៖** រាជរដ្ឋាភិបាលកម្ពុជា កំពុងសហការជាមួយរដ្ឋាភិបាលនៃបណ្តាប្រទេសទាំងក្នុងតំបន់និងក្នុងពិភពលោក ព្រមទាំងអង្គការជាតិ-អន្តរជាតិ និងវិស័យឯកជនដើម្បីរួមគ្នាប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា។ ដោយឡែកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានទទួលអណត្តិពីរាជរដ្ឋាភិបាល ក្នុងការការពារ និងការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ បានបំពេញការងារយ៉ាងសកម្ម និងសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងកិច្ចការពារជនរង គ្រោះដោយអំពើជួញដូរមនុស្ស ការងារកសាងគោលនយោបាយ ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការពង្រឹងកិច្ច សហប្រតិបត្តិការ និងការបង្កើនភាពជាដៃគូ។ ទោះបីក្រសួងសម្រេចបានសមិទ្ធផលជាច្រើនយ៉ាងណាក៏ដោយ ក៏ការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅមិនទាន់បានឆ្លើយតប បានទាំងស្រុងនៅឡើយទេ ជាពិសេស ការផ្តល់សេវា និងការបញ្ជូនជនរងគ្រោះទៅរក សេវាសមស្របនៅមានកម្រិត។

នេះជាការលើកឡើងរបស់លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាង លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថ្លែងក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ១សេចក្តីព្រាងចុងក្រោយ នៃគោលការណ៍ណែនាំស្តីពីយន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស» រៀបចំធ្វើនាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០នេះ។ លោក ញឹក វណ្ណារ៉ា បានថ្លែងឲ្យដឹងថា ដោយយោងលើតម្រូវការចាំបាច់ខាងលើនេះ ក្រសួងសង្គមកិច្ច បានសហការយ៉ាងជិតស្និទ្ធជាមួយសកម្មភាព អង្គការសហប្រជាជាតិ ដើម្បីសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស (UN-ACT) អង្គការ UN Women អង្គការរតនៈអន្តរជាតិ និងអង្គការក្តីសង្ឃឹម និងយុត្តិធម៌ ដែលបានគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាក្នុងដំណើរការកសាង គោលការណ៍ណែនាំ ស្តីពីការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេសក្នុងការរៀបចំសិក្ខាសាលា ពិគ្រោះយោបល់នេះឡើង។ លោកបានបន្ថែមថា ថ្ងៃនេះសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីសេចក្តីព្រាងចុងក្រោយនៃគោលការណ៍ ស្តីពីការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រមូលយោបល់ និងធាតុចូលសម្រាប់កែសម្រួល និងបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

លោក ញឹក វណ្ណារ៉ា បានបញ្ជាក់ថា ដើម្បីពង្រឹងប្រសិទ្ធភាពថែមទៀត នូវការបញ្ជូន និងការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស យើងចាំបាច់ត្រូវកសាងគោលការណ៍ណែនាំជាក់លាក់រួមមួយ ដែលមានលក្ខណៈចូលរួម មានន័យថា ការកសាងគោលការណ៍នេះត្រូវមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ដោយរួមមាន ក្រសួងស្ថាប័ន អង្គការជាតិ អន្តរជាតិ និងភ្នាក់ងារ អង្គការសហប្រជាជាតិ នៅគ្រប់ដំណាក់កាលនៃការកសាងឯកសារ ។

លោកសម្តែងក្តីសង្ឃឹមជឿជាក់ថា មន្ត្រីគ្រប់រូប នឹងខិតខំអស់ពីកំលាំងកាយ កំលាំងចិត្ត ដើម្បីពិភាក្សា និងផ្តល់មតិយោបល់ដ៏មានតម្លៃដល់សិក្ខាសាលានេះ ដើម្បីឲ្យក្រុមការងារបច្ចេកទេសបានកែសម្រួលសេចក្តីព្រាងគោលការណ៍កាន់តែមានប្រសិទ្ធភាពខ្ពស់ និងបម្រើឧត្តមប្រយោជន៍ដល់ជនរងគ្រោះរបស់យើង ។ បន្ថែមពីលើនេះ លោក ញ៉ឹក វណ្ណារ៉ា បានថ្លែងអំណរគុណ ដល់ UN-ACT អង្គការ UN Worren អង្គការវតនៈអន្តរជាតិ និងអង្គការក្តីសង្ឃឹម និងដែលបានឧបត្ថម្ភគាំទ្រ និងផ្តល់កិច្ចសហការយ៉ាងល្អប្រសើរដល់ក្រសួង ស.អ.យ ក្នុងដំណើរ ការរៀបចំបង្កើត និងកែសម្រួលសេចក្តីព្រាងគោលការណ៍ណែនាំ ជាពិសេស បានផ្តល់ការគាំទ្រសម្រាប់ដំណើរការ រៀបចំសិក្ខាសាលានេះផងដែរ៕

## កូវីដ១៩! ពលករខ្មែរ វិលត្រឡប់មកកម្ពុជាវិញ អាចប្រឈមនឹងភាពងាយរងគ្រោះ ដោយសារខ្វះកិច្ចគាំពារសង្គម

https://dap-news.com/ ByVNT108Posted on July 30, 2020

ភ្នំពេញ ៖ លោកស្រី គ្រស្ទីន ផាកូ ប្រធានបេសកកម្ម អង្គការអន្តរជាតិទេសន្តរប្រវេសន៍ ប្រចាំនៅកម្ពុជា មានប្រសាសន៍ថា ក្នុងស្ថានភាពជំងឺកូវីដ-១៩ ដែលកំពុងរីករាលដាល ពេញសកលលោកនោះ បណ្តាលឲ្យពលករខ្មែរវិលត្រឡប់មកកម្ពុជាវិញ អាចកាន់តែប្រឈមនឹងភាពងាយរងគ្រោះជាងមុន ដោយសារកង្វះខាតកិច្ចគាំពារសង្គមការទទួលបានព័ត៌មាននៅមានកម្រិតព្រមទាំងហានិភ័យនៃអំពើជួញដូរមនុស្សនិងការកេងប្រវ័ញ្ចកើនឡើង។

ក្នុងសិក្ខាសាលាពិគ្រោះយោបល់ ថ្នាក់ជាតិលើកទី២ កម្រិតថ្នាក់ដឹកនាំ ស្តីពីកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នាព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ លោកស្រី គ្រស្ទីន ផាកូ បានឲ្យដឹងថា ស្ថានភាពវិបត្តិជំងឺកូវីដ-១៩ មានផលប៉ះពាល់ ដោយមិនស្មើភាពគ្នា ទៅដល់ប្រជាជន ដែលសង្ឃឹមនឹងទទួលបានជីវិតកាន់តែប្រសើរឡើង ហើយធ្វើការឆ្លងព្រំដែន ដើម្បីទាញក្រុមគ្រួសាររបស់ពួកគេឲ្យចាកចេញពីភាពក្រីក្រ ដោយបង្ហាញឲ្យឃើញ ពីភាពងាយរងគ្រោះរបស់ពលករ នៅក្នុងអំឡុងពេលលំបាកនេះ។ លោកស្រីមានប្រសាសន៍ថា « នៅប្រទេសកម្ពុជា ផលប៉ះពាល់នៃជំងឺកូវីដ-១៩ បានធ្វើឲ្យពលករទេសន្តរប្រវេសន៍ ជាង១០០.០០០នាក់ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ នៅខែមីនា ឆ្នាំ ២០២០។ នៅពេលត្រឡប់ ទៅកាន់សហគមន៍របស់ពួកគេវិញ ពលករដែលបានវិលត្រឡប់ទាំងនោះ អាចកាន់តែប្រឈម នឹងភាពងាយរងគ្រោះជាងមុន ដោយសារតែ កង្វះខាតកិច្ចគាំពារសង្គម ការទទួលបានព័ត៌មាននៅមានកម្រិត ព្រមទាំងហានិភ័យ នៃអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចកើនឡើង»។

លោកស្រីបន្ថែមថា ដោយសាររដ្ឋាភិបាល ជុំវិញពិភពលោក បានណែនាំការរឹតត្បិតការធ្វើដំណើរ ត្រូវបានអនុម័ត ដើម្បីធ្វើឲ្យមានភាពថយចុះ នៃការចម្លងជំងឺកូវីដ-១៩ ធ្វើឲ្យជះឥទ្ធិពលយ៉ាងខ្លាំង ដល់ការបំលាស់ទី និងទេសន្តរប្រវេសន៍។ នៅពេល ដែលប្រទេសជិតខាងប្រទេសកម្ពុជា ចាប់ផ្តើមបើកព្រំដែនឡើងវិញ ពេលនោះយើងឃើញការកើនឡើង នៃទេសន្តរប្រវេសន៍ ជាពិសេស ទៅកាន់ប្រទេសថៃ។ តើយើងអាចជួយគាំទ្រ ដល់ពលករទេសន្តប្រវេសន៍ទាំងនោះ ដោយរបៀបណា ដើម្បីធានាថា ដំណើរទេសន្តប្រវេសន៍របស់ពួកគេ គឺស្របច្បាប់ និងស្របតាមតម្រូវការ ដើម្បីកាត់បន្ថយ ភាពងាយរងគ្រោះរបស់ពលករ៕ ដោយ ៖ អេង ប៊ូឆេង

## ប្រជាពលរដ្ឋខ្មែរចំនួន ៤៥នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្ពានឆ្វេង-ស្ពានស្តាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 29-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្ម

តា ដោយទ្បេកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៥នាក់ ស្រី ២៣នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្រ្តីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥០នាក់

https://www.facebook.com/GDIOfficial 29-07-2020

នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ចំនួន៥០នាក់ ស្រី២០នាក់៕

## ថៃកំពុងបង្កើនកងកម្លាំងប៉ូលិស ដើម្បីបង្ក្រាបការជួញដូរមនុស្សទូទាំងប្រទេស!

http://freshnewsasia.com/ 2020-07-30 09:56am

**(បាងកក)៖** មន្រ្តីប៉ូលីសជាន់ខ្ពស់នៃ អង្គភាពប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស របស់ប្រទេសថៃ បានប្តេជ្ញាជំរុញការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពបន្ថែមដល់ មន្រ្តីប៉ូលីសនៅនៅទូទាំងប្រទេស ដើម្បីឆ្លើយតបឲ្យបានកាន់តែល្អប្រសើរឡើង ខណៈដែលចំនួនបទល្មើសនៃការជួញដូរផ្លូវភេទ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម នៅខាងក្រៅទីក្រុងបាងកក បានកើនឡើងជាលំដាប់។ នេះបើតាមការចេញផ្សាយ ដោយសារព័ត៌មាន CNA នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៣០ ខែកក្កដា ឆ្នាំ២០២០។

ឧត្តមសេនីយ៍ឯក ចារ៉ាវ៉ាត់ វ៉ៃសាយ៉ា (Jaruvat Vaisaya) ប្រធានមន្ទីរប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ កងរាជអាវុធហត្ថថៃបាននិយាយថា ប្រទេសថៃមានកង្វះខាតមន្រ្តីនៅតាមមូលដ្ឋាន ដែលមានជំនាញក្នុងការស៊ើបអង្កេត ករណីជួញដូរមនុស្ស។ ឧត្តមសេនីយ៍ឯករូបនេះ បានគូសបញ្ជាក់ទៀតថា «**យើងបានដឹងអំពីការកើនឡើងជាខ្លាំង នូវករណីជួញដូរមនុស្សតាមបណ្តាខេត្តឆ្ងាយៗ ដែលយើងមិនអាចបញ្ជូនមន្រ្តីជំនាញរបស់យើង ទៅឲ្យបានទាន់ពេលវេលា... មន្រ្តីប៉ូលីសជាទូទៅ មិនដឹងពីរបៀបដោះស្រាយករណីជួញដូរមនុស្សទេ ដោយអ្នកខ្លះមិនអាចទាំង កំណត់អត្តសញ្ញាណជនរងគ្រោះទៀតផង**»។

ដោយមើលពីភាពខ្វះខាតនេះ លោក Vaisaya បាននិយាយថា រដ្ឋាភិបាលថៃនៅសប្តាហ៍នេះ បានរៀបចំបើកវគ្គបណ្តុះបណ្តាលមួយ ស្តីអំពីជំនាញប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជូនមន្រ្តីប៉ូលីស និងមន្រ្តីរាជការចំនួន ១៥០នាក់មកពីទូទាំងប្រទេស ដើម្បីជួយបង្រៀនពួកគេ ក្នុងការកំណត់អត្តសញ្ញាណ និងជួយសង្គ្រោះជនរងគ្រោះ។ ជាសរុបប្រទេសថៃមានមន្រ្តីជំនាញ ប្រឆាំងនឹងការជួញដូរមនុស្សចំនួន ១,៦៤០នាក់នៅទូទាំងប្រទេស ដែលក្នុងនោះមានជាង ១០០នាក់ប្រចាំការនៅទីក្រុងបាងកក។

គួរជម្រាបថា ប្រទេសអាស៊ីអាគ្នេយ៍មួយនេះ បានរងការរិះគន់យ៉ាងខ្លាំង នាប៉ុន្មានឆ្នាំចុងក្រោយនេះ ចំពោះការបរាជ័យក្នុងការបញ្ឈប់ សកម្មភាពជួញដូរមនុស្សក្នុងវិស័យវាយនភ័ណ្ឌ និងនេសាទសមុទ្រ ក៏ដូចជាការជួញដូរ

ផ្លូវភេទជាដើម។ ទោះជាយ៉ាងណា អាជ្ញាធរថៃបានអះអាងថា ខ្លួនបានជួយសង្គ្រោះជនរងគ្រោះពីការជួញដូរចំនួន ១,៨០៧នាក់កាលពីឆ្នាំមុន ដោយក្នុងនោះ ៦០% ជាស្ត្រីដែលភាគច្រើនមកពីប្រទេសភូមា៕

## ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០

## សម្តេចក្រឡាហោម ស ខេងៈ កិច្ចការពារពលករទេសន្តប្រវេសន៍គឺជាកិច្ចការដ៏ចាំបាច់គប្បីត្រូវយកចិត្តទុកដាក់

https://www.rasmeinews.com/ July 30, 2020, 10:03 AM

ដោយៈតារាវិទូ(ភ្នំពេញ)៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានមានប្រសាន៍ថា កិច្ចការពារពលករទេសន្តប្រវេសន៍គឺជាកិច្ចការដ៏ចាំបាច់ដែលគប្បីត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លាពីប្រទេសដើមនិងប្រទេសគោលដៅ។ខណៈកម្ពុជាកំពុងមានពលករទេសន្តប្រវេសន៍ជាង១០ម៉ឺននាក់។ សម្តេចក្រឡាហោមបានលើកឡើងបែបនេះ នៅក្នុងឱកាសអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ ស្តីពីកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តប្រវេសន៍ដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់ នាព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ នៅក្រសួងមហាផ្ទៃ ។ សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ឲ្យដឹងថា៖ ចាប់២១ មីនា រហូតមកដល់២៣កក្កដា២០២០ កម្ពុជាមានពលករដែលធ្វើទេសន្តប្រវេសន៍ប្រមាណ ១០៣.០០០ នាក់ ក្នុងនោះជាស្ត្រី៤៥ ។ រាជរដ្ឋាភិបាលបាននិងកំពុងទទួលសង្គ្រោះពលករដែលវិលត្រឡប់មកវិញដោយព្យាយាមឆ្លងដែនខុសច្បាប់និងតាមច្រក មិនផ្លូវការគេចវេះពីស្ថានភាពលំបាកក្នុងប្រទេសគោលដៅក្នុងអំឡុងពេលដែលប្រទេសគោលដៅកំពុងរឹតបន្តឹង ឬបិទប្រទេសដើម្បីកាត់បន្ថយការឆ្លងនូវជំងឺកូវីដ ១៩ ។ សម្តេចក្រឡាហោមបានបន្តថា៖ «ស្ថានភាពបែបនេះនឹងមិនអាចបញ្ចប់ដោយឆាប់បាននោះទេ ហើយក៏អាចអូសបន្លាយបន្តទៀតក្នុងរយៈពេលវែង ហេតុនេះកិច្ចការពារពលករទេសន្តប្រវេសន៍គឺជាកិច្ចការដ៏ចាំបាច់ដែលគប្បីត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លាពីប្រទេសដើមនិងប្រទេសគោលដៅ»។

រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មការជាតិប្រឆាំងការជួញដូរមនុស្សជាសេនាធិការបានសហការជាមួយនឹងអង្គការទេសន្តប្រវេសន៍អន្តរជាតិដើម្បីរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងឡាយនិងការជ្រើសរើសដោយឯកភាពនឹងទទួលបានការទទួលខុសត្រូវរួមគ្នាក្នុងការអនុវត្តន៍ ដើម្បីលើកកម្ពស់សុវត្ថិភាពភាពរៀបរយស្របច្បាប់របស់ពលករទេសន្តប្រវេសន៍ ។ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ ស្តីពីកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តប្រវេសន៍ ដោយសុវត្ថិភាពរៀបរយនិងស្របច្បាប់នៅថ្ងៃនេះបានជ្រើសរើជាបឋមគោលបំណងចំនួនបី និងមានគោលបំណងត្រៀមចំនួនបួនសម្រាប់ការពិភាក្សាឡើងវិញបន្ទាប់ពីការសម្រេចក្នុងកិច្ចប្រជុំនេះ ព្រះរាជាណាចក្រកម្ពុជានឹងសម្រេចដាក់បញ្ចូលគោលបំណងដែលជ្រើសរើសបានទៅក្នុងផែនការសកម្មភាពសម្រាប់ឆ្នាំជាបន្តបន្ទាប់ដើម្បីធានាថា ការធ្វើទេសន្តប្រវេសន៍របស់ប្រជាជនកម្ពុជាទៅប្រទេសគោលដៅទាំងឡាយក៏ដូចជាជនទេសន្តប្រវេសន៍ ដែលមកពីបណ្តាប្រទេសក្រៅចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រកបដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់។

នៅក្នុងកិច្ចប្រជុំត្រៀមនេះតំណាងអន្តរក្រសួងស្ថាប័នបានផ្តោតការយកចិត្តទុកដាក់លើវិស័យ ៤ ដែលពាក់ព័ន្ធនឹងបញ្ហាទេសន្តប្រវេសន៍គឺទី១.ការការពារ ជនទេសន្តប្រវេសន៍ទាំងជនទេសន្តរប្រវេសន៍ប្រក្រតីនិងទេសន្តប្រវេសន៍មិនប្រក្រតីនិងទាំងអ្នកមានគម្រោងចាកចេញទៅធ្វើការក្រៅប្រទេសទាំងអ្នកកំពុងស្នាក់នៅនិងធ្វើការនៅក្រៅប្រទេស ទាំងអ្នកវិលត្រឡប់មកវិញ។ ទី២.ការគ្រប់គ្រងទិន្នន័យការរៀបចំប្រព័ន្ធទិន្នន័យសម្រាប់កត់ត្រានិងគ្រប់គ្រងឱ្យបានជាក់លាក់នូវ ទិន្នន័យជនទេសន្តប្រវេសន៍ទាំងប្រក្រតីនិងមិនប្រក្រតី ដើម្បីងាយស្រួលក្នុងការដាក់វិធានការឆ្លើយតបទៅនឹងស្ថានភាពនានាដែលជាភាពប្រឈមរបស់ពលរដ្ឋនិងប្រទេសជាតិ ។ទី ៣. ការគាំទ្រដំណើរការនៃការវិលត្រឡប់និងការធ្វើសមាហរណកម្មជនទេសន្តប្រវេសន៍ត្រូវការរៀបចំគោលនយោបាយវិធានការ

និងនីតិវិធីដាក់លាក់ដោយមានកិច្ចសហការជាមួយរដ្ឋាភិបាលនៃបណ្ដាប្រទេសពាក់ព័ន្ធ ដើម្បីទទួលបានទិន្នន័យលក្ខខណ្ឌ នៃការបញ្ជូនវិធីបញ្ជូនជាពិសេសការកំណត់វិធានការការពារស្ត្រី និងកុមារដែលសង្ស័យថា រងគ្រោះជាពិសេសដោយអំពើជួញដូរមនុស្ស និងទី ៤. ការកំណត់និងការផ្តល់អត្តសញ្ញាណដោយស្របច្បាប់ជាពិសេសសម្រាប់កូនរបស់ជនទេសន្តរប្រវេសន៍នៅកម្ពុជាដែលបានកើតនៅក្នុងប្រទេសកម្ពុជា ៕ BR/Ha

## សម្តេចក្រឡាហោម ស ខេង៖ ជនទេសន្តរប្រវេសន៍ភាគច្រើន ស្ថិតក្នុងស្ថានភាពលំបាក និងជាអ្នកដែលគ្មានជំនាញ ចាកចេញពីប្រទេស ដោយមិនស្របច្បាប់

https://www.cen.com.kh/ July 30, 2020

ភ្នំពេញ៖ គិតចាប់ពីថ្ងៃទី២១ ខែមិនា រហូតដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ ពលករកម្ពុជាដែលវិលត្រឡប់ពីការធ្វើទេសន្តរប្រវេសន៍ក្នុងអំឡុងកូវីដ១៩ មានប្រមាណ១០ម៉ឺន៣ពាន់នាក់ ក្នុងនោះប្រមាណ៤៥ភាគរយ។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានលើកឡើងថា បញ្ហាទេសន្តរប្រវេសន៍តែងតែមានភាពប្រឈមតិច ឬច្រើន ហើយក្នុងដំណាក់កាលនៃការរាតត្បាតនៃជំងឺកូវីដ ១៩នេះ ការធ្វើទេសន្តរប្រវេសន៍រឹតតែប្រឈមខ្លាំង ហើយក៏អាចអូសបន្លាយបន្តទៀតក្នុងរយៈពេលវែង ហេតុដូចនេះ កិច្ចការពារពលករ ទាំងនៅក្នុងប្រទេសកំណើត និងប្រទេសគោលដៅនានាដែលពលករបានធ្វើទេសន្តរប្រវេសន៍ គឺជាភារកិច្ចចាំបាច់ ដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវយកចិត្តទុកដាក់។ នេះបើតាមប្រសាសន៍របស់សម្តេចក្រឡាហោម ក្នុងឱកាសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បើកកម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ កម្រិតថ្នាក់ដឹកនាំ ស្តីពីកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់(GCM) នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៣០ ខែកក្កដា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ។

សម្តេចក្រឡាហោម បានមានប្រសាសន៍ថា ជនទេសន្តរប្រវេសន៍ដែលតែងទទួលរងនូវភាពប្រឈមពីការធ្វើទេសន្តរប្រវេសន៍ ជាអ្នកស្វែងរកការងារ ឬជាជនភៀសខ្លួនពីតំបន់មានគ្រោះអាសន្នជាដើម ហើយបើតាមការស្រាវជ្រាវនៅទូទាំងពិភពលោក ជនទេសន្តរប្រវេសន៍ភាគច្រើន ដែលស្ថិតក្នុងស្ថានភាពលំបាក និងរងគ្រោះ ភាគច្រើនជាអ្នកដែលគ្មានជំនាញ និងចាកចេញពីប្រទេសដោយមិនស្របច្បាប់។ សម្តេចបានបន្ថែមថា ជនទេសន្តរប្រវេសន៍ដែលប្រថុយប្រថានចាកចេញ ដោយខ្វះកិច្ចការពារពីប្រព័ន្ធច្បាប់ តែងត្រូវបានជនឆ្លៀតឱកាស កេងប្រវ័ញ្ចយកផលចំណេញពីស្ថានភាពទ័លច្រករបស់អ្នកទាំងនោះ ដោយធ្វើការជួញដូរមនុស្ស រំលោភបំពាន កេងប្រវ័ញ្ចកម្លាំងពលកម្មធ្ងន់ធ្ងរ តាមបែបទាសភាព ធ្វើឲ្យធ្លាក់ខ្លួនជាពិការ វង្វេងស្មារតី បាត់បង់ភាពជាមនុស្ស ឬរហូតដល់បាត់បង់ជីវិតផងដែរ។ ជាងនេះទៀត សម្តេចក្រឡាហោម ក៏បានលើកឡើងថា ការរាតត្បាតនៃជំងឺកូវីដ១៩ បានធ្វើឲ្យបញ្ហាទេសន្តរប្រវេសន៍រឹតតែប្រឈមខ្លាំង និងបានឲ្យប្រទេសដែលទទួលពលករ ក៏ប្រឈមខ្លាំងទៅនឹងភាពប្រែប្រួលជាអវិជ្ជមាននៃចរន្តសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចក្នុងស្រុក ដែលជំរុញឲ្យដំណើរការនៃរោងចក្រសហគ្រាស និងវិស័យសេវាកម្មនានារាំងស្ទះ និងត្រូវផ្អាកដំណើរការជាបន្តបន្ទាប់។ សម្តេចក្រឡាហោម បានបន្ថែមថា ក្នុងអំឡុងពេលដែលប្រទេសគោលដៅមានការរឹតបន្តឹង និងបិទប្រទេស ដើម្បីទប់ស្កាត់ការឆ្លងជំងឺកូវីដ ១៩ ព្រមជាមួយគ្នានោះ ប្រទេសកម្ពុជាបាននិងកំពុងទទួលសង្គ្រោះពលករ ដែលវិលត្រឡប់មកវិញដោយគេចវេះពីស្ថានភាពលំបាកក្នុងប្រទេសគោលដៅ និងព្យាយាមឆ្លងដែនដោយខុសច្បាប់ និងតាមច្រកមិនផ្លូវការ។

វិស័យសំខាន់ៗចំនួន៤ ពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍ ដែលក្រសួងមហាផ្ទៃ រួមជាមួយតំណាងពីអន្តរក្រសួង នឹងយកមកពិភាក្សា ដើម្បីរៀបចំដាក់បញ្ចូលនូវគោលបំណងរួមដែលជាលទ្ធផល ទៅក្នុងផែនការសកម្មភាពឆ្នាំបន្តបន្ទាប់ ក្នុងការធានាថា ការធ្វើទេសន្តរប្រវេសន៍របស់ប្រជាជនកម្ពុជា ទៅប្រទេសគោលដៅ

ទាំងឡាយ ក៏ដូចជា ជនទេសន្តរប្រវេសន៍ដែលមកពីប្រទេសក្រៅចូលក្នុងព្រះរាជាណាចក្រកម្ពុជា នឹងប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ សម្រាប់វិស័យទាំង៤ ពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍ ដែលសម្តេចក្រឡាហោម បានលើកឡើងរួមមាន៖

១.ការការពារជនទេសន្តរប្រវេសន្ត៖ ទាំងជនទេសន្តរប្រវេសន្តប្រក្រតី និងជនទេសន្តរប្រវេសន្តមិនប្រក្រតី ទាំងអ្នកដែលមានគម្រោង ចាកចេញទៅធ្វើការក្រៅប្រទេស ទាំងអ្នកដែលកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេស ទាំងអ្នកវិលត្រឡប់មកវិញ។

២.ការគ្រប់គ្រងទិន្នន័យ៖ ការរៀបចំប្រព័ន្ធទិន្នន័យសម្រាប់កត់ត្រា និងគ្រប់គ្រងឲ្យបានជាក់លាក់ នូវទិន្នន័យ ជនទេសន្តរប្រវេសន៍ទាំងប្រក្រតី និងមិនប្រក្រតី ដើម្បីងាយស្រួលក្នុងការដាក់វិធានការឆ្លើយតបទៅនឹងស្ថានភាពនានា ដែលជាភាពប្រឈមរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិ។

៣.ការគាំទ្រដំណើរការ នៃការវិលត្រឡប់ និងការធ្វើសមាហរណកម្មជនទេសន្តរប្រវេសន៍៖ ត្រូវការរៀបចំគោលនយោបាយ វិធានការ និងនីតិវិធីជាក់លាក់ដោយមានកិច្ចសហការជាមួយរដ្ឋាភិបាលនៃប្រទេសពាក់ព័ន្ធ ដើម្បីទទួលបានទិន្នន័យ លក្ខខណ្ឌនៃការបញ្ជូន វិធីបញ្ជូន ជាពិសេស ការកំណត់វិធានការការពារស្ត្រី និងកុមារ ដែលសង្ស័យថារងគ្រោះ ជាពិសេសដោយអំពើជួញដូរមនុស្ស។

៤.ការកំណត់ និងការផ្តល់អត្តសញ្ញាណដោយស្របច្បាប់ ជាពិសេសសម្រាប់កូនរបស់ជនទេសន្តរប្រវេសន៍កម្ពុជា ដែលបានកើតនៅក្រៅប្រទេសកម្ពុជា៕ **ដោយ៖កូឡាប**

## មន្ត្រីសង្គមកិច្ចៈ កម្ពុជា ត្រូវការគោលការណ៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងជនរងគ្រោះដោយអំពើជួញដូរមនុស្ស

https://www.rasmeinews.com/ July 30, 2020, 2:33 PM

**ដោយៈ មេសា/ភ្នំពេញៈ** លោក ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានប្រសាសន៍អំពីតម្រូវការរបស់ កម្ពុជា ក្នុងគ្រប់គ្រង និង ឆ្លើយតបដល់តម្រូវការរបស់ជនរងគ្រោះពីអំពើជួញដូរមនុស្សថា ‶ រាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយសហការជាមួយរដ្ឋាភិបាល នៃ បណ្តាប្រទេសនានាទាំងក្នុងតំបន់ និង ក្នុងពិភពលោក អង្គការជាតិ អន្តរជាតិ និង វិស័យឯកជន ហើយ ដើម្បី ពង្រឹងប្រសិទ្ធភាពថែមទៀត ក្នុងការបញ្ជូន និងការផ្តល់សេវាដល់ជនរងគ្រោះ យើងត្រូវការជាចាំបាច់នូវគោលការណ៍ណែនាំមួយ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ដោយរួមមាន ក្រសួង ស្ថាប័នអង្គការជាតិ អន្តរជាតិ និង ភ្នាក់ងារ អង្គការសហប្រជាជាតិ ជាដើមផងដែរ ដើម្បី ឲ្យគោលការណ៍នេះ កាន់តែមានប្រសិទ្ធភាពខ្ពស់ និងបម្រើឧត្តមប្រយោជន៍ដល់ជនរងគ្រោះ ‶ ។ លោក ញ៉ឹក វណ្ណារ៉ា មានប្រសាសន៍យ៉ាងដូច្នេះ នៅក្នុងពិធីបើកបើក សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី សេចក្តីព្រាង ចុងក្រោយ នៃ គោលការណ៍ណែនាំស្តីពីការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស នាថ្ងៃទី៣០ កក្កដា ២០២០ សណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ ។

សូមជម្រាបថា គោលការណ៍ណែនាំស្តីពីយន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលបានឈានដល់ដំណាក់កាលចុងក្រោយនេះ ត្រូវបានតាក់តែងឡើងដោយមានរចនាសម្ព័ន្ធសំខាន់ៗ ៦ ផ្នែកគឺ៖ ផ្នែកទី ១ ជាយន្តការបញ្ជូនជនរងគ្រោះ , ផ្នែកទី ២ គឺជាទស្សនទានចំពោះយន្តការបញ្ជូនជនរងគ្រោះ ការត្រួតពិនិត្យវាយតម្លៃ និង គោលនយោបាយបទដ្ឋានអប្បបរមា , ផ្នែកទី ៣ គឺជាការកំណត់អត្តសញ្ញាណជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស និង សិទ្ធិរបស់ជនទាំងនោះ , ផ្នែកទី ៤ គឺជាភារកិច្ចទំនួលខុសត្រូវ របស់អ្នកផ្តល់សេវា ,

ផ្នែកទី ៥ គឺជារបៀបដំណើរការក្នុងការបញ្ជូនជនរងគ្រោះទៅរកសេវាសមស្រប និង ផ្នែកទី ៦ គឺជាមធ្យោបាយត្រួតពិនិត្យ និង វាយតម្លៃទៅលើការអនុវត្តក្នុងការបញ្ជូនជនរងគ្រោះទៅទទួលសេវាជាដើម ។

កម្ពុជា ត្រូវបានទទួលស្គាល់ថា ជាប្រភព ឆ្លងកាត់ និង គោលដៅ នៃការជួញដូរមនុស្សទៅប្រទេស ថៃ ម៉ាឡេស៊ី ចិន ឥណ្ឌូណេស៊ី ជប៉ុន វៀតណាម និង ប្រទេសដទៃទៀត ដោយក្នុងនោះ បុរស ត្រូវបានជួញដូរក្នុងគោលដៅកេងប្រវ័ញ្ចពលកម្មដោយបង្ខំក្នុងវិស័យឧស្សាហកម្ម កសិកម្ម នេសាទ រោងចក្រ និង សំណង់ ខណៈស្ត្រីត្រូវបានជួញដូរក្នុងគោលបំណងធ្វើអាជីវកម្មផ្លូវភេទ ការងារដោយបង្ខំ ឬ អ្នកបម្រើនៅតាមផ្ទះ និង ពរពោះជំនួស ចំណែកកុមារ ត្រូវបានជួញដូរក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មដោយបង្ខំក្នុងក្រុមអ្នកសុំទាន ពេស្យាចារ លក់ផ្កា ឬ ទំនិញផ្សេងៗតាមចិញ្ចើមថ្នល់ និង ការប្រព្រឹត្តបទល្មើសផ្សេងៗទៀតជាច្រើនរូបភាព ។

ជាការកត់សម្គាល់ កន្លងមក ក្នុងកម្រិតថ្នាក់ជាតិ កម្ពុជា បានដាក់ចេញនូវច្បាប់ និង យន្តការនានាជាបន្តបន្ទាប់ ដូចជាការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានលេខាធិការដ្ឋាន និង ក្រុមការងារជំនាញចំនួន ៦ ហើយក្រុមនីមួយៗ ដឹកនាំដោយរដ្ឋមន្ត្រីមកពីក្រសួងចំនួន ៦ និង គណៈកម្មាធិការរាជធានីខេត្ត និងអង្គការពាក់ព័ន្ធក្នុងការត្រួតពិនិត្យការិយាល័យជំនាញ ទៅកម្រិតនាយកដ្ឋាន និង មន្ទីរ ។

លោកស្រី ព្រំ សាខន ប្រធាននាយកដ្ឋានប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស នៃក្រសួងសង្គមកិច្ច ឱ្យដឹងថា កិច្ចខិតខំប្រឹងប្រែងកន្លងមកទទួលបានលទ្ធផលជាច្រើន ជាក់ស្តែងកាលពីឆ្នាំ ២០១៨ ទទួលបានជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ៨៤៨ នាក់ បណ្តុះបណ្តាលវិជ្ជាជីវៈ និង ធ្វើសមាហរណកម្ម ចំនួន ៣០៣ នាក់ ។ ដោយឡែកមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ទទួលបានជនរងគ្រោះ ចំនួន ១៣១ នាក់ ធ្វើមាតុភូមិនិវត្តជនសង្ស័យថារងគ្រោះដោយអំពើរជួញដូរមនុស្សចំនួន ៨ ៤៨៩ នាក់ តាមរយៈស្ថានបេសកកម្មការទូតកម្ពុជា ប្រចាំប្រទេសជាគោលដៅចំនួន ៨ ៕ Kh

## ពិធីបិទវគ្គបណ្តុះបណ្តាលជំនាញ ស្តីពីការឆ្លើយតបចំពោះបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិនធឺណែត

https://gdlf-kh.com/ 2020/07/30/ Sam Sophearum កែប

ខេត្តកែប ៖ ក្រោយពីទទួលបានការបណ្តុះបណ្តាលជំនាញ ស្តីពីការឆ្លើយតបចំពោះបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិនធឺណែត រយៈពេល២ថ្ងៃកន្លះ (២៨-៣០,០៧,២០២០) រួចមក នៅព្រឹកថ្ងៃព្រហស្បតិ៍ ១០ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០២០ លោកឧត្តមសេនីយ៍ត្រី សម្បត្តិ សុធារដ្ឋ ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តកែប និងលោក សំ លៀងសិលា នាយកប្រតិបត្តិ នៃអង្គការសកម្មភាពដើម្បីកុមារ (APLE)។

ពិធីខាងលើដោយមានការអញ្ជើញចូលរួមពីលោក លោកស្រី ស្នងការរងទទួលផែនប្រឆាំងការជួញដូរមនុស្ស នាយ នាយរងការិយាល័យ និងមន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន មកពីបណ្តារាជធានី ខេត្ត រួមមាន៖ ភ្នំពេញ កែប កំពត ព្រះសីហនុ កំពង់ចាម និងខេត្តក្រចេះ សរុបចំនួន៣១នាក់។

លោកសំ លៀងសិលា នាយកប្រតិបត្តិនៃអង្គការ(APLE) បានមានប្រសាសន៍ ផ្តោតអំពីសារៈសំខាន់នៃវគ្គសិក្សាខាងលើរួមមាន៖ ការយល់ដឹងពីហានិភ័យរបស់កុមារក្នុងការប្រើប្រាស់អ៊ិនធឺណែត ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទកុមារ បទល្មើសនិងចរិកលក្ខណៈជនប្រព្រឹត្តផ្លូវភេទលើកុមារតាមអនឡាញ ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការប្រមូលភស្តុតាងឌីជីថលក្របខណ្ឌច្បាប់ពាក់ព័ន្ធ និងយុទ្ធសាស្ត្របង្ការ ទប់ស្កាត់បទល្មើទាំងនោះ។

មានប្រសាសន៍ទៅកាន់ពិធីលោកឧត្តមសេនីយ៍ត្រី សម្បត្តិ សុធារដ្ឋ ស្នងការនគរបាលខេត្តកែប បានកោតសរសើរ គាំទ្រ និងថ្លែងអំណរគុណចំពោះអង្គការសកម្មភាពដើម្បីកុមារ (APLE) និងនាយកដ្ឋានប្រឆាំងការជួញ

ជូរមនុស្សនិងការពារអនីតិជន ព្រមទាំងមូលនិធិBreand for the world (Bfdw) នៃប្រទេសអាឡឺម៉ង់ ដែលតែងតែឧបត្ថម្ភបង្កើតវគ្គសិក្សានេះឡើង និងបង្ហាត់បង្រៀន ការបញ្ជ្រាបការយល់ដឹងពីជំងឺកូវីដ-១៩ តាមប្រព័ន្ធអ៊ិនធឺណែត និងបញ្ចប់វគ្គដោយជោគជ័យ ដើម្បីត្រីវិស័យដ៏សំខាន់សំរាប់យកទៅអនុវត្តឱ្យបានចំទិសដៅ នៅក្នុងអង្គភាពខេត្តរបស់ខ្លួន ៕

## អ្នកនាំពាក្យក្រសួងការបរទេស៖ ពលរដ្ឋខ្មែរចំនួន៧៩នាក់នឹងត្រឡប់ពីប្រទេសហ្ស៊ីកដានី ឥណ្ឌា និងប៉ាគីស្ថាន មកដល់កម្ពុជាវិញនៅព្រឹកនេះ

http://www.freshnewsasia.com/ 2020-07-31 07:28 am

**(ភ្នំពេញ)៖** លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឲ្យដឹងថា នៅព្រឹកថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០នេះ មានប្រជាពលរដ្ឋខ្មែរចំនួន៧៩នាក់ នឹងត្រឡប់មកពីប្រទេសហ្ស៊ីកដានី, ឥណ្ឌា និងប៉ាគីស្ថាន ចូលមកដល់កម្ពុជាវិញ តាមជើងហោះហើរចំនួន២ផ្សេងគ្នា។ លោក កុយ គួង បានបញ្ជាក់ថា ដោយមានកិច្ចខិតខំប្រឹងប្រែង និងសម្របសម្រួលរបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសអេហ្ស៊ីប ពលករខ្មែរចំនួន២៨នាក់ និងទារក១នាក់ ដែលត្រូវបានរោងចក្រវាយនភណ្ឌចំនួន០២ (Vega Textile Co., Ltd. និង Camel Textile International Corporation) នៅប្រទេសហ្ស៊ីកដានី បញ្ឈប់កិច្ចសន្យាការងារ ដែលពួកគាត់នឹងធ្វើដំណើរចេញពីប្រទេសហ្ស៊ីកដានី នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ ដោយឆ្លងកាត់ប្រទេសមីយ៉ាន់ម៉ា ហើយនឹងមកដល់ប្រទេសកម្ពុជានៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង០៨៖១៥ព្រឹក តាមជើងយន្តហោះលេខ 8M1105។ ពលករខ្មែរចំនួន២៨នាក់នេះ គឺស្ថិតក្នុងចំណោមពលករខ្មែរសរុបចំនួន៨៣ ដែលកំពុងធ្វើការងារនៅក្នុងរោងចក្រទាំងពីរខាងលើ។ អ្នកនាំពាក្យរូបនេះបន្តទៀតថា នៅព្រឹកថ្ងៃនេះផងដែរ ពលរដ្ឋកម្ពុជាចំនួន៥០នាក់ (ជាអ្នកដំណើរទូទៅអ្នកមកពីពិនិត្យជំងឺ និងនិស្សិត) មកពីប្រទេសឥណ្ឌា និងប្រទេសប៉ាគីស្ថាន ក៏នឹងធ្វើដំណើរត្រឡប់មកកម្ពុជា ឆ្លងកាត់ប្រទេសម៉ាឡេស៊ី តាមជើងយន្តហោះពាណិជ្ជកម្មរបស់ក្រុមហ៊ុនអាកាសចរណ៍ ម៉ាឡេស៊ី លេខ MH754 ដែលនឹងចេញដំណើរ ពីទីក្រុងគូឡាឡាំពួ នៅវេលាម៉ោង៩៖០០នាទីព្រឹក ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ហើយនឹងទៅដល់ទីក្រុងភ្នំពេញ នៅវេលាម៉ោង១០៖០០នាទីព្រឹកនេះ៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៦នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 30-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៦នាក់ ស្រី ០៤នាក់ និងកុមារ ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានចុះល្បាតស្ទាបស្ទង់ ពិនិត្យឃើញឃាត់ពលករខ្មែរ ឆ្លងដែនខុសច្បាប់ចំនួន ០៣នាក់

https://www.facebook.com/GDIOfficial 30-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៤និង៤៥នាទី ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០២០ បានចុះល្បាតស្ទាបស្ទង់ ពិនិត្យឃើញឃាត់ពលករខ្មែរ ឆ្លងដែនខុសច្បាប់ចំនួន ០៣នាក់។ នគរបាលប៉ុស្តិ៍ បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់នេះ មាន ១-ឈ្មោះ ហៃ បញ្ញា ភេទប្រុស អាយុ ២៨ឆ្នាំ, ២-ឈ្មោះហេង លាងហាយ ភេទប្រុស អាយុ ៣៤ឆ្នាំ មាទីលំនៅភូមិទួយជ័យ ឃុំព្រះធាតុ ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ និង៣-ឈ្មោះ ងុំ សុភ័ក្រ ភេទប្រុស អាយុ ៣៦ឆ្នាំ មានទីលំនៅភូមិឧត្តុង ឃុំឧត្តុង្គ ស្រុកពាមជ ខេត្តព្រៃវែង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព អនុវត្តនីតិវិធី ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការ របស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបាន ការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៧១នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្ទាបឆ្វេង-ស្ទាបស្តាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 30-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទ ទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូល ធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្ទាបឆ្វេង-ស្ទាបស្តាំចំនួន ៧១នាក់ ស្រី ១៩នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយ ស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅ លំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៧នាក់

https://www.facebook.com/GDIOfficial 30-07-2020

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរ ជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិន អនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹម ត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិល ចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៧នាក់ ស្រី ២១នាក់ និង ពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិត បញ្ជាក់សុខភាព៕

## អាជ្ញាធរថៃចាប់ផ្សឹកព្រះសង្ឃខ្មែរ ៥អង្គ ដែលលួចចូលទឹកដីថៃដោយខុសច្បាប់

https://www.rfa.org/khmer/ ដោយ ជាតិ ចំណាន 2020-07-30

អាជ្ញាធរប្រទេសថៃ បានចាប់ផ្សឹកព្រះសង្ឃខ្មែរប្រាំអង្គ និងគ្រោងបញ្ជូនមកខ្មែរវិញ ដោយសារព្រះសង្ឃខ្មែរទាំងនេះលួចចូលទឹកដីថៃដោយខុសច្បាប់ និងដើរអង្គាសប្រាក់ពីពលរដ្ឋថៃ។ កាសែតបាងកកប៉ុស្តិ៍ (Bangkok Post) ចុះផ្សាយ កាលពីថ្ងៃទី២៩ កក្កដាថា មន្ត្រីផ្នែកអន្តោប្រវេសន៍របស់ប្រទេសថៃ ថា ព្រះសង្ឃខ្មែរទាំងប្រាំអង្គបានលួចចូលទឹកដីថៃតាមព្រៃ ដែលជាប់ព្រំប្រទល់ខេត្តស្រះកែវ របស់ប្រទេសថៃ រួចបន្តដំណើរទៅខេត្តសមុទ្រប្រាកាន ដើម្បីអង្គាសប្រាក់ពីពលរដ្ឋថៃ នៅតំបន់នោះ។ កាសែតដដែលបន្តថា បន្ទាប់ពីមានការចាប់ខ្លួនព្រះសង្ឃខ្មែរចំនួន ១១អង្គ កាលពីថ្ងៃទី១១ ខែកក្កដា ទើបអាចធ្វើឱ្យពួកគេ អាចចាប់បានសង្ឃខ្មែរប្រាំអង្គទៀត កាលពីថ្ងៃទី២៨ ខែកក្កដា។ ព្រះសង្ឃទាំង ១១អង្គនោះ បានលួចគង់នៅជីទំនេរ ដែលមានព្រៃក្រាស់ មួយកន្លែងនៅតាមបណ្ដោយផ្លូវ ទៅព្រលានយន្តហោះអន្តរជាតិសុវណ្ណភូមិ (Suvarnabhumi Airport) របស់ប្រទេសថៃ។ បន្ទាប់ពីមានការសាកសួរ ព្រះសង្ឃ ១១អង្គ បានប្រាប់ប៉ូលីស ពីទីតាំងផ្សេងទៀត ដែលព្រះសង្ឃខ្មែរប្រាំអង្គទៀតគង់នៅដោយខុសច្បាប់ គឺក្នុងគម្រោងអគារដែលគេបោះបង់ចោលមួយ នៅក្នុងខេត្តសមុទ្រប្រាកាន។ បន្ទាប់ពីការឃាត់ខ្លួនអាជ្ញាធរថៃបាននាំព្រះសង្ឃខ្មែរទាំង ៥អង្គនោះទៅវត្តមួយដើម្បីផ្សឹក និងគ្រោងបញ្ជូនមកកម្ពុជាវិញ បន្ទាប់ពីអនុវត្តទោសរបស់ប្រទេសថៃរួចរាល់។

ចាប់តាំងពីមានការរីករាលដាលនៃជំងឺកូវីដ-១៩មក ប្រទេសថៃបានចាប់បញ្ជូនពលរដ្ឋខ្មែរមកកម្ពុជាវិញជាច្រើននាក់។ ពួកគេថា ការចាប់បញ្ជូននេះដោយសារតែពលរដ្ឋខ្មែរទាំងនោះ មិនគោរពគោលការណ៍របស់អជ្ញាធរថៃក្នុងការដាក់ប្រទេសក្នុងគ្រាមានអាសន្ន និងការលួចឆ្លងដែនចូលទឹកដីថៃ ដោយខុសច្បាប់ ក្នុងពេលប្រទេសថៃកំពុងរឹតបណ្ដឹងការចេញចូល ក្នុងពេលមានវិបត្តិសកលនៃជំងឺកូវីដ-១៩។ មន្ត្រីសង្គមស៊ីវិលថា កត្តាជីវភាព និងការអួសទានពីមេខ្យល់ ទើបបណ្ដាលឱ្យពលរដ្ឋខ្មែរមួយចំនួនប្រថុយប្រថានគ្រោះថ្នាក់លួចឆ្លងដែនចូលទឹកដីថៃ ដោយខុសច្បាប់។ មន្ត្រីសង្គមស៊ីវិលទាំងនោះស្នើឱ្យរដ្ឋាភិបាល រៀបចំផែនការឱ្យបានច្បាស់លាស់ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងនោះ ដោយមានការផ្សព្វផ្សាយបញ្ហាប្រឈមពីការចំណាកស្រុកខុសច្បាប់ ឱ្យបានទូលំទូលាយ បង្ហាញគោលនយោបាយគាំពារពីតម្រូវការចាំបាច់ ដាក់បម្រាមកំណត់ចំពោះការផ្អាកបងបំណុលរបស់ធនាគារ និងជំរុញផលិតផលដាំដុះក្នុងស្រុក៕